# ការស្វែងរកយុត្តិធម៌ ៖ ការពិនិត្យឡើងវិញមួយអំពីដំណើរការ អ.វ.ត.ក.



# តារាងមាតិកា


| | |
|---|---|
| សេចក្ដីផ្ដើម | 1 |
| អក្សរកាត់ និងពាក្យកាត់ | 3 |
| ផែនទីកម្ពុជាប្រជាធិបតេយ្យឆ្នាំ ១៩៧៦ | 5 |
| ផ្នែក I: ទិដ្ឋភាពទូទៅអំពី អ.វ.ត.ក | 7 |
| ១) ការបង្កើតតុលាការ | 8 |
| ២) យុត្តាធិការ | 9 |
| ៣) រចនាសម្ព័ន្ធ | 10 |
| ៤) ដំណើរការតុលាការ | 23 |
| ផ្នែក II: សំណុំរឿង | 30 |
| ១) ទណ្ឌិត, ជនជាប់ចោទ, ជនត្រូវចោទ និង ជនសង្ស័យ | 31 |
| ២) ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ | 32 |
| ៣) សំណុំរឿង ០០១ | 33 |
| ៤) សំណុំរឿង ០០២ | 38 |
| ៥) សំណុំរឿង ០០៤/១ | 54 |
| ៦) សំណុំរឿង ០០៤/២ | 60 |
| ៧) សំណុំរឿង ០០៣ | 66 |
| ៨) សំណុំរឿង ០០៤ | 74 |
| ៩) ប្រភព និងលក្ខណៈនៃភស្តុតាង | 80 |
| ផ្នែក III: សមិទ្ធផល | 83 |
| ១) គណនេយ្យភាព | 84 |
| ២) យុត្តិសាស្ត្រ | 88 |
| ៣) ការកសាងសមត្ថភាព | 100 |
| ផ្នែក IV: បញ្ហាប្រឈម | 103 |
| ១) បញ្ហាប្រឈមផ្នែករចនាសម្ព័ន្ធ | 104 |
| ២) ថវិកា | 114 |
| ៣) ការកន្លងផុតទៅនៃពេលវេលា | 117 |
| ធនធានខាងក្រៅ | 119 |

# សេចក្ដីផ្ដើម

ក្នុងឆ្នាំ២០០៥ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានចាប់ផ្តើមឡើង បន្ទាប់ពីការចរចាអស់រយៈពេលយ៉ាងយូររវាងអង្គការសហប្រជាជាតិ(អ.ស.ប) និងរាជរដ្ឋាភិបាលកម្ពុជា។ នៅក្នុងឯកសារមូលដ្ឋានគោលរបស់ខ្លួន អ.ស.ប និង រាជរដ្ឋាភិបាលកម្ពុជា បានកំណត់គោលបំណង អ.វ.ត.ក ថាដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មអន្តរជាតិ និងឧក្រិដ្ឋកម្មថ្នាក់ជាតិជាក់លាក់ ដែលបានប្រព្រឹត្តក្នុងអំឡុងពេលនៃរបបនេះ។ តុលាការផ្អែកលើគំរូយុត្តិធម៌ព្រហ្មទណ្ឌបែបជជីកដេញដោលដោយចៅក្រម ដោយមានទិដ្ឋភាពច្បាប់កូមិនឡូមួយចំនួន។ ស្ថិតក្នុងគំរូនេះ ចៅក្រមកម្ពុជា និងចៅក្រមអន្តរជាតិ ព្រះរាជអាជ្ញា មេធាវីការពារក្តី មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកចាត់ចែងកិច្ចការរដ្ឋបាល បានអនុវត្តការងាររបស់តុលាការ។

ការពិនិត្យឡើងវិញនេះ ផ្តល់នូវទស្សនវិស័យច្បាស់លាស់របស់សហព្រះរាជអាជ្ញាអំពី អ.វ.ត.ក។ គោលបំណងចម្បងរបស់វាគឺ ដើម្បីបង្ហាញរូបភាពដែលជាវត្ថុបំណងរបស់តុលាការទៅកាន់ប្រជាជនកម្ពុជា រួមទាំងសង្គមស៊ីវិល និងស្ថាប័នយុត្តិធម៌ ក៏ដូចជាសហគមន៍អន្តរជាតិ ជាពិសេសអ្នកដែលកំពុងអនុវត្តក្នុងវិស័យយុត្តិធម៌ សិទ្ធិមនុស្ស និងការសិក្សាស្រាវជ្រាវ។

ការពិនិត្យឡើងវិញនេះកំណត់អត្តសញ្ញាណដោយសង្ខេប នៃលក្ខណៈសំខាន់ៗរបស់ អ.វ.ត.ក និងស្វែងយល់អំពីកេរដំណែលផ្នែកប្រតិបត្តិការ ការចូលរួម និងកេរដំណែលជាបទដ្ឋានរបស់ខ្លួន។ វាមានផ្នែកធំៗចំនួនបួន។

*ទីមួយ* វាគូសបញ្ជាក់ពីក្របខ័ណ្ឌស្ថាប័នរបស់ អ.វ.ត.ក រួមមាន អាណត្តិយុត្តាធិការ រចនាសម្ព័ន្ធ សមាសភាព ដំណើរការតុលាការ និងលក្ខណៈពិសេសរបស់ខ្លួន។ *ទីពីរ* វាផ្តល់នូវទិដ្ឋភាពនៃកិច្ចដំណើរការនីតិវិធី និងលទ្ធផលនៃរឿងក្តីទាំងប្រាំពីរ ដែលបានចោទប្រកាន់។ *ទីបី* ការពិនិត្យឡើងវិញនេះរាយការណ៍អំពីសមិទ្ធផលសំខាន់របស់ អ.វ.ត.ក។ ជាចុងក្រោយ វាស្វែងយល់ពីបញ្ហាប្រឈមរបស់តុលាការ ដំណោះស្រាយដែលបានរកឃើញ និងមេរៀនដែលទទួលបាន។

ការពិនិត្យឡើងវិញនេះគឺជាផលិតផលតែមួយគត់ ដែលនាំមកជារួមនូវទិដ្ឋភាពនៃការងាររបស់ អ.វ.ត.ក នាពេលបច្ចុប្បន្ន ដែលរកឃើញក្នុងប្រភពផ្សេងៗគ្នាក្នុងលក្ខណៈដែលអាចចូលមើលបាន និងច្បាស់លាស់។

# ការឧទ្ទិស

ការពិនិត្យឡើងវិញនេះធ្វើឡើង ដើម្បីឧទ្ទិសជាដំបូងបំផុតគឺចំពោះជនរងគ្រោះទាំងជនរងគ្រោះដែលនៅរស់ និងជនរងគ្រោះ ដែលបានស្លាប់បាត់បង់ជីវិតដោយឧក្រិដ្ឋកម្មដ៏រន្ធត់ ដែលប្រព្រឹត្តដោយខ្មែរក្រហមប្រឆាំងនឹងពួកគេ ចំពោះអ្នកដែលចូលមកផ្តល់ព័ត៌មាន ឬអ្នកផ្តល់សក្ខីកម្មអំពីឧក្រិដ្ឋកម្មទាំងនោះ និងអ្នកជំនាញនៅក្នុងស្ថាប័ន និងផ្នែកទាំងអស់នៃតុលាការនេះ ដែលជំនាញនិងការខិតខំប្រឹងប្រែងរបស់ពួកគេបាននាំមកនូវវិធានការយុត្តិធម៌មួយចំនួនជូនអ្នកដែលបានទទួលរងនូវភាពភ័យខ្លាចដែលមិននឹកស្មានដល់។

# សេចក្តីថ្លែងអំណរគុណ

អតីតសហព្រះរាជអាជ្ញាអន្តរជាតិសូមអរគុណចំពោះបុគ្គលិក និងបុគ្គលិកកម្មសិក្សានៃការិយាល័យសហព្រះរាជអាជ្ញា ដែលបានចូលរួមចំណែកក្នុងការបង្កើតកូនសៀវភៅពិនិត្យឡើងវិញនេះ ដែលមានឈ្មោះដូចតទៅ៖ លោក ឆាយ ណារឿន លោក មឿង ប៊ុនណាត លោក តួច វណ្ណារិទ្ធ លោក William Smith លោក Vincent de Wilde d'Estmael កញ្ញា Ruth Mary Hackler, Nisha Patel, Kate Mac Sweeney, Malina Gilka, Deniz Güzel, Roberta Spiteri, Serena Daoli, Charlotte Munk, Charlotte Soubelet, Angèle Richermoz, Eponine Howarth, Muskan Yadav, Moïra Van de Poël និង Lau Shun Nok Ryan។

សូមអរគុណជាពិសេសចំពោះកញ្ញា Chloé Veuve ដែលជាអ្នកកែច្នៃបង្កើតរូបរាង និងខ្លឹមសារនៃកូនសៀវភៅនេះ ព្រមទាំងជាអ្នកធ្វើសេចក្តីព្រាង និងសម្របសម្រួលក្នុងការផ្សំផ្គុំកូនសៀវភៅនេះឡើងទាំងជាភាសាខ្មែរ និងអង់គ្លេស។ សូមអរគុណជាពិសេសផងដែរចំពោះកញ្ញា Helen Worsnop ដែលបានជួយក្នុងការបង្កើត និងការសម្របសម្រួលក្នុងការធ្វើកូនសៀវភៅនេះ ព្រមទាំងចំពោះការធ្វើសេចក្តីព្រាងផ្នែកជាច្រើននៃកូនសៀវភៅនេះ និងការងារត្រួតពិនិត្យ ការកែសម្រួល និងការធ្វើសំយោគសេចក្តីព្រាងដែលបានផ្តល់ដោយបុគ្គលអ្នករួមចំណែកម្នាក់ៗ។

ជាចុងក្រោយ អតីតសហព្រះរាជអាជ្ញាអន្តរជាតិ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) និងសមាគមព្រះរាជអាជ្ញាច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដែលបោះពុម្ព និងផ្សព្វផ្សាយស្នាដៃនេះនៅលើគេហទំព័ររបស់ខ្លួន។

Brenda J. Hollis

សហព្រះរាជអាជ្ញាអន្តរជាតិ





# អក្សរកាត់ និងពាក្យកាត់

| | |
|---|---|
| BAKC | គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |
| CAT | អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ឆ្នាំ១៩៨៤ |
| ស.ច.ស | សហចៅក្រមស៊ើបអង្កេត |
| ប.ក.ក | បក្សកុម្មុយនីស្តកម្ពុជា |
| CPNLAF | កងទ័ពប្រជាជនរំដោះជាតិកម្ពុជា |
| DC-Cam | មជ្ឈមណ្ឌលឯកសារកម្ពុជា |
| អ.វ.ត.ក | អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា |
| កិច្ចព្រមព្រៀង អ.វ.ត.ក | កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ២០០៣ |
| ច្បាប់ អ.វ.ត.ក | ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (ដែលបានវិសោធនកម្ម) ឆ្នាំ២០០៤ |
| FUNK | រណសិរ្សរួបរួមជាតិកម្ពុជា |
| អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ | អនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ ឆ្នាំ១៩៤៨ |
| ការបំពារបំពានយ៉ាងធ្ងន់ធ្ងរ | ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ |
| អនុសញ្ញាទីក្រុងហ្សឺណែវ III | អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ទាក់ទងនឹងការប្រព្រឹត្តិលើឈ្លើយសឹក |
| អនុសញ្ញាទីក្រុងហ្សឺណែវ IV | អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ទាក់ទងនឹងការការពារជនស៊ីវិលក្នុងពេលសង្គ្រាម |
| GRUNK | រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា |
| ស.ច.ស.អ | សហចៅក្រមស៊ើបអង្កេតអន្តរជាតិ |
| ICC | តុលាការព្រហ្មទណ្ឌអន្តរជាតិ |
| ICCPR | កតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ |
| ស.ព.អ | សហព្រះរាជអាជ្ញាអន្តរជាតិ |
| ICTR | សាលក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ៉្វាន់ដា |
| ICTY | សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី |
| JCE | សហឧក្រិដ្ឋកម្មរួម |
| ស.ច.ស.ជ | សហចៅក្រមស៊ើបអង្កេតជាតិ |
| ស.ព.ជ | សហព្រះរាជអាជ្ញាជាតិ |

| | |
|---|---|
| ក.ស.ឧ.ស | ការិយាល័យសហធៅក្រមស៊ើបអង្កេត |
| ក.ស.ព | ការិយាល័យសហព្រះរាជអាជ្ញា |
| អ.ប.ជ | អង្គបុរេជំនុំជម្រះ |
| អ.ជ.ត.ក | អង្គជំនុំជម្រះតុលាការកំពូល |
| SCSL | តុលាការពិសេសសម្រាប់សៀរ៉ាឡេអូន |
| STL | តុលាការពិសេសសម្រាប់លីបង់ |
| អ.ជ.ស.ដ | អង្គជំនុំជម្រះសាលាដំបូង |
| អ.ស.ប | អង្គការសហប្រជាជាតិ |
| UNAKRT | ជំនួយអង្គការសហប្រជាជាតិសម្រាប់ការជំនុំជម្រះក្តីខ្មែរក្រហម |
| UNSG | អគ្គលេខាធិការអង្គការសហប្រជាជាតិ |

# ផែនទីកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧៦




*បោះពុម្ពដោយក្រសួងសិក្សាធិការ កម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៦ © គេហទំព័រ អ.វ.ត.ក*

# ផ្នែក I៖ ទិដ្ឋភាពទូទៅអំពី អ.វ.ត.ក

# ការបង្កើតតុលាការ

តុលាការត្រូវបានបង្កើតឡើងដោយសារលទ្ធផលនៃសំណើផ្លូវការ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧ របស់រាជរដ្ឋាភិបាលកម្ពុជាទៅកាន់អង្គការសហប្រជាជាតិ ស្នើសុំជំនួយដើម្បីនាំយកមកកាត់សេចក្ដីនូវជនទាំងឡាយណាដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មអន្តរជាតិ ដែលប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការកាន់អំណាចរបស់ខ្មែរក្រហម ចាប់ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩។

ក្នុងខែកុម្ភៈ ឆ្នាំ១៩៩៩ ក្រុមអ្នកជំនាញអង្គការសហប្រជាជាតិមួយក្រុម បានស្នើឱ្យមានការបង្កើតសាលាក្ដីអន្តរជាតិមួយ នៅក្រៅប្រព័ន្ធតុលាការជាតិកម្ពុជា។ ទោះជាយ៉ាងណា បន្ទាប់ពីការចរចាអស់រយៈពេលយ៉ាងយូរ - ដែលមានការពន្យារពេលស្ទើតែមួយឆ្នាំពីខែកុម្ភៈ ឆ្នាំ២០០២ - រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ បានចុះហត្ថលេខាលើ **កិច្ចព្រមព្រៀង អ.វ.ត.ក** នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ដើម្បីបង្កើត អ.វ.ត.ក នៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់របស់កម្ពុជា។

កិច្ចព្រមព្រៀង អ.វ.ត.ក ត្រូវបានអនុវត្តនៅក្នុងប្រទេសកម្ពុជាតាមរយៈ **ច្បាប់ អ.វ.ត.ក** ដែលអនុម័តនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ និងបានធ្វើវិសោធនកម្មនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។ បន្ទាប់ពីវិសោធនកម្មនេះ កិច្ចព្រមព្រៀង អ.វ.ត.ក បានចូលជាធរមាននៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥។

នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៦ អគារ អ.វ.ត.ក ដែលស្ថិតក្នុងខណ្ឌពោធិ៍សែនជ័យ នៅទីក្រុងភ្នំពេញ ត្រូវបានប្រគល់ជាផ្លូវការដោយកងយោធពលខេមរភូមិន្ទ។ ត្រឹមចុងខែតុលា ឆ្នាំ២០០៦ ការិយាល័យរដ្ឋបាល អង្គជំនុំជម្រះ សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត និងផ្នែកគាំពារការការពារក្ដី ត្រូវបានបង្កើតឡើង និងអាចដំណើរការបាន។

តុលាការបានដំណើរការពេញលេញនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ ដោយមានការអនុម័ត **វិធានផ្ទៃក្នុង**របស់ខ្លួនបន្ទាប់ពីការពិភាក្សាដេញដោល ដែលអូសបន្លាយជាយូរ។



*អគ្គលេខាធិការរងទទួលបន្ទុកកិច្ចការច្បាប់នៃ អ.ស.ប លោក Hans Corell និងឯកឧត្តមទេសរដ្ឋមន្ត្រី សុខ អាន ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣*

# យុត្តាធិការ

យុត្តាធិការរបស់តុលាការមានចែងនៅក្នុងមាត្រា ១, ២(១) និងមាត្រា៩ នៃ កិច្ចព្រមព្រៀង អ.វ.ត.ក និងជំពូក II និង VIII នៃច្បាប់ អ.វ.ត.ក។

កិច្ចព្រមព្រៀង អ.វ.ត.ក និង ច្បាប់ អ.វ.ត.ក ទទួលស្គាល់យុត្តាធិការបុគ្គល និង យុត្តាធិការពេលវេលារបស់តុលាការ ក្នុងការវិនិច្ឆ័យទោស **មេដឹកនាំជាន់ខ្ពស់**កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែល**ទទួលខុសត្រូវខ្ពស់បំផុត** ចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិនិងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលត្រូវបានប្រព្រឹត្តក្នុងអំឡុង **ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥** ដល់ **ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩**។

វិសាលភាពនៃយុត្តាធិការលើរឿងក្តីរបស់តុលាការនេះ មានចែងនៅក្នុងមាត្រា ៣ ដល់មាត្រា ៨ នៃច្បាប់ អ.វ.ត.ក រួមមានឧក្រិដ្ឋកម្មដូចខាងក្រោម៖

- **ឧក្រិដ្ឋកម្មថ្នាក់ជាតិ** ស្ថិតក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦៖ មនុស្សឃាត ទារុណកម្ម និងការវាយប្រហារលើសាសនា។
- **អំពើប្រល័យពូជសាសន៍**ចែងក្នុងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍។
- **ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** រួមបញ្ចូលទាំង ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា និងអំពើអមនុស្សធម៌ផ្សេងៗទៀត។
- **អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ** រួមមាន ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព និង ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់។
- **ការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌** ក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធ អនុលោមតាមអនុសញ្ញាទីក្រុងឡាអេ ឆ្នាំ១៩៥៤ ស្តីពីការការពារសម្បត្តិវប្បធម៌ក្នុងពេលមានជម្លោះប្រដាប់អាវុធ។ និង
- **ឧក្រិដ្ឋកម្មប្រឆាំងបុគ្គលដែលទទួលបានការការពារជាអន្តរជាតិ** ស្ថិតក្រោម អនុសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦១ ស្តីពីទំនាក់ទំនងការទូត។

មាត្រា ២៩ថ្មី នៃច្បាប់ អ.វ.ត.ក ចែងអំពីការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលចំពោះ **ការរៀបចំផែនការ ការញុះញង់ ការបញ្ជា ការជួយនិងជំរុញ ឬការប្រព្រឹត្ត**ឧក្រិដ្ឋកម្មខាងលើ ក៏ដូចជា **ការទទួលខុសត្រូវរបស់ថ្នាក់លើ**ចំពោះការខកខានមិនបានរារាំង ឬដាក់ទណ្ឌកម្មអ្នកដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ។ សហឧក្រិដ្ឋកម្មរួមត្រូវបានទទួលស្គាល់ថា ជាទម្រង់មួយនៃការប្រព្រឹត្តិឧក្រិដ្ឋកម្ម។ មាត្រា២៩ថ្មី ក៏បញ្ជាក់ពី (i) ភាពមិនអាចរកបាននូវការការពារខ្លួន ដែលសំអាងលើការប្រព្រឹត្តិតាមបញ្ជារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬថ្នាក់លើ និងថា (ii) មុខតំណែង ឬឋានៈរបស់បុគ្គលនោះ មិនបន្ធូរបន្ថយការទទួលខុសត្រូវ ឬកាត់បន្ថយចំពោះការផ្តន្ទាទោសគាត់នោះឡើយ។

# រចនាសម្ព័ន្ធ

អ.វ.ត.ក ត្រូវបានពិពណ៌នាថាជាតុលាការ "កូនកាត់" ឬ "អន្តរជាតូបនីយ-កម្ម"។ ខណៈពេលដែលពាក្យទាំងនេះអាចសំដៅទៅលើរចនាសម្ព័ន្ធសាលាក្តីផ្សេងៗ ក្នុងករណីរបស់ អ.វ.ត.ក ពាក្យទាំងនេះពិពណ៌នាអំពីតុលាការដែលបង្កើតឡើងក្រោមច្បាប់ក្នុងស្រុករបស់កម្ពុជា អនុលោមតាមសន្ធិសញ្ញាអន្តរជាតិរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ដែលប្រតិបត្តិការតែមួយគត់នៅក្នុងប្រទេសកម្ពុជាដោយមានការចូលរួមពីអន្តរជាតិ។ ក្របខ័ណ្ឌគតិយុត្តរបស់តុលាការតម្រូវឱ្យ អ.វ.ត.ក អនុវត្តនូវបទដ្ឋានកាត់ក្តីដោយត្រឹមត្រូវយុត្តិធម៌ជាអន្តរជាតិ។

រចនាសម្ព័ន្ធរបស់ អ.វ.ត.ក ផ្អែកលើប្រព័ន្ធច្បាប់ស៊ីវិលរបស់កម្ពុជា ដែលកើតចេញពីគំរូស៊ើបអង្កេតរបស់បារាំង។ ស្ថាប័ននីមួយៗរបស់តុលាការ មានទាំងបុគ្គលិកជាតិ និងអន្តរជាតិ ទីប្រឹក្សា និងកម្មសិក្សាការី។

ភាសាផ្លូវការរបស់តុលាការ គឺភាសាខ្មែរ ចំណែកភាសាការងារផ្លូវការ គឺជាភាសាខ្មែរ ភាសាអង់គ្លេស និង ភាសាបារាំង ។

តុលាការមានស្ថាប័នសំខាន់ៗចំនួនបួន ហើយនៅរក្សាដដែលពេលប្តូរទៅដំណាក់កាលមុខងារសេសសល់ ដែលមានផ្នែក និងអង្គភាពផ្សេងៗនៅក្នុងស្ថាប័ននីមួយៗ។ លើសពីនេះ វិធានផ្ទៃក្នុងបានបង្កើតគណៈកម្មាធិការចំនួនបីដែលបានកោះប្រជុំជាទៀងទាត់ខុសៗគ្នា។

## ស្ថាប័ន និងផ្នែករបស់ អ.វ.ត.ក

**ការិយាល័យសហព្រះរាជអាជ្ញា** គឺជាការិយាល័យឯករាជ្យមួយនៅ អ.វ.ត.ក។ មានសហព្រះរាជអាជ្ញាចំនួនពីររូប ម្នាក់ជាសហព្រះរាជអាជ្ញាជាតិ ហើយនិងម្នាក់ទៀតជាសហព្រះរាជអាជ្ញាអន្តរជាតិ ដោយពួកគេមានសិទ្ធិអំណាចស្មើគ្នា។ សហព្រះរាជអាជ្ញាទាំងពីររូប តម្រូវឱ្យមានឯករាជ្យភាពក្នុងការអនុវត្តមុខងាររបស់ខ្លួន ដោយមិនទទួលយក ឬស្វែងរកការណែនាំពីរដ្ឋាភិបាលណាមួយ ឬពីប្រភពផ្សេងទៀតឡើយ។ សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ បានតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជា ក្នុងករណីសហព្រះរាជអាជ្ញាអន្តរជាតិ បន្ទាប់ពីត្រូវបានតែងតាំងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិរួចមក ការតែងតាំងរបស់ពួកគេត្រូវមានការបញ្ជាក់ពីព្រះរាជក្រឹត្យកម្ពុជា។

ក្នុងអំឡុងពេលដំណាក់កាលតុលាការនៃ អ.វ.ត.ក តួនាទីរបស់សហព្រះរាជអាជ្ញាគឺត្រូវចោទប្រកាន់អ្នកដែលខ្លួនជឿថាមានភស្តុតាងបញ្ជាក់ថា បុគ្គលនោះគឺជាមេដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហម និង/ឬ អ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងសម័យខ្មែរក្រហម។ ដោយរួមគ្នាជាមួយបុគ្គលិករបស់ខ្លួនសហព្រះរាជអាជ្ញាដំណើរការលើពាក្យបណ្តឹងធ្វើការស៊ើបអង្កេតបឋមចូលរួមក្នុងការស៊ើបអង្កេតតាមផ្លូវតុលាការ និងធ្វើការចោទប្រកាន់រឿងក្តីនៅទូទាំងដំណាក់កាលមុនការជំនុំជម្រះ ដំណាក់កាលជំនុំជម្រះ និងដំណាក់កាលបណ្តឹងសាទុក្ខ រួមទាំងការអនុវត្តការកាត់ទោសចុងក្រោយដែលចេញដោយអង្គជំនុំជម្រះ។

សហព្រះរាជអាជ្ញាក៏ទទួលបន្ទុកបញ្ជាក់ពីមូលហេតុ នៃការស្លាប់របស់បុគ្គលនៅក្នុងមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក ផងដែរ ដូចដែលបានធ្វើកន្លងមកពេលដែល អៀង សារី និង នួន ជា បានទទួលមរណភាព (វិធាន ៣២*ស្ទួន*)។

សហព្រះរាជអាជ្ញា និងបុគ្គលិករបស់ខ្លួនក៏បានចូលរួមក្នុងការផ្សព្វផ្សាយ និងលើកកម្ពស់ការកសាងសមត្ថភាពជាមួយបុគ្គលិកជាតិ និងអន្តរជាតិ និងកម្មសិក្សាការីផងដែរ។

គិតត្រឹមខែកញ្ញា ឆ្នាំ២០២៤ មានសហព្រះរាជអាជ្ញាជាតិមួយរូបគឺ លោកស្រី ជា លាង និងសហព្រះរាជអាជ្ញាអន្តរជាតិចំនួនបួនរូបគឺ លោក Robert Petit (កាណាដា៖ ២០០៦-២០០៩) លោក Andrew Cayley KC (ចក្រភពអង់គ្លេស៖ ២០០៩-២០១៣) លោក Nicholas Koumjian (សហរដ្ឋអាមេរិក៖ ២០១៣-២០១៩) លោកស្រី Brenda J. Hollis (សហរដ្ឋអាមេរិក៖ ឆ្នាំ២០១៩-២០២២) និងលោក Dale Lysak (កាណាដា៖ ២០២៣-បច្ចុប្បន្ន)។បន្ទាប់ពីលោកស្រី Hollis បានលាឈប់ពីមុខដំណែង គាត់ត្រូវបានជំនួយដោយសហព្រះរាជអាជ្ញាអន្តរជាតិបម្រុងគឺលោក Fergal Gaynor (អៀរឡង់)។



*អតីត ស.ព.អ លោក Nicholas Koumjian និង ស.ព.ជ លោកស្រី ជា លាង*
*© គេហទំព័រ អ.វ.ត.ក*



**ការិយាល័យសហចៅក្រមស៊ើបអង្កេត** គឺជាការិយាល័យ អ.វ.ត.ក ឯករាជ្យមួយទៀត។ការិយាល័យនេះរួមមានសហចៅក្រមស៊ើបអង្កេតចំនួនពីររូបគឺកម្ពុជាមួយរូប និងអន្តរជាតិមួយរូប ដែលមានឯករាជ្យភាព និងសិទ្ធិអំណាចស្មើគ្នា។ ពួកគេត្រូវបានតែងតាំងស្រដៀងគ្នាដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងករណី ស.ច.ស.អ បន្ទាប់ពីការតែងតាំងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ - និងព្រះរាជក្រឹត្យ។

ក្នុងអំឡុងពេលដំណាក់កាលតុលាការ ស.ច.ស មានតួនាទីស៊ើបអង្កេតជាចំបង (វិធាន ៥៥-៦៩) ដែលទទួលខុសត្រូវក្នុងការប្រមូលភស្តុតាងនិងស៊ើបអង្កេតអង្គហេតុដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា។ នៅក្នុងការអនុវត្ត ការស៊ើបអង្កេតត្រូវបានអនុវត្តដោយបុគ្គលិកនិងអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស អនុលោមតាមដីកាចាត់ឱ្យស៊ើបសួរជំនួស (វិធាន ៦២)។ បន្ទាប់ពីការស៊ើបអង្កេតត្រូវបានបញ្ចប់ ស.ច.ស ចេញដីកាដំណោះស្រាយ។ ដីកាដំណោះស្រាយអាចជាដីកាបង្គាប់ឱ្យបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់ ដែលរំលត់កិច្ចដំណើរការនីតិវិធី។

មកទល់ពេលនេះមាន ស.ច.ស.ជ ចំនួនមួយរូបគឺចៅក្រម យូ ប៊ុនឡេង និង ស.ច.ស.អ ចំនួនបួនរូប គឺចៅក្រម Marcel Lemonde (បារាំង៖ ២០០៦-២០១០) ចៅក្រម Siegfried Blunk (អាល្លឺម៉ង់៖ ២០១០-២០១១) ចៅក្រម Mark Harmon (អាមេរិក៖ ២០១២-២០១៥) និងចៅក្រម Michael Bohlander (អាល្លឺម៉ង់៖ ២០១៥-បច្ចុប្បន្ន)។ ស.ច.ស.អ បម្រុង Laurent Kasper-Ansermet បានដើរតួជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងរយៈពេលខ្លី (២០១១-២០១២)។



*ស.ច.ស.ជ ចៅក្រម យូ ប៊ុនឡេង និង ស.ច.ស.អ ចៅក្រម Michael Bohlander*
*© គេហទំព័រ អ.វ.ត.ក*

**អង្គជំនុំជម្រះតុលាការ** ត្រូវបានបង្កើតឡើងដោយចៅក្រមកម្ពុជា និងអន្តរជាតិ និងចៅក្រមបម្រុង នៅក្នុងអង្គជំនុំជម្រះចំនួនបី៖ អ.ប.ជ អ.ជ.ស.ដ និង អ.ជ.ត.ក ដែលអង្គជំនុំជម្រះនីមួយៗមានប្រធានជាជនជាតិកម្ពុជា។ ចៅក្រមម្នាក់ៗត្រូវតែឯករាជ្យ និងមានបទពិសោធន៍ផ្នែកច្បាប់ជាចាំបាច់។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតែងតាំងចៅក្រមទាំងអស់ ដោយចៅក្រមអន្តរជាតិត្រូវបានតែងតាំងដោយអគ្គលេខាធិការ អ.ស.ប។ បន្ទាប់មក ការតែងតាំងត្រូវបានបញ្ជាក់ដោយព្រះរាជក្រឹត្យ។

- **អង្គបុរេជំនុំជម្រះ**

អង្គបុរេជំនុំជម្រះ មានចៅក្រមជាតិចំនួនបីរូប និងចៅក្រមអន្តរជាតិចំនួនពីររូប ហើយសេចក្តីសម្រេចទាមទារឱ្យមានការបោះឆ្នោត ដោយសំឡេងភាគច្រើន (យ៉ាងហោចណាស់ចៅក្រមបួនរូប ក្នុងចំណោមប្រាំរូប)។ ដូច្នេះសេចក្តីសម្រេចណាមួយតម្រូវឱ្យមានការបោះឆ្នោតគាំទ្រទាំងចៅក្រមជាតិ និងចៅក្រមអន្តរជាតិ ទោះបីជាសំឡេងរួមគ្នាច្បាស់លាស់អាចប្រែប្រួលក៏ដោយ។ សេចក្តីសម្រេចរបស់ អ.ប.ជ គឺជាសេចក្តីសម្រេចស្ថាពរ។

ក្នុងអំឡុងពេលដំណាក់កាលតុលាការតួនាទីរបស់ អ.ប.ជ មានច្រើនផ្នែក។ ដើមឡើយត្រូវបានរៀបចំឡើងជាស្ថាប័នដើម្បីដោះស្រាយការខ្វែងគំនិតគ្នារវាងសហព្រះរាជអាជ្ញា និង ស.ច.ស (វិធាន ៧១ & ៧២) មុខងារចម្បងរបស់អង្គជំនុំជម្រះនេះ នៅក្នុងការអនុវត្តគឺដូចជាអង្គជំនុំជម្រះបណ្តឹងឧទ្ធរណ៍មុនការជំនុំជម្រះ។ ដូច្នេះ អង្គជំនុំជម្រះនេះ ស្តាប់សវនាការបណ្តឹងឧទ្ធរណ៍ពីគ្រប់ភាគីប្រឆាំងនឹងសេចក្តីសម្រេច និងដីកាបង្គាប់ដែលចេញដោយ ស.ច.ស (វិធាន ៧៤) ក៏ដូចជាពាក្យសុំប្រកាសទុកជាមោឃៈលើទិដ្ឋភាពនៃការស៊ើបអង្កេតបឋម ឬការស៊ើបអង្កេតតាមផ្លូវតុលាការ (វិធាន ៧៦)។ ដូចគ្នាទៅនឹងសភាស៊ើបសួររបស់តុលាការកម្ពុជាដែរ ស្ថាប័ននេះក៏ដើរតួជា “អង្គភាពត្រួតពិនិត្យនៅដំណាក់កាលស៊ើបអង្កេត” ដោយមានយុត្តាធិការដែលមានជាប់មកជាមួយក្នុងការត្រួតពិនិត្យនិងសើរើរឿងក្តី ដើម្បីធានាថា ការស៊ើបអង្កេតគឺពេញលេញ និងស្របច្បាប់។ អង្គជំនុំជម្រះនេះ ក៏មានយុត្តាធិការលើពាក្យសុំប្តឹងជំទាស់ ស.ច.ស (វិធាន ៣៤) និងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចផ្នែករដ្ឋបាលមួយចំនួនផងដែរ (វិធាន ១១, ២២, ២៣ *ស្ទួនបី* & ៣៨) និងការកំណត់ទាក់ទងនឹងការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ (វិធាន ៣៥)។

គិតត្រឹមខែកញ្ញា ឆ្នាំ២០២៤ ចៅក្រមខាងក្រោម បម្រើការ ឬបានបម្រើការជាចៅក្រម អ.ប.ជ៖ ចៅក្រមជាតិ ចៅក្រម ប្រាក់ គឹមសាន (ប្រធាន៖ ២០០៦-បច្ចុប្បន្ន) ចៅក្រម ន័យ ថុល (២០០៦-បច្ចុប្បន្ន) ចៅក្រម ហួត វុទ្ធី (២០០៦-

បច្ចុប្បន្ន) និង ចៅក្រម ប៉ែន ពេជ្រសាលី (បម្រុង៖ ២០០៦-បច្ចុប្បន្ន) និងចៅក្រមអន្តរជាតិ ចៅក្រម Baik Kang Jin (សាធារណៈរដ្ឋកូរ៉េ៖ ២០១៥-បច្ចុប្បន្ន) ចៅក្រម Olivier Beauvallet (បារាំង៖ ២០១៥-បច្ចុប្បន្ន) ចៅក្រម Steven J. Bwana (បម្រុង តង់សានី៖ ២០១៣-បច្ចុប្បន្ន) ចៅក្រម Katinka Lahuis (ហូឡង់៖ ២០០៦-២០១២) ចៅក្រម Rowan Downing (អូស្ត្រាលី៖ ២០០៦-២០១៥) ចៅក្រម Catherine Marchi-Uhel (បារាំង៖ ២០១០-២០១១) និង ចៅក្រម Chang-ho Chung (សាធារណរដ្ឋកូរ៉េ៖ ២០១១-២០១៥)។

- **អង្គជំនុំជម្រះសាលាដំបូង**

ដូច អ.ប.ជ ដែរ អ.ជ.ស.ដ ត្រូវបានបង្កើតឡើងដោយ ចៅក្រមជាតិបីរូប និងចៅក្រមអន្តរជាតិពីររូប ដោយតម្រូវឲ្យមានការបោះឆ្នោតភាគច្រើនលើសលុបដូចគ្នា។ ខុសពីអង្គបុរេជំនុំជម្រះ ចៅក្រមបម្រុងនៃ អ.ជ.ស.ដ ត្រូវតែមានវត្តមាននៅគ្រប់ដំណាក់កាល នៃកិច្ចដំណើរការនីតិវិធី ប៉ុន្តែមិនមានសិទ្ធិបញ្ចេញទស្សនៈ ឬធ្វើការសម្រេចចិត្តណាមួយឡើយ រហូតដល់ត្រូវបានតែងតាំងជំនួសចៅក្រមពេញសិទ្ធិ (វិធាន ៧៩(៣))។

អ.ជ.ស.ដ ធ្វើការជំនុំជម្រះក្តីរបស់ អ.វ.ត.ក និងចេញសាលក្រមជំនុំជម្រះ។ អង្គជំនុំជម្រះកំណត់អំពីភ័ស្តុតាងដើម្បីបញ្ជាក់ថាតើ ជនជាប់ចោទមានពិរុទ្ធភាពដែរឬទេ ចំពោះការចោទប្រកាន់មកលើជនជាប់ចោទរូបនោះ និងចេញសាលក្រមដែលជាសាលក្រមបង្ហាញពីពិរុទ្ធភាព ឬមិនមានពិរុទ្ធភាព។ អ.ជ.ស.ដ ក៏អាចធ្វើការស៊ើបអង្កេតថ្មី ក្រោមលក្ខខណ្ឌដូចគ្នានឹង ស.ច.ស ដែរ (វិធាន ៩៣)។ នៅក្នុងករណីមានសាលក្រមពិរុទ្ធភាព អ.ជ.ស.ដ សម្រេចលើការកាត់ទោស ហើយអាចផ្តល់សំណងដល់ដើមបណ្តឹងរដ្ឋប្បវេណី។

មកទល់ពេលនេះ ចៅក្រមខាងក្រោមបម្រើការ ឬធ្លាប់បម្រើការក្នុង អ.ជ.ស.ដ៖ ចៅក្រមជាតិ ចៅក្រម និល ណុន (ប្រធាន៖ ២០០៦-បច្ចុប្បន្ន) ចៅក្រម យ៉ា សុខន (២០០៦-បច្ចុប្បន្ន) ចៅក្រម យូរ ឧត្តរា (២០០៦-បច្ចុប្បន្ន) និងចៅក្រម ធូ មន្នី (បម្រុង៖ ២០០៦-បច្ចុប្បន្ន) និងចៅក្រមអន្តរជាតិ ចៅក្រម Claudia Fenz (អូទ្រីស៖ ២០១៤-បច្ចុប្បន្ន) ចៅក្រម Martin Karopkin (សហរដ្ឋអាមេរិក៖ ២០១៩-បច្ចុប្បន្ន) ចៅក្រម Dame Silvia Cartwright (នូវែលសេឡង់៖ ២០០៦-២០១៤) និង ចៅក្រម Jean-Marc Lavergne (បារាំង៖ ២០០៦-២០១៩)។

- **អង្គជំនុំជម្រះតុលាការកំពូល**

អ.ជ.ត.ក ត្រូវបានបង្កើតឡើងដោយចៅក្រមជាតិ ចំនួនបួនរូប និងចៅក្រមអន្តរជាតិ ចំនួនបីរូប ហើយសេចក្តីសម្រេច និងសាលដីកា ទាមទារឱ្យមានការបោះឆ្នោតដោយសំឡេងភាគច្រើនលើសលុប (យ៉ាងហោចណាស់ចៅក្រមប្រាំរូបក្នុងចំណោមប្រាំពីររូប)។ សេចក្តីសម្រេចរបស់ អ.ជ.ត.ក ជាសេចក្តីសម្រេចស្ថាពរ។

អ.ជ.ត.ក ជំនួសសាលាឧទ្ធរណ៍ និងតុលាការកំពូលក្នុងប្រព័ន្ធជាតិកម្ពុជា មកជាស្ថាប័នតុលាការតែមួយ ហើយបម្រើការជាអង្គជំនុំជម្រះសាលាឧទ្ធរណ៍ និងតុលាការចុងក្រោយរបស់ អ.វ.ត.ក ពោលគឺជាអំណាចតុលាការខ្ពស់បំផុតរបស់ អ.វ.ត.ក ដែលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះនេះ មិនអាចត្រូវបានពិនិត្យឡើងវិញឡើយ។

អង្គជំនុំជម្រះនេះអាចស្តាប់បណ្តឹងសាទុក្ខពីភាគីទាំងអស់ប្រឆាំងនឹងសេចក្តីសម្រេច និងសាលក្រមដែលចេញដោយ អ.ជ.ស.ដ។ បទដ្ឋាននៃការពិនិត្យឡើងវិញរបស់អង្គជំនុំជម្រះ ប្រហាក់ប្រហែលនឹងអ្វីដែលមាននៅតុលាការ

ICTY, ICTR និង SCSL ដែរ។ ខុសពីសាលាឧទ្ធរណ៍កម្ពុជា អង្គជំនុំជម្រះនេះមិនសម្រេចលើរឿងក្តី *ជាថ្មីឡើងវិញ* ទេ។ ទោះយ៉ាងណាក៏ដោយ អ.ជ.ត.ក អាចពិនិត្យភស្តុតាង និងកោះហៅ ឬទទួលយកភស្តុតាងថ្មី ដើម្បីកំណត់បញ្ហា (វិធាន ១០៤(១))។ ក្នុងនាមជាតុលាការចុងក្រោយ អង្គជំនុំជម្រះនេះក៏មានយុត្តាធិការ ដើម្បីបំពេញកិច្ចក្នុងផលប្រយោជន៍យុត្តិធម៌ ដើម្បីផ្តល់ភាពច្បាស់លាស់ និងភាពប្រាកដប្រជាផ្នែកច្បាប់ផងដែរ។

រហូតមកដល់បច្ចុប្បន្ន ចៅក្រមខាងក្រោមបម្រើការ ឬបានបម្រើការនៅក្នុង អ.ជ.ត.ក៖ ចៅក្រមជាតិ ចៅក្រម គង់ ស្រ៊ឹម (ប្រធាន៖ ២០០៦-បច្ចុប្បន្ន) ចៅក្រម សោម សិរីវឌ្ឍ (២០០៦-បច្ចុប្បន្ន) ចៅក្រម យ៉ា ណារិន (២០០៦-បច្ចុប្បន្ន) ចៅក្រម ម៉ុង មុន្នីចរិយា (២០០៦-បច្ចុប្បន្ន) និងចៅក្រម ស៊ិន រិទ្ធ (បម្រុង៖ ២០០៦-បច្ចុប្បន្ន) និង ចៅក្រមអន្តរជាតិ ចៅក្រម Maureen Harding Clark (អៀរឡង់៖ ២០១៩-បច្ចុប្បន្ន) ចៅក្រម Chandra Nihal Jayasinghe (ស្រីលង្កា៖ ២០០៦-បច្ចុប្បន្ន) ចៅក្រម Florence Ndepele Mwachande Mumba (សំប៊ី៖ ២០១២-បច្ចុប្បន្ន) ចៅក្រម Motoo Noguchi (ជប៉ុន៖ ២០០៦-២០១២ បម្រុង ២០២៤-បច្ចុប្បន្ន) ចៅក្រម Agnieszka Klonowiecka-Milart (ប៉ូឡូញ៖ ២០០៦-២០១៨)៖ និងចៅក្រម Katrien Gabrel Witteman (ហូឡង់៖ ២០២៤-បច្ចុប្បន្ន) ។

**ការិយាល័យរដ្ឋបាល** ត្រូវបានដឹកនាំដោយប្រធាន ដែលតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា និងអនុប្រធានដែលត្រូវបានតែងតាំងដោយអគ្គលេខាធិការ អ.ស.ប។ អនុប្រធានក៏ជាអ្នកសម្របសម្រួលរបស់ UNAKRT ផងដែរ ដែលជាបេសកកម្មរបស់អង្គការសហប្រជាជាតិ ផ្តល់ជំនួយបច្ចេកទេសដល់ អ.វ.ត.ក ។



*បន្ទប់សវនាការ អ.វ.ត.ក © គេហទំព័រ អ.វ.ត.ក*

ការិយាល័យរដ្ឋបាល ទទួលខុសត្រូវចំពោះការគាំទ្រ និងការសម្របសម្រួលដំណើរការតុលាការរបស់ អ.វ.ត.ក រួមទាំងការជ្រើសរើសបុគ្គលិក អ.វ.ត.ក និងការគ្រប់គ្រងកន្លែងឃុំឃាំងរបស់ អ.វ.ត.ក ផងដែរ។ ដូចបានពិភាក្សាខាងក្រោមការិយាល័យរដ្ឋបាលបានដើរតួនាទីដឹកនាំក្នុងអំឡុងពេលដំណាក់កាលមុងារសេសសល់។ នៅក្នុងដែនកំណត់ជាក់លាក់ ការិយាល័យរដ្ឋបាលបម្រើជាបណ្តាញផ្លូវការរបស់ អ.វ.ត.ក សម្រាប់ទំនាក់ទំនងទាំងខាងក្នុង និងខាងក្រៅ ធ្វើសេចក្តីព្រាង និងពិនិត្យឯកសារផ្លូវការរបស់ អ.វ.ត.ក និងទទួលខុសត្រូវរួមក្នុងការចាត់ចែងទំនាក់ទំនងជាមួយរាជរដ្ឋាភិបាលកម្ពុជា អង្គការសហប្រជាជាតិ និងសហគមន៍ម្ចាស់ជំនួយ។ អនុប្រធានគ្រប់គ្រងធនធាន ដែលផ្តល់តាមរយៈមូលនិធិទំនុកចិត្តរបស់អង្គការសហប្រជាជាតិ។

ការិយាល័យរដ្ឋបាលរួមមាន ផ្នែកថវិកា និងហិរញ្ញវត្ថុ ផ្នែកគ្រប់គ្រងតុលាការ (រួមបញ្ចូល អង្គភាពសោតទស្សន៍ អង្គភាពទំនាក់ទំនងមន្ទីរឃុំឃាំង អង្គភាពបកប្រែភាសា ការិយាល័យជួរមុខ អង្គភាពបណ្ណសារ អង្គភាពប្រតិចារឹក និងអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ផ្នែកសេវាកម្មទូទៅ ផ្នែកបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង ផ្នែកគ្រប់គ្រងធនធានមនុស្ស ផ្នែកកិច្ចការសាធារណៈ ផ្នែក

សន្តិសុខនិងសុវត្ថិភាព និង ផ្នែកគាំពារជនរងគ្រោះ។ ផ្នែកគាំពារការការពារក្តី និង ផ្នែកសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក៏ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ការិយាល័យរដ្ឋបាលផងដែរ។ ទោះជាយ៉ាងណា ជាសំខាន់ផ្នែកទាំងពីរនេះត្រូវបានកំណត់អាណត្តិឱ្យមានស្វ័យភាព ទាក់ទងនឹងបញ្ហាសំខាន់ៗ។

ប្រធានស្តីទីឯកឧត្តម ក្រាញ់ តូនី និងអនុប្រធានលោក Knut Roesandhaug (ន័រវែស)។ ឯកឧត្តម ស៊ាន វិសុទ្ធ ប្រធានពីឆ្នាំ២០០៥ ដល់ឆ្នាំ ២០០៨ ហើយអតីតអនុប្រធានគឺលោកស្រី Michelle Lee (ចិន៖ ២០០៥-២០០៨)។

- **ផ្នែកគាំពារការការពារក្តី**

ក្រុមមេធាវីការពារក្តីនីមួយៗ មានសហមេធាវីពីររូប ឬច្រើនជាងនេះ យ៉ាងតិចខ្មែរម្នាក់ និងអន្តរជាតិម្នាក់ ដែលត្រូវបានគាំទ្រដោយជំនួយការ រួមទាំងទីប្រឹក្សាផ្នែកច្បាប់ និងអ្នកគ្រប់គ្រងសំណុំរឿងម្នាក់។ មេធាវីការពារក្តីរបស់ អ.វ.ត.ក គឺជាករណីលើកលែង ចំពោះរចនាសម្ព័ន្ធដែលទទួលគាំទ្រដោយមូលនិធិពីរនៅ អ.វ.ត.ក។ តាមមាត្រា ១៧(គ) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ការចំណាយលើផ្នែកការពារក្តី ជាបន្ទុកតែមួយគត់របស់ អ.ស.ប។

ផ្នែកគាំពារការពារក្តីត្រូវបានបង្កើតឡើងក្រោមវិធាន ១១ ដើម្បីគ្រប់គ្រងទិដ្ឋភាពរដ្ឋបាលនៃមុខងារការពារក្តី និងដំណើរការតាមវិធានផ្ទៃក្នុង និង បទប្បញ្ញត្តិរដ្ឋបាលរបស់ខ្លួន។ នេះគឺជាផ្នែកតែមួយគត់ដែលគ្រប់គ្រងផ្ទាល់មុខដោយបុគ្គលិក អ.ស.ប ដែលមានប្រធានផ្នែក ដែលរាយការណ៍ដោយផ្ទាល់ទៅអនុប្រធានការិយាល័យរដ្ឋបាល។ ក្នុងនាមជាអ្នកគ្រប់គ្រងគម្រោងជំនួយផ្នែកច្បាប់របស់ អ.វ.ត.ក ផ្នែកគាំពារការការពារក្តី បម្រើមុខងារសំខាន់ក្នុងការផ្តល់ដល់ជនជាប់ចោទដែលត្រូវការជំនួយ នូវបញ្ជីមេធាវីជាតិ និងអន្តរជាតិ ដែលអាចការពារក្តីពួកគេ ចុះកិច្ចសន្យាផ្តល់សេវាកម្មផ្លូវច្បាប់ជាមួយមេធាវីដែលបានជ្រើសរើស វាយតម្លៃលើការបំពេញកិច្ចសន្យាទាំងនោះ និងការអនុញ្ញាតលើការទូទាត់។ ផ្នែកនេះក៏អនុម័តលើការតែងតាំងសមាជិកក្រុមការពារក្តីផ្សេងទៀតផងដែរ។

លើសពីនេះ ផ្នែកគាំពារការការពារក្តី មានការទទួលខុសត្រូវក្នុងការគាំទ្រចំពោះមេធាវីទាំងអស់ដែលត្រូវបានអនុមតិឱ្យការពារបុគ្គលនៅចំពោះមុខ អ.វ.ត.ក រួមទាំង i) ធ្វើការជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (BAKC) ដើម្បីកំណត់សិទ្ធិរបស់ពួកគេក្នុងការបង្ហាញខ្លួននៅចំពោះមុខ អ.វ.ត.ក ii) ការផ្តល់ជំនួយផ្នែកច្បាប់ជាមូលដ្ឋាន និងការគាំទ្រផ្នែករដ្ឋបាល និង iii) ការរៀបចំការបណ្តុះបណ្តាលសម្រាប់ពួកគេក្នុងការពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការជាមួយ BAKC។ ផ្នែកនេះក៏ដើរតួជាសំឡេងមួយសម្រាប់ផ្នែកការការពារក្តីនៅក្នុងព្រឹត្តិការណ៍ផ្សព្វផ្សាយនិងនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ និងការរៀបចំកម្មវិធីកម្មសិក្សាសម្រាប់មេធាវីវ័យក្មេង។

- **ផ្នែកគាំពារជនរងគ្រោះ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

*ការចូលរួមរបស់ជនរងគ្រោះនៅ អ.វ.ត.ក*

ជនរងគ្រោះអាចចូលរួមក្នុងកិច្ចដំណើរការរបស់ អ.វ.ត.ក តាមវិធីផ្សេងៗ។ ឧទាហរណ៍ ជនរងគ្រោះអាចជ្រើសរើសចូលរួមតាមនីតិវិធីមិនផ្លូវការ ឬអាចចូលរួមជាផ្លូវការក្នុងនាមជាអ្នកដាក់ពាក្យប្តឹង ឬ ជាដើមបណ្តឹងរដ្ឋប្បវេណី។ ការចូលរួមរបស់ជនរងគ្រោះត្រូវបានគ្រប់គ្រងដោយវិធានផ្ទៃក្នុង (ជាមួយនឹង

គោលការណ៍ទូទៅ ដូចមានចែងក្នុងវិធាន ២៣ និង ២៣*ស្ទួន*, *ស្ទួនពីរ*, *ស្ទួនបី*, *ស្ទួនបួន*) និង សេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ។

នៅក្រោមក្របខ័ណ្ឌតុលាការរបស់ អ.វ.ត.ក ដើមបណ្តឹងរដ្ឋប្បវេណី គឺជាភាគីនៃកិច្ចដំណើរការនីតិវិធី។ ពួកគេមានសិទ្ធិឱ្យគេតំណាងនៅក្នុងកិច្ចដំណើរការនីតិវិធី និងស្វែងរកសំណងសមូហភាព និងសំណងផ្នែកសីលធម៌ ក្នុងករណីដែលពួកគេបង្ហាញថា ពួកគេបានទទួលរងព្យសនកម្មលើរាងកាយ សម្ភារ ឬផ្លូវចិត្តដែលកើតចេញ យ៉ាងហោចណាស់ ពីលទ្ធផលផ្ទាល់នៃឧក្រិដ្ឋកម្មមួយនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់លើជនជាប់ចោទ។ នៅដំណាក់កាលមុនការជំនុំជម្រះ ពួកគេចូលរួមជាលក្ខណៈបុគ្គល ជាក្រុម ឬ ជាផ្នែកនៃសមាគមជនរងគ្រោះ ហើយត្រូវតែតំណាងដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី យ៉ាងហោចណាស់ចាប់ពីពេលចេញដីកាដំណោះស្រាយតទៅ។ ក្នុងការអនុវត្ត មេធាវីជាច្រើនបានតែងតាំងតាំងពីដំណាក់កាលដំបូង ហើយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះហើយ ដែលអាចប្តឹងតវ៉ាក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណី ក្នុងដំណាក់កាលមុនការជំនុំជម្រះ រួមទាំងលើបញ្ហានានា ដូចជាជំហានស៊ើបអង្កេតដែលគួរតែត្រូវបានអនុវត្តដោយសហចៅក្រមស៊ើបអង្កេត។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីកម្ពុជាចំនួនបីរូប ត្រូវបានផ្តល់ប្រាក់ខែដោយភាគីជាតិនៃការិយាល័យរដ្ឋបាល។ មេធាវីភាគច្រើនទៀតដែលនៅសល់ ទោះបីដើមដំបូងទទួលបានមូលនិធិពីប្រភពខាងក្រៅ ដូចជាអង្គការក្រៅរដ្ឋាភិបាលក៏ដោយ ពេលនេះមិនទទួលបានប្រាក់ខែទេ។

នៅខែកុម្ភៈ ឆ្នាំ២០១០ បន្ទាប់ពីការកាត់ក្តីសំណុំរឿង ០០១ វិធានផ្ទៃក្នុងត្រូវបានធ្វើវិសោធនកម្មដើម្បីបង្រួបបង្រួមដើមបណ្តឹងរដ្ឋប្បវេណីទៅជាក្រុមមួយនៅដំណាក់កាលជំនុំជម្រះ និងដំណាក់កាលផ្សេងៗទៀត ដោយមានសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានតែងតាំងតំណាងឱ្យផលប្រយោជន៍ពួកគេ ដើរតួជារចនាសម្ព័ន្ធក្រោមឆត្រតែមួយសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី។

*ផ្នែកគាំពារជនរងគ្រោះ*

ផ្នែកគាំពារជនរងគ្រោះដែលបង្កើតឡើងដោយវិធាន ១២ និង ១២*ស្ទួន*គឺជាចំណុចទំនាក់ទំនងដំបូងរវាង អ.វ.ត.ក និងជនរងគ្រោះ ហើយត្រូវបានកំណត់អាណត្តិដែលមានតួនាទីផ្សេងៗដើម្បីជួយសម្រួលដល់ការចូលរួមរបស់ជនរងគ្រោះប្រកបដោយប្រសិទ្ធភាព នៅក្នុងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក។

ក្រោមការត្រួតពិនិត្យរបស់សហព្រះរាជអាជ្ញា និង ស.ច.ស តាមដែលសមស្រប ផ្នែកនេះដំណើរការលើពាក្យបណ្តឹង និងលើកម្មវិធីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ដើមបណ្តឹរដ្ឋប្បវេណី។ ផ្នែកនេះក៏ផ្តល់ព័ត៌មានទូទៅដល់ជនរងគ្រោះ(ក្រុមមនុស្សទូលំទូលាយជាងអ្នកដែលមានឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី)។

ជាពិសេសសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីផ្នែកគាំពារជនរងគ្រោះរៀបចំ និងរក្សាបញ្ជីឈ្មោះមេធាវីជាតិ និងអន្តរជាតិ ដែលបានចុះបញ្ជីជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើតំណាងពួកគេនៅចំពោះមុខ អ.វ.ត.ក និងសម្របសម្រួលការធ្វើតំណាងនោះ។ ផ្នែកនេះក៏រក្សាបញ្ជីសមាគមជនរងគ្រោះដែលត្រូវបានអនុម័ត ដើម្បីធ្វើសកម្មភាពជំនួសឱ្យដើមបណ្តឹងរដ្ឋប្បវេណី នៅពេលចាំបាច់ផងដែរ។ ផ្នែកគាំពារជនរងគ្រោះជួយនិងគាំទ្រដល់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងម្ចាស់បណ្តឹងក្នុងកិច្ចដំណើរការតុលាការ ទោះបីជាជនរងគ្រោះផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ឬ ស.ច.ស ក៏ដោយ អង្គភាព

គាំពារសាក្សី និងអ្នកជំនាញផ្តល់ការគាំទ្រចាំបាច់ទាំងអស់សម្រាប់គោលបំណងនោះ។ ផ្នែកគាំពារជនរងគ្រោះ ក៏ធ្វើការជាមួយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីផងដែរ ក្នុងការទំនាក់ទំនងជាមួយស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលតាមការសមស្រប ដើម្បីគាំទ្រការកំណត់អត្តសញ្ញាណ ការរចនា និងការអនុវត្តគម្រោងស្តីពីសំណង។ ផ្នែកនេះជួយសម្រួលដល់វិធានការក្រៅប្រព័ន្ធតុលាការផ្សេងទៀត ដូចជាជំនួយផ្លូវចិត្ត ដើម្បីជាប្រយោជន៍ដល់ជនរងគ្រោះជាទូទៅ។

ផ្នែកគាំពារជនរងគ្រោះក៏ផ្តល់ការគាំទ្រដល់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនិងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែរ ពេលដែលពួកគេជួបជាមួយកូនក្តីរបស់ខ្លួន ពោលគឺដើមបណ្តឹងរដ្ឋប្បវេណី។ សម្រាប់ការជួបប្រជុំទាំងនេះ ផ្នែកគាំពារជនរងគ្រោះរៀបចំភ័ស្តុភារ ព្រមទាំងទទួល និងចាត់ចែងមូលនិធិម្ចាស់ជំនួយពីខាងក្រៅ ដែលទទួលបានសម្រាប់គោលបំណងនេះ។

### *សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី*

ផ្នែកសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានបង្កើតឡើងក្រោមវិធាន ១២, ១២*ស្ទួន* និង ២៣(៣)។ សម្រាប់គោលបំណងរដ្ឋបាល សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដំណើរការជា "ផ្នែកមួយ"នៅក្នុងការិយាល័យរដ្ឋបាល ទោះជាយ៉ាងណា ផ្នែកនេះមានស្វ័យភាពក្នុងការសម្រេចចិត្តរបស់ពួកខ្លួន និងដំណើរការជាភាគីឯករាជ្យចំពោះកិច្ចដំណើរការនីតិវិធីដូចគ្នានឹងក្រុមការពារក្តី ឬ ក.ស.ព ដែរ។ យោងតាមវិធានផ្ទៃក្នុងត្រូវមានសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីកម្ពុជាមួយរូប និងអន្តរជាតិមួយរូប គាំទ្រដោយសមាជិកក្រុមផ្សេងទៀតតាមការចាំបាច់។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបំពេញកិច្ចរួមគ្នាលើគ្រប់បញ្ហាទាំងអស់ លុះត្រាតែពួកគេបានផ្ទេរសិទ្ធិអំណាចទៅឱ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីតែមួយរូប សម្រាប់ដោះស្រាយលើបញ្ហាជាក់លាក់ណាមួយ។

មុខងារស្នូលរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺធ្វើជាតំណាងឱ្យក្រុមដើមបណ្តឹងរដ្ឋប្បវេណីជារួមនៅក្នុងពេលជំនុំជម្រះនិងនៅក្នុងឱកាសផ្សេងៗទៀត រួមទាំងការដាក់ពាក្យសុំតែមួយសម្រាប់សំណងសមូហភាព និងសីលធម៌។ ផ្នែកនេះទទួលខុសត្រូវចុងក្រោយសម្រាប់ ការតស៊ូមតិជារួម យុទ្ធសាស្ត្រ និងតំណាងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.ជ.ស.ដ និង អ.ជ.ត.ក ដោយបង្ហាញរាល់សារណាផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណីទៅកាន់អង្គជំនុំជម្រះ ក៏ដូចជាសម្របសម្រួលលើការងាររបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងកិច្ចប្រជុំជាមួយដើមបណ្តឹងរដ្ឋប្បវេណី។ ដូច្នេះមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីព្យាយាមគាំទ្រសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដូចដែលបានព្រមព្រៀងគ្នារវាងពួកគេ។

ត្រឹមខែកញ្ញា ឆ្នាំ២០២៤ មានសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិមួយរូប គឺលោក ពេជ អង្គ និង សហមេធាវីនាំមុខតំណាងដើមបណ្តឹង រដ្ឋប្បវេណីអន្តរជាតិបួនរូបគឺ Elisabeth Simonneau Fort (បារាំង៖ ២០១១-២០១៤) Marie Guiraud (បារាំង៖ ២០១៤-២០១៩) Megan Hirst (អូស្ត្រាលី៖ ២០១៩-២០២២) និង Falguni Debnath (កាណាដា៖ ២០២២-២០២៣)។ មិនមានការតែងតាំងជំនួសទេ បន្ទាប់ពីលោកស្រី Debnath បានលាឈប់។

# គណៈកម្មាធិការ អ.វ.ត.ក

## គណៈកម្មាធិការរដ្ឋបាលតុលាការ

យោងតាមវិធាន ១៩ គណៈកម្មាធិការរដ្ឋបាលតុលាការ រួមមានចៅក្រមជាតិចំនួនបីរូប ចៅក្រមមួយរូបជាប្រធាន និងចៅក្រមអន្តរជាតិពីររូប ព្រមទាំងសហព្រះរាជអាជ្ញា ប្រធាននិងអនុប្រធានការិយាល័យរដ្ឋបាល ក្នុងសមត្ថភាពពិគ្រោះយោបល់។ កិច្ចប្រជុំរបស់គណៈកម្មាធិការរដ្ឋបាលតុលាការ គឺធ្វើឡើងជាការសម្ងាត់ ហើយត្រូវបានធ្វើឡើងតាមគំនិតផ្តួចផ្តើមរបស់ប្រធាន។

មុខងារចម្បងរបស់គណៈកម្មាធិការរដ្ឋបាលតុលាការ គឺផ្តល់យោបល់ និងណែនាំការិយាល័យរដ្ឋបាលលើគ្រប់សកម្មភាពទាំងអស់ ទាក់ទងនឹងការគាំទ្រផ្នែករដ្ឋបាល និងតុលាការ ដែលផ្តល់ជូនសហព្រះរាជអាជ្ញា ស.ច.ស និងអង្គជំនុំជម្រះ រួមទាំង ការរៀបចំ និងការអនុវត្តថវិកា។ ក្នុងកាលៈទេសៈខ្លះ គណៈកម្មាធិការនេះក៏ជ្រើសរើសចៅក្រមដើម្បីស្តាប់សវនាការលើការប្តឹងជំទាស់ផងដែរ (វិធាន ៣៤)។

## គណៈកម្មាធិការវិធាន និងនីតិវិធី

អនុលោមតាមវិធាន ២០ គណៈកម្មាធិការវិធាន និងនីតិវិធី ត្រូវបានបង្កើតឡើងដោយចៅក្រមជាតិចំនួនប្រាំរូប ចៅក្រមមួយរូបជាប្រធាន និងចៅក្រមអន្តរជាតិចំនួនបួនរូប។ គណៈកម្មាធិការនេះទទួល និងពិចារណាលើសំណើសុំធ្វើវិសោធនកម្មវិធានផ្ទៃក្នុង និង សេចក្តីព្រាងសំណើសម្រាប់ការពិភាក្សានៅក្នុងកិច្ចប្រជុំពេញអង្គ។ គណៈកម្មាធិការវិធាន និងនីតិវិធី ក៏អាចអនុម័តសេចក្តីណែនាំអនុវត្ត ទាក់ទងនឹងការប្រព្រឹត្តិទៅនៃ អ.វ.ត.ក ដែលត្រូវពិនិត្យនិងធ្វើវិសោធនកម្មជាបន្តបន្ទាប់ដោយសភាពេញអង្គ។ គណៈកម្មាធិការវិធាន និងនីតិវិធី អាចពិនិត្យឡើងវិញលើបទប្បញ្ញត្តិរដ្ឋបាលនៃផ្នែកណាមួយផ្សេងទៀតនៃ អ.វ.ត.ក ដើម្បីកំណត់អំពីភាពស៊ីចង្វាក់គ្នានៃបទប្បញ្ញត្តិទាំងនោះជាមួយវិធានផ្ទៃក្នុង។

## កិច្ចប្រជុំពេញអង្គ

អនុលោមតាមវិធាន ១៨ កិច្ចប្រជុំពេញអង្គ គឺជាកិច្ចប្រជុំសម្ងាត់ដែលជាទូទៅត្រូវបានកោះប្រជុំរៀងរាល់៦ខែម្តង។ ស.ច.ស និង ចៅក្រម អ.ប.ជ អ.ជ.ស.ដ និង អ.ជ.ត.ក និងចៅក្រមបម្រុង សហព្រះរាជអាជ្ញា និងសហព្រះរាជអាជ្ញាបម្រុង ប្រធានផ្នែកគាំពារការការពារក្តី ប្រធានផ្នែកគាំពារជនរងគ្រោះ និងប្រធាននិងអនុប្រធានការិយាល័យរដ្ឋបាល អាចចូលរួមកិច្ចប្រជុំនេះ។ សម័យប្រជុំត្រូវបានបើក និងដឹកនាំដោយប្រធាន អ.ជ.ត.ក។

ដោយបានអនុម័តវិធានផ្ទៃក្នុងតាំងពីដើមដំបូងក្នុងឆ្នាំ២០០៧ មុខងារចម្បងរបស់អង្គប្រជុំ គឺពិនិត្យ និងធ្វើវិសោធនកម្មលើវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តណាមួយដែលបានអនុម័តដោយគណៈកម្មាធិការវិធាន និងនីតិវិធី។ លើសពីនេះ អង្គប្រជុំសម្រេចលើបញ្ហានានាទាក់ទងនឹងដំណើរការផ្ទៃក្នុងរបស់ អ.វ.ត.ក តាមសំណើរបស់គណៈកម្មាធិការរដ្ឋបាលតុលាការ និងអនុម័តរបាយការណ៍ប្រចាំឆ្នាំ ដើម្បីដាក់ជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងអគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលត្រូវបានស្នើឡើងដោយការិយាល័យរដ្ឋបាល។

ទោះបីសហព្រះរាជអាជ្ញាអាចបោះឆ្នោតលើវិធានផ្ទៃក្នុងទាក់ទងនិងការគ្រប់គ្រងរដ្ឋបាលរបស់ អ.វ.ត.ក (វិធាន ១-២០) ក៏ដោយ ក៏ការសម្រេចចិត្តដែលនៅសល់ អាចត្រូវបានធ្វើឡើងដោយសំឡេងភាគច្រើនលើសលុបរបស់សហចៅក្រមស៊ើបអង្កេត និងចៅក្រមអង្គជំនុំជម្រះ។


អង្គជំនុំជម្រះ និង ការិយាល័យតុលាការ
អង្គជំនុំជម្រះតុលាការ
អង្គបុរេជំនុំជម្រះ
អង្គជំនុំជម្រះសាលាដំបូង
អង្គជំនុំជម្រះតុលាការកំពូល
ការិយាល័យសហចៅក្រមស៊ើបអង្កេត
ការិយាល័យសហព្រះរាជអាជ្ញា
ការិយាល័យរដ្ឋបាល
ការិយាល័យប្រធាន ការិយាល័យអនុប្រធាន
ផ្នែកគាំពារការការពារក្តី
ផ្នែកគាំពារជនរងគ្រោះ
ផ្នែកសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី
ផ្នែកគ្រប់គ្រងតុលាការ
ផ្នែកកិច្ចការសាធារណៈ
បុគ្គលិក
ថវិកា & ហិរញ្ញវត្ថុ
សេវាកម្មទូទៅ
សន្តិសុខ & សុវត្ថិភាព
បច្ចេកវិទ្យាទំនាក់ទំនងព័ត៌មាន
កិច្ចប្រជុំពេញអង្គ
គណៈកម្មាធិការរដ្ឋបាលតុលាការ
គណៈកម្មាធិការវិធាន និង និតិវិធី

# មុខងារសេសសល់

អ.វ.ត.ក បានឈានចូលដល់ដំណាក់កាលមុខងារសេសសល់របស់ខ្លួន នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ បន្ទាប់ពីការចេញសាលដីកាជាលាយលក្ខណ៍អក្សរក្នុងសំណុំរឿង ០០២/០២ ក្នុងខែធ្នូ ឆ្នាំ២០២២។ យោងតាម **កិច្ចព្រមព្រៀងបន្ថែមទៅលើកិច្ចព្រមព្រៀង អ.វ.ត.ក** តុលាការពេលនេះគួរកំពុងអនុវត្តមុខងារសេសសល់ សម្រាប់រយៈពេលបីឆ្នាំដំបូង។ មុខងារទាំងអស់នេះចែកចេញជាពីរប្រភេទសំខាន់ៗ៖

## ១. មុខងារតុលាការ៖

- ពិនិត្យលើការអនុវត្ត និងដឹកនាំធ្វើចំណាត់ការលើការពិនិត្យសាលដីកាស្ថាពរ
- ផ្តល់ការការពារដល់ជនរងគ្រោះ និងសាក្សី
- ដាក់ទណ្ឌកម្ម ឬបញ្ជូនទៅឱ្យអាជ្ញាធរមានសមត្ថកិច្ច នូវជនណាដែលបង្កការជ្រៀតជ្រែកដោយចេតនាទៅក្នុងកិច្ចការរដ្ឋបាលតុលាការ ឬការផ្តល់សក្ខីកម្មក្លែងក្លាយ
- គ្រប់គ្រងការអនុវត្តទោស និង
- តាមដានលើការប្រព្រឹត្តិចំពោះទណ្ឌិត

## ២. ការទំនាក់ទំនងជាមួយនឹងសាធារណជនអំពី អ.វ.ត.ក៖

- ថែទាំ អភិរក្ស និងគ្រប់គ្រងបណ្ណសាររបស់ អ.វ.ត.ក រួមទាំងការដកចំណាត់ថ្នាក់ឯកសារ និងសម្ភារៈ
- ឆ្លើយតបទៅនឹងសំណើសុំសិទ្ធិចូលពិនិត្យមើលឯកសារ
- ផ្សព្វផ្សាយព័ត៌មានដល់សាធារណជន ទាក់ទងនឹង អ.វ.ត.ក និង
- តាមដានលើការអនុវត្តសំណងដែលបានផ្តល់ជូនដើមបណ្តឹងរដ្ឋប្បវេណី។



ការធានាឱ្យមានការពន្យល់អំពីមុខងារសេសសល់ដល់ដៃគូសំខាន់ៗ តាមរយៈសកម្មភាពផ្សព្វផ្សាយសមស្រប គឺជាការសំខាន់ ដើម្បីឱ្យការអនុវត្តមុខងារទាំងនេះមានប្រសិទ្ធភាព និងប្រសិទ្ធផល។ ដើម្បីសម្រេចបានលើការងារនេះ ដំណាក់កាលសេសសល់ត្រូវតែបន្តអនុវត្តតាមគោលបំណងនៃកិច្ចព្រមព្រៀង អ.វ.ត.ក រួមទាំង យុត្តិធម៌ និងការបង្រួបបង្រួមជាតិ តាមរយៈការអនុវត្តគម្រោងកេរដំណែលដ៏មានអត្ថន័យនៅក្នុងប្រទេសកម្ពុជា និងលើឆាកអន្តរជាតិដែលរួមចំណែកដល់ដំណើរការសះស្បើយរបស់ជនរងគ្រោះ និងគូសបញ្ជាក់អំពីការងារ និងសមិទ្ធផលរបស់តុលាការ។

នៅក្នុងដំណាក់កាលសេសសល់បុគ្គលិក អ.វ.ត.ក ត្រូវបានកាត់បន្ថយយ៉ាងច្រើនសម្បើម ដោយចៅក្រម សហព្រះរាជអាជ្ញា មេធាវីការពារក្តី និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទទួលបានប្រាក់កម្រៃផ្អែកលើមូលដ្ឋានសមាមាត្រ។ ខណៈដែលស្ថាប័ន និងផ្នែកនីមួយៗនៅរក្សាតួនាទី និងឯករាជភាពរបស់ខ្លួនទៅតាមច្បាប់ក្រោយពីទទួលបានការអនុម័តច្បាស់លាស់ពីប្រធានស្ថាប័ន និងប្រធានផ្នែករួចមក កិច្ចសហការរវាងបុគ្គលិក អ.វ.ត.ក ទាំងអស់គឺជារឿងសំខាន់មិនអាចខ្វះបានក្នុងការបំពេញមុខងារឱ្យមានប្រសិទ្ធភាព។ ស្រដៀងគ្នានេះ ភាពបត់បែនសម្រាប់ផ្នែកទាំងអស់ដើម្បីបញ្ចូលបុគ្គលិកប្រឹក្សាតាមការចាំបាច់ដើម្បីបំពេញអាណត្តិ និង/ឬកេរដំណែលរបស់តុលាការ ត្រូវការដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងប្រសិទ្ធផលក្នុងរយៈពេលវែង។ ទោះជាយ៉ាងណា ជាការអនុវត្តជាក់ស្តែងវាច្បាស់ណាស់ថាមានតែការិយាល័យរដ្ឋបាលប៉ុណ្ណោះបានរក្សាអាណត្តិការងារដោយ ក.ស.ព ត្រូវបានដកចេញសូម្បីតែកន្លែងធ្វើការនៅអគា អ.វ.ត.ក ថ្មីក៏គ្មានដែរ។

គិតត្រឹមខែកញ្ញា ឆ្នាំ២០២៤ វាច្បាស់ណាស់ថា ធនធានត្រូវបានប្រើប្រាស់ទៅលើការផ្សព្វផ្សាយ សម្រាប់សិស្ស និងនិស្សិត ក៏ដូចជាទស្សនកិច្ចណែនាំសម្រាប់និស្សិតបរទេស។ មជ្ឈមណ្ឌលធនធានថ្មីរបស់ អ.វ.ត.ក ពេលនេះបើកដំណើរការហើយ ហើយមាន៖ (១) បណ្ណាល័យ និងកន្លែងស្រាវជ្រាវ (២) សាលពហុបំណងសម្រាប់រៀបចំសិក្ខាសាលា និងតុលាការប្រឌិត (៣) សាលពិគ្រោះ និងពិព័រណ៍ និង (៤) ទីកន្លែងសម្រាប់ការរំលឹក និងការចងចាំ។ រថយន្តក្រុងចល័តថ្មីមួយ ដែលបន្ថែមពីលើមជ្ឈមណ្ឌលធនធាននេះ ប្រើប្រាស់ដើម្បីធានាថា សម្ភារៈអប់រំអំពី អ.វ.ត.ក ត្រូវបាននាំយកទៅដល់ទីជនបទរបស់ប្រទេសកម្ពុជា។ ឯកសារដើមនៃមន្ទីរ ស-២១ ដែលត្រូវបានប្រើប្រាស់ដោយ អ.វ.ត.ក ក្នុងពេលស៊ើបអង្កេត និងជំនុំជម្រះនោះ ត្រូវបានប្រគល់ត្រឡប់ទៅឱ្យសារមន្ទីរទួលស្លែងវិញ។ សំណៅសាធារណៈ ដូចជា បញ្ជីអ្នកទោស ពេលនេះត្រូវបានការិយាល័យរដ្ឋបាលដាក់ជាសាធារណៈ និងអាចចូលពិនិត្យមើលតាមរយៈអនឡាញបានយ៉ាងងាយស្រួល។

ការថែរក្សាបណ្ណសារ អ.វ.ត.ក. និងធ្វើយ៉ាងណាឱ្យ "បណ្ណសារទាំងនោះអាចចូលពិនិត្យមើលបានយ៉ាងទូលំទូលាយ" គឺពិតជាមុខងារសេសសល់ដ៏សំខាន់បំផុត។ អ.វ.ត.ក បច្ចុប្បន្ននេះអះអាងថា កំពុងធ្វើយ៉ាងណាឱ្យផ្នែកសាធារណៈនៃបណ្ណសាររបស់ខ្លួនអាចចូលប្រើប្រាស់បានជាសាធារណៈតាមអនឡាញ។ ទោះជាយ៉ាងណា គិតត្រឹមខែកញ្ញា ឆ្នាំ២០២៤ បណ្ណសារហាក់ដូចជាអាចចូលប្រើប្រាស់បានតែអ្នកដែលមានវត្តមានផ្ទាល់នៅ មជ្ឈមណ្ឌលធនធាន អ.វ.ត.ក នៅទីក្រុងភ្នំពេញប៉ុណ្ណោះ។ បញ្ហានេះគួរត្រូវបានដោះស្រាយឱ្យបានកាន់តែឆាប់ដូចដែលអាចធ្វើទៅបាន។



មុនពេល អ.វ.ត.ក. បានផ្លាស់មកដំណាក់កាលនៃមុខងារសេសសល់របស់ខ្លួន សហចៅក្រមរបាយការណ៍របស់ អ.វ.ត.ក ស្ដីពីមុខងារសេសសល់ ទាក់ទងនឹងជនរងគ្រោះ បានផ្ដល់អនុសាសន៍ស្ដីពីគំនិតផ្ដួចផ្ដើមសមស្របទាក់ទងនឹងជនរងគ្រោះ និងសិក្ខាសាលាបីថ្ងៃស្ដីពីជនរងគ្រោះត្រូវបានធ្វើឡើងនៅទីក្រុងភ្នំពេញ។ ទោះបីជាការផ្ដោតដំបូងនេះលើជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណីក្ដី ពេលនេះគម្រោងនានាដែលផ្ដោតលើជនរងគ្រោះក្នុងចំនួនតិចបំផុត កំពុងត្រូវបានអនុវត្ត។ ការណ៍នេះអាចពន្យល់មួយផ្នែកថាមកពីកង្វះធាតុចូលសកម្មពីសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអន្តរជាតិណាម្នាក់ ជាមុខតំណែងមួយដែលប្រហែលជាមិនត្រូវបានបំពេញ បើទោះជាមានបទប្បញ្ញត្តិចែងយ៉ាងច្បាស់លាស់សម្រាប់មុខតំណែងនេះនៅក្នុងកិច្ចព្រមព្រៀងបន្ថែមក៏ដោយ។




*ការដាក់ឱ្យដំណើរការរថយន្តក្រុងចល័ត អ.វ.ត.ក. © គេហទំព័រ អ.វ.ត.ក*

ស្រដៀងគ្នាដែរ គម្រោងល្អៗមួយចំនួនដែលបានជ្រើសរើសដោយ ក.ស.ព ត្រូវបានបោះបង់ចោល ជំនួសមកវិញដោយគម្រោងដែលការិយាល័យរដ្ឋបាលចង់បាន។ ក្នុងចំណោមគម្រោងទាំងនេះមាន គម្រោងបញ្ជីអ្នកទោស ស-២១ របស់ ក.ស.ព ដែលជាការវិភាគលើឯកសារ ស-២១ ដើម្បីបង្កើតនូវកំណត់ហេតុមួយដែលលម្អិត និងត្រឹមត្រូវចំពោះបុគ្គលដែលបានជាប់ឃុំនៅទីនោះ និងជោគវាសនារបស់ពួកគេដែលមិនត្រូវគេដឹង។ ប្រជាជនកម្ពុជាជាច្រើននៅតែមិនបានដឹងថាតើ គ្រួសារ និងមិត្តភក្តិរបស់ពួកគេបានស្លាប់នៅ ស-២១ ឬយ៉ាងណា ហើយឱកាសកែតម្រូវភាពអយុត្តិធម៌នេះដើម្បីជាប្រយោជន៍ដល់ជនរងគ្រោះនៃរបបខ្មែរក្រហមត្រូវបានបាត់បង់។

ខណៈដែលសកម្មភាពមុខងារសេសសល់ដែលត្រូវបានកំណត់អាណត្តិមួយចំនួនហាក់ដូចជាកំពុងដំណើរការ ជារួមដំណាក់កាលមុខងារសេសសល់របស់ អ.វ.ត.ក នេះ តម្រូវឱ្យមានកម្មវិធីបន្ថែមសំខាន់ៗ និងការចូលរួមពីតួអង្គចម្បងមួយចំនួន។

# ដំណើរការតុលាការ

ដំណើរការតុលាការនៅ អ.វ.ត.ក មានបីដំណាក់កាល៖ (i) ដំណាក់កាល**មុនការជំនុំជម្រះ** រួមមាន ដំណាក់កាលស៊ើបសួរបឋម និង **ស៊ើបសួរតាមផ្លូវតុលាការ** (ii) ដំណាក់កាល**ជំនុំជម្រះ និង** (iii) ដំណាក់កាល **បណ្តឹងសាទុក្ខ**។

## ដំណាក់កាលមុនការជំនុំជម្រះ

- **កិច្ចស៊ើបសួរបឋម**

ការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មនៅ អ.វ.ត.ក គឺមានតែសហព្រះរាជអាជ្ញាប៉ុណ្ណោះជាអ្នកផ្តួចផ្តើម(*)។ សហព្រះរាជអាជ្ញា ធ្វើចំណាត់ការលើពាក្យបណ្តឹង (វិធាន ៤៩) និង ដឹកនាំកិច្ចស៊ើបសួរបឋមជាសម្ងាត់ (វិធាន ៥០) ដើម្បីកំណត់ថា មានភ័ស្តុតាងបញ្ជាក់អំពីឧក្រិដ្ឋកម្មក្រោមយុត្តាធិការរបស់ អ.វ.ត.ក ត្រូវបានប្រព្រឹត្តឡើងដែរឬទេ និងដើម្បីកំណត់អត្តសញ្ញាណជនសង្ស័យ (ជនដែលគេជឿថា តាមការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន គឺជា "មេដឹកនាំជាន់ខ្ពស់" ឬ ជាជនម្នាក់នៃ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ) និងសាក្សីសក្តានុពល។ កិច្ចស៊ើបសួរអាចត្រូវបានធ្វើឡើងដោយនគរបាលយុត្តិធម៌ ឬ អ្នកស៊ើបអង្កេត តាមសំណើរបស់សហព្រះរាជអាជ្ញា។ តាមការអនុវត្ត បុគ្គលិក ក.ស.ព រួមទាំងអ្នកច្បាប់ និងអ្នកស៊ើបអង្កេត គឺជាអ្នកដែលបានស៊ើបអង្កេត។

(*) យោងតាមវិធាន១(២) នៃវិធានផ្ទៃក្នុង សេចក្តីយោងទាំងអស់នៅក្នុងវាក្យខណ្ឌនេះទៅលើសហព្រះរាជអាជ្ញា និង ស.ច.ស រួមទាំងកិច្ចបំពេញ រួមគ្នា និងកិច្ចដែលបំពេញម្នាក់ៗ ទោះដោយផ្ទាល់ ឬការធ្វើប្រតិភូកម្មអំណាចក្តី។

តាមវិធាន ៥៣(១) បើសិនសហព្រះរាជអាជ្ញា មានមូលហេតុនាំឱ្យជឿបានថា ឧក្រិដ្ឋកម្មដែលស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក ត្រូវបានប្រព្រឹត្តនោះ សហព្រះរាជអាជ្ញា នឹងបើកកិច្ចស៊ើបសួរតាមរយៈការបញ្ជូន**ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ**ទៅ ស.ច.ស ប្រឆាំងនឹងបុគ្គលដែលមានឈ្មោះ ឬគ្មានឈ្មោះណាម្នាក់ ឬច្រើននាក់។ ដីកាសន្និដ្ឋាននេះ មានជាអាទិ៍ សេចក្តីសង្ខេបនៃអង្គហេតុសម្រាប់ស៊ើបអង្កេត ឈ្មោះជនសង្ស័យ និងប្រភេទនៃបទល្មើសដែលបានចោទប្រកាន់។ សំណុំរឿង និងភ័ស្តុតាងដាក់បន្ទុកនិងដោះបន្ទុកដែលមានត្រូវបានដាក់អមទៅជាមួយនឹងដីកាសន្និដ្ឋាននេះ។ ចាប់ពីចំណុចនេះតទៅ និងនៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីទាំងអស់ សហព្រះរាជអាជ្ញាមានកាតព្វកិច្ចដាក់បង្ហាញសម្ភារណាដែល បើតាមចំណេះដឹងជាក់ស្តែងរបស់ខ្លួនអាចបញ្ជាក់អំពីភាពគ្មានទោស ឬបន្ធូរបន្ថយពិរុទ្ធភាពរបស់ជនសង្ស័យ/ជនត្រូវចោទ/ជនជាប់ចោទ ឬប៉ះពាល់ទៅលើភាពជឿជាក់នៃភ័ស្តុតាងដាក់បន្ទុក។

ក្នុងពេលណាមួយនៅក្នុងអំឡុងនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ សហព្រះរាជអាជ្ញាអាចដាក់ **ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម** ស្នើឱ្យ ស.ច.ស ស៊ើបអង្កេតទៅលើអង្គហេតុថ្មី។ មានការបញ្ជាក់អះអាងតាមផ្លូវតុលាការថា សហព្រះរាជអាជ្ញាតែម្នាក់ អាចចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមបាន បើសិនជានីតិវិធីនៃការខ្វែងយោបល់គ្នាដូចមានចែងក្នុងវិធាន ៧១ ត្រូវបានអនុវត្ត។

- **កិច្ចស៊ើបសួរតាមផ្លូវតុលាការ**

តាមវិធាន ៥៥(២) ស.ច.ស មានកាតព្វកិច្ចស៊ើបអង្កេតជាសម្ងាត់លើអង្គហេតុទាំងអស់ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ ប្រសិនបើនៅក្នុងអំឡុងនៃកិច្ចស៊ើបសួរ ស្រាប់តែលេចចេញអង្គហេតុថ្មីដែល ស.ច.ស បានដឹង នោះ ស.ច.ស ត្រូវជូនដំណឹងមកសហព្រះរាជអាជ្ញា ហើយ ស.ច.ស អាចបើកកិច្ចស៊ើបសួរលើអង្គហេតុថ្មីទាំងនោះបានលុះត្រាតែ ស.ច.ស បានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមណាមួយប៉ុណ្ណោះ។ ដើម្បីពន្លឿនដំណើរការតុលាការ ស.ច.ស អាចកាត់បន្ថយទំហំនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ ស្របតាមវិធាន ៦៦*ស្ទួន* ដោយការច្រានចោលអង្គហេតុណាមួយនៅក្នុងដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដរាបណាអង្គហេតុដែលនៅសល់ គឺជាតំណាងឱ្យវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ មានការបញ្ជាក់អះអាងតាមផ្លូវតុលាការថា ស.ច.ស តែម្នាក់អាចបំពេញកិច្ចស៊ើបសួរបាន ឱ្យតែយន្តការនៃការខ្វែងយោបល់គ្នាក្នុងវិធាន ៧២ ត្រូវបានអនុវត្ត។

ស.ច.ស មានវិសាលភាពនៃអំណាចស៊ើបអង្កេតធំទូលាយ ស្របតាមវិធាន ៥៥(៥) រួមមាន i) ការសួរចម្លើយជនសង្ស័យ និងជនត្រូវចោទ ii) ការស្តាប់ចម្លើយជនរងគ្រោះ សាក្សី និង អ្នកជំនាញ iii) ការរឹបអូសវត្ថុតាង iv) ការដឹកនាំកិច្ចស៊ើបសួរនៅកន្លែងកើតហេតុ v) ការស្វែងរកព័ត៌មាន និងជំនួយពីរដ្ឋណាមួយ អង្គការសហប្រជាជាតិ ឬ អង្គការអន្តររដ្ឋាភិបាលឬមិនមែនរដ្ឋាភិបាលដទៃទៀត និង vi) ការចេញដីកាកោះ ដីកាបង្គាប់ឱ្យនាំខ្លួន និងដីកាបង្គាប់ឱ្យឃុំខ្លួន (*សូមមើលផងដែរ* វិធាន ៤១-៤៥)។ ស.ច.ស ក៏អាចបង្គាប់ឱ្យមានវិធានការការពារដល់ជនរងគ្រោះ និងសាក្សី ដែលការបង្ហាញខ្លួនរបស់ពួកគេនៅចំពោះមុខ ស.ច.ស អាចបង្កនូវគ្រោះថ្នាក់ដល់ជីវិត ឬសុខភាពរបស់ពួកគាត់ ឬដល់សមាជិកគ្រួសារ ឬសាច់ញាតិជិតស្និតរបស់ពួកគាត់ (វិធាន២៩, ៥៥(៥)(ខ))។

លើគ្រប់ករណីទាំងអស់ ភ័ស្តុតាងត្រូវបានប្រមូលដោយអ្នកច្បាប់ និងអ្នកស៊ើបអង្កេតរបស់ អ.វ.ត.ក ដោយបំពេញកិច្ចស្របតាមដីកាចាត់ឱ្យស៊ើបសួរជំនួស (វិធាន ៥៥(៩), ៦២)។ សហព្រះរាជអាជ្ញា ជនត្រូវចោទ និងដើម្បីបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិចូលរួមក្នុងកិច្ចស៊ើបសួរតាមរយៈការធ្វើសំណើសុំបំពេញកិច្ចស៊ើបសួរ ស្របតាមវិធាន ៥៥(១០)។ ក្រៅពីការដឹកនាំការស្រាវជ្រាវជាបឋមដោយមានកម្រិតបំផុតដែលជាការចាំបាច់មិនអាចខ្វះបាន សម្រាប់ការអនុវត្តឱ្យមានប្រសិទ្ធភាពនៃសិទ្ធិទាំងនោះចំពោះសំណើបំពេញកិច្ចស៊ើបសួរ ភាគីមិនអាចធ្វើការស៊ើបអង្កេតដោយខ្លួនឯងទេ។

នៅក្នុងអំឡុងនៃកិច្ចស៊ើបសួរ តាមវិធាន ៥៥(៤) ស.ច.ស អាចដាក់ឱ្យស្ថិតក្រោមការពិនិត្យ (“mettre en examen” ឬ “charge”) លើជនសង្ស័យដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា និងប្រឆាំងនឹងបុគ្គលផ្សេងទៀតដែលមានភ័ស្តុតាងច្បាស់លាស់និងស៊ីចង្វាក់ដែលបង្ហាញថា ជននោះអាចមានការ

១. ការស៊ើបអង្កេតបឋម
ការិយាល័យសហព្រះរាជអាជ្ញា

២. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ
ការិយាល័យសហព្រះរាជអាជ្ញា

ទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលបានយោងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។

ជាធម្មតា ស.ច.ស បានឱ្យជនត្រូវចោទបង្ហាញខ្លួនជាលើកដំបូង ស្របតាមវិធាន ៥៧ ដោយក្នុងពេលនេះ ជនត្រូវចោទនឹងត្រូវបានជូនដំណឹងអំពីបទចោទប្រឆាំងនឹងគាត់ ធ្វើកំណត់ហេតុអំពីអត្តសញ្ញាណរបស់គាត់ និងជូនដំណឹងអំពីសិទ្ធិមានមេធាវី និងសិទ្ធិនៅស្ងៀមមិននិយាយស្តី។ ប្រសិនបើត្រូវឃាត់ខ្លួន ជនត្រូវចោទក៏មានសិទ្ធិលើកអំពីបញ្ហាផ្សេងៗ ទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្នផងដែរ។ នៅដំណាក់កាលនេះ ជនត្រូវចោទមានសិទ្ធិចូលពិនិត្យមើលសំណុំរឿង។

ក្នុងអំឡុងពេលបង្ហាញខ្លួនលើកដំបូង ឬក្នុងពេលណាមួយនៅក្នុងអំឡុងនៃកិច្ចស៊ើបសួរ ស.ច.ស អាចសួរចម្លើយជនត្រូវចោទដោយមានការយល់ព្រមពីជនត្រូវចោទ (វិធាន ៥៧, ៥៨)។ បើសិនជាត្រូវធ្វើដូច្នេះមែន ជនត្រូវចោទមានសិទ្ធិពិគ្រោះយោបល់ជាមួយមេធាវីជាមុន លុះត្រាតែជនត្រូវចោទបានលះបង់ចោលនូវសិទ្ធិដូច្នេះដោយធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬក្នុងករណីអាសន្ន។ សហព្រះរាជអាជ្ញា និងក្នុងករណីខ្លះ ភាគីផ្សេងទៀតមានសិទ្ធិបង្ហាញវត្តមាន និងធ្វើសំណើទៅ ស.ច.ស ដើម្បីសួរនូវសំណួរជាក់លាក់នានាអំពីជនត្រូវចោទ។

បន្ទាប់ពីសវនាការតទល់រួចមក ស.ច.ស អាចបង្គាប់ឱ្យឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន ស្របតាមវិធាន ៦៣ ដោយផ្អែកលើទឡ្ហីករណ៍នានាដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង ដូចជាការថែរក្សាសន្តិសុខរបស់ជនត្រូវចោទ ការថែរក្សាភស្តុតាង និងសណ្តាប់ធ្នាប់សាធារណៈ ឬដើម្បីទប់ស្កាត់ពួកគេពីការដាក់សម្ពាធលើសាក្សី ឬជនរងគ្រោះ។ អ្នកដែលត្រូវបានដាក់ឱ្យស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្ន ត្រូវតែបង្ហាញខ្លួននៅចំពោះមុខ ស.ច.ស ដោយផ្ទាល់យ៉ាងហោចណាស់រៀងរាល់បួនខែម្តង ហើយ ស.ច.ស ត្រូវផ្តល់ឱកាសឱ្យជនត្រូវចោទពិភាក្សាអំពីការប្រព្រឹត្តិ និងលក្ខខណ្ឌផ្សេងៗរបស់ពួកគេ។

ប្រសិនបើ ស.ច.ស ពិចារណាថា កិច្ចស៊ើបសួរត្រូវបានបញ្ចប់ ស.ច.ស ត្រូវចេញ **សេចក្តីជូនដំណឹងអំពីការបិទបញ្ចប់** ស្របតាមវិធាន ៦៦(១) ដោយទុករយៈពេល ១៥ថ្ងៃ ដល់ភាគីដាក់សំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែម។ ការបដិសេធលើសំណើសុំ អាចប្តឹងឧទ្ធរណ៍បានទៅ អ.ប.ជ ដោយគ្រប់ភាគីទាំងអស់ (វិធាន ៦៦(២), (៣))។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ក៏ត្រូវដាក់ក្នុងរយៈពេល ១៥ថ្ងៃនេះដែរ (វិធាន ២៣*ស្ទួន*(២))។ ការបដិសេធលើសំណើសុំអាចប្តឹងឧទ្ធរណ៍ទៅ អ.ប.ជ បាន ប៉ុន្តែមិនបញ្ឈប់ កិច្ចដំណើរនីតិវិធីឡើយ។

- **ដីកាសន្និដ្ឋានស្ថាពរ**

នៅពេលសំណើសុំបំពេញកិច្ចស៊ើបសួរទាំងអស់ត្រូវបានសម្រេច ហើយដំណើរការលើបណ្តឹងឧទ្ធរណ៍ដែលពាក់ព័ន្ធក៏បានបញ្ចប់ ស.ច.ស បញ្ជូនសំណុំរឿងទៅ សហព្រះរាជអាជ្ញា ស្របតាមវិធាន ៦៦(៤)។ បើសិន សហព្រះរាជអាជ្ញាយល់ថា កិច្ចស៊ើបសួរត្រូវបានបញ្ចប់ សហព្រហរាជអាជ្ញា ចេញ **ដីកាសន្និដ្ឋានស្ថាពរ** ជាលាយលក្ខណ៍អក្សរ។ ដីកាសន្និដ្ឋានស្ថាពរ បង្ហាញអំពីការយល់ឃើញ

៣. ការស៊ើបអង្កេតតាមផ្លូវតុលាការ
ការិយាល័យសហចៅក្រមស៊ើបអង្កេត

៤. ដីកាសន្និដ្ឋានស្ថាពរ
ការិយាល័យសហព្រះរាជអាជ្ញា

របស់ សហព្រះរាជអាជ្ញា ស្ដីពីអង្គហេតុដែលបានស៊ើបអង្កេត និងការកំណត់បទចោទលើអង្គហេតុទាំងនោះ ព្រមទាំងធ្វើសំណើឱ្យ ស.ច.ស ចោទប្រកាន់ជនត្រូវចោទនិងបញ្ជូនខ្លួនជនត្រូវចោទទៅជំនុំជម្រះ ឬឱ្យលើកលែងចោទប្រកាន់រឿងក្ដីនោះ។ ដីកាសន្និដ្ឋានស្ថាពរដោយឡែកពី ស.ព.ជ និង ស.ព.អ ក៏អនុញ្ញាតផងដែរនៅក្រោមក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក។ អនុលោមតាមការអនុវត្តនៅ អ.វ.ត.ក ជនត្រូវចោទមានសិទ្ធិឆ្លើយតប។ ស.ច.ស មិនជាប់កាតព្វកិច្ចតាមដីកាសន្និដ្ឋានស្ថាពររបស់ សហព្រះរាជអាជ្ញា ឬតាមចម្លើយតបរបស់ជនត្រូវចោទទេ។

- **ដីកាដំណោះស្រាយ**

ស្របតាមវិធាន ៦៧ បន្ទាប់មកទៀត ស.ច.ស តម្រូវឱ្យចេញ (ក) **ដីកាដំណោះស្រាយ** ទាក់ទងនឹងអង្គហេតុទាំងអស់ដែលប្ដឹងទៅ ស.ច.ស ដោយសហព្រះរាជអាជ្ញា។ ដីកាដំណោះស្រាយត្រូវចោទប្រកាន់ជនត្រូវចោទ និងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះបើសិនមានភ័ស្ដុតាងគ្រប់គ្រាន់ ឬលើកលែងចោទប្រកាន់រឿងក្ដីនោះ។ ដីកាដំណោះស្រាយអាចបញ្ជូនរឿងក្ដីទៅជំនុំជម្រះចំពោះអំពើណាមួយជាក់លាក់ ឬប្រឆាំងបុគ្គលណាម្នាក់និងលើកលែងចោទប្រកាន់អ្នកផ្សេងទៀត។ ទោះជាយើងមានការកំណត់តាមផ្លូវតុលាការថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនអាចចេញបានចំពោះអង្គហេតុនានាដែលមិនបានចោទប្រកាន់តាមវិធាន ៥៥(៤) ក៏ដោយ តែការនេះមិនបានដកចេញនូវកាតព្វកិច្ចរបស់ ស.ច.ស មិនឱ្យឈានទៅសម្រេចលើរាល់អង្គហេតុ ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមនោះទេ។

ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវកំណត់អត្តសញ្ញាណជនជាប់ចោទ សេចក្ដីរៀបរាប់អំពីអង្គហេតុជាក់ស្ដែង និងការកំណត់បទចោទលើអង្គហេតុទាំងនោះដោយ ស.ច.ស រួមទាំង បទប្បញ្ញត្តិនៃបទឧក្រិដ្ឋដែលពាក់ព័ន្ធ និងប្រភេទនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ (វិធាន ៦៧(២)។ រឿងក្ដីនឹងត្រូវបានលើកលែងប្រសិនបើអំពើទាំងនោះមិនមែនជាបទឧក្រិដ្ឋ ដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក ចារីមិនត្រូវបានកំណត់អត្តសញ្ញាណ ឬពុំមានភ័ស្ដុតាងគ្រប់គ្រាន់ក្នុងការចោទប្រកាន់ជនត្រូវចោទ (វិធាន ៦៧(៣)។ តាមវិធាន ៧៩(១) ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានចេញដោយ ស.ច.ស (ឬ អ.ប.ជ បន្ទាប់ពីបណ្ដឹងឧទ្ធរណ៍) បានប្ដឹងទៅ អ.ជ.ស.ដ ជាស្វ័យប្រវត្តិ។

- **បណ្ដឹងឧទ្ធរណ៍មុនការជំនុំជម្រះទៅ អ.ប.ជ**

គ្រប់ពេលនៃកិច្ចស៊ើបសួរ និងនៅពេលចេញដីកាដំណោះស្រាយ ភាគីទាំងអស់អាចប្ដឹងឧទ្ធរណ៍ទៅ អ.ប.ជ ជំទាស់នឹងសេចក្ដីសម្រេច និងដីកាសម្រេចណាមួយរបស់ ស.ច.ស បាន រួមទាំង ដីកាដំណោះស្រាយផង ប៉ុន្តែសិទ្ធិក្នុងការប្ដឹងឧទ្ធរណ៍ទាំងនេះ គឺខុសៗគ្នា។ សហព្រះរាជអាជ្ញា អាចប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ និងសេចក្ដីសម្រេចផ្សេងទៀតទាំងអស់របស់ ស.ច.ស

(វិធាន ៧៤(២))។ ជនត្រូវចោទ ឬជនជាប់ចោទអាចប្ដឹងឧទ្ធរណ៍ជំទាស់បានតែដីកា ឬសេចក្ដីសម្រេច ដែលបានរាយឈ្មោះក្រោមវិធាន ៧៤(៣) ប៉ុណ្ណោះ ដែលរួមមាន "ការបញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក" ទាក់ទងនឹងការឃុំខ្លួនបណ្ដោះអាសន្ន និងការបដិសេធលើសំណើសុំបំពេញកិច្ចស៊ើបសួរ។ ដើមបណ្ដឹងរដ្ឋប្បវេណីអាចប្ដឹងឧទ្ធរណ៍ជំទាស់នឹងសេចក្ដីសម្រេច ឬដីកាដូចមានចែងនៅក្នុងវិធាន ៧៤(៤) ដែលរួមមាន ដីកាប្រកាសមិនទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី និងដីកាបដិសេធ ដែលសហព្រះរាជអាជ្ញាបានប្ដឹងឧទ្ធរណ៍ផងដែរ។ អ.ប.ជ បានអនុម័តយកការបកស្រាយវិធានទាំងនេះក្នុងន័យមិនតឹងរ៉ឹង ស្របតាមវិធាន ២១ ដើម្បីធានាថា សិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌របស់ភាគីទាំងអស់ ត្រូវបានការពារ។

ជាការបន្ថែម នៅក្នុងពេលណាមួយនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ ភាគី ឬ ស.ច.ស ពិចារណាថា ផ្នែកណាមួយនៃកិច្ចដំណើរការនីតិវិធីមិនយកជាបានការ និងទុកជាមោឃៈ ពួកគាត់អាចផ្ដួចផ្ដើមនីតិវិធីមោឃភាពស្របតាមវិធាន ៧៦ ដើម្បីនាំយកបញ្ហានោះមកចំពោះមុខ អ.ប.ជ។

## ដំណាក់កាលជំនុំជម្រះ

តាមវិធាន៧៩(១) អ.ជ.ស.ដ ត្រូវបាន ស.ច.ស ឬ អ.ប.ជ ប្ដឹងឱ្យទទួលយកដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ តាមវិធាន ៨៩*ស្ទួនពីរ* បើសិនជាមានតម្រូវការនូវផលប្រយោជន៍យុត្តិធម៌ អ.ជ.ស.ដ អាចបំបែកកិច្ចដំណើរការនីតិវិធីទៅជាការជំនុំជម្រះដាច់ដោយឡែកពីគ្នាពាក់ព័ន្ធនឹងផ្នែកនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដូចដែលអង្គជំនុំជម្រះនេះបានធ្វើក្នុងសំណុំរឿង ០០២។ សហព្រះរាជអាជ្ញាត្រូវបង្ហាញភស្តុតាងអំពីពិរុទ្ធភាពរបស់ជនជាប់ចោទឱ្យហួសពីវិមតិសង្ស័យ (វិធាន ៨៧(១)) ផ្អែកលើភស្តុតាងនៅចំពោះមុខខ្លួន។ ភស្តុតាងទាំងអស់ដែល អ.ជ.ស.ដ សម្រេចដើម្បីស្វែងរកការពិតនោះ គឺអាចទទួលយកបាន លើកលែងតែត្រូវបានហាមឃាត់ដោយវិធានផ្ទៃក្នុង។

ដោយមានករណីលើកលែងតិចតួច សវនាការទាំងអស់ត្រូវធ្វើជាសាធារណៈ (វិធាន ៧៦(៦)) ដោយមានវត្តមានជនជាប់ចោទ និងមេធាវីការពារក្ដីរបស់ពួកគេ វៀរលែងតែអវត្តមានជនជាប់ចោទត្រូវបានអនុញ្ញាតដោយ អ.ជ.ស.ដ (វិធាន ៨១)។ មានពេលម្ដងម្កាលក្នុងពេលជំនុំជម្រះ អ.ជ.ស.ដ កំណត់ពេលប្រជុំរៀបចំសវនាការ ដើម្បីប្រឹក្សាជាមួយភាគីដើម្បីធានាថា សវនាការនឹងប្រព្រឹត្តទៅដោយត្រឹមត្រូវយុត្តិធម៌ និងឆាប់រហ័ស (វិធាន ៧៩(៧))។

ការជំនុំជម្រះចាប់ផ្ដើមជាមួយនឹងសវនាការបឋម (វិធាន ៨០*ស្ទួន*) ដោយ អ.ជ.ស.ដ ពិចារណាលើបញ្ហាបឋម ដូចជា អញ្ញត្រកម្មរបស់ភាគី ស្របតាមវិធាន៨៩ និងបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់ភាគី ជាដើម។ បន្ទាប់មកតុលាការរំកិលខ្លួនចូលសវនាការលើអង្គសេចក្ដី នៅពេលចាប់ផ្ដើម គឺក្រឡាបញ្ជីឡើងអានបទចោទប្រឆាំងជនជាប់ចោទ (វិធាន ៨៩ស្ទួន(១)) ហើយបន្ទាប់មកទៀត ភាគីចាប់ផ្ដើមធ្វើសេចក្ដីសន្និដ្ឋានបើកការជំនុំជម្រះ។ បន្ទាប់មក ទើប

៧. សាលក្រម
អង្គជំនុំជម្រះសាលាដំបូង

៨. បណ្ដឹងសាទុក្ខ
អង្គជំនុំជម្រះតុលាការកំពូល

មានការសួរដេញដោលទៅលើជនជាប់ចោទ ហើយក្រោយពីនោះទើបប្រធានអង្គសវនាការប្រាប់ជនជាប់ចោទអំពីសិទ្ធិរបស់គាត់។

ជាទូទៅ អ.ជ.ស.ដ បំបែកការជំនុំជម្រះជាផ្នែកៗ ដោយធ្វើសវនាការលើភ័ស្តុតាងអំពីទីតាំងឧក្រិដ្ឋកម្មជាក់លាក់ អំពីព្រឹត្តិការណ៍ផ្សេងៗ ឬអំពើរបស់ជនជាប់ចោទ។ ក្នុងពេលសវនាការ អ.ជ.ស.ដ កោះហៅសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវសួរដេញដោលដោយអង្គជំនុំជម្រះ សហព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារក្តី ដើម្បីបញ្ជាក់ការពិតអំពីអង្គហេតុនានាដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ក្រោមវិធាន ២៩ នៃវិធានផ្ទៃក្នុង អ.ជ.ស.ដ អាចបង្គាប់ឱ្យមានវិធានការការពារផ្សេងៗដូចជាការប្រើរហស្សនាម ការបំប្លែងសំឡេង ឬ ការធ្វើសវនាការដោយសម្ងាត់ជាដើម ក្នុងករណីដែលផលប្រយោជន៍ផ្នែកសន្តិសុខរបស់សាក្សី របស់ដើមបណ្តឹងរដ្ឋប្បវេណី និងក្រុមគ្រួសាររបស់ពួកគេតម្រូវ។ អ.ជ.ស.ដ ក៏ផ្តល់ពេលវេលាសម្រាប់ធ្វើសវនាការលើឯកសារផងដែរ ដោយ អ.ជ.ស.ដ ពិចារណាលើភ័ស្តុតាងជាឯកសារ និង/ឬ ជាខ្សែវីដេអូ ឬខ្សែអាត់សំឡេង ដែលភាគីបានបង្ហាញ ព្រមទាំងធ្វើសវនាការលើកំណត់ហេតុស្តីពីផលប៉ះពាល់ជនរងគ្រោះ ដោយជ្រើសយកចេញពីក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណី។ អ.ជ.ស.ដ អាចទទួលយកភ័ស្តុតាងឯកសារថ្មីបន្ថែមទៀត ប្រសិនបើខ្លួនយល់ថា ឯកសារថ្មីនោះនាំដល់ការបញ្ជាក់អំពីការពិត តាមការផ្តួចផ្តើមរបស់ខ្លួន។

ក្រោយពីពិនិត្យភ័ស្តុតាងទាំងអស់ អ.ជ.ស.ដ អញ្ជើញឱ្យភាគីដាក់សារណា និងសេចក្តីសន្និដ្ឋានបិទសវនាការ ចំណាប់អារម្មណ៍ចុងក្រោយរបស់ជនជាប់ចោទផ្ទាល់ (វិធាន ៩៤) និងការទាមទារចុងក្រោយរបស់ដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សំណងខូចខាត មុនពេលត្រឡប់ទៅពិភាក្សាជាសម្ងាត់ (វិធាន ៩៦)។

បន្ទាប់មក អ.ជ.ស.ដ នឹងចេញ **សាលក្រម** ជាលាយលក្ខណ៍អក្សរ ទាក់ទងនឹងបទចោទទាំងអស់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ (វិធាន ៩៨, ១០១) ដោយធ្វើការសម្រេចថាតើ មានភ័ស្តុតាងបញ្ជាក់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទដែរឬទេ។ ការកាត់ទោសតម្រូវឱ្យមានសំឡេងភាគច្រើនលើសលុបបួនសំឡេងពីចៅក្រមទាំងប្រាំរូបនៃ អ.ជ.ស.ដ (វិធាន ៩៨(៤))។ បើសិនជាជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធភាព អ.ជ.ស.ដ ក៏សម្រេចផងដែរអំពីការប្រកាសទោស (វិធាន ៩៨(៥)) ហើយអាចផ្តល់សំណងជាសមូហភាពដល់ជនរងគ្រោះ (វិធាន ១០១(៥))។ សាលក្រមត្រូវបានប្រកាសនៅក្នុងសវនាការជាសាធារណៈ (វិធាន១០២)។ នៅក្នុងសំណុំរឿង ០០២/០២ សាលក្រមជាលាយលក្ខណ៍អក្សរបានចេញនៅក្នុងពេលណាមួយបន្ទាប់ពីការប្រកាសជាសាធារណៈ។

ក្នុងអំឡុងពេលសវនាការ ភាគីអាចប្តឹងសាទុក្ខ ក្រោមវិធាន ១០៤ និង ១០៥ លើបញ្ហាចតិចតួចមួយចំនួន ដែលមានផលប៉ះពាល់ភ្លាមៗលើកិច្ចដំណើរការនីតិវិធីសវនាការ រួមមាន សេចក្តីសម្រេចដែលមានអនុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី និងបញ្ហាពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ន វិធានការការពារ និង

## ៩. សាលដីកាបណ្តឹងសាទុក្ខ

អង្គជំនុំជម្រះតុលាការកំពូល

## ១០. ការអនុវត្តទោស

ការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ។ សេចក្តីសម្រេចផ្សេងទៀតអាចនឹងត្រូវប្តឹងសាទុក្ខបានផងដែរ ក្នុងករណីដែលធ្វើឡើងស្របពេលជាមួយបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម។ ជាទូទៅ បណ្តឹងសាទុក្ខភ្លាមៗមិនមានអានុភាពបង្អង់កិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.ជ.ស.ដ ឡើយ។

## ដំណាក់កាលបណ្តឹងសាទុក្ខ

សហព្រះរាជអាជ្ញា មេធាវីការពារក្តី និងដើមបណ្តឹងរដ្ឋប្បវេណី អាចប្តឹងសាទុក្ខប្រឆាំងសាលក្រមសាលាដំបូង ឬសេចក្តីសម្រេចទៅកាន់ អ.ជ.ត.ក។ ប៉ុន្តែ សិទ្ធិប្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី មានព្រំដែនកំណត់ច្រើនជាង។ ដោយត្រូវបានតំណាងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងសាទុក្ខជំទាស់នឹងសេចក្តីសម្រេចរបស់ អ.ជ.ស.ដ ស្តីពីសំណង និងអាចប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម បានតែក្នុងករណីដែលសហព្រះរាជអាជ្ញា បានប្តឹងសាទុក្ខប៉ុណ្ណោះ។ ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចផ្តន្ទាទោសបានទេ (វិធាន ១០៥(គ))។

ភាគីដែលប្តឹងសាទុក្ខ ត្រូវលើកអំពីកំហុសអង្គច្បាប់ ដែលធ្វើឲ្យអស់សុពលភាពសាលក្រម ឬសេចក្តីសម្រេចទាំងមូល ឬមួយផ្នែក កំហុសអង្គហេតុដែលធ្វើឲ្យមានភាពអយុត្តិធម៌ជាក់ស្តែង ឬការភ័ន្តច្រឡំដែលស្តែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់ អ.ជ.ស.ដ ដែលនាំឲ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ (វិធាន ១០៤)។ កំហុសនីតិវិធីដែលបានធ្វើឡើងដោយ អ.ជ.ស.ដ អាចធ្វើឲ្យមានការបដិសេធសាលក្រមបាន លុះត្រាតែវាបង្កឲ្យមាន "លទ្ធផលអយុត្តិធម៌ធំធេងនៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការ" តែប៉ុណ្ណោះ។

ជាផ្នែកនៃដំណើរការបណ្តឹងសាទុក្ខ ចៅក្រម អ.ជ.ត.ក អាចកោះហៅ ឬទទួលយកភ័ស្តុតាងថ្មី ដើម្បីកំណត់លើបញ្ហាណាមួយ រួមទាំង ការកោះហៅសាក្សីថ្មី (វិធាន ១០៤(១))។ បន្ថែមលើការទទួលយកសារណាបណ្តឹងសាទុក្ខជាលាយលក្ខណ៍អក្សរនិងចម្លើយតបពីភាគី អ.ជ.ត.ក ដឹកនាំធ្វើសវនាការជាសាធារណៈលើបណ្តឹងសាទុក្ខ ស្របតាមវិធាន ១០៩ ដោយភាគីបង្ហាញសេចក្តីសន្និដ្ឋានរបស់ខ្លួន ហើយជនជាប់ចោទមានឱកាសថ្លែងជូន អ.ជ.ត.ក។

បន្ទាប់ពីការពិភាក្សាគ្នារួចមក ចៅក្រម អ.ជ.ត.ក ចេញ **សាលដីកា** ស្របតាមវិធាន ១១១។ សេចក្តីសម្រេចនេះតម្រូវឲ្យមានសំឡេងភាគច្រើនលើសលុបប្រាំរូប ពីក្នុងចំណោមចៅក្រមទាំងប្រាំពីររូបរបស់ អ.ជ.ត.ក ហើយសាលដីកានេះ គឺជាសាលក្រមស្ថាពរ។ ទណ្ឌិត ឬបើក្រោយការស្លាប់របស់ទណ្ឌិតសាច់ញាតិ ឬបុគ្គលដែលបានចាត់តាំងផ្សេងទៀត អាចស្នើសុំសើរើសាលដីកាបាន តែក្នុងករណីមានកំណត់តិចតួចបំផុត ដូចមានចែងនៅក្នុងវិធាន ១១២ ប៉ុណ្ណោះ។ ក្នុងអំឡុងនៃដំណាក់កាលសេសសល់ មានតែទណ្ឌិត និងតែនៅក្នុងអំឡុងនៃជីវិតរបស់ខ្លួន និង សហព្រះរាជអាជ្ញាប៉ុណ្ណោះ ដែលមានសិទ្ធិស្នើសុំសើរើសាលដីកា (កិច្ចព្រមព្រៀងបន្ថែម មាត្រា ២(៣))។

- **ការអនុវត្តទោស**

មិនដូចតុលាការ ICTY, ICTR និង SCSL ទេ អនុលោមតាមវិធាន ១១៣ ពេលណាអង្គជំនុំជម្រះបានអនុមតិការប្រកាសទោសដាក់ពន្ធនាគារហើយ ពេលនោះសហព្រះរាជអាជ្ញា គឺជាអ្នកទទួលខុសត្រូវចំពោះការអនុវត្តទោស ដោយសហការជាមួយអាជ្ញាធរកម្ពុជា មិនមែនការិយាល័យរដ្ឋបាលទេ។ ទណ្ឌិតរបស់ អ.វ.ត.ក ត្រូវបានផ្ទេរពីមន្ទីរឃុំឃាំង អ.វ.ត.ក ទៅជាប់ពន្ធនាគារជាតិណាមួយ ឲ្យតែលក្ខខណ្ឌនៃការជាប់ឃុំឃាំងនោះស្របទៅនឹងបទដ្ឋានអន្តរជាតិក្នុងការប្រព្រឹត្តិចំពោះអ្នកទោស។

# ផ្នែក II៖ សំណុំរឿង

# ទណ្ឌិត ជនជាប់ចោទ ជនត្រូវចោទ និង ជនសង្ស័យ

សំណុំរឿង ០០១



កាំង ហ្គេកអ៊ាវ
ហៅ ឌុច

សំណុំរឿង ០០២



នួន ជា
ហៅ បងធំទីពីរ



ខៀវ សំផន
ហៅ ហែម



អៀង សារី
ហៅ វ៉ាន់



អៀង ធីរិទ្ធ
ហៅ ភា

សំណុំរឿង ០០៣



មាស មុត
ហៅ ខែ មុត



ស៊ូ ម៉េត
ហៅ តាម៉េត

សំណុំរឿង ០០៤



យឹម ទិត្យ
ហៅ តាទិត្យ



អ៊ឹម ចែម
ហៅ យាយចែម



អោ អាន
ហៅ តាអាន

# ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ




( X ): ស្លាប់ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី

( § ): រឿងក្តីត្រូវបានលើកលែងចោទប្រកាន់

( * ): ត្រូវបានរកឃើញថាមិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមក្នុងការជំនុំជម្រះ

(O): រឿងក្តីត្រូវបានរំលត់

# សំណុំរឿង ០០១

## កាំង ហ្កេកអ៊ាវ ហៅ ឌុច



**ការស៊ើបអង្កេត៖** សហព្រះរាជអាជ្ញាបានបើកការស៊ើបអង្កេតបឋមនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៦។ ពួកគាត់បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ដោយបានស្នើសុំឱ្យ ស.ច.ស បើកកិច្ចស៊ើបសួរក្នុងឧក្រិដ្ឋកម្មនានា ដែល ឌុច, នួន ជា, ខៀវ សំផន, អៀង សារី និង អៀង ធីរិទ្ធ ត្រូវបានចោទថាទទួលខុសត្រូវ។ នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ ស.ច.ស បានចេញដីកាបង្គាប់ឱ្យនាំខ្លួន ឌុច ដែលបន្ទាប់មកត្រូវបានបញ្ជូនទៅកាន់មន្ទីរឃុំឃាំង អ.វ.ត.ក.។ ដើម្បីពន្លឿនរឿងក្ដីរបស់គាត់ ស.ច.ស បានចេញដីកាបំបែកកិច្ចស៊ើបសួរនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ដោយបានបង្កើតសំណុំរឿង ០០១ ទាក់ទងនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ឌុច ដែលបានចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មនានា ដែលកើតឡើងចេញពីប្រតិបត្តិការមន្ទីរសន្តិសុខ ស.២១(ត្រូវបានស្គាល់ផងដែរថាទួលស្លែង) ដោយរួមទាំងទីតាំងសម្លាប់មនុស្ស ជើងឯក និងជំរុំកសាង ព្រៃ ស (ស.២៤)។

នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ ស.ច.ស. បានចេញ ដីកាដំណោះស្រាយចោទប្រកាន់ ឌុច និងបញ្ជូនខ្លួនគាត់ទៅជំនុំជម្រះ ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការពារបំពានធ្ងន់ធ្ងរ។ ឌុច មិនត្រូវបានចោទប្រកាន់ថាជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យនោះទេ ប៉ុន្តែត្រូវបានចោទប្រកាន់ថាជាជនម្នាក់ក្នុងចំណោមអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងចន្លោះឆ្នាំ១៩៧៥ និង ១៩៧៩ ដោយយោងទៅលើសិទ្ធិអំណាចតាមឋានានុក្រមជាផ្លូវការរបស់គាត់ និងក្នុងមុខតំណែងរបស់គាត់ជាអនុប្រធាន និងក្រោយមកជាប្រធាន ស.២១។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះចោទប្រកាន់ថា ឌុច ទទួលខុសត្រូវចំពោះការឃុំខ្លួនជាប្រព័ន្ធ ការធ្វើទារុណកម្ម និងការសម្លាប់អ្នកទោសរាប់ពាន់នាក់ រួមទាំងបុរស ស្ត្រី និងកុមារ ដែលពួកគេភាគច្រើនគឺជាកម្មាភិបាល ប.ក.ក.។ អ្នកជាប់ឃុំត្រូវបានបញ្ជូនមកពីទូទាំងប្រទេស ពីគ្រប់ភូមិភាគ តំបន់ស្វយ័ត កងពលកងទ័ពបដិវត្តកម្ពុជា និងក្រសួងក៏ដូចជាមកពីដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យ។ ជនបរទេសមួយចំនួនក៏ត្រូវបានឃុំខ្លួននៅក្នុង ស.២១ ផងដែរ រួមមានជនជាតិវៀតណាម ថៃ អាមេរិក អង់គ្លេស និងអូស្ត្រាលី។

មានតែសហព្រះរាជអាជ្ញាទេដែលបានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨ ដោយបានស្នើសុំថា ឌុច ក៏ត្រូវ

ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៦
បើកការស៊ើបអង្កេតបឋម

ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧
បើកការស៊ើបអង្កេតតាមផ្លូវតុលាការ

ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨
ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានតម្កល់

ថ្ងៃទី១៧ ខែកម្ភៈ ឆ្នាំ២០០៩
ការជំនុំជម្រះចាប់ផ្ដើម

ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០
ចេញសាលក្រម

ថ្ងៃទី៣ ខែកម្ភៈ ឆ្នាំ២០១២
ចេញសាលដីកាបណ្ដឹងសាទុក្ខ

ចោទប្រកាន់ចំពោះបទល្មើស (១) មនុស្សឃាត និងទារុណកម្ម តាមក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ ("ឧក្រិដ្ឋកម្មថ្នាក់ជាតិ") និង (២) ការទទួលខុសត្រូវក្នុងទម្រង់ជាសហឧក្រិដ្ឋកម្មរួម (JCE)។ នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ អ.ប.ជ បានទទួលយកទឡ្ហីករណ៍ទីមួយនៃបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា និងបានបដិសេធទឡ្ហីករណ៍ទីពីរ ដោយបានកែប្រែ និងបញ្ជាក់ លើដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងបានបញ្ជូនខ្លួនឌុចទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត) ការបំពារបំពានធ្ងន់ធ្ងរ (ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់) និងបទមនុស្សឃាតគិតទុកជាមុន និងបទទារុណកម្មក្នុងនាមជាឧក្រិដ្ឋកម្មថ្នាក់ជាតិ។

**ការជំនុំជម្រះ៖** ការជំនុំជម្រះបានចាប់ផ្តើមនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ជាមួយនឹងសវនាការបឋម។ សវនាការលើភស្តុតាងបានចាប់ផ្តើមពីថ្ងៃទី៣០ ខែមីនា ដល់ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ បន្ទាប់ពីសវនាការចំនួន ៧២ ថ្ងៃ។ អ.ជ.ស.ដ. បានស្តាប់សវនាការបុគ្គលចំនួន ៥៥នាក់៖ សាក្សី ២៤នាក់ (សាក្សីអង្គហេតុចំនួន ១៧នាក់ និងសាក្សីអត្តចរិតចំនួន ៧នាក់) សាក្សីជំនាញចំនួន ៩នាក់ និង ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២២នាក់ និងបានទទួលយកឯកសារប្រមាណ ១.០០០ ធ្វើជាភស្តុតាង។ ភាគីទាំងអស់បានដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលនៅថ្ងៃទី១០ និង ១១ ខែវិច្ឆិកា ឆ្នាំ២០០៩។

សេចក្តីសន្និដ្ឋានបិទកិច្ចពិភាក្សាដេញដោលត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី២៣ ដល់ ២៧ ខែវិច្ឆិកា ឆ្នាំ២០០៩។ នៅថ្ងៃទី២៥ ខែវិច្ឆិកា ឌុច បានទទួលស្គាល់ការទទួលខុសត្រូវផ្នែក "ផ្លូវចិត្ត និងផ្លូវច្បាប់" ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅ ស.២១ ប៉ុន្តែបានស្នើសុំចៅក្រមសម្រេចឱ្យគាត់រួចខ្លួនពីការចោទប្រកាន់ទាំងអស់។ ម្យ៉ាងវិញទៀត មេធាវីការពារក្តីបានស្នើសុំចៅក្រមអង្គជំនុំជម្រះសាលាដំបូងឱ្យពិចារណាបទបញ្ជា និងការគាបសង្កត់របស់ថ្នាក់លើនៅក្នុងស្ថានសម្រាលទោស។

អ.ជ.ស.ដ បានចេញសាលក្រមរបស់ខ្លួននៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០។ អង្គជំនុំជម្រះបានរកឃើញថា អស់រយៈពេលជាងបីឆ្នាំ ឌុច បានគ្រប់គ្រងនិងកែប្រែប្រព័ន្ធនៅ ស.២១ ដែលនាំឱ្យមានការស្លាប់មិនតិចជាង

សេចក្តីសម្រេចចំនួន
៤៤៤

ឯកសារដាក់ដោយភាគីចំនួន
២៧៨ ឯកសារ

ថ្ងៃសវនាការធ្វើឡើងដោយ
អ.ជ.ស.ដ & អ.ជ.ត.ក
ចំនួន ៨៨ ថ្ងៃ

ដើមបណ្តឹងរដ្ឋប្បវេណីចំនួន
៩០ នាក់

សក្ខីកម្មក្នុងសវនាការចំនួន
៥៥

ភស្តុតាងដែលបានទទួលយកចំនួន (*)
~ ១០០០

អ្នកចូលរួមវនាការចំនួន
៣៦.៤៩៣ នាក់

(*) ភស្តុតាងពីសំណុំរឿងត្រូវស្ថិតក្រោមការពិនិត្យនៅពេលសវនាការ និងនៅពេលដែល អ.ជ.ស.ដ. ចេញសេចក្តីសម្រេចរបស់ខ្លួន។ ការណ៍នេះអនុវត្តចំពោះសំណុំរឿង ០០១ និង សំណុំរឿង ០០២។

១២,២៧២ នាក់ ដោយការសម្លាប់ ឬដោយសារលក្ខខណ្ឌនៅ ស.២១។ អ្នកទោសភាគច្រើនក៏ត្រូវបានធ្វើទារុណកម្មជាលក្ខណៈប្រព័ន្ធផងដែរ។ ចៅក្រមបានរកឃើញថា ឌុច គឺជាមនុស្សមានការអប់រំ និងឆ្លាតវៃ ដែលការទទួលយករបស់គាត់នូវការតែងតាំងជាអនុប្រធាន និងក្រោយមកជាប្រធាន ស-២១ បានបង្ហាញពីស្មារតីនៃកាតព្វកិច្ចរបស់គាត់ចំពោះបក្សកុម្មុយនីស្តកម្ពុជា និងថាគាត់បានដឹងយ៉ាងច្បាស់អំពីលក្ខណៈ និងភាពធ្ងន់ធ្ងរខ្លាំងនៃឧក្រិដ្ឋកម្មរបស់គាត់នៅពេលនោះ។ ជាលទ្ធផល ឌុច ត្រូវបានរកឃើញថា មានពិរុទ្ធភាពនៃរាល់បទចោទទាំងអស់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (ដែលដាក់បញ្ចូលក្រោមការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ជាមួយនឹងអំពើរំលោភលើផ្លូវភេទត្រូវបានកំណត់ប្រភេទថាជាការធ្វើទារុណកម្ម) និងការបំពារបំពានធ្ងន់ធ្ងរ។ ដោយកត់សម្គាល់ពីលក្ខណៈដ៏គួរឱ្យតក់ស្លុត និងសាហាវនៃឧក្រិដ្ឋកម្មរបស់គាត់ប៉ុន្តែដោយការរកឃើញស្ថានសម្រាលទោសសំខាន់ៗ (ការចូលរួមសហការជាមួយអង្គជំនុំជម្រះ ការទទួលស្គាល់ការទទួលខុសត្រូវ ការបង្ហាញពីវិប្បដិសារី (ទោះបីជាបានកាត់បន្ថយដោយសំណើសុំឱ្យរួចខ្លួននៅក្នុងពេលធ្វើសេចក្ដីសន្និដ្ឋានបិទ) បរិយាកាសគាបសង្កត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងលទ្ធភាពស្ដារនីតិសម្បទារបស់គាត់) អ.ជ.ស.ដ. បានកាត់ទោស ឌុច ឱ្យជាប់ពន្ធនាគារចំនួន ៣៥ ឆ្នាំ។ ជាការឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញានៅមុនពេលជំនុំជម្រះ អ.ជ.ស.ដ. បានបញ្ជាក់ថា JCE គឺជាបញ្ញាចម្រូងចម្រាសក្នុងសំណុំរឿង ០០១ ទោះបីជាការដកវាចេញពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ នៅក្នុងសាលក្រម អង្គជំនុំជម្រះបានសម្រេចថា JCE I និង II (ទម្រង់មូលដ្ឋាន និងជាប្រព័ន្ធរបស់វា) អាចអនុវត្តបាននៅ អ.វ.ត.ក. និងបានផ្ដន្ទាទោស ឌុច ចំពោះឧក្រិដ្ឋកម្ម ដែលបណ្ដាលមកពីការចូលរួមរបស់គាត់ក្នុង JCE។

អ.ជ.ស.ដ បានសម្រេចថា ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៦៦ នាក់ បានទទួលរងព្យសនកម្មដែលកើតចេញពីឧក្រិដ្ឋកម្មរបស់ ឌុច។ ក្នុងចំណោមការទាមទារសំណងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី អ.ជ.ស.ដ. បានបោះពុម្ពផ្សាយជាសាធារណៈនូវសេចក្ដីថ្លែងសុំទោសរបស់ ឌុច និង ការទទួលស្គាល់អំពីការទទួលខុសត្រូវ នៅលើគេហទំព័រ អ.វ.ត.ក. និងបានរៀបរាប់ឈ្មោះដើមបណ្ដឹងរដ្ឋប្បវេណី និងសាច់ញាតិដែលបានបាត់បង់របស់ពួកគាត់នៅក្នុងសាលក្រម។ អង្គជំនុំជម្រះបានបដិសេធការទាមទារដែលដាក់កាតព្វកិច្ចទៅលើភាគីទីបី (i) ការផ្ដល់សំណងជាប្រាក់ ឬ ការបង្កើតមូលនិធិសម្រាប់ជនរងគ្រោះ ii) ការសូមទោសជារដ្ឋ និងការបង្កើតទិវាជាតិនៃការចងចាំ iii) ការទទួលបានវិធានការសុខាភិបាល និងអប់រំដោយឥតគិតថ្លៃ) ឬ ការទាមទារដែលខ្វះភាពជាក់លាក់ (i) ការផលិតភាពយន្តឯកសារ និងការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយនូវផ្នែកនៃសាលក្រម ii) ការសារសង់កន្លែងរំលឹក និង iii) ការអភិរក្សបណ្ណសារ ទីកន្លែង និងសម្ភារៈសិល្បៈ)។



*ការចែកសៀវភៅសាលក្រមសំណុំរឿង០០១ © គេហទំព័រ អ.វ.ត.ក*

អ.ជ.ស.ដ មិនអាចចេញសេចក្តីសម្រេចដោយសំឡេងភាគច្រើនលើសិទ្ធិរបស់ អ.វ.ត.ក ក្នុងការចោទប្រកាន់តាមច្បាប់ជាតិ ដូច្នេះហើយបានជាពិរុទ្ធភាពរបស់ ឌុច នៅក្នុងបទចោទទាំងនោះពុំបានកំណត់។ ចៅក្រមអន្តរជាតិបានសម្រេចថាពុំមានសិទ្ធិដូច្នេះនៅជាធរមានទេ ដោយសារច្បាប់អាជ្ញាយុកាល១០ឆ្នាំ នៅក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ បានផុតរលត់តាំងពីមុនការពន្យារពេលក្នុងឆ្នាំ២០០១ ដោយមាត្រា៣នៃច្បាប់ អ.វ.ត.ក. ទៅទៀត ដែលជាការរំលោភលើគោលការណ៍ប្រតិសកម្ម។ ផ្ទុយទៅវិញចៅក្រមជាតិបានសម្រេចថា ច្បាប់អាជ្ញាយុកាលជាធរមានត្រូវបានព្យួរតាំងពីឆ្នាំ១៩៧៩ ដោយសារប្រព័ន្ធតុលាការកម្ពុជាត្រូវបានធ្វើឲ្យលែងដំណើរការដោយរបបកម្ពុជាប្រជាធិបតេយ្យ និងសង្គ្រាមស៊ីវិល។



ឌុច ក្នុងអំឡុងរបបខ្មែរក្រហម

**បណ្តឹងសាទុក្ខ៖** នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១០ សហព្រះរាជអាជ្ញាបានប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ផ្អែកលើទឡ្ហីករណ៍ចំនួនបី ដោយចោទ អ.ជ.ស.ដ. ថាមានកំហុស i) ក្នុងការដាក់ទោសមិនគ្រប់គ្រាន់ជាក់ស្តែង ii) ការខកខានក្នុងការកាត់ទោស ឌុច ចំពោះឧក្រិដ្ឋកម្មទាំងអស់ដែលបានរកឃើញថា គាត់ជាអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនោះ ពេលដែលអង្គជំនុំជម្រះនេះបានធ្វើការកំណត់បទចោទនៃអំពើរំលោភសេពសន្ថវៈទៅជាការធ្វើទារុណកម្ម ហើយបានស្រូបទោសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងអស់ ឲ្យនៅក្រោមឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និង iii) ការខកខានក្នុងការកាត់ទោស ឌុច ចំពោះឧក្រិដ្ឋកម្មនៃការធ្វើឲ្យទៅជាទាសករនៃអ្នកជាប់ឃុំទាំងអស់នៅមន្ទីរ ស.២១។ នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០ ឌុច បានប្តឹងសាទុក្ខ ដោយអះអាងថា អ.ជ.ស.ដ. មានកំហុស i) ក្នុងការសម្រេចថា គាត់ស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. និង ii) នៅក្នុងការកំណត់ទោសរបស់គាត់។ ក្រុមដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនបានប្តឹងសាទុក្ខប្រឆាំងនឹងការបដិសេធរបស់ អ.ជ.ស.ដ. លើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងគម្រោងសំណងមួយចំនួន។

សវនាការលើបណ្តឹងសាទុក្ខបានធ្វើឡើងចាប់ពីថ្ងៃទី២៨ ដល់ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១១ ហើយសាលដីកា បានចេញនៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២។ អ.ជ.ត.ក. បានច្រានចោលបណ្តឹងសាទុក្ខរបស់ ឌុច ទាំងស្រុង ហើយនិងទឡ្ហីករណ៍ទីបីរបស់សហព្រះរាជអាជ្ញាផងដែរ។ ចំពោះទឡ្ហីករណ៍របស់សហ ព្រះរាជអាជ្ញាដែលនៅសល់ អ.ជ.ត.ក. បានបូកបន្ថែមការកាត់ទោសដាច់ដោយឡែកនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល (ដែលរួមបញ្ចូលទាំង ការធ្វើមនុស្សឃាត) ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងៗទៀត។ អ.ជ.ត.ក ពុំទទួលស្គាល់ថា

អំពើរំលោភសេពសន្ថវៈបានកើតមានឡើងជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដាច់ដោយឡែកទេនៅក្នុងឆ្នាំ១៩៧៥ ហើយបានតម្កល់ការកំណត់បទចោទជាអំពើទារុណកម្ម។ ជាចុងក្រោយ ការកាត់ទោសរយៈពេល ៣៥ឆ្នាំរបស់ ឌុច ត្រូវបានជំនួសមកវិញដោយការដាក់ទោសជាប់ពន្ធនាគារមួយជីវិត។ អ.ជ.ត.ក. ក៏បានទទួលយកភាគីដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១០ នាក់ បន្ថែមផងដែរ។ សាលដីកាមិនទទួលយកគម្រោងសំណងបន្ថែមណាមួយមកអនុវត្តជាបន្តទៀតឡើយ។

នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៣ ឌុច ត្រូវបានបញ្ជូនទៅកាន់ពន្ធនាគារខេត្តកណ្តាលដើម្បីបន្តអនុវត្តទោសរបស់គាត់។ គាត់ទទួលមរណភាពនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត នៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២០។



*អ្នករស់រានមានជីវិតពី ស-២១ ជុំ ម៉ី និង ប៊ូ ម៉េង លើកសាលដីកា ឌុច*
*© គេហទំព័រ អ.វ.ត.ក*

## ទិដ្ឋភាពពិសេសមានតែមួយ

**ការជាប់ឃុំឃាំងខុសច្បាប់នៅក្រៅ អ.វ.ត.ក៖** អ.ជ.ត.ក បានសម្រេចថា ឌុច ពុំមានសិទ្ធិបន្ធូរបន្ថយទោសសម្រាប់ការជាប់ឃុំឃាំងខុសច្បាប់របស់ខ្លួនដោយតុលាការយោធាកម្ពុជា ពីឆ្នាំ១៩៩៩ ដល់ឆ្នាំ២០០៧ ទេ ដោយសារការខូចខាតនោះមិនពាក់ព័ន្ធនឹង អ.វ.ត.ក។ យ៉ាងណាមិញគាត់ទទួលបានការប៉ះប៉ូវចំពោះពេលវេលាដែលគាត់បានជាប់ឃុំឃាំងនៅទីនោះ។

**យុត្តាធិការបុគ្គល៖** បន្ទាប់ពី អ.ជ.ស.ដ ច្រានចោលការអះអាងរបស់ ឌុច ថាគាត់មិនស្ថិតក្រោមយុត្តាធិការបុគ្គលនៃ អ.វ.ត.ក, អ.ជ.ត.ក បានបញ្ជាក់ថា ចំណោទអំពីយុត្តាធិការតែមួយគត់ដែលត្រូវសួរ គឺថាតើជនជាប់ចោទជាមន្ត្រីខ្មែរក្រហម ដែរឬអត់។ ចំណែកសំណួរថាតើ គាត់ជាមេដឹកនាំ "ជាន់ខ្ពស់" និង/ឬ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" តាមអត្ថន័យនៃក្របខណ្ឌច្បាប់ អ.វ.ត.ក វាគឺជារឿងផ្តាច់មុខនៃសេចក្តីសម្រេចផ្នែកគោលនយោបាយ ក្រោមឆន្ទានុសិទ្ធិតែមួយគត់របស់ ស.ព និង ស.ច.ស ដើម្បីផ្តោតធនធានដ៏កម្ររបស់ អ.វ.ត.ក ទៅលើតែករណីធ្ងន់ធ្ងរបំផុត។

**ការបង្ខិតបង្ខំ និងបញ្ជារបស់ថ្នាក់លើ៖** អ.ជ.ស.ដ បានច្រានចោលការទាមទាររបស់ ឌុច ដែលថា គាត់ពុំមានការទទួលខុសត្រូវព្រហ្មទណ្ឌ ឬតាមជម្រើសផ្សេង សុំឱ្យបន្ធូរបន្ថយទោសរបស់គាត់ ដោយសារគាត់បានធ្វើតាមការបង្ខិតបង្ខំ និងបញ្ជារបស់ថ្នាក់លើ។ អ.ជ.ស.ដ បានសម្រេចថា មាត្រា ២៩(៤)ថ្មី នៃច្បាប់ អ.វ.ត.ក បានច្រានចោលជាមុននូវការពឹងផ្អែកលើបញ្ជារបស់ថ្នាក់លើ និងថាមិនអាចសំអាងលើការបង្ខិតបង្ខំទៅនៅពេលដែលការគំរាមកំហែងដែលគេអាចមើលឃើញនោះ កើតចេញពីការអនុវត្តគោលនយោបាយដ៏រន្ធត់មួយដែលក្នុងនោះ ឌុច មានឆន្ទៈនិងបានចូលរួមយ៉ាងសកម្ម។ អ.ជ.ត.ក បានតម្កល់សេចក្តីសម្រេចទាំងនេះ។

# សំណុំរឿង ០០២

## នួន ជា, ខៀវ សំផន, អៀង សារី & អៀង ធីរិទ្ធ



**ការស៊ើបអង្កេត៖** ការបំបែកកិច្ចដំណើរការនីតិវិធីរឿងក្តីនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ខែកក្កដា ឆ្នាំ២០០៧ បានបង្កើតសំណុំរឿង០០២ ប្រឆាំងនឹង នួន ជា, ខៀវ សំផន, អៀង ធីរិទ្ធ និង អៀង សារី។ ស.ច.ស. បានចេញដីកាបង្គាប់ឱ្យនាំខ្លួន នួន ជា នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៧។ គាត់បានមកបង្ហាញខ្លួនលើកដំបូង នៅថ្ងៃទី១៩ ខែកញ្ញា និងត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។ ក្រោយការចាប់ខ្លួនពួកគេ និងការបង្ហាញខ្លួនលើកដំបូង នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ អៀង សារី និង អៀង ធីរិទ្ធ ក៏ត្រូវបានដាក់ឱ្យស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្នផងដែរ។ ចំណែកឯ ខៀវ សំផន វិញ គាត់ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ហើយប្រាំថ្ងៃក្រោយមកគាត់ត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។

ចន្លោះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៨ និង ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមចំនួនប្រាំ ដើម្បីពង្រីក និងបញ្ជាក់វិសាលភាពនៃការស៊ើបអង្កេត រួមទាំងការចោទប្រកាន់បន្ថែមអំពីអំពើហិង្សាផ្លូវភេទ និងឃេនឥរ និងអំពើប្រល័យពូជសាសន៍លើជនជាតិចាម។

នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ស.ច.ស. បានចេញដីកាដំណោះស្រាយចោទប្រកាន់អ្នកជាប់ឃុំទាំងបួនរូបនេះ។ ស.ច.ស. បានរកឃើញភ័ស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ពួកគេទទួលខុសត្រូវ តាមរយៈការចូលរួមក្នុងទម្រង់ JCE សម្រាប់ i) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ii) អំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម និងចាម iii) ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និង iv) ការរំលោភលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ("ឧក្រិដ្ឋកម្មថ្នាក់ជាតិ") ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនិងព្រឹត្តិការណ៍ទាំងអស់ខាងក្រោមនេះ។

- មន្ទីរសន្តិសុខចំនួន ១១៖ នៅ ភ្នំពេញ៖ **មន្ទីរសន្តិសុខ ស-២១**, តំបន់ ២៥

ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៦
បើកការស៊ើបអង្កេតបឋម

ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧
បើកការស៊ើបអង្កេតតាមផ្លូវតុលាការ

ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១
ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានបញ្ជាក់

ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១
ការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ ចាប់ផ្តើម

ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤
ចេញសាលក្រមសំណុំរឿង០០២/០១

(ភូមិភាគនិរតី)៖ **មន្ទីរសន្តិសុខ សង់**, តំបន់ ១៣ (ភូមិភាគនិរតី)៖ **មន្ទីរសន្តិសុខក្រាំងតាចាន់**, តំបន់ ៣៧ (ភូមិភាគបស្ចិម)៖ **មន្ទីរសន្តិសុខ កោះខ្យង** តំបន់ ៣១ (ភូមិភាគបស្ចិម)៖ **មន្ទីរសន្តិសុខ ព្រៃដំរីស្រុត**, តំបន់ ៣ (ភូមិភាគពាយ័ព្យ)៖ **មន្ទីរសន្តិសុខ វត្តគិរីរម្យ**, តំបន់ ១០៦ (ភូមិភាគឧត្តរ)៖ **មន្ទីរសន្តិសុខភូមិភាគឧត្តរ**, តំបន់ ១០២ (អតីតភូមិភាគឦសាន)៖ **មន្ទីរសន្តិសន្តិសុខ អូរកន្សែង**, តំបន់ ១០៥ (អតីតភូមិភាគឦសាន)៖ **មន្ទីរសន្តិសុខ ភ្នំក្រោល**, តំបន់២៣ (ភូមិភាគបូព៌ា)៖ **មន្ទីរសន្តិសុខ វត្តផ្លក**, តំបន់ ៥០៥ (អតីតភូមិភាគឦសាន)៖ **មន្ទីរសន្តិសុខគោកក្ដួច**។

- ទីតាំងសម្លាប់មនុស្សចំនួន ៤៖ នៅ តំបន់ ៣១ (ភូមិភាគបស្ចិម)៖ **ទីតាំងសម្លាប់មនុស្សព្រៃត្រពាំងអំពិល ទីតាំងសម្លាប់មនុស្សព្រៃត្រពាំងព្រីង**, តំបន់ ៧ (ភូមិភាគពាយ័ព្យ)៖ **ទីតាំងសម្លាប់មនុស្សទួលពោធិព្រៃ**, តំបន់ ២០ (ភូមិភាគបូព៌ា)៖ **ទីតាំងសម្លាប់មនុស្សស្ទឹងតូច**។
- ការដ្ឋាននិងសហករណ៍ជាច្រើន៖ នៅ ភ្នំពេញ៖ **ការដ្ឋានព្រៃ ស (ស-២៤)**, តំបន់ ១៣ (ភូមិភាគនិរតី)៖ **សហករណ៍ត្រាំកក់**, តំបន់ ៥ (ភូមិភាគពាយ័ព្យ)៖ **ការដ្ឋានទំនប់ត្រពាំងថ្ម**, តំបន់ ៤២ និង ៤៣ (ភូមិភាគកណ្តាល)៖ **ការដ្ឋានទំនប់ ១ មករា**, តំបន់ ៣៥ (ភូមិភាគនិរតី)៖ **ការដ្ឋានស្រែអំបិល**, តំបន់ ៣១ (ភូមិភាគបស្ចិម)៖ **ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង**។
- ការប្រព្រឹត្តលើក្រុមគោលដៅ៖ **ពុទ្ធសាសនិក ជនជាតិចាម ជនជាតិវៀតណាម** និង **អតីតមន្ត្រីរបបសាធារណរដ្ឋខ្មែរ** រួមមានមន្ត្រីរដ្ឋការ និងអតីតបុគ្គលិកនិងក្រុមគ្រួសាររបស់ពួកគេ។
- ការផ្លាស់ទីលំនៅប្រជាជន៖ **ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១)** (ពីភ្នំពេញ ក្នុងខែមេសា ឆ្នាំ១៩៧៥) **ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)** (ពីភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) ភូមិភាគនិរតី ភូមិភាគបស្ចិម និង ភូមិភាគបូព៌ា រវាងខែកញ្ញា ឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៧) **ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី៣)** (ពីភូមិភាគបូព៌ា នៅចុងឆ្នាំ១៩៧៧ និងទៅទូទាំងឆ្នាំ១៩៧៨) និង
- **ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរួមដំណេកដោយបង្ខំ**៖ ទូទាំងប្រទេស។

ដីកាដំណោះស្រាយចោទប្រកាន់ថា ឧក្រិដ្ឋកម្មទាំងអស់នេះបានប្រព្រឹត្តឡើងអនុលោមតាមគោលបំណងឧក្រិដ្ឋរួម (JCE) ដែលបានចាប់ផ្តើមមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងបានបន្តរហូតដល់យ៉ាងហោចណាស់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ប.ក.ក. បានចូលរួមចំណែក

ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤
ចាប់ផ្តើមសវនាការសំណុំរឿង ០០២/០២

ថ្ងៃទី ២៣ខែវិច្ឆិកា ឆ្នាំ២០១៦
ចេញសាលដីកាសំណុំរឿង ០០២/០១

ថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១៨
ចេញសាលក្រមសំណុំរឿង ០០២/០២

ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២
ចេញសាលដីកាសំណុំរឿង ០០២/០២

ក្នុងគោលបំណងនោះ - មានដូចជា នួន ជា និង អៀង សារី (ឧបនាយករដ្ឋមន្ត្រីការបរទេស) គណៈកម្មាធិការមជ្ឈិម - មានដូចជា ខៀវ សំផន ប្រធានក្រសួង ប.ក.ក. - មានដូចជា អៀង ធីរិទ្ធ (រដ្ឋមន្ត្រីសង្គមកិច្ច) លេខាភូមិភាគ និងតំបន់ និងលេខាកងពលមជ្ឈិមបក្ស។ អ្នកចូលរួមក្នុងគោលបំណងឧក្រិដ្ឋរួមនេះមានបំណងអនុវត្តបដិវត្តន៍សង្គមនិយមឱ្យបានឆាប់រហ័សតាមរយៈ "មហាលោតផ្លោះ" និងដើម្បីការពារបក្សប្រឆាំងនឹងខ្មាំងខាងក្នុង និងខាងក្រៅ ដោយមធ្យោបាយចាំបាច់ណាក៏ដោយ។ ដើម្បីសម្រេចបានគោលបំណងនេះ ពួកគេបានរៀបចំ និងអនុវត្តគោលនយោបាយចំនួនប្រាំ ដែលកាន់តែកើនឡើងនិងរីករាលដាលក្នុងរបបទាំងមូល និងបានបង្កើតប្រព័ន្ធមួយដែលប្រជាជនកម្ពុជាហៅថាជា "គុកឥតជញ្ជាំង"៖

១.ការផ្លាស់ទីលំនៅប្រជាជនជាច្រើនលើកពីទីប្រជុំជន និងទីក្រុងទៅកាន់តំបន់ជនបទ និងរវាងតំបន់ជនបទ។

២. ការបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋាន។

៣. ការអប់រំកសាង "សមាសភាពមិនល្អ" និងការសម្លាប់ "ខ្មាំង" ទាំងខាងក្នុង និងខាងក្រៅជួរបក្ស។

៤. ការកំណត់គោលដៅលើក្រុមជាក់លាក់ និង

៥. បទបញ្ញាស្តីពីការរៀបអាពាហ៍ពិពាហ៍។

ស.ច.ស. បានទទួលយកដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២.១២៣ នាក់ ប៉ុន្តែ បណ្តឹងឧទ្ធរណ៍ចំនួន ៩៤ បានដាក់តំណាងឱ្យអ្នកដាក់ពាក្យសុំចំនួន ១.៧៤៧ នាក់ ដែលត្រូវបានជំទាស់។ នៅខែមិថុនា ឆ្នាំ២០១១ អ.ប.ជ. បានទទួលយកដោយសំឡេងភាគច្រើននូវដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១.៧២៨ នាក់ បន្ថែមទៀត ដោយបានសម្រេចថា ស.ច.ស. គួរណាស់តែទទួលស្គាល់ជនរងគ្រោះទាំងអស់នៃ





ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង អនុលោមតាមគោលនយោបាយទាំងប្រាំនៅទូទាំងប្រទេស។ ចៅក្រម Marchi-Uhel បានជំទាស់ ដោយទទួលស្គាល់តែអ្នកដាក់ពាក្យណាដែលបានបង្ហាញអំពីព្យសនកម្ម ដែលជាវិបាក *ផ្ទាល់*នៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ប៉ុណ្ណោះ។ គាត់ក៏បានពង្រីកការសន្មតអំពីព្យសនកម្មផ្លូវចិត្តទៅលើសាក្សីនៃឧក្រិដ្ឋកម្មទាំងអស់ មិនត្រឹមតែឧក្រិដ្ឋកម្មដែល "មានលក្ខណៈហិង្សារ និងគួរឱ្យតក់ស្លុតខ្លាំង" នោះទេ។ នៅខែកក្កដា ឆ្នាំ២០១១ អ.ប.ជ. បានពិចារណា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងដោយសំឡេងភាគច្រើន បានទទួលយកពាក្យសុំចំនួន ១២ បន្ថែមទៀត។

**តួរលេខសំណុំរឿង ០០២**

**សេចក្តីសម្រេចចំនួន ១.៥៣៥**

**ឯកសារដាក់ដោយភាគីចំនួន ៧.៤២៥ ឯកសារ**

នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ អ.ប.ជ. បានតម្កល់ដីកាដំណោះស្រាយនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា, ខៀវ សំផន និង អៀង សារី ហេតុដូច្នេះ ដីកាដំណោះស្រាយបានបញ្ជូនទៅ អ.ជ.ស.ដ.។ សំអាងហេតុជាលាយលក្ខណ៍អក្សរបានចេញនៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ (ខៀវ សំផន) ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ (អៀង ធីរិទ្ធ, នួន ជា) និង ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ (អៀង សារី)។ ខណៈដែលតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយសំឡេងភាគច្រើន អ.ប.ជ. បានធ្វើការកែប្រែសំខាន់ៗចំនួនពីរ៖ i) តម្រូវឱ្យមានចំណងទាក់ទងជម្លោះប្រដាប់អាវុធសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង ii) លុបចោលការរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតែឯង និងបានកំណត់វាឡើងវិញជាអំពើអមនុស្សធម៌ផ្សេងៗទៀត (អំពើហិង្សារផ្លូវភេទ)។

**ការជំនុំជម្រះ៖** ឆ្លើយតបទៅនឹងអញ្ញត្រកម្មពីជនជាប់ចោទទាំងបួននាក់ និង សហព្រះរាជអាជ្ញា អ.ជ.ស.ដ. - ដោយសំអាងលើហេតុផលផ្សេងពីក្នុងសំណុំរឿង ០០១ - បានសម្រេច ថាខ្លួនមិនត្រូវបានប្តឹងត្រឹមត្រូវអំពីឧក្រិដ្ឋកម្មថ្នាក់ជាតិទេ។ អ.ជ.ស.ដ. បានដកចេញ លក្ខខណ្ឌតម្រូវនៃចំណងទាក់ទងជម្លោះប្រដាប់អាវុធសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយបានបញ្ជាក់ថាទម្រង់ JCE III មិនមែនជាច្បាប់ទំនៀមទម្លាប់អន្តរជាតិទេគិតត្រឹមឆ្នាំ១៩៧៥ និងបានសម្រេចថាមិនមានអាជ្ញាយុកាលសម្រាប់ការចោទប្រកាន់អំពីការបំពារបំពានយ៉ាងធ្ងន់ធ្ងរឡើយ។ អ.ជ.ស.ដ. បានបដិសេធ ការអះអាងរបស់ អៀង សារី ដែលថាការចោទប្រកាន់រូបគាត់នៅ អ.វ.ត.ក. បានរំលោភលើ *គោលការណ៍ស្តីពីគ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* និងពាក្យពេចន៍នៃព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសគាត់ក្នុងឆ្នាំ១៩៩៦។

## សំណុំរឿង ០០២/០១

ដោយសារតែដីកាបញ្ជូនរឿងទៅជំនុំជម្រះទូលំទូលាយពេក នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ អ.ជ.ស.ដ. បានសម្រេច អនុលោមតាមវិធាន ៨៩*ស្ទួនពីរ* បំបែកសំណុំរឿង ០០២ ទៅជាការជំនុំជម្រះតូចជាងនេះ ដោយបង្កើតជាសំណុំរឿង ០០២/០១ ដែលមាន **ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និង ទី២**។ ទោះបីជាសំណើលើកទីមួយរបស់សហព្រះរាជអាជ្ញាមិនបានជោគជ័យនៅក្នុងខែតុលា ឆ្នាំ២០១២ អ.ជ.ស.ដ. បានយល់ព្រម ពង្រីកវិសាលភាពនេះ ដោយបញ្ចូលការសម្លាប់មន្ត្រីរបបសាធារណរដ្ឋខ្មែរនៅ**ទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ** ក្រោយពេលខ្មែរក្រហមបានកាន់កាប់អំណាចនៅខែមេសា ឆ្នាំ១៩៧៥។ នៅខែកុម្ភៈ ឆ្នាំ២០១៣ អ.ជ.ត.ក. បានមោឃភាព ដីកាបំបែកសំណុំរឿងលើកទីមួយ និងបានណែនាំឱ្យបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរ។ ជាការឆ្លើយតប នៅខែមេសា ឆ្នាំ២០១៣ អ.ជ.ស.ដ. ជាថ្មីម្តងទៀត បានបំបែក សំណុំរឿង ០០២ ហើយជាថ្មីម្តងទៀត រួមបញ្ចូល **ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និង ទី២** និង **ទួលពោធិ៍ជ្រៃ** ទៅក្នុងសំណុំរឿង ០០២/០១។ បណ្តឹងសាទុក្ខបន្ថែមទៀតរបស់សហព្រះរាជអាជ្ញា និង នួន ជា មិនជោគជ័យឡើយ និងមិនមានក្រុមប្រឹក្សាជំនុំជម្រះទីពីរត្រូវបានបង្កើតឡើងនោះទេ។

នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១ ពីរបីថ្ងៃមុនការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ បានចាប់ផ្តើម អៀង ធីរិទ្ធ ត្រូវបានរកឃើញថាមិនមានកាយសម្បទានិងបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ដោយសារមានជំងឺវង្វេងវង្វាន់កាន់តែធ្ងន់ធ្ងរ ដែលជាប្រភេទជំងឺភ្លេចភ្លាំងបាត់បង់ការចងចាំ។ ចៅក្រម អ.ជ.ស.ដ. បានបង្គាប់ឱ្យផ្អាកកិច្ចដំណើរការនីតិវិធី និងបង្គាប់ឱ្យមានការដោះលែងដោយឥតលក្ខខណ្ឌ ប៉ុន្តែ អ.ជ.ត.ក. បានច្រានចោលដីកាបង្គាប់នេះ ដោយបានណែនាំ អ.ជ.ស.ដ. ឱ្យផ្តល់ការព្យាបាលបន្ថែមទៀត ដោយមានការពិគ្រោះជាមួយអ្នកជំនាញវេជ្ជសាស្ត្រ។ បន្ទាប់ពី អ.ជ.ស.ដ. គ្រាន់តែបញ្ជាក់ឡើងវិញលើសេចក្តីសន្និដ្ឋានពីមុនរបស់ខ្លួន នៅក្នុង

**តួរលេខសំណុំរឿង**
**០០២ /០១**

**ភ័ស្តុតាងដែលបានទទួលយកចំនួន**
**៥.៨២៤**

**ដើមបណ្តឹងរដ្ឋប្បវេណីចំនួន**
**៣.៨៦៧ នាក់**

**ថ្ងៃសវនាការធ្វើឡើងដោយ អ.ជ.ស.ដ & អ.ជ.ត.ក**
**ចំនួន ២៤៤ ថ្ងៃ**

**សក្ខីកម្មក្នុងតុលាការចំនួន**
**៩៥**

**អ្នកចូលរួមសវនាការចំនួន**
**១១៧.២២២ នាក់**

ខែកញ្ញា ឆ្នាំ២០១២ អ.ជ.ត.ក. បានដាក់លក្ខខណ្ឌ លើការដោះលែង អៀង ធីរិទ្ធ ហើយគាត់បានចេញពីមន្ទីរឃុំឃាំង អ.វ.ត.ក. ដោយស្ថិតក្រោមការត្រួតពិនិត្យរបស់អ្នកឃ្លាំមើលម្នាក់ ដែលតែងតាំងដោយតុលាការក្រុងភ្នំពេញ។ ក្នុងខែធ្នូ ឆ្នាំ២០១២ អ.ជ.ត.ក. បានដាក់ការត្រួតពិនិត្យតាមផ្លូវតុលាការ អ.វ.ត.ក. រួមមានការវាយតម្លៃបែបវេជ្ជសាស្ត្រអៀងរាល់ ៦ ខែម្តង។ អៀង ធីរិទ្ធ ទទួលមរណភាពនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៥។

ការជំនុំជម្រះក្តីជនជាប់ចោទបីនាក់ដែលនៅសល់ បានចាប់ផ្តើមនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ ជាមួយនឹងសេចក្តីសន្និដ្ឋានបើកកិច្ចពិភាក្សាដេញដោល។ នៅថ្ងៃទី២២ និង ២៣ ខែវិច្ឆិកា នួន ជា, អៀង សារី និង ខៀវ សំផន បានធ្វើសេចក្តីថ្លែងរៀងៗខ្លួន។ អ.ជ.ស.ដ. បានស្តាប់សក្ខីកម្មបុគ្គលចំនួន ៩២ នាក់៖ សាក្សី ៥៨ នាក់ (៥៣ នាក់ជាសាក្សីអង្គហេតុ ៥ នាក់ ជាសាក្សីអត្តចរិត) អ្នកជំនាញ ៣ រូប និង ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣១ នាក់។ អ.ជ.ស.ដ. បានទទួលយកចម្លើយចំនួន ១.១២៤ និងប្រតិចារិករបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលមិនបានមកបង្ហាញខ្លួន។ នួន ជា បានឆ្លើយសំណួរចៅក្រម និងភាគី និងបានធ្វើសេចក្តីថ្លែងជាច្រើនអំពីតួនាទីនិងមុខងាររបស់គាត់នៅក្នុង ប.ក.ក. ។ បន្ទាប់ពីឆ្លើយសំណួរពាក់ព័ន្ធនឹងជីវប្រវត្តិ និងការបញ្ចេញយោបល់លើ កថាខណ្ឌជាក់លាក់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះរួចមក ខៀវ សំផន ភាគច្រើននៅស្ងៀម ប៉ុន្តែបានឆ្លើយសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួយ។ អៀង សារី បាននិយាយបញ្ជាក់លើព័ត៌មានជីវប្រវត្តិ។

នៅពេល អៀង សារី ទទួលមរណភាពនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងគាត់ត្រូវបានបញ្ចប់។

ការជំនុំជម្រះបានបញ្ចប់នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ ក្រោយថ្ងៃសវនាការចំនួន ២១៤ ថ្ងៃ។ ភាគីបានដាក់សារណាបិទកិច្ចពិភាក្សាដេញដោលក្នុងខែកញ្ញា ឆ្នាំ២០១៣ និងសេចក្តីសន្និដ្ឋានបិទកិច្ចពិភាក្សាដេញដោលធ្វើឡើងពីថ្ងៃទី១៦ ដល់ ៣១ ខែតុលា ឆ្នាំ២០១៣។ នៅថ្ងៃចុងក្រោយ ខៀវ សំផន និង នួន ជា បានធ្វើសេចក្តីថ្លែងចុងក្រោយរបស់ខ្លួន។



*តុលាការប្រជាជនបដិវត្តន៍ក្នុងទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៧៩*
*© គេហទំព័រ អ.វ.ត.ក*

សាលក្រមបានប្រកាសនៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ដោយសម្រេចថា នួន ជា និង ខៀវ សំផន មានពិរុទ្ធ ជាពិសេសដោយសារការចូលរួមរបស់ពួកគេក្នុង JCE ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយលើប្រជាជនថ្មី និងអតីតមន្ត្រីរបបសាធារណរដ្ឋខ្មែរ និង អំពើអមនុស្សធម៌ផ្សេងៗទៀត (ការជម្លៀសដោយបង្ខំ ការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស និងការបាត់ខ្លួនដោយបង្ខំ)។ អង្គជំនុំជម្រះបាន

រកឃើញថា i) ជាអប្បរមាមានមនុស្សចន្លោះពី ២.៣៣០.០០០ នាក់ ទៅ ២.៤៣០.០០០ នាក់ គឺជាជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងពេល**ផ្លាស់ទីលំនៅប្រជាជនដោយបង្ខំដំណាក់កាលទី១ និង ទី២** ដែលត្រូវបានធ្វើឡើងក្នុងលក្ខខណ្ឌ "ធ្ងន់ធ្ងរ ឥតឈប់ឈរ និងអមនុស្សធម៌" និងអមដោយការធ្វើបាបប្រជាជនថ្មី និងមន្ត្រីរបបសាធារណរដ្ឋខ្មែរ និង ii) ជាអប្បរមាមានអតីតទាហាន និង មន្ត្រីរដ្ឋការស៊ីវិលនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានសម្លាប់នៅ**ទួលពោធិ៍ជ្រៃ** នៅថ្ងៃទី២៥ ឬ ២៦ ខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីត្រូវបានបញ្ជូនមកពីខេត្តពោធិ៍សាត់ ដោយយកលេសថាអប់រំកសាង និងសមាហរណកម្មទៅក្នុងកងទ័ពខ្មែរក្រហម។ អ.ជ.ស.ដ. បានរកឃើញថា មានការប្រព្រឹត្តិដូចៗគ្នាដែលកើតមានឡើងមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែលខ្មែរក្រហម "បានរំដោះ" ទីក្រុងកម្ពុជា ហើយបន្ទាប់មកបានចាប់ខ្លួន សម្លាប់ បាត់ខ្លួន ហើយម្យ៉ាងវិញទៀតបានធ្វើបាបមន្ត្រីរបបសាធារណរដ្ឋខ្មែរ។

***នួន ជា៖*** អ.ជ.ស.ដ. បានរកឃើញថា នួន ជា *ហៅ* "បងទី២" គឺជាបុគ្គលម្នាក់ក្នុងចំណោមស្ថាបនិក ប.ក.ក.។ គាត់បានបម្រើការងារជា**អនុលេខា ប.ក.ក.** ចាប់តាំងពីឆ្នាំ១៩៦០ និងជា **សមាជិកពេញសិទ្ធិនៃគណៈកម្មាធិការអចិន្ត្រៃយ៍ និងមជ្ឈិម** ដែលបានចូលរួមក្នុងការប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ទាំងអស់ដែលមានកំណត់ត្រានៅសេសសល់ផងដែរ។ គាត់កាន់តួនាទីផ្លូវការមួយចំនួននៅក្នុងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងជាប់ពាក់ព័ន្ធខ្លាំងក្នុងកិច្ចការរដ្ឋបាលរបស់របបនោះ។ ចាប់ពីថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ គាត់ទទួលខុសត្រូវ "**ការងារបក្ស សកម្មភាពសង្គម វប្បធម៌ និង អប់រំ**" ដែលអប់រំកសិករ និងសមាជិក ប.ក.ក. រួមបញ្ចូលទាំងការចងកំហឹង និងការប្រុងប្រយ័ត្នចំពោះខ្មាំង។ គាត់ក៏បានគ្រប់គ្រងលើការងារឃោសនាការផងដែរ ដែលតែងនិពន្ធទស្សនាវដ្តីទង់បដិវត្តន៍ និងទស្សនាវដ្តីយុវជន និងយុវនារីបដិវត្តន៍។ ចាប់ពីថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ គាត់គឺជា**ប្រធានសភាតំណាងប្រជាជន** ដែលកម្រកោះប្រជុំណាស់ និងមិនបានអនុម័តច្បាប់ណាមួយឡើយ។ ចាប់ពីខែកញ្ញា ឆ្នាំ១៩៧៦ ដល់ខែកញ្ញា ឆ្នាំ១៩៧៧ នួន ជា គឺជា**នាយករដ្ឋមន្ត្រីស្តីទី** ក្នុងអំឡុងពេលអវត្តមាន ប៉ុល ពត ដោយមូលហេតុសុខភាព។

អ.ជ.ស.ដ. បានសម្រេចថាដោយបានចូលរួមចំណែកក្នុងអំណាចធ្វើការសម្រេចចិត្តចុងក្រោយរបស់បក្ស នួន ជា បានដើរតួនាទីសំខាន់ក្នុងការបង្កើត និងគ្រប់គ្រង JCE។ គាត់គឺជាអ្នកបង្កើតគោលនយោបាយដ៏សំខាន់ ដែលត្រួតពិនិត្យមើលលើរាល់សកម្មភាពរបស់បក្ស ហួសពីការទទួលខុសត្រូវផ្លូវការរបស់គាត់ទៅទៀត។ គាត់បានផ្តួចផ្តើមគំនិត និងបានអនុម័តមាគ៌ារបស់បក្ស ផ្អែកតាមទ្រឹស្តីម៉ាក្ស-លេនីនក្នុងការបង្កើតបដិវត្តន៍កុម្មុយនីស្តតាមរយៈការតស៊ូប្រដាប់អាវុធដែលផ្អែកលើ កសិករដើម្បីដាក់ចេញនូវភាពផ្តាច់ការនៃវណ្ណៈអធន។ គាត់បានបង្កើត និងបានអនុវត្តគោលនយោបាយអប់រំ សេដ្ឋកិច្ច យោធា កសិកម្ម និងសន្តិសុខ រួមទាំងបញ្ហាវិន័យ និងការបោសសម្អាតកម្មាភិបាល ការបែងចែកប្រជាជនជា "វណ្ណៈ" ទៅតាមការគំរាមកំហែងរបស់ពួកគេ និងការគ្រប់គ្រងយ៉ាងតឹងរឹងលើព័ត៌មានតាមគោលការណ៍រក្សាការសម្ងាត់។

នួន ជា គឺជាសមាជិកបក្សដ៏សំខាន់ម្នាក់ ដែលកម្មាភិបាលស៊ីវិល និងយោធាបញ្ជូនរបាយការណ៍ទៅឱ្យ និងជាអ្នកដែលបានផ្តល់ការណែនាំដល់ពួកគេ។ ទោះបីជា អ.ជ.ស.ដ. បានរកឃើញថា នួន ជា មិនស្ថិតនៅក្នុងគណៈកម្មាធិការយោធារបស់គណៈកម្មាធិការមជ្ឈិម គាត់បានចូលរួមយ៉ាងទូលំទូលាយក្នុងបញ្ហាយោធា ដែលបង្កើតគោលនយោបាយយោធាកម្ពុជាប្រជាធិបតេយ្យ និងបានធានា

ឱ្យមានការអនុវត្តគោលនយោបាយនោះ ជាពិសេស ក្នុងពេលសង្គ្រាមប្រឆាំងវៀតណាម។ គាត់បានទទួលអាវុធជាប្រព័ន្ធ បានធ្វើដំណើរទៅប្រទេសចិន និងកូរ៉េខាងជើងយ៉ាងហោចណាស់ម្តង។

ទាក់ទងនឹង**ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១** អ.ជ.ស.ដ. បានផ្អែកលើការទទួលស្គាល់របស់ នួន ជា ដែលថា គាត់បានចូលរួមក្នុងការសម្រេចជម្លៀសក្រុងភ្នំពេញ ដោយបានចូលរួមក្នុងការប្រជុំក្នុងឆ្នាំ១៩៧៤ និង ១៩៧៥ ដើម្បីពិភាក្សាអំពី "ការរំដោះ" និងការជម្លៀសចេញពីទីក្រុង និងក្រោយមកទៀតការរារាំងប្រជាពលរដ្ឋខ្លួនមិនឱ្យត្រឡប់ទៅវិញ។ គាត់បានឃើញប្រជាជនចាកចេញពីក្រុងភ្នំពេញក្នុងស្ថានភាពលំបាក និងបានឃើញសាកសពនៅតាមផ្លូវក្នុងទីក្រុង។ ទាក់ទងនឹង**ទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ** នួន ជា បានលើកកម្ពស់ការកំណត់គោលដៅដ៏ស៊ីចង្វាក់គ្នាលើមន្ត្រីរបបសាធារណរដ្ឋខ្មែរ នៅពេល "រំដោះ" ទីក្រុង និងទីប្រជុំជននានា។ ស្រដៀងគ្នានេះដែរ ចំពោះ**ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២** វិញ គាត់បានអនុម័ត និងបានគាំទ្រការផ្លាស់ទីរវាងតំបន់ជនបទ ក៏ដូចជាលក្ខខណ្ឌរស់នៅដ៏អាក្រក់នៅទូទាំងប្រទេស និងការស្អប់ខ្ពើមប្រជាជនថ្មី។

***ខៀវ សំផន៖*** អ.ជ.ស.ដ. បានរកឃើញថា បន្ទាប់ពីការងារនៅរដ្ឋសភាជាតិកម្ពុជា ខៀវ សំផន បានចាកចេញពីក្រុងភ្នំពេញ ក្នុងឆ្នាំ១៩៦៧ នៅពេលដែលសម្តេច នរោត្តម សីហនុ បានចោទប្រកាន់គាត់ជាសាធារណៈថាបានញុះញង់កសិករឱ្យបះបោរនៅសំឡូត ក្នុងខេត្តបាត់ដំបង។ គាត់បានភៀសខ្លួនទៅកាន់ខេត្តតាកែវ នៅក្រោមការគ្រប់គ្រង និងការការពាររបស់ តាម៉ុក ដែលជាសមាជិកកម្មាធិការអចិន្ត្រៃយ៍ ហើយបានចូលរួមជាមួយ ប.ក.ក. ជាផ្លូវការនៅឆ្នាំ១៩៦៩ ដោយបានក្លាយជា**សមាជិកត្រៀមនៃគណៈកម្មាធិការមជ្ឈិម** ក្នុងឆ្នាំ១៩៧១។ នៅខែមីនា ឆ្នាំ១៩៧០ ក្រោយពេលដែលសម្តេច សីហនុ ត្រូវបានទម្លាក់ចេញពីអំណាចនៅក្នុងរដ្ឋប្រហាររបបសាធារណរដ្ឋខ្មែរ សម្តេច សីហនុ បានដាក់ឈ្មោះ ខៀវ សំផន ជា **អនុប្រធាន FUNK** ដែលជាចលនានយោបាយ និងជា **ឧបនាយករដ្ឋមន្ត្រី** និង ជា**រដ្ឋមន្ត្រីការពារជាតិ** នៅក្នុងរដ្ឋាភិបាលនិរទេស GRUNK។ គាត់បានក្លាយជា **អគ្គមេបញ្ជាការកងទ័ពរំដោះប្រជាជនកម្ពុជា** (CPNLAF) ទោះបីជាជាក់ស្តែង ប៉ុល ពត គឺជាអ្នកដឹកនាំកងកម្លាំង CPNLAF។ ខៀវ សំផន បានទទួលស្គាល់ថា គាត់បានដើរតួនាទីសំខាន់ ទោះបីថាមិនសំខាន់ដាច់ខាតក៏ដោយ ក្នុងទំនាក់ទំនងរវាង ប.ក.ក. និង សម្តេច សីហនុ។ ដោយទទួលបានការគោរពខ្លាំង គាត់ទទួលបានការគាំទ្រ និងភាពស្របច្បាប់សម្រាប់ ប.ក.ក. ចន្លោះឆ្នាំ១៩៧០ និង ១៩៧៥ ដោយបានរៀបចំការឃោសនារបស់ FUNK ធ្វើការបណ្តុះបណ្តាលនយោបាយ និងអំពាវនាវឱ្យមានការតស៊ូបែបហិង្សាប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែរ។

ក្រោយខែមេសា ឆ្នាំ១៩៧៥ រដ្ឋាភិបាល GRUNK របស់សម្តេច សីហនុ បានគ្រប់គ្រងអំណាចជាផ្លូវការ។ ខៀវ សំផន ទទួលបានតួនាទីរដ្ឋាភិបាលរបស់គាត់ និងបានបន្តអនុវត្តមុខងារការទូត។ ក្នុងខែសីហា ឆ្នាំ១៩៧៥ ខៀវ សំផន បានធ្វើដំណើរទៅកាន់ប្រទេសចិន និងកូរ៉េខាងជើង ដើម្បីចរចាដំណើរមាតុភូមិនិវត្តរបស់សម្តេច សីហនុ ហើយនៅដើមឆ្នាំ១៩៧៦ បានអមដំណើរព្រះអង្គក្នុងព្រះរាជទស្សនកិច្ចតំបន់ជនបទនៃប្រទេសកម្ពុជា ដែលក្នុងពេលនោះបានទៅមើលការដ្ឋាន និងបានឃើញពលករដែលត្រូវបង្ខំឱ្យធ្វើការរាប់ពាន់នាក់។ ក្នុងខែតុលា ឆ្នាំ១៩៧៥ ខៀវ សំផន ត្រូវបានតែងតាំងជាសមាជិកម្នាក់ក្នុងចំណោមពីរនាក់របស់**មន្ទីរ ៨៧០** ដែលត្រួតពិនិត្យការអនុវត្តសេចក្តី

សម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍។ នៅខែមីនា ឆ្នាំ១៩៧៦ គាត់ទទួលបានការតែងតាំងជា**សមាជិកនៃគណៈកម្មាធិការត្រួតពិនិត្យការទិញ** និងជា**ប្រធានគណៈកម្មាធិការធនាគារ**។ ក្នុងខែមេសា ឆ្នាំ១៩៧៦ នៅពេលដែលសម្តេច សីហនុ និងសមាជិក GRUNK បានលាឈប់ពីដំណែង ដើម្បីបើកផ្លូវឱ្យបង្កើតរដ្ឋាភិបាលមួយតាមរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន ត្រូវបានតែងតាំងជា **ប្រធាននៃគណៈប្រធានរដ្ឋ** (ប្រមុខរដ្ឋ) និងបានក្លាយជា**សមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិមរបស់ ប.ក.ក.**។ គាត់ក៏ជា**សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍***តាមព្រឹត្តន័យ*ផងដែរ និងបានចូលរួមយ៉ាងសកម្មក្នុងការប្រជុំនានា ដែលធ្វើឱ្យគាត់ស្ថិតក្នុងក្រុមសមាជិកមជ្ឈិមបក្សដ៏តូចមួយដែលមានអំណាចពេញលេញ និងទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ។ គាត់ដឹកនាំវគ្គបណ្តុះបណ្តាលសម្រាប់មេដឹកនាំជាន់ខ្ពស់ ប.ក.ក./កម្ពុជាប្រជាធិបតេយ្យផ្សេងទៀត មេបញ្ជាការយោធា និងភូមិភាគ និងមន្ត្រីថ្នាក់តំបន់ ដែលរួមបញ្ចូលទាំងការកំណត់អត្តសញ្ញាណ និងការលុបបំបាត់ខ្មាំង ការបង្កើតសហករណ៍ និងការដ្ឋាន និងការបំពេញផែនការការងារ។

អ.ជ.ស.ដ. បានរកឃើញថាតាមរដ្ឋធម្មនុញ្ញ ក្នុងឋានៈជាប្រមុខរដ្ឋ ខៀវ សំផន មិនមានអំណាចប្រតិបត្តិផ្លូវការទេ ប៉ុន្តែបានបន្តការពាររបបនោះតាមរយៈការបំពេញមុខងាររបស់គាត់ខាងការទូត និងពិធីការផ្សេងៗ និងតាមរយៈការគាំទ្រគោលនយោបាយ និងភាពជោគជ័យរបស់ ប.ក.ក.។

ទាក់ទងនឹង**ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១** និង**ទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ** អ.ជ.ស.ដ. សម្រេចថា ខៀវ ខំផន បានរស់នៅ និងធ្វើការនៅជិតមេដឹកនាំជាន់ខ្ពស់ផ្សេងទៀត នៅពេលដែលពួកគេបង្កើត និងអនុវត្តគោលនយោបាយជម្លៀសទីក្រុង និងទីប្រជុំជននានា រួមទាំងទីក្រុងភ្នំពេញ និងកំណត់គោលដៅលើមន្ត្រីរបបសាធារណរដ្ឋខ្មែរ។ ទាក់ទងនឹង**ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២** អ.ជ.ស.ដ. បានរកឃើញថា ខៀវ សំផន បានដឹងថា លក្ខខណ្ឌរស់នៅក្នុងប្រទេសទាំងមូលមានលក្ខណៈអាក្រក់ខ្លាំង ដោយសារតែកង្វះអាហារ និង ជំងឺ។ ទោះជាយ៉ាងណា មេដឹកនាំបក្ស រួមទាំង ខៀវ សំផន បានរៀបផែនការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ ដោយមិនមានការយល់ព្រម និងមិនបានផ្តល់ជំនួយសុខាភិបាលដល់អ្នកដែលត្រូវបានជម្លៀសឡើយ។

អ.ជ.ស.ដ. បានកាត់ទោសជនជាប់ចោទទាំងពីររូបដាក់ពន្ធនាគារមួយជីវិត ដោយពិចារណាលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានរៀបរាប់ដោយជនរងគ្រោះជាច្រើននាក់ ក៏ដូចជាវិសាលភាពភូមិសាស្ត្រនិងពេលវេលាដ៏ធំធេងនៃការធ្វើឱ្យរងគ្រោះ និងផលប៉ះពាល់ធ្ងន់ធ្ងរ និងយូរអង្វែងលើជនរងគ្រោះ និងសាច់ញាតិរបស់ពួកគេ។

បន្ទាប់ពីការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ ក្រុមបញ្ចូលគ្នាមានភាគីដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣.៨៦៧ នាក់។ អ.ជ.ស.ដ. បានទទួលយកសំណើ ១១ ក្នុងចំណោមសំណើសុំចំនួន ១៣ របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ដែលស្នើសុំសំណងសម្ងហភាព និងផ្លូវចិត្ត ដែលរួមមានការចងចាំជនរងគ្រោះ ជំនួយផ្លូវចិត្ត និងការអប់រំ។ ទាំងនេះគឺ i) ទិវាជាតិនៃការចងចាំ (២០ ឧសភា) ii)គម្រោងសាងសង់បូជនីដ្ឋានសាធារណៈនៅភ្នំពេញដើម្បីរម្លឹកវិញ្ញាណក្ខន្ធជនរងគ្រោះដោយការជម្លៀសដោយបង្ខំនៅភ្នំពេញ iii & iv) ការព្យាបាលតាមរបៀបការចងក្រងជាសក្ខីកម្ម និងការបង្កើតក្រុមជួយខ្លួនឯង v & vi) គម្រោងពិព័រណ៍ និងការអប់រំ vii) ការបញ្ចូលការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ និងទីតាំង

សម្លាប់មនុស្សទួលពោធិ៍ជ្រៃ ទៅក្នុងកម្មវិធីអប់រំតាមសាលារៀនរបស់កម្ពុជា viii) ការសាងសង់មជ្ឈមណ្ឌលសិក្សាសន្តិភាព ix) ការបោះពុម្ពកូនសៀវភៅស្តីពីអង្គហេតុ ក្នុងសំណុំរឿង ០០២/០១ និងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី និង x & xi) ការបោះពុម្ព និងចែកចាយសាលក្រមសង្ខេប និងពេញលេញនៃសំណុំរឿង០០២/០១។

**បណ្តឹងសាទុក្ខ៖** នៅខែវិច្ឆិកា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញា បានប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់ អ.ជ.ស.ដ. ដែលច្រានចោល JCE III ថាមិនមែនជាទម្រង់មួយនៃការទទួលខុសត្រូវ។ នួន ជា និង ខៀវ សំផន បានដាក់សារណានៃបណ្តឹងសាទុក្ខរបស់ពួកគេនៅខែធ្នូ ឆ្នាំ២០១៤ ដោយមានទឡ្ហីករណ៍ ២២៣ និង ១៤៨ រៀងៗខ្លួន ដោយអះអាងថា កំហុសអង្គហេតុ និងអង្គច្បាប់នាំឱ្យមានការដោះលែងពួកគេឱ្យរួចខ្លួន។ នៅខែមករា ឆ្នាំ២០១៥ នួន ជា និង ខៀវ សំផន បានឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។ សហព្រះរាជអាជ្ញា បានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងសាទុក្ខរបស់ជនជាប់ចោទនៅខែមេសា ឆ្នាំ២០១៥ ហើយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់ចម្លើយតបរបស់ពួកគាត់នៅថ្ងៃទី២៥ ខែឧសភា។ តាមសំណើរបស់ នួន ជា អ.ជ.ត.ក. បានសម្រេចកោះហៅសាក្សី ៣ នាក់ មកបំភ្លឺនៅក្នុងខែកក្កដា ឆ្នាំ២០១៥។

សវនាការលើបណ្តឹងសាទុក្ខបានបើកធ្វើឡើងនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥។ ប៉ុន្តែដោយសារមិនមានតំណាងផ្លូវច្បាប់របស់ នួន ជា ទើបសវនាការត្រូវបានពន្យារពេលរហូតដល់ខែកុម្ភៈ ឆ្នាំ២០១៦។ អង្គជំនុំជម្រះបានដាក់ទណ្ឌកម្មលើសហមេធាវីជាតិរបស់ នួន ជា ចំពោះកំហុសវិជ្ជាជីវៈ និងបានណែនាំឱ្យអង្គភាពគាំពារការការពារក្តី តែងតាំងមេធាវីការពារក្តីប្រចាំការ។

ចៅក្រម អ.ជ.ត.ក. បានចេញសាលដីការបស់ខ្លួននៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ដោយតម្កល់ទោសជាច្រើន ប៉ុន្តែបានទាត់ចោលការសម្លាប់រង្គាលថាមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងអំឡុងនៃ **ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និង ទី២** និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ (លើប្រជាជនថ្មី) ក្នុងអំឡុងនៃ **ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២**។ អ.ជ.ត.ក. បានទាត់ចោលការកាត់ទោសទាំងអស់ទាក់ទងនឹង **ទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ** ដោយពួកគាត់បានសម្រេចថា ពុំមានគោលនយោបាយដែលផ្តោតគោលដៅទៅលើមន្ត្រីសាធារណរដ្ឋខ្មែរឡើយគិតត្រឹមខែមេសា ឆ្នាំ១៩៧៥។ អ.ជ.ត.ក. បានរកឃើញថា បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាមិនអាចទទួលយកបាន ប៉ុន្តែដូចបានពន្យល់នៅក្នុងផ្នែក *ករណីយុត្តិសាស្ត្រ* ពួកគាត់បានសម្រេចដោយឡែកថា JCE III មិនមានការទទួលស្គាល់ទេក្នុងឆ្នាំ១៩៧៥។ អ.ជ.ត.ក. បានតម្កល់ទោសជាប់ពន្ធនាគារមួយជីវិត។

## សំណុំរឿង ០០២/០២

នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ អ.ជ.ត.ក. បានបង្គាប់ថា ដើម្បីធានាថា បទចោទនៅក្នុងសំណុំរឿង០០២/០១ និង ០០២/០២ តំណាងសមស្របឱ្យដីកាដំណោះស្រាយនៃសំណុំរឿង០០២ សំណុំរឿង០០២/០២ ត្រូវតែមានយ៉ាងហោចណាស់មន្ទីរសន្តិសុខស-២១ ការដ្ឋានមួយ សហករណ៍មួយ និងអំពើប្រល័យពូជសាសន៍។ នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤ អ.ជ.ស.ដ. បានបង្គាប់ថា សំណុំរឿង០០២/០២ ត្រូវមាន: **មន្ទីរសន្តិសុខស-២១ ការដ្ឋានទំនប់ ១ មករា សហករណ៍ត្រាំកក់** អំពើប្រល័យពូជសាសន៍ (**ជនជាតិវៀតណាម** និង

ប្រជាជន**ចាម) មន្ទីរសន្តិសុខក្រាំងតាចាន់ ទីតាំងការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង មន្ទីរសន្តិសុខអូរកន្សែង មន្ទីរសន្តិសុខភ្នំក្រោល ការដ្ឋានទំនប់អាងត្រពាំងថ្ម និងអាពាហ៍ពិពាហ៍ដោយបង្ខំ** ហើយនឹង **អំពើរំលោភសេពសន្ថវៈ** នៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ នៅទូទាំងប្រទេស។ អ.ជ.ស.ដ. បានបំភ្លឺថា ភ័ស្តុតាងដែលបានទទួលយកនៅក្នុងសំណុំរឿង០០២/០១ គឺជាផ្នែកមួយនៃសំណុំរឿង០០២/០២ ប៉ុន្តែថា គូភាគីនឹងមានឱកាសធ្វើតេស្ត និងតវ៉ាចំពោះភ័ស្តុតាងទាំងនោះទាន់នៅថ្មីៗ។ ការសម្រេចផ្នែកអង្គហេតុ និងអង្គច្បាប់នៅក្នុងសំណុំរឿង០០២/០១ មិនធ្វើឱ្យ អ.ជ.ស.ដ. ជាប់កាតព្វកិច្ចណាមួយទេ និងអាចកំណត់ជាថ្មីបាន។ នៅខែកុម្ភៈ ឆ្នាំ២០១៧ អ.ជ.ស.ដ. បានអនុញ្ញាតតាមសំណើរបស់សហព្រះរាជអាជ្ញា និងបានរំលត់កិច្ចដំណើរការនីតិវិធីលើអង្គហេតុដែលនៅសេសសល់ទាំងអស់ដែលមិនមាននៅក្នុងសំណុំរឿង០០២/០១ ឬ ០០២/០២។

សវនាការជំនុំជម្រះសំណុំរឿង០០២/០២ បានចាប់ផ្តើមនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ នៅពេលដែល នួន ជា បានធ្វើសេចក្តីថ្លែងបើកកិច្ចពិភាក្សាដេញដោលជាថ្មី។ ទោះជាយ៉ាងណា មេធាវីការពារក្តី ខៀវ សំផន បានអវត្តមាននៅទូទាំងដំណើរការជំនុំជម្រះដែលនៅសេសសល់ក្នុងឆ្នាំ២០១៤ ទាំងមូល ដែលការណ៍នេះចាំបាច់ត្រូវពន្យារពេលកិច្ចដំណើរការនីតិវិធី និងការតែងតាំងមេធាវីការពារក្តីប្រចាំការ។ សវនាការលើភ័ស្តុតាងបានចាប់ផ្តើមនៅថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ និងបានបញ្ចប់នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧ ក្រោយរយៈពេល ២៧៤ ថ្ងៃនៃថ្ងៃសវនាការ។ បុគ្គលចំនួន ១៨៥ នាក់ បានមកផ្តល់សក្ខីកម្ម ដែលក្នុងនោះរួមមាន ១១៤ នាក់ជាសាក្សី ៦៣ នាក់ជាភាគីដើមបណ្តឹងរដ្ឋប្បវេណី និង ៨ នាក់ ជាអ្នកជំនាញ។ នៅខែឧសភា ឆ្នាំ២០១៧ គូភាគីបានដាក់សារណាបិទកិច្ចពិភាក្សាដេញដោល សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់សំណើទាមទារសំណងរបស់ខ្លួន ហើយសេចក្តីថ្លែងបិទកិច្ចពិភាក្សាដេញដោលក៏បានធ្វើឡើងនៅក្នុងខែមិថុនា ឆ្នាំ២០១៧។ នួន ជា រក្សាសិទ្ធិនៅស្ងៀមមិននិយាយស្តីដោយមានករណីលើកលែងមានព្រំដែនកំណត់ គឺមានតែ ខៀវ សំផន ម្នាក់ប៉ុណ្ណោះដែលបានធ្វើសេចក្តីថ្លែងស្តាពរ។

អ.ជ.ស.ដ. បានប្រកាសសាលក្រមកាត់ទោសរបស់ខ្លួននៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ២០១៨ ដោយផ្តល់សេចក្តីសម្រេចផ្ទាល់មាត់ដោយសង្ខេប និងផ្នែកសម្រេចសេចក្តី។ បីថ្ងៃក្រោយមក ខៀវ សំផន បានប្តឹងសាទុក្ខសុំឱ្យ អ.ជ.ត.ក. ទុកជាមោឃៈសាលក្រមរបស់ អ.ជ.ស.ដ. ដោយសារមិនបានផ្តល់សំអាងហេតុជាលាយលក្ខណ៍អក្សរ និងឱ្យប្រកាសទុក្ខជាមោឃៈនូវសាលក្រមជាលាយលក្ខណ៍អក្សរអនាគតណាមួយដែលមាន។ អ.ជ.ត.ក. បានសម្រេចថា បណ្តឹងសាទុក្ខនេះមិនអាចទទួលយកបានទេ ដោយសារមិនមាន "កាលៈទេសៈចាប់បង្ខំដែលនាំឱ្យអង្គជំនុំជម្រះមិនអាចចេញសាលក្រមជាលាយលក្ខណ៍អក្សរដែលមានសំអាងហេតុពេញលេញ និងជាចុងក្រោយនៅលើអង្គសេចក្តី" នោះឡើយ។

**ចូរលេខសំណុំរឿង**
**០០២ /០២**

**ភ័ស្តុតាងដែលបានទទួលយកចំនួន**
**១០.៨០៤**

**ដើមបណ្តឹងរដ្ឋប្បវេណីចំនួន**
**៣.៨៦៥ នាក់**

**ថ្ងៃសវនាការធ្វើឡើងដោយ អ.ជ.ស.ដ & អ.ជ.ត.ក**
**ចំនួន ២៩៧ ថ្ងៃ**

**សក្ខីកម្មក្នុងតុលាការចំនួន**
**១៨៥**

**អ្នកចូលរួមសវនាការចំនួន**
**៨៥.០៦៤ នាក់**

សាលក្រមជាលាយលក្ខណ៍អក្សរជាភាសាខ្មែរមានចំនួន ៣៨៨៣ ទំព័រ (ភាសាអង់គ្លេសចំនួន ២២៦៨ ទំព័រ) ដែលបានចេញនៅពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ ដោយរកឃើញថា ឧក្រិដ្ឋកម្មទាំងឡាយដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ បង្កើតបានជាផ្នែកនៃទម្រង់ស៊ីចង្វាក់គ្នានៃអំពើដែលបានប្រព្រឹត្តនៅទូទាំងកម្ពុជា តាំងពីមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នោះ អ.ជ.ស.ដ. បានកាត់ទោសជនជាប់ចោទទាំងពីររូប ហើយជាថ្មីម្តងទៀត គឺដោយសារការចូលរួមប្រព្រឹត្តិរបស់ពួកគេនៅក្នុង JCE មួយនៃ i) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ សាសនា និងពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ការបាត់ខ្លួនដោយបង្ខំ ការផ្លាស់ទីលំនៅដោយបង្ខំ អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈជនរងគ្រោះជាស្ត្រីនៃអាពាហ៍ពិពាហ៍ដោយបង្ខំ) ii) អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ (ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់) និង iii) អំពើប្រល័យពូជសាសន៍លើក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ វៀតណាម។ អ.ជ.ស.ដ. បានកាត់ទោស នួន ជា បន្ថែមទៀតចំពោះអំពើប្រល័យពូជសាសន៍លើក្រុមជាតិពន្ធុ និងសាសនាចាម នៅក្រោមទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ។

អ.ជ.ស.ដ. បានរកឃើញថា អត្ថិភាពនៃគោលនយោបាយឧក្រិដ្ឋដែលបានចោទប្រកាន់ គឺបានកើតឡើងពិតប្រាកដមែន ហើយ នួន ជា និង ខៀវ សំផន មានចំណែកនៅក្នុងគោលបំណងឧក្រិដ្ឋកម្មរួមនេះ៖ ការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងអំពើប្រល័យពូជសាសន៍ដែលមានលក្ខណៈរីករាលដាល គឺជាការរំពឹងទុកតែមួយគត់ដែលសមហេតុផល នៅក្នុងប្រព័ន្ធទូទាំងប្រទេសនៃការបង្កើត សហករណ៍ ការដ្ឋាន បទបញ្ញាស្តីពីការរៀបអាពាហ៍ពិពាហ៍ និងមន្ទីរសន្តិសុខ ដែលបានបិទបាំងនៅក្នុងការឃោសនាអំពីការសម្អាត ការប្រុងប្រយ័ត្នខ្ពស់ និងកំហឹងប្រឆាំងខ្មាំង ហើយដែលបានដឹកនាំដោយពួកវណ្ណៈកាន់អំណាចថ្មីមួយដែលមានកម្រិតអប់រំផ្លូវការណ៍ទាបបំផុត។

***នួន ជា៖*** ដោយបានធ្វើសេចក្តីសម្រេចស្រដៀងគ្នាអំពីតួនាទី និងការទទួលខុសត្រូវរបស់ នួន ជា (សូមមើលខាងលើ) អ.ជ.ស.ដ. បានរកឃើញថា គាត់គឺជាបុគ្គលដ៏សំខាន់ម្នាក់ក្នុងការបង្កើតគោលនយោបាយទាក់ទងនឹងការបង្កើត និងដំណើរការសហករណ៍ ការដ្ឋាន និងមន្ទីរសន្តិសុខ។ គាត់បានចុះទៅពិនិត្យ **ការដ្ឋានទំនប់ ១ មករា** លើសពីមួយលើក និងបានឃើញផ្ទាល់ភ្នែកនូវភាពលំបាកវេទនារបស់កម្មករ។ នួន ជា បានបញ្ជា និងអនុវត្តការបោសសម្អាតយ៉ាងធំមួយ រួមទាំងការបោសសម្អាតដ៏ធំនៅ**ភូមិភាគពាយ័ព្យ ភូមិភាគកណ្តាល និង ភូមិភាគបូព៌ា**។ គាត់បានពាក់ព័ន្ធដោយផ្ទាល់ក្នុងការគ្រប់គ្រង**មន្ទីរសន្តិសុខស-២១** តាំងពីមុនពេលគាត់បានធ្វើជាមេផ្ទាល់របស់ ឌុច នៅក្នុងខែសីហា ឆ្នាំ១៩៧៧ មកម្ល៉េះ ដោយគាត់ទទួលចម្លើយសារភាព និងបញ្ជាលើការសួរចម្លើយអ្នកទោសជាក់លាក់ខ្លះ ព្រមទាំងការដក និងការថតរូបសាកសពអ្នកទោសដែលបានសម្លាប់។ គណៈកម្មាធិការអចិន្ត្រៃយ៍ដែល នួន ជា ជាសមាជិកម្នាក់ផងនោះ បានចេញបញ្ជាឱ្យសម្លាប់អ្នកទោសនៅកន្លែងផ្សេងទៀត រួមទាំងអ្នកទោសជាង ១០០ នាក់ ជាជនជាតិថារាយនៅ **មន្ទីរសន្តិសុខអូរកន្សែង**។

អ.ជ.ស.ដ. បានរកឃើញថា នួន ជា គឺជាមនុស្សដ៏សំខាន់នៅក្នុងការបង្កើត និងផ្សព្វផ្សាយគោលនយោបាយកំណត់គោលដៅ**ជនជាតិវៀតណាម ពុទ្ធសាសនិកជន មន្ត្រីសាធារណរដ្ឋខ្មែរ** និង **ចាម**។ ឧទាហរណ៍ គាត់បានបញ្ជាឱ្យ ឌុច សួរចម្លើយអ្នកទោសវៀតណាម ធ្វើកំណត់ហេតុចម្លើយសារភាពរបស់ពួកគេ និងផ្សព្វផ្សាយចម្លើយសារភាពទាំងនោះតាមវិទ្យុផ្សាយសំឡេង ដែលបន្ទាប់មកគេយកទៅប្រើក្នុងការបោះពុម្ពផ្សេងៗ និងនៅក្នុងសកម្មភាពឃោសនារបស់កម្ពុជាប្រជាធិបតេយ្យ។ ទោះបី អ.ជ.ស.ដ. មិនជឿថា នួន ជា បានដឹងថា ការសម្លាប់**ចាម** បានប្រព្រឹត្តឡើងក្នុងចេតនាដើម្បីបំផ្លាញក្រុមនេះយ៉ាងដូច្នេះក្តី តែ អ.ជ.ស.ដ. ជឿថា នួន ជា បានដឹងថា ការប្រព្រឹត្តិបានកើតឡើងមែន ប៉ុន្តែគាត់ខកខានមិនបានចាត់វិធានការ។

អ.ជ.ស.ដ. បានច្រានចោលអំណះអំណាងរបស់ នួន ជា ដែលថា ឧក្រិដ្ឋកម្មទាំងនោះមានយុត្តិកម្ម ដោយសារស្ថានភាពអាសន្នដែលកើតមានជាប្រចាំ ដែលបញ្ឆេះដោយអត្ថិភាពនៃការគំរាមកំហែងរបស់វៀតណាម ចំពោះសន្តិសុខជាតិ និងអធិបតេយ្យភាពរបស់កម្ពុជាប្រជាធិបតេយ្យ តាមរយៈការបញ្ជ្រាបចូលមកក្នុងជួរកងទ័ពរបស់ ប.ក.ក. និងការប៉ុនប៉ងរដ្ឋប្រហារចាប់ពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៨។ អ.ជ.ស.ដ. បានធ្វើការវិភាគទៅលើរដ្ឋប្រហារដូចដែលគេបានអះអាងនោះ តែរកមិនឃើញនូវភ័ស្តុតាងគួរឱ្យជឿជាក់បានណាមួយដែលថា វាបានកើតឡើងនោះទេ៖ ព្រឹត្តិការណ៍ "ដែលមិនស៊ីចង្វាក់គ្នា" របស់មេធាវីនោះ គឺបានពឹងផ្អែកទាំងស្រុងលើភ័ស្តុតាងមិនត្រឹមត្រូវដែលទទួលបានដោយការធ្វើទារុណកម្ម និងថា ពុំមានសញ្ញាបង្ហាញថា វៀតណាមបានគាំទ្រក្រុមផ្ទៃក្នុងនៅភូមិភាគបូព៌ា និងភូមិភាគពាយ័ព្យ ឡើយ។ ទោះជារដ្ឋប្រហារ*បាន*កើតឡើងក៏ដោយ ក៏ពួកគេមិនអាចយកលេសនៃការដាក់ក្នុងមន្ទីរឃុំឃាំងដោយគ្មានដំណើរការច្បាប់ត្រឹមត្រូវ ការធ្វើទារុណកម្ម និងការសម្លាប់ដោយខុសច្បាប់ចំពោះខ្មាំងវៀតណាម និងជនក្បត់កម្ពុជាដូចដែលពួកគេចោទប្រកាន់នោះទេ។

***ខៀវ សំផន៖*** ក្រោយពីមានការសម្រេចស្រដៀងគ្នាទាក់ទងនឹងតួនាទី និងការទទួលខុសត្រូវរបស់គាត់ (សូមមើលខាងលើ) អ.ជ.ស.ដ. ជាថ្មីម្តងទៀត បានទាត់ចោលអំណះអំណាងរបស់ ខៀវ សំផន ដែលថា គាត់មិនបានដឹង មិនបានឃើញ និងមិនបានឮអ្វីទាំងអស់ ហើយក៏មិនមែនជាផ្នែកនៃក្រុមអ្នកធ្វើសេចក្តីសម្រេចចិត្តកម្រិតខ្ពស់នោះដែរ។ មុនខែមេសា ឆ្នាំ១៩៧៥ គោលនយោបាយឧក្រិដ្ឋទាំងប៉ុន្មាន រួមទាំងគោលនយោបាយសមូហភាវូបនីយកម្មដោយបង្ខំ ការសម្លាប់គូប្រឆាំងនយោបាយ ការបោសសម្អាតរបស់ ប.ក.ក. និងបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍ ជាដើម គឺសុទ្ធតែមានផែនការ និងបានអនុវត្តនៅក្នុង "តំបន់រំដោះ"ទាំងអស់ និងមានភ័ស្តុតាងបញ្ជាក់ថា គាត់គឺជាមេដឹកនាំ ប.ក.ក. ម្នាក់ដ៏លេចធ្លោ។ នៅទូទាំងកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន បានរស់នៅ និងធ្វើការជាមួយមេដឹកនាំជាន់ខ្ពស់ដទៃទៀត បានចូលរួមប្រជុំជាមួយគណៈកម្មាធិការអចិន្ត្រៃយ៍ជាកិច្ចប្រជុំដែលសេចក្តីសម្រេចសំខាន់ៗត្រូវបានធ្វើឡើង និងបានធ្វើដំណើរនៅក្នុងប្រទេសកម្ពុជាដោយបានឃើញលក្ខខណ្ឌនៃភាពរងទុក្ខវេទនាទាំងអម្បាលម៉ាន។ គាត់បានទទួលសារាចរណ៍ណែនាំឯកសារគោលនយោបាយ និងទស្សនាវដ្តី*ទង់បដិវត្តន៍* របស់ ប.ក.ក. ដោយនៅក្នុងឯកសារទាំងនេះហើយដែលបានលើកយកមកពិភាក្សាអំពីការអនុវត្តគោលនយោបាយទាំងនោះ។ គាត់បានទទួលស្គាល់ថា គាត់បានឃើញការចាប់ខ្លួនសមាជិកគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ ព្រមទាំងបានថ្លែងជាសាធារណៈថា បក្សបានធ្វើឱ្យ "ពួកគិញឃ្លួន" ចាញ់ហើយ ដោយបានទទួលស្គាល់ថា មានខ្លះត្រូវបានសម្លាប់ក្រៅច្បាប់ទៀតផង។

អ.ជ.ស.ដ. បានរកឃើញថា ខៀវ សំផន បានញុះញង់ឱ្យមានគោលនយោបាយរបស់ ប.ក.ក. និងបានការពាររបបនេះមិនឱ្យមានការពិនិត្យពិច័យ ដូចបានពិភាក្សាខាងលើ។ ក្នុងនាមជាសមាជិកមួយរូបនៃមន្ទីរ៨៧០ និងជាអ្នកគ្រប់គ្រងសេដ្ឋកិច្ច និងពាណិជ្ជកម្មរបស់កម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន បានផ្ដល់លទ្ធភាពនាំឱ្យមានការប្រព្រឹត្តិទៅនៃរដ្ឋបាលកម្ពុជាប្រជាធិបតេយ្យដែលជាការបំផ្លិចបំផ្លាញដល់ប្រជាជនរបស់ខ្លួនឯង៖ ខណៈដែលកម្មករបានទទួលរងនូវទុក្ខវេទនាដោយសារតែលក្ខខណ្ឌជាប់កាតព្វកិច្ចនៃការបង្កបង្កើនផលស្រូវ និងកង្វះអាហារ គាត់បែរជាបានធានាថា សហករណ៍គឺជាអ្នកប្រមូលផលស្រូវជាសម្ភហភាព សម្រាប់ការនាំចេញទៅវិញ។ តាមសេចក្ដីថ្លែងការណ៍ផ្សេងៗ ខៀវ សំផន បានកំណត់**ជនជាតិវៀតណាម**សម្រាប់ការប្រព្រឹត្តដោយរើសអើង តាមរយៈការទទូចឱ្យប្រជាជនកម្ពុជាប្រជាធិបតេយ្យ "ស្ទបយួនកាន់តែខ្លាំងពីមួយថ្ងៃទៅមួយថ្ងៃ" និងបានស្នើឱ្យ "កម្ទេចពួកគេចោលជារៀងរហូត"។ គាត់ក៏ជាអ្នកញុះញង់ឱ្យមានការកម្ទេចសមាជិករដ្ឋបាល**សាធារណរដ្ឋខ្មែរ** ផងដែរ។ គាត់បានណែនាំក្រសួងទាំងអស់ឱ្យរៀបចំ**ការរៀបការ** និងជំរុញគោលនយោបាយបង្កើនចំនួនប្រជាជនឆាប់រហ័ស។ អ.ជ.ស.ដ. បានរកឃើញថាទោះបី ខៀវ សំផន បានដឹងអំពីឧក្រិដ្ឋកម្មទាំងប៉ុន្មានប្រឆាំងនឹង**ចាម** ដែលជាផ្នែកមួយនៃគោលនយោបាយដើម្បីបង្កើតសង្គមខ្មែរតែមួយដែលគ្មានជំនឿសាសនា តែគេមិនមានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីបញ្ជាក់ថា គាត់មានចេតនាបំផ្លាញក្រុមនេះយ៉ាងដូច្នេះទេ ហើយក៏បានលើកលែងការចោទប្រកាន់ប្រឆាំងនឹងគាត់ពីបទអំពើប្រល័យពូជសាសន៍។

អ.ជ.ស.ដ. បានទទួលយកសំណើរួមចំនួន ៣៨៦៥ របស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានស្នើសុំសម្រាប់សំណងមួយផ្នែក។ គម្រោងនានាត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីធានាមិនឱ្យកើតឡើងវិញនៃឧក្រិដ្ឋកម្មបែបនេះ រួមមាន៖ i) ការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម តាមរយៈការបណ្ដុះបណ្ដាលគ្រូបង្រៀននិងសាស្ត្រាចារ្យសាកលវិទ្យាល័យ និងការរៀនតាម App ii) គម្រោងអណ្ដើកក្លាហាន ជាគម្រោងអន្តរព័ត៌មាន ដែលលើកកម្ពស់ការយល់ដឹងអំពីប្រវត្តិសាស្ត្រ និងភាពក្លាហានរបស់ដើមបណ្ដឹងរដ្ឋប្បវេណី iii) គម្រោងប្រព័ន្ធផ្សព្វផ្សាយសហគមន៍៖ ប្រជាជនចាម និងខ្មែរក្រហម iv) ផ្កាស្លាក្រោមអង្គការ ជាគម្រោងរបាំដែលចងក្រងនូវអាពាហ៍ពិពាហ៍ដោយបង្ខំ និង v) សំឡេងពីជនជាតិភាគតិច៖ ការលើកកម្ពស់ការយល់ដឹងអំពីការប្រព្រឹត្តិចំពោះអាណិកជនវៀតណាម និងចាម។ គម្រោងផ្សេងទៀតដែលបម្រើឱ្យការធ្វើសម្បទាឡើងវិញ រួមមាន សុខុមាលភាពផ្នែកសុខភាព និងផ្លូវចិត្ត និងការកាត់បន្ថយភាពក្រីក្រ និងការបដិសេធការចូលរួមក្នុងសង្គមនៃដើមបណ្ដឹងរដ្ឋប្បវេណី។ គម្រោងបំពេញចិត្តនានា រួមមាន i) ការបោះពុម្ពរឿងរ៉ាវមិនធ្លាប់បានគេដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលជាសៀវភៅមួយក្បាលសរសេរអំពីរឿងរ៉ាវរបស់ដើមបណ្ដឹងរដ្ឋប្បវេណីជាង៣០ ដែលពួកគាត់មិនបានមកផ្ដល់សក្ខីកម្មនៅ អ.វ.ត.ក. ii) ផ្ទាំងគំនូដើម្បីការចងចាំអំពីក្រាំងតាចាន់ និង iii) ការចូលមើលជាសាធារណៈ និងឥតគិតថ្លៃនូវកំណត់ត្រាតុលាការ និងសម្ភាររបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹង អ.វ.ត.ក.។

ដោយសារស្ថានទម្ងន់ ទំហំ និងភាពឃោរឃៅនៃបទឧក្រិដ្ឋទាំងនេះ ព្រមទាំងចំនួន និងភាពងាយរងគ្រោះរបស់ជនរងគ្រោះ អ.ជ.ស.ដ. បានកាត់ទោស នួន ជា និង ខៀវ សំផន ឱ្យជាប់ពន្ធនាគារមួយជីវិត។ ចៅក្រម បានបញ្ចូលទោសក្នុងសំណុំរឿង ០០២/០១ និង ០០២/០២ ទៅជាទោសជាប់ពន្ធនាគារមួយជីវិតតែមួយ។

នួន ជា បានស្លាប់នៅក្រោយនោះបន្តិច គឺនៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៩ ហើយ អ.ជ.ត.ក. ក៏បានបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងគាត់នៅក្នុងខែដដែលនោះ។ អ.ជ.ត.ក. បានបញ្ជាក់អះអាងថា ការណ៍នេះមិនបានធ្វើឱ្យសាលក្រមសាលាដំបូងទៅជាមោឃភាពទេ បើទោះជាមរណភាពរបស់គាត់បានរារាំងដល់ដំណើរការពិនិត្យលើបណ្តឹងសាទុក្ខក៏ដោយ ក៏សច្ចធារណ៍នៃនិរទោសមិនស្មើនឹងការដោះលែងឱ្យរួចខ្លួនក្រោយមរណភាពនោះដែរ ហើយសំណងខូចខាតរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនប៉ះពាល់ឡើយ។

**បណ្តឹងសាទុក្ខ៖** សហព្រះរាជអាជ្ញាបានប្តឹងសាទុក្ខប្រឆាំងនឹងការច្រានចោលជនរងគ្រោះជាបុរសនៃការរួមភេទដោយបង្ខំ ពីការកាត់ទោសនេះ។ បណ្តឹងសាទុក្ខរបស់ ខៀវ សំផន មានមូលដ្ឋានចំនួន ២៥៦ ដែលចោទប្រកាន់ទាំងកំហុសអង្គច្បាប់ និងអង្គហេតុ ហើយសហព្រះរាជអាជ្ញា និង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក៏បានឆ្លើយតប។ បន្ទាប់ពីមានការពន្យារពេលដោយសារជំងឺកូវីដរួចមក អ.ជ.ត.ក. ក៏បានកំណត់ពេលសម្រាប់សវនាការលើបណ្តឹងសាទុក្ខ ចាប់ពីថ្ងៃទី១៦ ដល់ ១៩ ខែសីហា ឆ្នាំ២០២១ ដែលបានធ្វើឡើងក្នុងលក្ខណៈពាក់កណ្តាលទូរនិម្មិត។

នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ អ.ជ.ត.ក. បានប្រកាសសាលដីការបស់ខ្លួនដោយសាលដីកាជាលាយលក្ខណ៍អក្សរមានសំអាងហេតុពេញលេញ ត្រូវបានចេញនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។ អ.ជ.ត.ក. បានតម្កល់នូវការកាត់ទោសទាំងអស់តាមសាលក្រមសាលាដំបូង ដោយមានការលើកលែងតិចតួចទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាតនៅ**មន្ទីរសន្តិសុខភ្នំក្រោល** និងការធ្វើទុក្ខបុកម្នេញលើប្រជាជនថ្មីនៅ **ការដ្ឋានទំនប់ ១ មករា**។ ដូចមានចែងនៅក្នុងវាក្យខណ្ឌស្តីពី*ករណីយុត្តិសាស្ត្រ* អ.ជ.ត.ក. បានបដិសេធការកាត់ទោស ខៀវ សំផន ចំពោះការជួយនិងជំរុញ ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាត ទៅជា*ចេតនាមិនផ្ទាល់* (ផ្លូវច្បាប់)វិញ ហើយក៏បានបញ្ចូលទោសនេះទៅជាការប្រព្រឹត្តតាមរយៈ JCE។ អ.ជ.ត.ក. បានផ្តល់តាមសំណើនៅក្នុងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ក្នុងការកាត់ទោស ខៀវ សំផន ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀតដែលមានចរិកជាការរួមភេទដោយបង្ខំ ទាក់ទងនឹងបុរសជាជនរងគ្រោះនៃអាពាហ៍ពិពាហ៍ដោយបង្ខំ។ អ.ជ.ត.ក. បានតម្កល់ទោសជាប់ពន្ធនាគារមួយជីវិតរបស់គាត់ឱ្យនៅដដែល។

តាមការផ្តួចផ្តើមរបស់សហព្រះរាជអាជ្ញា ខៀវ សំផន ត្រូវបានបញ្ជូនទៅកាន់ពន្ធនាគារខេត្តកណ្តាល នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣ នៅក្រោមលក្ខខណ្ឌនៃការឃុំឃាំងសមរម្យសម្រាប់មនុស្សមានវ័យចាស់ជរា ការចល័ត និងស្ថានភាពសុខភាពមានកម្រិត។ គាត់ត្រូវបានដាក់ឱ្យស្ថិតក្រោមការតាមដានរបស់ ICRC។

## ទិដ្ឋភាពពិសេសមានតែមួយ

**គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ៖** ក.ស.ច.ស., អ.ប.ជ. និង អ.ជ.ស.ដ. បានសម្រេចថា យុត្តាធិការ អ.វ.ត.ក. ក្នុងការចោទប្រកាន់ អៀង សារី មិនត្រូវបានរារាំងដោយគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* បន្ទាប់ពីសវនាការជំនុំជម្រះ និងការកាត់ទោសគាត់ដោយ *កំបាំងមុខ* ដែលបានធ្វើឡើងដោយតុលាការប្រជាជនបដិវត្តន៍ក្នុងខែសីហា ឆ្នាំ១៩៧៩ នោះទេ។ ពួកគាត់បានសន្និដ្ឋានថាមានអត្ថិភាពនៃវិធាននីតិវិធីអន្តរជាតិស៊ីចង្វាក់គ្នានិងគ្រប់គ្រាន់មួយដែលថា គោលការណ៍នេះមិនអាចអនុវត្តបានដោយសារ វិការៈជាមូលដ្ឋានដែលមានអត្ថិភាពនៅក្នុងកិច្ចដំណើរការនីតិវិធីជាតិ។ សវនាការជំនុំជម្រះក្នុងឆ្នាំ១៩៧៩ មិនបានធ្វើឡើងដោយតុលាការដែលមិនលម្អៀង និងអញ្ញាក្រឹតដែលបានបង្កើតឡើងដោយច្បាប់ និងអនុវត្តតាមដំណើរការត្រឹមត្រូវតាមច្បាប់ឡើយ៖ ចៅក្រមលម្អៀងបានកំណត់ពិរុទ្ធភាពជាមុន ហើយមេធាវីការពារក្តីបានធ្វើសកម្មភាពប្រឆាំងផលប្រយោជន៍របស់ជនជាប់ចោទ។

**ការលើកលែងទោសនិងអនុគ្រោះទោសដោយព្រះរាជក្រឹត្យ៖** នៅខែកញ្ញា ឆ្នាំ១៩៩៦ ព្រះមហាក្សត្រសម្តេចព្រះនរោត្តម សីហនុ បានចេញព្រះរាជក្រឹត្យលើកលែងទោសប្រហារជីវិត និងការរឹបអូសទ្រព្យសម្បត្តិរបស់ អៀង សារី ដែលបានប្រកាសដោយតុលាការប្រជាជនបដិវត្តន៍ក្នុងឆ្នាំ១៩៧៩ ហើយបានផ្តល់ការលើកលែងទោសដល់គាត់នៅក្រោមច្បាប់ស្តីពី ការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់ឆ្នាំ១៩៩៤។ អ.ប.ជ. និង អ.ជ.ស.ដ. បានសម្រេចថា ការលើកលែងទោស អៀង សារី គឺកំណត់ត្រឹមតែការកាត់ទោសឆ្នាំ១៩៧៩ ប៉ុណ្ណោះ ហើយការលើកលែងទោសពីការចោទប្រកាន់នាពេលអនាគត គឺកំហិតត្រឹមច្បាប់ឆ្នាំ១៩៩៤ ដែលមិនគ្របដណ្តប់លើបទល្មើសដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក. ឡើយ។ អ.ជ.ស.ដ. ក៏បានពិចារណាផងដែរថា ការបកស្រាយព្រះរាជក្រឹត្យនេះថាជាការលើកលែងទោសចំពោះអំពើប្រល័យពូជសាសន៍ ការធ្វើទារុណកម្ម និងអំពើបំពារបំពានធ្ងន់ធ្ងរ មិនស្របនឹងកាតព្វកិច្ចនៃសិទ្ធិសញ្ញារបស់កម្ពុជាក្នុងការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មទាំងនោះ និងកាតព្វកិច្ចរបស់កម្ពុជាក្នុងកតិកាសញ្ញា ICCPR ក្នុងការផ្តល់ដំណោះស្រាយមានប្រសិទ្ធភាពជូនជនរងគ្រោះឡើយ។ មិនមានសញ្ញាណាមួយបង្ហាញពីចេតនារបស់ព្រះមហាក្សត្រ ពីការមិនគោរពនូវកាតព្វកិច្ចអន្តរជាតិទាំងនោះទេ។

**ការរឹតត្បិតក្នុងការប្រាស្រ័យទំនាក់ទំនងនៅក្នុងមន្ទីរឃុំឃាំង៖** ដោយមានការរឹតត្បិតនូវរាល់ការទំនាក់ទំនងគ្នាទាំងអស់កន្លងមករវាង អៀង សារី និង អៀង ធីរិទ្ធ នៅខែមីនា ឆ្នាំ២០០៨ ស.ច.ស. បានអនុញ្ញាតឲ្យអ្នកទាំងពីរដែលជាប្តីប្រពន្ធបានរៀបការជាមួយគ្នា បានជួបគ្នាជារៀងរាល់សប្តាហ៍។ នៅលើបណ្តឹងឧទ្ធរណ៍ អ.ប.ជ. បានច្រានចោលសេចក្តីសម្រេចនោះដោយសម្រេចថា ការធ្វើដូច្នេះគឺស្មើនឹង ការបំបែក *តាមព្រឹត្តន័យ* នៃជនត្រូវចោទ និងបានរំលោភលើវិធាន ២១(២) នៃវិធានផ្ទៃក្នុង។ ស.ច.ស. អាចដាក់កំហិតលើការធ្វើទំនាក់ទំនងរវាងជនជាប់ឃុំឃាំងបាន វៀរលែងតែក្នុងវិធានការចាំបាច់ និងបណ្តោះអាសន្នដើម្បីការពារផលប្រយោជន៍នៃកិច្ចស៊ើបសួរប៉ុណ្ណោះ តែនៅទីនេះលក្ខខណ្ឌនេះមិនបានបំពេញទេ និយាយឲ្យខ្លីប្តី

ប្រពន្ធនេះយ៉ាងហោចណាស់ក៏បានពិភាក្សាគ្នាអំពីរឿងក្ដីនេះជាង៣០ឆ្នាំមកហើយដែរ។ ទោះជាមានសេចក្ដីសម្រេចដូច្នេះក្ដី ស.ច.ស. នៅតែបដិសេធសិទ្ធិរបស់ជនជាប់ឃុំឃាំងដទៃទៀតពីការប្រាស្រ័យទំនាក់ទំនងគ្នា។ តាមបណ្ដឹងឧទ្ធរណ៍របស់ នួន ជា អ.ប.ជ. បានច្រានចោលដីកាសម្រេចនេះដែរ ដោយសម្រេចថា ស.ច.ស. មិនបានបង្ហាញអត្តសញ្ញាណភ័ស្តុតាងណាមួយអំពីហានិភ័យរឹងមាំដែលថា ជនជាប់ឃុំឃាំងនឹងឃុបឃិតគ្នាដើម្បីដាក់សម្ពាធទៅលើសាក្សី ឬជនរងគ្រោះឡើយ។

**បណ្ដឹងជិតចិត្ត៖** ពេញមួយដំណើរការនៃសំណុំរឿង០០២ មានការប្ដឹងជិតចិត្តមួយចំនួនចំពោះចៅក្រម ស.ច.ស. ចៅក្រម អ.ជ.ស.ដ. និងចៅក្រម នៃ អ.ជ.ត.ក. ដោយចោទប្រកាន់ថា មានភាពលម្អៀង និងជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ។ ប៉ុន្តែ បណ្ដឹងជិតចិត្តទាំងអស់ត្រូវបានបដិសេធដោយក្រុមប្រឹក្សាជំនុំជម្រះពិសេស ដែលបានរកឃើញសច្ចធារណ៍ថា ចៅក្រមមិនលម្អៀងទេ ហើយចៅក្រមទាំងអស់មិនបានអនុវត្តតាមជំនឿផ្ទាល់ខ្លួនឡើយ ដោយសារពួកគាត់បានស្បថចូលកាន់តំណែង និងមានគុណវុឌ្ឍិផ្នែកច្បាប់។

# សំណុំរឿង ០០៤/១

## អ៊ឹម ចែម



**ការស៊ើបអង្កេតបឋម៖** សំណុំរឿង ០០៤ បានកើតចេញពីការស៊ើបសង្កេតបឋមតែមួយដែលបានបើកដំណើរការកាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៦។ យ៉ាងណាមិញ ស.ព.ជ និង ស.ព.អ មានការខ្វែងយោបល់គ្នាក្នុងការបញ្ជូនដីកាបញ្ជូនរឿងឱ្យស៊ើបសួរចំពោះបុគ្គលឈ្មោះ អ៊ឹម ចែម, អោ អាន និង យឹម ទិត្យ ក្នុងនាមជាជនសង្ស័យ ទៅ ស.ច.ស។ នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ស.ព.អ បានបញ្ជូនការខ្វែងយោបល់គ្នាទៅ អ.ប.ជ ដែលជាអ្នករារាំងការអនុវត្តសេចក្តីសម្រេចរបស់ ស.ព.អ ក្នុងការចេញដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដោយសារពុំមានសំឡេងភាគច្រើនលើសលុប ដែលបញ្ហានេះត្រូវបានដោះស្រាយនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ដោយប្រើសេចក្តីសម្រេចស្វ័យប្រវត្តិដែលថា "ការចោទប្រកាន់ត្រូវតែបន្ត"។

**កិច្ចស៊ើបសួរតាមផ្លូវតុលាការ៖** អាស្រ័យហេតុនេះ ស.ព.អ ស្តីទីបានដាក់ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ ដែលជាការបើកកិច្ចស៊ើបសួរតាមផ្លូវតុលាការ ទៅលើឧក្រិដ្ឋកម្មទាំងឡាយនៅភូមិភាគនិរតី ភូមិភាគពាយ័ព្យ និងភូមិភាគកណ្តាល (ឧត្តរចាស់) ដែលមានឈ្មោះ អ៊ឹម ចែម, អោ អាន និង យឹម ទិត្យ ជាអ្នកទទួលខុសត្រូវ។ ជនសង្ស័យទាំងបីត្រូវបានចោទប្រកាន់ថា ជាកម្មាភិបាលភូមិភាគនិរតី និងជាជំនួយការដ៏គួរឱ្យទុកចិត្តរបស់លេខាភូមិភាគនិរតី និងជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ប.ក.ក. គឺ តា ម៉ុក ដែលបានដឹកនាំកម្មាភិបាលភូមិភាគនិរតីផ្សេងទៀត មកកាន់ភូមិភាគពាយ័ព្យ និងភូមិភាគឧត្តរ ដើម្បីបោសសម្អាតនិងជំនួសកម្មាភិបាលដែលមានស្រាប់ ក្នុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨។ នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ ថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៥ និងថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥ ស.ព.អ បានដាក់ដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទៀតដើម្បីពង្រីក និងបំភ្លឺអំពីវិសាលភាពនៃកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៤ រួមទាំងការចោទប្រកាន់បន្ថែមលើអំពើហិង្សាផ្លូវភេទ និងយ៉េនឌ័រ និងអំពើប្រល័យពូជសាសន៍ខ្មែរក្រោម នៅភូមិភាគពាយ័ព្យ និងភូមិភាគនិរតី។

នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ ស.ច.ស.អ បម្រុង បានជូនដំណឹងទៅ អ៊ឹម ចែម ថាគាត់ជាជនសង្ស័យម្នាក់នៅក្នុងកិច្ចស៊ើបសួររបស់ អ.វ.ត.ក ដែលកំពុងដំណើរការ។ នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ ស.ច.ស.អ បានកោះហៅ អ៊ឹម ចែម និងមេធាវីរបស់គាត់ឱ្យចូលបង្ហាញខ្លួនជាលើកដំបូង នៅថ្ងៃទី៨ ខែសីហា

ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៦
បើកការស៊ើបអង្កេតបឋម

ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩
បើកការស៊ើបអង្កេតតាមផ្លូវតុលាការ

ថ្ងៃទី២២ ខែកម្ភៈ ឆ្នាំ២០១៧
ស.ច.ស ចេញដីកាសម្រេចលើកលែងចោទប្រកាន់

ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៨
អ.ប.ជ ចេញសេចក្តីពិចារណា - រឿងក្តីត្រូវបានបដិសេធ

ឆ្នាំ២០១៤ ដើម្បីស្តាប់បទចោទរបស់គាត់ ស្របតាមវិធាន៥៥(៤) នៃវិធានផ្ទៃក្នុង។ អ៊ឹម ចែម បានជំទាស់នឹងសុពលភាពនៃដីកាកោះនេះ ដោយសារ ស.ច.ស.អ បានចេញដីកានេះតែម្នាក់ឯង និងបានស្នើឱ្យធ្វើមោឃភាពលើដីកានេះ ព្រមទាំងបានដាក់ញត្តិទៅ អ.ប.ជ សុំឱ្យផ្អាកការអនុវត្តដីកានេះ។ អ.ប.ជ បានតម្កល់ដីកានេះជាឯកឆន្ទថា មានសុពលភាពត្រឹមត្រូវ៖ ដោយសារ ស.ព ឬ ស.ច.ស អាចបំពេញកិច្ចតែម្នាក់បាន នៅពេលការខ្វែងយោបល់គ្នាត្រូវបានចុះកំណត់ហេតុ ហើយថិរវេលាសម្រាប់ការបញ្ជូនរបស់ អ.ប.ជ ត្រូវបានផុតកំណត់។ ទោះបីជាមានសេចក្តីសម្រេចក៏ដោយ ក៏ អ៊ឹម ចែម នៅតែបដិសេធមិនចូលបង្ហាញខ្លួន។ ស.ច.ស.អ បានចេញដីកាបង្គាប់ឱ្យនាំខ្លួន នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤ ប៉ុន្តែនគរបាលយុត្តិធម៌ខកខានមិនបានអនុវត្តដីកានេះ។

នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ ដោយពុំមានការនាំខ្លួន និងការបង្ហាញខ្លួនដោយស្ម័គ្រចិត្តរបស់ អ៊ឹម ចែម ស.ច.ស.អ បានសម្រេចចោទប្រកាន់គាត់ *ដោយកំបាំងមុខ* ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ (“ឧក្រិដ្ឋកម្មជាតិ”) ដោយបានចោទថា បានប្រព្រឹត្តឡើងនៅលើទីតាំងឧក្រិដ្ឋកម្មចំនួនពីរគឺ **មន្ទីរសន្តិសុខភ្នំទ្រយោង** និង **ការដ្ឋានទំនប់ស្ពានស្រែង** នៅក្នុងអំឡុងនៃការកាន់អំណាចរបស់គាត់ជាលេខាស្រុកព្រះនេត្រព្រះ ក្នុងតំបន់៥ (ភូមិភាគពាយ័ព្យ)។ ស.ច.ស.អ បានជូនដំណឹងដល់មេធាវីរបស់គាត់អំពីបទចោទ រួមទាំងប្រវេសន៍នៃសិទ្ធិទទួលបានការជំនុំជម្រះដោយត្រឹមត្រូវរបស់គាត់ និងបានផ្តល់ឱ្យពួកគេនូវសិទ្ធិចូលពិនិត្យសំណុំរឿង។ អ៊ឹម ចែម បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់ ស.ច.ស.អ នេះ ហើយនៅថ្ងៃទី១ ខែមីនា ឆ្នាំ២០១៦ ចៅក្រម អ.ប.ជ បានចេញសេចក្តីពិចារណារបស់ខ្លួន។ ដោយសារពួកគេមិនអាចរកសំឡេងភាគច្រើនលើសលុប សេចក្តីសម្រេចរបស់ ស.ច.ស.អ នៅដដែលគ្មានផ្លាស់ប្តូរ មានន័យថា នៅជាធរមាន។ ទោះបីបទចោទទាំងនេះតំណាងឱ្យបទចោទតិចជាងបទចោទដើមដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានរបស់ ស.ព.អ ក៏ដោយ ក៏ពុំមានបទចោទបន្ថែមទៀតត្រូវបានចោទប្រកាន់លើ អ៊ឹម ចែម ដោយ ស.ច.ស នោះឡើយ។

ភ័ស្តុតាងចំនួន
~៨.៩០០
ថ្ងៃសវនាការដោយ
ក.ស.ច.ស & អ.ប.ជ
**ចំនួន ២ ថ្ងៃ**
អ្នកដាក់ពាក្យជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន
**១.៨៤២ នាក់**
ដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលយកចំនួន
**០ នាក់**

នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ ស.ច.ស បានជូនដំណឹងដល់គូភាគី អំពីការបិទបញ្ចប់កិច្ចស៊ើបសួរតាមផ្លូវតុលាការប្រឆាំង អ៊ឹម ចែម ហើយនៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៦ ស.ច.ស បានបង្គាប់ឱ្យបំបែកសំណុំរឿងរបស់គាត់ចេញពីសំណុំរឿង ០០៤ **ដោយបង្កើតជា សំណុំរឿង ០០៤/១**។ នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ស.ព.ជ បានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន ដោយស្នើឱ្យលើកលែងចោទប្រកាន់លើសំណុំរឿងនេះ ដោយសារមិនមានយុត្តាធិការបុគ្គល ខណៈដែល ស.ព.អ ក៏បានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួនដោយស្នើឱ្យចោទប្រកាន់ អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរផ្អែកលើអង្គហេតុទាំងអស់នៅចំពោះមុខ ស.ច.ស។

**ដីកាដំណោះស្រាយ៖** នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧ ស.ច.ស បានចេញដីកាដំណោះស្រាយរួមមួយ (ផ្អែកសម្រេចសេចក្តី) ដោយលើកលែងចោទប្រកាន់

សំណុំរឿង ០០៤/១ ដោយសារពួកគេបានរកឃើញថា អ.វ.ត.ក ពុំមានយុត្តាធិការបុគ្គលលើ អ៊ឹម ចែម។ ជាលទ្ធផល ស.ច.ស បានសម្រេចថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១.៨៤២ នាក់ដែលមាននៅក្នុងសំណុំរឿង ០០៤ គ្មានបណ្តឹងទាមទារប្រឆាំងនឹងគាត់ឡើយ។

នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ស.ច.ស បានផ្សព្វផ្សាយដីកាដំណោះស្រាយ (សំអាងហេតុ)។ ស.ច.ស បានរកឃើញថា ភ័ស្តុតាងដែលបានកំណត់អំពីការទទួលខុសត្រូវរបស់ អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មជាតិនៅលើទីតាំងទាំងពីរ ត្រូវបានចោទប្រកាន់តាំងពីដើមនៅក្រោមវិធាន៥៥(៤) នៃវិធានផ្ទៃក្នុង គឺ **មន្ទីរសន្តិសុខភ្នំទ្រយោង** និង **ការដ្ឋានទំនប់ស្ពានស្រែង**។ ទោះបីជាមានសិទ្ធិអំណាច និងកាតព្វកិច្ចក្នុងការចោទប្រកាន់និងការបញ្ជូនទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មទាំងអស់ដែលបានកំណត់ដោយភ័ស្តុតាងក៏ដោយ ក៏ ស.ច.ស បានដឹកនាំធ្វើតែ "ការពិនិត្យត្រួសៗ" លើទីតាំង និងព្រឹត្តិការណ៍ឧក្រិដ្ឋកម្មផ្សេងទៀតដែលពួកគេត្រូវបានប្តឹងឱ្យទទួលយកដោយ ស.ព.អ តែប៉ុណ្ណោះ ប៉ុន្តែមិនបានចោទប្រកាន់នៅក្រោមវិធាន៥៥(៤)ពីដំបូងដែលកំណត់ថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មជាតិ ត្រូវបានប្រព្រឹត្តឡើងនៅទីនោះទេ។ ទីតាំងឧក្រិដ្ឋកម្មដែលមិនបានចោទប្រកាន់ទាំងនេះរួមមានសម្រាប់តំបន់៥ (ភូមិភាគពាយ័ព្យ)៖ ក) <u>ស្រុកព្រះនេត្រព្រះ៖</u> i) បរិវេណ**វត្តព្រះនេត្រព្រះ** និងទីតាំងដែលពាក់ព័ន្ធ និង ii) **មន្ទីរសន្តិសុខភូមិចក្រី** និង **ទីតាំងសម្លាប់មនុស្សព្រៃតាវត់** ខ) <u>ស្រុកស៊ីសុផុន៖</u> **មន្ទីរសន្តិសុខ** និង **ទីតាំងសម្លាប់មនុស្សវត្តចម្ការខ្នុរ** និង គ) <u>ស្រុកភ្នំស្រុក៖</u> **ការដ្ឋានទំនប់អាងត្រពាំងថ្ម** និងតំបន់១៣ (ភូមិភាគនិរតី)៖ <u>ស្រុកកោះអណ្តែត៖</u> **មន្ទីរសន្តិសុខវត្តអង្គស្រីមុន្នី** និង **ទីតាំងសម្លាប់មនុស្សព្រៃសុខុន**។ ទោះបី ស.ច.ស បានរកឃើញថា អ៊ឹម ចែម មិនអាចត្រូវបានចោទប្រកាន់និងបញ្ជូនទៅជំនុំជម្រះចំពោះអង្គហេតុទាំងនេះ ដោយសារតែគាត់មិនត្រូវបានចោទប្រកាន់តាំងពីដំបូងក៏ដោយ ក៏ពួកគេបានពិនិត្យមើលអង្គហេតុទាំងនេះសម្រាប់គោលបំណងយុត្តាធិការបុគ្គល ប៉ុន្តែបានសន្និដ្ឋានថា សូម្បីតែពិចារណាទៅលើឧក្រិដ្ឋកម្មទាំងបានចោទ និងទាំងមិនបានចោទ ក៏ អ៊ឹម ចែម នៅតែមិនស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឡើយ។

កំណត់ហេតុស្តាប់ចម្លើយចំនួន
**១.៣៤០**

ភាគីដាក់ឯកសារចំនួន
**៤៤៧ ឯកសារ**

សេចក្តីសម្រេចចំនួន
**៧៥៥**

សេចក្តីសម្រេចដោយសំឡេងភាគច្រើនលើសលុបចំនួន **២៧** ក្នុងចំណោមការសម្រេចចំនួន **៣៤** របស់ អ.ប.ជ

ចំពោះតួនាទីរបស់ អ៊ឹម ចែម គឺ ស.ច.ស បានរកឃើញថា ចាប់ពីឆ្នាំ១៩៧០ ឬ ១៩៧២ រហូតដល់ប្រហែលខែមីនា ឆ្នាំ១៩៧៧ នៅតំបន់១៣ (ភូមិភាគនិរតី) គាត់គឺជា **លេខាសមាគមនារីតំបន់** ប៉ុន្តែមិនទាន់ជា លេខាស្រុកកោះអណ្តែត ឬ សមាជិកគណៈកម្មាធិការតំបន់ទេ។ ស.ច.ស បានរកឃើញផងដែរថា នៅពាក់កណ្តាលឆ្នាំ១៩៧៧ អនុលោមតាមផែនការមួយដែលមានការរួមចំណែករបស់ តាម៉ុក និងកម្មាភិបាលភូមិភាគនិរតីផ្សេងទៀត អ៊ឹម ចែម បានដឹកនាំការផ្លាស់ប្តូរកម្មាភិបាលភូមិភាគនិរតីជាលើកទីពីរ មកកាន់ភូមិភាគពាយ័ព្យ ជាកន្លែងដែលពួកគេបានចាប់ខ្លួន និងសម្លាប់មនុស្សដែលពួកគេបានសន្មតថាជាខ្មាំង។ ចាប់ពីពេលដែលគាត់បានមកដល់ភូមិភាគពាយ័ព្យភ្លាម រហូតដល់ខែមករា ឆ្នាំ១៩៧៩ គាត់គឺជា **លេខាស្រុកព្រះនេត្រព្រះ** ដែលជាអ្នករៀបចំដឹកនាំការងារការដ្ឋាននិងមន្ទីរសន្តិសុខនានា ព្រមទាំងចេញបញ្ជាឱ្យគេ

ចាប់ខ្លួននិងសម្លាប់មនុស្ស។ អ៊ឹម ចែម បានក្លាយជា **សមាជិកគណៈកម្មាធិការតំបន់៥** នៅដើម-ពាក់កណ្ដាលឆ្នាំ១៩៧៨។

ស.ច.ស បានសន្និដ្ឋានថា អ.វ.ត.ក មិនមានយុត្តាធិការបុគ្គលលើគាត់ទេ ដោយសារ *មានជាអាទិ៍* i) ទោះបីគាត់ជា "តារាដែលទើបរះ" ក្នុងឋានានុក្រមកម្ពុជាប្រជាធិបតេយ្យ និងជាសមាជិក JCE ទូទាំងភូមិភាគ និងតួនាទីរបស់គាត់ក្នុងការដឹកនាំកម្មាភិបាលមកកាន់ភូមិភាគពាយ័ព្យដែលឲ្យដឹងថា ជាអ្នកមានតួនាទីជាគន្លឹះមួយក៏ដោយ ក៏មុខងាររបស់គាត់ក្នុងភូមិភាគពាយ័ព្យត្រូវបានកំណត់ត្រឹមតែជាលេខាស្រុក ដែលជាឋានានុក្រមមួយដែលបានកាន់កាប់ដោយកម្មាភិបាល ប.ក.ក រាប់ពាន់នាក់ផ្សេងទៀត ដែលជាលទ្ធភាពក្នុងការគ្រប់គ្រងការដ្ឋានផ្សេងៗដែលមាននៅក្នុងស្រុកផ្សេងទៀតក្នុងតំបន់៥ ii) ទោះបីនៅពេលក្រោយមក គាត់បានក្លាយជាសមាជិកគណៈកម្មាធិការតំបន់៥ ក៏ដោយ តែគាត់មិនមានការពាក់ព័ន្ធនៅក្នុងកិច្ចការរដ្ឋបាលរបស់តំបន់នេះទាំងមូលទេ ហើយមុខតំណែងផ្លូវការពីមុនរបស់គាត់នៅក្នុងគណៈកម្មាធិការតំបន់១៣ ក្នុងពេលវេលានៃការបោសសម្អាតភូមិភាគពាយ័ព្យដែលជាការផ្ដោតដ៏សំខាន់មួយនៃការស៊ើបសួរ ក៏មិនបង្ហាញឲ្យឃើញនោះដែរ iii) លទ្ធភាពផ្ទាល់ខ្លួនរបស់គាត់ទៅកាន់មន្ត្រីថ្នាក់លើ ប.ក.ក. ក៏មិនមែនជារឿងសំខាន់ និង iv) ការកំណត់អំពីចំនួនជនរងគ្រោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល ចំនួនទីតាំងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ (រួមទាំង ការធ្វើមនុស្សឃាត ចំនួន ២.០០០ ទៅ ១០.៨០០) គឺទាប និងមិនច្បាស់លាស់ ហើយតួរលេខសម្រាប់ទីតាំងមិនបានចោទប្រកាន់ (រួមទាំង ការធ្វើមនុស្សឃាតចំនួន ១.៥០០ ទៅ ៨.៣០០ នៅភូមិភាគពាយ័ព្យ) មានភាពស្រពិចស្រពិលជាងនេះទៅទៀត។

**បណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ៖** ស.ព.អ បានដាក់បណ្ដឹងឧទ្ធរណ៍របស់គាត់ប្រឆាំងដីកាដំណោះស្រាយនៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៧។ ទឡ្ហីករណ៍ចំនួនប្រាំមួយរបស់គាត់ គឺគ្របដណ្ដប់ទៅលើកំហុសដូចបានចោទប្រកាន់ ដូចជា ១) ការខកខានរបស់ ស.ច.ស ក្នុងការពិចារណាទៅលើអង្គហេតុទាំងអស់ដែលបានប្ដឹងមកពួកគាត់ និងផលប៉ះពាល់ដែលកើតចេញពីលទ្ធផលនោះទៅលើការវាយតម្លៃយុត្តាធិការបុគ្គល ii) ការវិភាគ និងការប្រើប្រាស់ធាតុផ្សំគតិយុត្តនៃការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការបាត់ខ្លួនដោយបង្ខំ និង iii) ការរកឃើញថា នៅភូមិភាគនិរតី អ៊ឹម ចែម មិនមែនជាលេខាស្រុកកោះអណ្ដែត និងក៏មិនមែនជាសមាជិកគណៈកម្មាធិការតំបន់១៣។



*រូបភាពក្នុងពេលសវនាការ អ.ប.ជ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧*
*© គេហទំព័រ អ.វ.ត.ក*

អ.ប.ជ បានបើកសវនាការចំនួនពីរថ្ងៃ គឺថ្ងៃទី១១ និង១២ ខែធ្នូ ឆ្នាំ២០១៧ ហើយបានចេញសេចក្ដីពិចារណារបស់ខ្លួននៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨។

ចៅក្រមមិនបានរកឃើញជាឯកច្ឆន្ទ *មានជាអាទិ៍* កំហុសនីតិវិធីផ្សេងៗនៅក្នុងការវាយតម្លៃរបស់ ស.ច.ស អំពីភាពជឿជាក់បាន និងតម្លៃភស្តុតាងនៃភស្តុតាង និងការពន្យារពេលមិនត្រឹមត្រូវក្នុងការបិទបញ្ចប់កិច្ចស៊ើបសួរទេ។ ថ្វីបើមានមតិខុសគ្នាអំពីអង្គសេចក្តីនៃការលើកលែងចោទប្រកាន់ក្នុងដីកាដំណោះស្រាយរបស់ ស.ច.ស ក្នុងសំណុំរឿង ០០៤/១ ដោយសារតែ អ.ប.ជ មិនអាចរកបាននូវសំឡេងភាគច្រើនលើសលុបក្នុងការលើកលែងចោទប្រកាន់ក្តី ក៏ពួកគេបានប្រកាសថា ដីកាដំណោះស្រាយនៅមានសុពលភាព។

ចៅក្រមជាតិ បានតម្កល់ដីកាដំណោះស្រាយរបស់ ស.ច.ស ដោយអះអាងថា អ.វ.ត.ក ពុំមានយុត្តាធិការបុគ្គលលើ អ៊ឹម ចែម។ ផ្ទុយទៅវិញ ចៅក្រមអន្តរជាតិអះអាងថា ខណៈដែល ស.ច.ស បានសម្រេចយ៉ាងត្រឹមត្រូវថា គ្មានបុគ្គលណាម្នាក់ត្រូវបានបញ្ជូនទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មដែលមិនបានចោទប្រកាន់ក្តី ក៏ពួកគេនៅតែមានកំហុសដោយសារមិនបានសម្រេចលើអង្គហេតុ *ទាំងអស់* ដែលបានប្តឹងពួកគាត់ និងគួរបានចោទប្រកាន់ អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មបន្ថែមក្នុងពេលណាមួយរហូតដល់ពេលចេញដីកាដំណោះស្រាយ។ ជាងនេះទៀត ពួកគេយល់ច្រឡំអំពីច្បាប់ស្តីពីការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងៗទៀតតាមរយៈការបាត់ខ្លួនដោយបង្ខំ និងបានបង្ហាញពីការយល់ឃើញទាំងមានកំហុស និងមានកម្រិតអំពីចំនួនជនរងគ្រោះ។ ជាលទ្ធផល ស.ច.ស ខកខានមិនបានធ្វើការកំណត់តាមផ្លូវច្បាប់ឱ្យបានត្រឹមត្រូវអំពីបទចោទប្រកាន់ទាំងអស់ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងតំបន់១៣ (ភូមិភាគនិរតី) និង តំបន់៥ (ភូមិភាគពាយ័ព្យ) ទេ។

ចៅក្រមអន្តរជាតិបានរកឃើញនូវភស្តុតាងគ្រប់គ្រាន់ដើម្បីកំណត់អំពីការទទួលខុសត្រូវរបស់ អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តតាមបណ្តាទីតាំងជាច្រើននៅទូទាំងតំបន់៥ និងតំបន់១៣ នៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល រួមទាំងវិសាលភាពដ៏ធំធេងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅ **មន្ទីរសន្តិសុខភ្នំទ្រយោង** និងនៅទីតាំងមិនបានចោទប្រកាន់ទាំងអស់ដែល ស.ច.ស "បានពិនិត្យត្រួសៗ" (ដូចបានវាយឈ្មោះខាងលើ)។ ជាការបន្ថែមយ៉ាងហោចណាស់នៅក្នុងតំបន់៥ទាំងមូល ពួកគេបានរកឃើញថា អ៊ឹម ចែម មានការទទួលខុសត្រូវចំពោះការធ្វើទុក្ខបុកម្នេញ**ជនជាតិវៀតណាម** និង **មន្ត្រីសាធារណរដ្ឋខ្មែរ** និងឧក្រិដ្ឋកម្មប្រឆាំងកម្មាភិបាលខ្មែរក្រហមនិងជនស៊ីវិលនៅក្នុងអំឡុងនៃ **ការបោសសម្អាតភូមិភាគពាយ័ព្យ** រួមទាំងជនរងគ្រោះដែលបានបញ្ជូនទៅ ស-២១ ផង។ តាមទស្សនៈរបស់ខ្លួន ជនរងគ្រោះដែល ស.ច.ស មើលរំលងមានចំនួនរាប់ម៉ឺននាក់។

ចៅក្រមអន្តរជាតិ ក៏បានរកឃើញនូវកំហុសជាច្រើននៅក្នុងការវាយតម្លៃរបស់ ស.ច.ស អំពីតួនាទីរបស់ អ៊ឹម ចែម ផងដែរ។ ពួកគេបានពិចារណាទៅលើតួនាទី និងការទទួលខុសត្រូវ*តាមព្រឹត្តន័យ* និង*តាមច្បាប់* របស់គាត់ថា លើសពីលេខាស្រុកជាមធ្យម ដោយហៅគាត់ថា "មិនអាចខ្វះបាន" ក្នុងការអនុវត្តគោលនយោបាយ បកក និងបានលើកអំពីតួនាទីនាំមុខជាពិសេសរបស់គាត់នៅក្នុងការបោសសម្អាតនៅភូមិភាគពាយ័ព្យ។ ផ្ទុយពីការសម្រេចរបស់ ស.ច.ស ចៅក្រមអន្តរជាតិ បានរកឃើញថា គាត់គឺជា **លេខាស្រុកកោះអណ្តែត** និងជា **សមាជិកគណៈកម្មាធិការតំបន់១៣** នៅភូមិភាគនិរតី និងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយ តាម៉ុក និងលទ្ធភាពដោយផ្ទាល់ទៅ*អង្គការ* ថ្នាក់លើ រួមទាំងជាមួយ ប៉ុល ពត ដែលនេះជាការបង្ហាញអំពីចរិតលក្ខណៈនៃឋានៈ និងអំណាច និងបុព្វសិទ្ធិក្រៅផ្លូវការរបស់គាត់។

ដោយពិចារណាទៅលើទម្ងន់នៃឧក្រិដ្ឋកម្មពិតប្រាកដ និងវិសាលភាពពេញលេញ

នៃការទទួលខុសត្រូវរបស់ អ៊ឹម ចែម ចៅក្រមអន្តរជាតិបានរកឃើញថា អ៊ឹម ចែម ស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក។

សេចក្តីពិចារណារបស់ អ.ប.ជ បានបិទបញ្ចប់សំណុំរឿង ០០៤/១។

## ទិដ្ឋភាពពិសេសមានតែមួយ

**យុត្តាធិការរបស់តុលាការជាតិកម្ពុជាចំពោះឧក្រិដ្ឋកម្មសម័យខ្មែរក្រហម៖** នៅក្នុងដីកាដំណោះស្រាយរបស់ខ្លួន ស.ច.ស បានរកឃើញថា យុត្តាធិការបុគ្គលក្នុងច្បាប់ អ.វ.ត.ក មានអនុភាពលុបលើយុត្តាធិការរបស់តុលាការកម្ពុជាធម្មតាចំពោះឧក្រិដ្ឋកម្មសម័យខ្មែរក្រហមទាំងអស់។ អ.ប.ជ មិនឯកភាពទេ ដោយពួកគេសម្រេចថា អ.វ.ត.ក មិនអាចកំណត់លើសកម្មភាពរបស់តុលាការកម្ពុជាផ្សេងទៀតឡើយ ហើយក្នុងច្បាប់ជាធរមានរបស់ អ.វ.ត.ក ក៏មិនបានទាត់ចោលយុត្តាធិការជាតិលើរឿងក្តីដែលមិនបានប្តឹងនៅ អ.វ.ត.ក ក៏ទេដែរ។ តុលាការកម្ពុជាធម្មតា មានយុត្តាធិការជាប់មកជាមួយស្រាប់យ៉ាងពេញលេញចំពោះកិច្ចការយុត្តិធម៌ព្រហ្មទណ្ឌ។

**"ការចោទប្រកាន់ដោយកំបាំងមុខ"៖** ពេល អ៊ឹម ចែម បដិសេធមិនបង្ហាញខ្លួនតាមការចូលបង្ហាញខ្លួនលើកដំបូង ស្របតាមវិធាន៥៧ នៃវិធានផ្ទៃក្នុង ទោះបីជាមានដីកាកោះ និងដីកាបង្គាប់ឲ្យនាំខ្លួនមានសុពលភាពក៏ដោយ ក៏ ស.ច.ស.អ នៅតែចោទប្រកាន់គាត់ "*ដោយកំបាំងមុខ*"។ នៅលើបណ្តឹងឧទ្ធរណ៍ អ.ប.ជ មានការខ្វែងគំនិតគ្នា។ ស.ច.ស.ជ បានរកឃើញថា ស.ច.ស.អ គ្មានសិទ្ធិចោទប្រកាន់ អ៊ឹម ចែម ដោយគ្មានវត្តមានរូបវន្តរបស់គាត់នៅពេលចូលបង្ហាញខ្លួនជាលើកដំបូងទេ។ ចៅក្រមអន្តរជាតិបំភ្លឺថា បើនិយាយក្នុងន័យតឹងរ៉ឹង អ៊ឹម ចែម មិនមែនត្រូវបានចោទប្រកាន់ *ដោយកំបាំងមុខ* ទេ៖ ស.ច.ស.អ បានចោទគាត់តាមវិធាន ៥៥(៤) នៃវិធានផ្ទៃក្នុង - ដែលជាសេចក្តីសម្រេច*ដោយភាគីតែម្ខាង* ផ្អែកលើភស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់គ្នានៃការទទួលខុសត្រូវព្រហ្មទណ្ឌ - ហើយបានជូនដំណឹងគាត់អំពីបទចោទទាំងនោះតាមរយៈមេធាវីរបស់គាត់។ បើតាមឯកសារយោងនៅ អ.វ.ត.ក ទាំងច្បាប់កម្ពុជានិងច្បាប់អន្តរជាតិ ពួកគេបានរកឃើញថា ពុំមានកំហុសនៅក្នុងសកម្មភាពរបស់ ស.ច.ស.អ ទេ។ ស.ច.ស.អ បានចាត់វិធានការសមហេតុផលគ្រប់យ៉ាងដើម្បីឲ្យធានាឲ្យមានការចូលបង្ហាញខ្លួនរបស់ អ៊ឹម ចែម និងដើម្បីជូនដំណឹងដល់គាត់អំពីបទចោទទាំងនោះ៖ ដូច្នេះ អវត្តមានរបស់ អ៊ឹម ចែម គឺជាការបង្កើតឡើងដោយខ្លួនឯង ហើយការផ្តល់ឋានៈជាជនត្រូវចោទ ឲ្យគាត់ជំរុញឲ្យមានការការពារចំពោះសិទ្ធិរបស់គាត់ក្នុងការទទួលបាននូវការជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌។

# សំណុំរឿង ០០៤/២



អោ អាន

**កិច្ចស៊ើបសួរតាមផ្លូវតុលាការ៖** នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ ស.ច.ស.អ បម្រុង បានជូនដំណឹងទៅ អោ អាន ថា គាត់ជាជនសង្ស័យម្នាក់នៅក្នុងសំណុំរឿង ០០៤ ដែលកំពុងតែដំណើរការស៊ើបអង្កេត។ នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ អោ អាន បានបង្ហាញខ្លួនដោយផ្ទាល់នៅក្នុងពេលចូលបង្ហាញខ្លួនជាលើកដំបូង ដែលពេលនោះគាត់ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ("ឧក្រិដ្ឋកម្មជាតិ") ដែលបានចោទប្រកាន់ថា បានប្រព្រឹត្តចាប់ពីចុងឆ្នាំ១៩៧៦ នៅភូមិភាគកណ្តាល។ ក្នុងនាមជាជនត្រូវចោទ គាត់ត្រូវបានផ្តល់នូវសិទ្ធិចូលពិនិត្យមើលសំណុំរឿង។ នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ អោ អាន ត្រូវបានចោទប្រកាន់បន្ថែម មានជាអាទិ៍ អំពើប្រល័យពូជសាសន៍ចាម នៅភូមិភាគកណ្តាល។

នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស.ច.ស បានជូនដំណឹងដល់គូភាគីថា កិច្ចស៊ើបសួរប្រឆាំង អោ អាន ត្រូវបានបិទបញ្ចប់ ហើយបានបំបែកសំណុំរឿង **ដោយបង្កើតនូវសំណុំរឿង ០០៤/២**។ ស.ច.ស.អ ក៏បានកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរអនុលោមតាមវិធាន៦៦ស្ទួន នៃវិធានផ្ទៃក្នុង ផងដែរ ដើម្បីផ្តោតទៅលើតំបន់៤១ (ភូមិភាគកណ្តាល) ជាកន្លែងដែល អោ អាន ធ្វើជាលេខាតំបន់។ ស.ច.ស បានបិទបញ្ចប់កិច្ចស៊ើបសួរជាលើកទី២ នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ ក្រោយពីបានអនុវត្តកិច្ចស៊ើបសួរបន្ថែម ដើម្បីឆ្លើយតបទៅនឹងសំណើសុំរបស់គូភាគី។

ស.ព.ជ និង ស.ព.អ បានដាក់ដីកាសន្និដ្ឋានស្ថាពរដាច់ដោយឡែកពីគ្នា។ នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧ ស.ព.ជ បានស្នើឱ្យលើកលែងចោទប្រកាន់សំណុំរឿង ០០៤/២ ដោយសារមិនមានយុត្តាធិការបុគ្គលលើ អោ អាន។ នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ ស.ព.អ បានស្នើឱ្យមានការចោទប្រកាន់ អោ អាន បញ្ជូនទៅជំនុំជម្រះពីបទអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

**ដីកាដំណោះស្រាយ៖** នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ ស.ច.ស បានជូនដំណឹងដល់គូភាគីថា ពួកគេបានពិចារណាក្នុងការចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និងខ្វែងគ្នា ដែលអនុញ្ញាតអាចធ្វើបានស្របតាមច្បាប់ អ.វ.ត.ក ហើយនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ពួកគេក៏បានចេញដីកា

ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៦
បើកការស៊ើបអង្កេតបឋម

ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩
បើកការស៊ើបអង្កេតតាមផ្លូវតុលាការ

ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨
ចេញដីកាដំណោះស្រាយផ្ទុយគ្នា

ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩
អ.ប.ជ ចេញសេចក្តីពិចារណា

ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០
អ.ជ.ត.ក បដិសេធរឿងក្តី

ដំណោះស្រាយទាំងពីរដែលផ្ទុយគ្នានេះ។ ស.ច.ស.ជ បានចេញដីកាសម្រេចលើកលែងចោទប្រកាន់ ព្រោះពួកគេរកឃើញថា អ.វ.ត.ក ពុំមានយុត្តាធិការបុគ្គល ដោយសារ អោ អាន បានចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្មដែលមានចរិកលក្ខណៈ "មិនស្វ័យភាព មិនសកម្ម មិនជាគំនិតបង្កើតថ្មី និងមិនផ្ទាល់"។ ស.ច.ស.អ បានចេញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយបង្គាប់ឱ្យបញ្ជូនខ្លួន អោ អាន ទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើឱ្យទៅជាទាសករ ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងសាសនា) និងឧក្រិដ្ឋកម្មជាតិ។ ដើម្បីកំណត់អំពីយុត្តាធិការបុគ្គល គាត់បានរកឃើញថា មុខតំណែង និងអំពើប្រព្រឹត្តរបស់ អោ អាន បានស្តែងចេញយ៉ាងច្បាស់អំពីខ្លួនគាត់ក្នុងនាមជាអ្នកដើរតួនាទីដ៏សំខាន់ម្នាក់នៅក្នុងរចនាសម្ព័ន្ធកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងជាអ្នកចូលរួមប្រព្រឹត្តដោយឆន្ទៈនិងក្នុងទឹកចិត្តយ៉ាងមុះមុតក្នុងការអនុវត្តគោលនយោបាយឧក្រិដ្ឋដ៏អមនុស្សធម៌របស់ខ្លួន។ ដោយពិចារណាអំពីតួនាទីជាមូលដ្ឋានរបស់ អោ អាន ក្នុងការដឹកនាំការអនុវត្តការសម្លាប់រង្គាលជនជាតិចាមនៅភូមិភាគកណ្តាល បទចោទនៃអំពើប្រល័យពូជសាសន៍តែមួយបានផ្តល់ឱ្យយុត្តាធិការបុគ្គលរួចជាស្រេចហើយ។

ស.ច.ស.អ បានរកឃើញថា នៅចន្លោះពីចុងឆ្នាំ១៩៧៦ ទៅខែកុម្ភៈ ឆ្នាំ១៩៧៧ លេខាភូមិភាគនិរតី និងជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ បកក តាម៉ុក បានបញ្ជាឱ្យ អោ អាន និងកម្មាភិបាលភូមិភាគនិរតីមួយក្រុមឱ្យទៅកាន់ភូមិភាគកណ្តាល ដើម្បីបោសសម្អាត និងជំនួសកម្មាភិបាលមូលដ្ឋាន។ ពេលមកដល់ អោ អាន ត្រូវបានតែងតាំងជា **លេខាតំបន់៤១** ហេតុដូច្នេះ គាត់ក៏បានក្លាយជា **សមាជិកគណៈកម្មាធិការភូមិភាគកណ្តាល**។ ចាប់ពីចុងឆ្នាំ១៩៧៧ តមក គាត់គឺជា **អនុលេខាភូមិភាគកណ្តាល** ទំនងជាមានតួនាទីជា **លេខាស្តីទីភូមិភាគកណ្តាល** នៅពេល កែ ពក ដែលជាលេខាភូមិភាគអវត្តមាន។

ស.ច.ស.អ បានរកឃើញទៀតថា ក្នុងតួនាទីទាំងអស់នោះ និងអនុលោមតាមផែនការដែលបានរួមចំណែកដោយ កែ ពក និងកម្មាភិបាលជាន់ខ្ពស់ បកក ដទៃទៀត អោ អាន បានអនុវត្តគោលនយោបាយឧក្រិដ្ឋរបស់ ប.ក.ក. នៅភូមិភាគកណ្តាល និយាយឱ្យចំគឺ តំបន់៤១ ជាកន្លែងដែលគាត់បានអនុវត្តសិទ្ធិអំណាចស៊ីវិល និងយោធាទាំងស្រុង។ គាត់បានដឹកនាំការបោសសម្អាត បានបង្កើតនិងធ្វើប្រតិបត្តិការមន្ទីរសន្តិសុខ ទីតាំងសម្លាប់មនុស្ស និងការដ្ឋាននានា បានបញ្ជាឱ្យចាប់ខ្លួននិងសម្លាប់"ខ្មាំង" រួមទាំងចាម និងអ្នកជម្លៀសមកពីភូមិភាគបូព៌ា និងបានអនុវត្តគោលនយោបាយ បកក ស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរួមដំណេកដោយបង្ខំ ដោយបានចូលរួមជាអធិបតីដោយផ្ទាល់ក្នុងការរៀបការគូស្រករចំនួន ៣៣ គូ។ ដោយប្រើសិទ្ធិអំណាចថ្នាក់ភូមិភាគ អោ អាន បានចូលរួមប្រជុំជាមួយមេដឹកនាំជាន់ខ្ពស់ បកក រួមមាន ប៉ុល ពត និង សុន សេន បានគ្រប់គ្រងគម្រោងសាងសង់នៅទូទាំងភូមិភាគ និងបានដើរតួនាទីគន្លឹះក្នុងការបញ្ជូនចាម

ភស្តុតាងចំនួន
~១០.១០០

ថ្ងៃសវនាការដោយ
ក.ស.ច.ស & អ.ប.ជ
ចំនួន ៤ ថ្ងៃ

អ្នកដាក់ពាក្យជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន
១.៩២០ នាក់

ដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលយកដោយចៅក្រមអន្តរជាតិនៃ អ.ប.ជ
ចំនួន ៤៤៦ នាក់

និងកម្មាភិបាលនិងជនស៊ីវិលនៅភូមិភាគបូព៌ា ទៅកាន់ភូមិភាគកណ្ដាលដើម្បីសម្លាប់ចោល។

ដីកាបញ្ជូនរឿងទៅជំនុំជម្រះ បានរកឃើញថា អោ អាន មានការទទួលខុសត្រូវចំពោះ៖ i) ការសម្លាប់**ជនជាតិចាម** យ៉ាងតិច ១៧.១១៥ នាក់ នៅក្នុងខេត្តកំពង់ចាមក្នុងភូមិភាគកណ្ដាល ii) ការដាក់ក្នុងមន្ទីរឃុំឃាំងមនុស្សរាប់ពាន់នាក់ និងការសម្លាប់មនុស្សយ៉ាងតិច ១២.៩៤៤ នាក់ នៅតាមបណ្ដាមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សនៅ៖ **មន្ទីរសន្តិសុខមិត្តសុប មន្ទីរសន្តិសុខទួលបេង មន្ទីរសន្តិសុខវត្តអង្គញ្ញដី មន្ទីរសន្តិសុខវត្តអូរត្រកួន មន្ទីរសន្តិសុខវត្តបាធាយ មន្ទីរសន្តិសុខវត្តតាមាក ទីតាំងសម្លាប់មនុស្សវត្តភ្នំប្រុស** និង **ទីតាំងសម្លាប់មនុស្សគោកព្រីង** iii) បានធ្វើឲ្យទៅជាទាសករមនុស្សរាប់ពាន់នាក់ដោយដាក់ក្នុងលក្ខខណ្ឌអមនុស្សធម៌នៅ**ការដ្ឋានទំនប់អន្លង់ជ្រៃ** និង**ការរៀបការដោយបង្ខំ** និងរំលោភសេពសន្ថវៈនៅក្នុងស្រុកកំពង់សៀម និងស្រុកព្រៃឈរ។

**ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី៖** ស.ច.ស.អ បានទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៤៣៤ ក្នុងចំណោមអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ១៩២០ ខណៈ ស.ច.ស.ជ បានបដិសេធចោលទាំងអស់។ នៅលើបណ្ដឹងឧទ្ធរណ៍ អ.ប.ជ បានចេញសេចក្ដីពិចារណានៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០។ ចៅក្រមជាតិបានពិចារណាថា ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់គួរបានបដិសេធ ចំណែកចៅក្រមអន្តរជាតិបានរកឃើញថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីបន្ថែមចំនួន ១២នាក់ គួរបានទទួលយក។

**បណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ៖** បន្ទាប់មក មានបណ្ដឹងឧទ្ធរណ៍ខ្វែងគ្នាជាច្រើនបានកើតឡើងប្រឆាំងនឹងដីកាដំណោះស្រាយទាំងពីរ។ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ ស.ព.ជ បានប្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយតវ៉ាអំពីយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ចំពោះ អោ អាន និងបានអះអាងថា យុត្តិធម៌បានផ្ដល់រួចហើយតាមរយៈសំណុំរឿង ០០១ និង ០០២។ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ អោ អាន បានជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ផ្អែកលើមូលហេតុជាច្រើនពាក់ព័ន្ធនឹង i) នីត្យានុកូលភាពនៃការចេញដីកាដំណោះស្រាយផ្ទុយគ្នារបស់ ស.ច.ស ii) កំហុសអង្គហេតុ និងអង្គច្បាប់ដូចដែលគាត់បានចោទប្រកាន់ដែលមាននៅក្នុងការវាយតម្លៃរបស់ ស.ច.ស.អ អំពីស្ថានទម្ងន់នៃបទឧក្រិដ្ឋនិងតួនាទីព្រមទាំងការទទួលខុសត្រូវរបស់ អោ អាន និង iii) ភាពមិនត្រឹមត្រូវយុត្តិធម៌នៅក្នុងកិច្ចដំណើរការនីតិវិធីដូចដែលបានចោទប្រកាន់។ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ស.ព.អ បានស្នើឲ្យធ្វើការផ្លាស់ប្ដូរទៅលើដីកាសម្រេចលើកលែងចោទប្រកាន់ អាស្រ័យដោយកំហុសអង្គហេតុនិងអង្គច្បាប់ដែលគាត់អះអាងថាធ្វើឲ្យខូចតម្លៃនៃការអនុវត្តឆន្ទានុសិទ្ធិរបស់ ស.ច.ស.ជ ស្ដីពីយុត្តាធិការបុគ្គល និងស្នើឲ្យធ្វើចំណាត់ការបញ្ជូនសំណុំរឿងនេះទៅជំនុំជម្រះផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

កំណត់ហេតុស្ដាប់ចម្លើយ
ចំនួន
**១.៤៦២**

ភាគីដាក់ឯកសារចំនួន
**៥៩២ ឯកសារ**

សេចក្ដីសម្រេចចំនួន
**៩១៣**

សេចក្ដីសម្រេចដោយសំឡេងភាគច្រើនលើសលុបចំនួន **៤២** ក្នុងចំណោមការសម្រេចចំនួន **៥៥** របស់ អ.ប.ជ

សវនាការលើបណ្ដឹងឧទ្ធរណ៍បានធ្វើឡើងចាប់ពីថ្ងៃទី១៩ ដល់ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ហើយ អ.ប.ជ បានចេញសេចក្ដីពិចារណាជាសាធារណៈរបស់ខ្លួន នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩។ អ.ប.ជ បានរកឃើញជាឯកច្ឆន្ទថា ការចេញដីកាដំណោះស្រាយពីរដែលផ្ទុយគ្នាជាបន្តបន្ទាប់ បានរំលោភលើក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក និងជាការខុសច្បាប់។ បើពិនិត្យទៅលើយន្តការណ៍នៃការដោះស្រាយការខ្វែងយោបល់គ្នានៅក្នុងមាត្រា៥ និង មាត្រា៧ នៃកិច្ចព្រមព្រៀង អ.វ.ត.ក និង មាត្រា ២៣ថ្មី នៃច្បាប់ អ.វ.ត.ក នោះ អ.ប.ជ បានរកឃើញថា វាមានអត្ថិភាពដើម្បីបញ្ចៀសការជាប់គាំងផ្នែកនីតិវិធី ពេលណា ស.ព និង ស.ច.ស ដែលមានសិទ្ធិស្មើគ្នានិងឯករាជ្យ មានការខ្វែងយោបល់គ្នា។ ស.ច.ស មិនមានកាតព្វកិច្ចប្ដឹងទៅ អ.ប.ជ ឡើយប្រសិនបើពួកគេអាចឯកភាពគ្នាចំពោះដំណើរការនៃសកម្មភាពណាមួយស្របនឹងគោលជំហរស្វ័យប្រវត្តិដែល "ជាមូលដ្ឋាន និងកត្តាកំណត់" នៅក្នុងក្របខ័ណ្ឌច្បាប់ អ.វ.ត.ក ដែលចែងថា "កិច្ចស៊ើបសួរត្រូវតែបន្ត"។ យ៉ាងណាមិញ ក្នុងករណីមានភាពខុសគ្នាដែលមិនអាចផ្សះផ្សាបាន ដូចនៅទីនេះជាដើម រហូតធ្វើឱ្យ ស.ច.ស មានបំណងចង់បញ្ឈប់ការអនុវត្តសេចក្ដីសម្រេចផ្សេងៗទៀត នោះ ស.ច.ស *ត្រូវឱ្យ* នាំយកការខ្វែងយោបល់គ្នាទៅចំពោះមុខ អ.ប.ជ ដើម្បីដំណោះស្រាយដាច់ស្រេច ដោយប្រើគោលជំហរស្វ័យប្រវត្តិ ប្រសិនបើ អ.ប.ជ មិនអាចរកបានសំឡេងភាគច្រើនលើសលុប។

បន្ទាប់មក ចៅក្រម អ.ប.ជ បានពិចារណាលើសុពលភាពនៃដីកាដំណោះស្រាយនីមួយៗ។ ចៅក្រមជាតិបានតម្កល់ដីកាសម្រេចលើកលែងចោទប្រកាន់និងបានធ្វើមោឃភាពលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយផ្អែកជាចំបងលើការសន្និដ្ឋានរបស់ខ្លួនថា កិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ អ.វ.ត.ក បានកម្រិតយុត្តាធិការបុគ្គលត្រឹមតែជនជាប់ចោទប្រាំនាក់នៅក្នុងសំណុំរឿង ០០១ និង ០០២។

ផ្ទុយទៅវិញ ចៅក្រមអន្តរជាតិបានតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងបានធ្វើមោឃភាពដីកាសម្រេចលើកលែងចោទប្រកាន់។ តាមនីតិវិធី ពួកគាត់បានរកឃើញថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព ហើយដីកាសម្រេចលើកលែងចោទប្រកាន់ ត្រូវបានទុកជាមោឃៈនិងគ្មានសុពលភាព៖ ការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺស្របនឹងគោលការណ៍នៃការបន្តកិច្ចដំណើរការនីតិវិធី ដូចបានឆ្លុះបញ្ចាំងក្នុងគោលជំហរស្វ័យប្រវត្តិដែលចែងថា "កិច្ចស៊ើបសួរត្រូវតែបន្ត" ខណៈដែលការស្នើឱ្យចេញដីកាសម្រេចលើកលែងចោទប្រកាន់ គឺគ្រាន់តែជាការកំណត់ឡើងវិញនៃការខ្វែងយោបល់គ្នារបស់ ស.ច.ស.ជ ជាមួយនឹងការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលគាត់គួរតែបានបញ្ជូនទៅ អ.ប.ជ។ ការខកខានរបស់គាត់មិនបានធ្វើដូច្នេះ បានធ្វើឱ្យដីកាសម្រេចលើកលែងចោទប្រកាន់គ្មានសុពលភាព។ ចៅក្រមអន្តរជាតិក៏បានរកឃើញផងដែរថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះជាខ្លឹមសារ គឺមានសុពលភាព ដោយច្រានចោលបណ្ដឹងឧទ្ធរណ៍ទាំងរបស់ ស.ព.ជ និងទាំងទឡ្ហីករណ៍សំខាន់ៗទាំងអស់នៃបណ្ដឹងឧទ្ធរណ៍របស់ អោ អាន។ ដោយបានរកឃើញថា អ.ជ.ស.ដ ត្រូវបានប្ដឹងឱ្យទទួលយកដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាពនេះ ស្របតាមវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង(*) ចៅក្រមអន្តរជាតិបានបង្គាប់ឱ្យក្រឡាបញ្ជី អ.ប.ជ បញ្ជូនសេចក្ដីពិចារណា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និង សំណុំរឿង ០០៤/២ ទៅ អ.ជ.ស.ដ។

---

(*) វិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង ចែងថា ប្រសិនបើ អ.ប.ជ មិនអាចរកសំឡេងភាគច្រើនលើសលុបបានលើបណ្ដឹងឧទ្ធរណ៍ "សេចក្ដីសម្រេចដែលមិនមានសំឡេងគាំទ្រ [...] ត្រូវអនុវត្តដូចខាងក្រោម... ពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ ស.ច.ស [...] អ.ប.ជ ត្រូវសម្រេចប្ដឹងទៅ អ.ជ.ស.ដ ដោយឈរលើមូលដ្ឋានដីកាដំណោះស្រាយរបស់ ស.ច.ស"។

**បណ្តឹងវិវាទបន្តបន្ទាប់៖** ជាលទ្ធផល នាំឱ្យមានការជាប់គាំងផ្នែកនីតិវិធី។ ស.ព.អ បានចាប់ផ្តើមរៀបចំការធ្វើសវនាការដោយសំអាងថា អនុលោមតាមវិធាន ៧៧(១៣)(ខ) និង វិធាន ៧៩(១) នៃវិធានផ្ទៃក្នុង និងស្របតាមគោលជំហរស្វ័យប្រវត្តិ ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានប្តឹងទៅ អ.ជ.ស.ជ នៅពេល អ.ប.ជ ខកខានមិនបានសម្រេចច្រានចោលដីកានេះដោយសំឡេងភាគច្រើនលើសលុប។ តាមការយល់ឃើញរបស់ ស.ព.អ ការបញ្ជូនសំណុំរឿងគឺជាសកម្មភាពរដ្ឋបាលសុទ្ធសាធមួយដែលត្រូវធ្វើចេញពីគោលជំហរផ្លូវច្បាប់នេះ។ ផ្ទុយទៅវិញ អោ អាន បានពឹងផ្អែកលើសេចក្តីសម្រេចជាឯកច្ឆន្ទរបស់ អ.ប.ជ ដែលថា ការចេញដីកាដំណោះស្រាយពីរ គឺខុសច្បាប់ ដែលគាត់អះអាងថា សំណុំរឿង ០០៤/២ ត្រូវបានលើកលែងចោទប្រកាន់ ហើយចៅក្រមអន្តរជាតិនៃ អ.ប.ជ មិនត្រូវបានអនុញ្ញាតឱ្យបញ្ជូនសំណុំរឿងនេះទៅ អ.ជ.ស.ជ ទេ។ នៅក្នុងអំឡុងប៉ុន្មានខែនៃដើមឆ្នាំ២០២០ ស.ព.អ និង អោ អាន បានបញ្ជូនគោលជំហរផ្ទុយគ្នានេះទៅ អ.ប.ជ, អ.ជ.ស.ជ និង ការិយាល័យរដ្ឋបាល ដោយ ស.ព.អ បានស្នើជាចំបងឱ្យធ្វើចំណាត់ការសំណុំរឿង ០០៤/២ ទៅជំនុំជម្រះ និងបញ្ជូនសំណុំរឿងទៅ អ.ជ.ស.ជ ហើយ អោ អាន បានស្នើឱ្យលើកលែងការចោទប្រកាន់។



*ចៅក្រម អ.ប.ជ ក្នុងពេលសវនាការ នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩*
*© គេហទំព័រ អ.វ.ត.ក*

ចៅក្រមជាតិ និងចៅក្រមអន្តរជាតិនៃ អ.ប.ជ មានការខ្វែងយោបល់គ្នាក្នុងការបញ្ជូនសេចក្តីពិចារណា និងសំណុំរឿងទៅ អ.ជ.ស.ជ ហើយបានបញ្ជូនសេចក្តីណែនាំដែលផ្ទុយគ្នាទៅការិយាល័យរដ្ឋបាលនៅថ្ងៃទី២៨ និងទី២៩ ខែមករា ឆ្នាំ២០២០។ គោលជំហរទាំងនេះនៅតែមិនទាន់បានដោះស្រាយ។ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ចៅក្រមអន្តរជាតិនៃ អ.ប.ជ បានអះអាងថា i) អ.ជ.ស.ជ ត្រូវបានប្តឹងរួចហើយអំពីសំណុំរឿងនេះ តាមរយៈប្រតិបត្តិការនៃច្បាប់ ii) ពួកគេបានបញ្ជូនសំណើរដ្ឋបាលដែលមានសុពលភាពត្រឹមត្រូវទៅការិយាល័យរដ្ឋបាលរួចហើយ និង iii) ទាំងការិយាល័យរដ្ឋបាល និងទាំង អ.ជ.ស.ជ បានបំពេញកិច្ចស្របទៅតាមនោះ។ បួនថ្ងៃក្រោយមក ប្រធាន អ.ប.ជ ម្នាក់នៃចៅក្រមជាតិ បានថ្លែងថា គ្មានសកម្មភាពរដ្ឋបាលបន្ថែមទៀតដែលត្រូវធ្វើដោយ អ.ប.ជ នោះទេ។ ការិយាល័យរដ្ឋបាលបានបដិសេធ មិនបញ្ជូនសំណុំរឿង។

ក្នុងរយៈពេលជាមួយគ្នានេះដែរ អ.ជ.ស.ជ បានបញ្ជាក់អះអាងដដែលៗថា ខ្លួនបានដឹងអំពីសេចក្តីពិចារណាជាសាធារណៈរបស់ អ.ប.ជ ប៉ុន្តែបានបដិសេធមិនចាត់វិធានការដោយសារគ្មានការជូនដំណឹង "ជាផ្លូវការ"និងគ្មានការបញ្ជូនសំណុំរឿង។ ថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ អ.ជ.ស.ជ បានចេញសេចក្តីប្រកាសព័ត៌មានមួយដោយបានអះអាងថា នឹងមិនចាត់វិធានការទេ។ ចៅក្រមអន្តរជាតិបានទទួលស្គាល់ថា អ.ជ.ស.ជ មានសិទ្ធិអំណាចជាប់មកជាមួយ ក្នុងការដោះស្រាយបញ្ហានានាដែលបានលើកឡើងដោយគូភាគីនៃសំណុំរឿង ០០៤/២។ ប៉ុន្តែ ចៅក្រមជាតិបានប្រកាសថា "នឹងមិនមានសវនាការជំនុំជម្រះលើ អោ អាន ទេនៅពេលនេះ និងនៅពេលអនាគត"។ នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០២០ ឯកសារដែល ស.ព.អ បានដាក់ទៅ អ.ជ.ស.ជ ជាសំណៅរឹង ត្រូវបានបង្វិលត្រឡប់មកវិញ ដែលសរសេរសម្គាល់ថា "ត្រឡប់ទៅអ្នកបញ្ជូន"។

នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០ ស.ព.អ បានដាក់បណ្តឹងសាទុក្ខភ្លាមៗទៅ អ.ជ.ត.ក ប្រឆាំងនឹងការសម្រេចបញ្ចប់អនុភាពនៃសំណុំរឿង ០០៤/២ របស់ អ.ជ.ស.ជ ដោយតវ៉ា *មានជាអាទិ៍* ថា អ.ជ.ស.ជ i) ខកខានមិនបានផ្តល់អនុភាពលើគោលជំហរស្វ័យប្រវត្តិដែលបានប្តឹងមកខ្លួន តាមរយៈដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ និង ii) ការដាក់តាមទំនើងចិត្តនូវបុរេលក្ខខណ្ឌរដ្ឋបាលបន្ថែមទៅលើសេចក្តីពិចារណារបស់ខ្លួននៃសំណុំរឿងនេះ។

អ.ជ.ត.ក បានចេញសេចក្តីសម្រេចរបស់ខ្លួននៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០។ ដោយទទួលយកបណ្តឹងសាទុក្ខរបស់ ស.ព.អ ដើម្បីផ្តល់សច្ចភាពនិងភាពស្ថាពរផ្នែកច្បាប់ចំពោះសំណុំរឿង ០០៤/២ អ.ជ.ត.ក បានសន្និដ្ឋានថា អ.ជ.ស.ជ មិនទាន់បានទទួលបណ្តឹងទេ ដោយសារសំណុំរឿងមិនទាន់បានបញ្ជូន។ អង្គជំនុំជម្រះក៏បានសម្រេចថា ការសម្រេចរបស់ អ.ប.ជ ដែលថា ការចេញដីកាដំណោះស្រាយពីរជាបន្តបន្ទាប់គ្នាគឺខុសច្បាប់ ធ្វើឱ្យដីកាដំណោះស្រាយទាំងពីរទៅជាមោឃៈនិងអសារឥតបានការ និងដោយសារពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលអាចអនុវត្តបាន អ.ជ.ត.ក ក៏បញ្ចប់សំណុំរឿង ០០៤/២។

នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ ស.ច.ស បានបោះត្រា និងដាក់បញ្ចូលសំណុំរឿងទៅក្នុងបណ្ណសារដ្ឋាន។

## ទិដ្ឋភាពពិសេសមានតែមួយ

**ការចូលរួមរបស់មេធាវីការពារក្តីនៅក្នុងកិច្ចស៊ើបសួរតាមផ្លូវតុលាការ៖** នៅក្នុងសំណុំរឿង ០០៣ និង០០៤ ជនសង្ស័យត្រូវបានអនុញ្ញាតឱ្យមានសិទ្ធិចូលពិនិត្យមើលសំណុំរឿង តែនៅពេលដែលពួកគេត្រូវបានចោទប្រកាន់ជាផ្លូវការដោយ ស.ច.ស.អ អនុលោមតាមវិធាន ៥៥(៤) នៃវិធានផ្ទៃក្នុងប៉ុណ្ណោះ។ មុនពេលត្រូវបានចោទប្រកាន់ អោ អាន បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់ ស.ច.ស.អ ដែលបដិសេធសិទ្ធិនេះ ហើយ អ.ប.ជ បានចេញសេចក្តីពិចារណា។ ចៅក្រមជាតិបានសម្រេចថា បណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបានទេ ដោយរកឃើញថា អោ អាន គ្រាន់តែនិងនៅតែជាជនសង្ស័យម្នាក់នៅឡើយ ដែលគ្មានសិទ្ធិប្តឹងនៅចំពោះមុខ អ.ប.ជ ឡើយ។ ផ្ទុយទៅវិញ ចៅក្រមអន្តរជាតិបានសម្រេចថា ជនណាដែលមានបណ្តឹងព្រហ្មទណ្ឌប្រឆាំងនឹងខ្លួន ដូចបានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ត្រូវតែមានសិទ្ធិចូលពិនិត្យសំណុំរឿង ដើម្បីលើកកម្ពស់សិទ្ធិរបស់ពួកគេក្នុងការទទួលបាននូវការប្រព្រឹត្តិដោយស្មើភាព និងដើម្បីមានពេលវេលា និងបរិក្ខារគ្រប់គ្រាន់សម្រាប់ត្រៀមការពារខ្លួនរបស់ពួកគេ។ ដោយសារតែ អ.ប.ជ មិនបានទទួលសំឡេងភាគច្រើនលើសលុប នោះសេចក្តីសម្រេចរបស់ ស.ច.ស.អ នៅតែមានសុពលភាព ហើយ អោ អាន ត្រូវបានផ្តល់សិទ្ធិចូលពិនិត្យសំណុំរឿង តែនៅពេលគាត់ត្រូវបានចោទប្រកាន់ជាផ្លូវការនៅក្នុងខែមីនា ឆ្នាំ២០១៥ ប៉ុណ្ណោះ។

**ការមានគភ៌ដោយបង្ខំ និងការធ្វើឱ្យមានគភ៌ដោយបង្ខំ៖** នៅក្នុងសេចក្តីសម្រេចមួយ ដូចបានពិភាក្សាបន្ថែមនៅក្នុងវាក្យខ័ណ្ឌស្តីពីករណីយុត្តិសាស្ត្រនៅក្នុងកូនសៀវភៅនេះ ស.ច.ស.អ បានបដិសេធលើសំណើសុំឱ្យស៊ើបអង្កេតការមានគភ៌ដោយបង្ខំ និងការធ្វើឱ្យមានគភ៌ដោយបង្ខំ ក្នុងទស្សនៈដើម្បីកំណត់ពីអំពើប្រព្រឹត្តនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀត។

# សំណុំរឿង ០០៣





មាស មុត & ស៊ូ ម៉េត

**ការស៊ើបអង្កេតបឋម៖** ដូចសំណុំរឿង ០០៤ ដែរ សំណុំរឿង ០០៣ បានកើតចេញពីការស៊ើបអង្កេតបឋមដែលបានបើកធ្វើឡើងនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៦។ ស.ព.ជ និង ស.ព.អ មានការខ្វែងយោបល់គ្នាដូចគ្នាដែរ លើបញ្ហាថាតើត្រូវបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មី ដែលមានឈ្មោះ មាស មុត និង ស៊ូ ម៉េត ជាជនសង្ស័យ ទៅកាន់ ស.ច.ស ឬយ៉ាងណា។ ស.ព.អ បានបញ្ជូនការខ្វែងយោបល់គ្នានេះទៅកាន់ អ.ប.ជ នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨។ ក៏ដូចគ្នានឹងសំណុំរឿង ០០៤ ផងដែរ អ.ប.ជ ដោះស្រាយការខ្វែងយោបល់គ្នានេះនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ដោយប្រើសេចក្ដីសម្រេចតាមយន្តការស្វ័យប្រវត្តិ។

**កិច្ចស៊ើបសួរតាមផ្លូវតុលាការ៖** បន្ទាប់ពីនោះមក នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ ស.ព.អ ស្ដីទី បានបញ្ជូន ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ទៅ ស.ច.ស ដែលបានបើកកិច្ចស៊ើបសួរតាមផ្លូវតុលាការទៅលើការទទួលខុសត្រូវរបស់ជនសង្ស័យចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងដោយ **កងពល ១៦៤** និងប្រព្រឹត្តឡើងប្រឆាំងនឹងកងពល ១៦៤ (អតីតកងពលលេខ ៣ ដែលជាកងពលមជ្ឈិមរបស់កងទ័ពបដិវត្តន៍កម្ពុជា ដែលបានបង្កើតជាកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យ) និង **កងពល ៥០២** (កងទ័ពជើងអាកាសរបស់កម្ពុជាប្រជាធិបតេយ្យ) និងក្នុងអំឡុងពេល **បោសសម្អាតកងទ័ពបដិវត្តកម្ពុជា**។

នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ស.ច.ស.ជ និង ស.ច.ស.អ ចៅក្រម Blunk ដែលបានចូលកាន់តំណែងបន្ទាប់ពីសហចៅក្រមស៊ើបអង្កេតអន្តជាតិ ចៅក្រម Lemonde ក្នុងខែធ្នូ ឆ្នាំ២០១០ បានជូនដំណឹងសហព្រះរាជអាជ្ញាថា ពួកគាត់បានពិចារណាថាសំណុំរឿង ០០៣ ត្រូវបានបិទបញ្ចប់ហើយ។ ស.ព.អ បានដាក់សំណើជាច្រើន ស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែម ដោយអះអាងថា កិច្ចស៊ើបសួរមិនពេញលេញទាល់តែសោះ។ ការបដិសេធមិនទទួលយកសំណើទាំងនេះម្ដងហើយម្ដងទៀតរបស់ ស.ច.ស នាំឲ្យមានបណ្ដឹងឧទ្ធរណ៍ជាច្រើនទៅកាន់ អ.ប.ជ ក្នុងរយៈពេលប៉ុន្មានខែក្រោយមក។ ស.ច.ស.អ Blunk បានលាឈប់ពីតំណែង ដែលមានប្រសិទ្ធភាពពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១១ ហើយនៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១១ ស.ច.ស.អ បម្រុង Kasper-Ansermet បានបង្គាប់ឲ្យចាប់ផ្ដើមការស៊ើបអង្កេតឡើងវិញ និងបានទទួលយកសំណើសុំឲ្យបំពេញកិច្ចស៊ើបសួររបស់ ស.ព.អ ដោយបានសន្និដ្ឋានថា ការស៊ើបអង្កេតដែលបានធ្វើឡើង

ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៦
បើកការស៊ើបអង្កេតបឋម

ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩
បើកការស៊ើបអង្កេតតាមផ្លូវតុលាការ

ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨
ចេញដីកាដំណោះស្រាយផ្ទុយគ្នា

ថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១
អ.ប.ជ ចេញសេចក្ដីពិចារណា

ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១
អ.ជ.ត.ក បដិសេធរឿងក្ដី

កន្លងមក "មានវិការៈ និងអយុត្តិធម៌ចំពោះភាគីទាំងអស់"។ នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ គាត់បានជូនដំណឹង មាស មុត និង ស៊ូ ម៉េត ថា ពួកគេគឺជាជនសង្ស័យនៅក្នុងការស៊ើបអង្កេតដែលកំពុងធ្វើ។ នៅខែមីនា ឆ្នាំ២០១២ ស.ច.ស.អ បម្រុងបានលាឈប់ពីតំណែង ដែលមានប្រសិទ្ធភាពចាប់ពីថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១២ ហើយ ស.ច.ស.អ Harmon បានចូលកាន់តំណែងនៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១២។

នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣ ស.ច.ស បានជូនដំណឹងដល់ភាគីថា ស៊ូ ម៉េត បានស្លាប់បាត់ទៅហើយ ដូច្នេះកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងរូបគាត់ត្រូវបានបញ្ចប់នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៥។

នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ ស.ព.អ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ១) ផ្តល់ការបញ្ជាក់ពាក់ព័ន្ធនឹងការបោសសម្អាតកងពល ១៦៤ ឧក្រិដ្ឋកម្មប្រព្រឹត្តឡើងនៅក្នុងដែនទឹក និងតាមបណ្តាកោះនានា ដែលអះអាងដោយកម្ពុជាប្រជាធិបតេយ្យ និងការបោសសម្អាតកងពល ១១៧ និងកម្មាភិបាលតំបន់ ៥០៥ នៅក្នុងខេត្តក្រចេះ នៅចុងឆ្នាំ១៩៧៨ និង ២) ប្តឹងទៅ ស.ច.ស អំពីអង្គហេតុនានាទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈនៅតំបន់ស្វយ័តកំពង់សោម ដែលជាកន្លែងកងពល ១៦៤ មានមូលដ្ឋានស្ថិតនៅក្រោមការបញ្ជារបស់ មាស មុត។

នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ ស.ច.ស.អ បានកោះហៅ មាស មុត សម្រាប់ការបង្ហាញខ្លួនលើកដំបូងនៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៤ ដើម្បីដាក់គាត់ឱ្យស្ថិតក្រោមការពិនិត្យតាមវិធាន ៥៥(៤) នៃវិធានផ្ទៃក្នុង ប៉ុន្តែ មាស មុត បានបដិសេធមិនទទួលស្គាល់ដីកាកោះនោះទេ។ នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៤ អ.ប.ជ បានបដិសេធការជំទាស់ពីមុនរបស់ មាស មុត ទៅនឹងសុពលភាពនៃដីកាកោះ ដែលចុះហត្ថលេខាដោយ ស.ច.ស តែម្នាក់។ មាស មុត ខកខានមិនបានមកបង្ហាញខ្លួននៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៤ បន្ទាប់មក ស.ច.ស.អ បានចេញដីកាបង្គាប់ឱ្យនាំខ្លួន និងបានបង្គាប់ឱ្យនគរបាលយុត្តិធម៌នាំខ្លួន មាស មុត មកកាន់ អ.វ.ត.ក។ បន្ទាប់ពីការខកខានមិនបានអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន និងដោយមិនមានការបង្ហាញខ្លួនដោយស្ម័គ្រចិត្តរបស់ មាស មុត នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ ស.ច.ស.អ សម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការត្រួតពិនិត្យដោយកំបាំងមុខ ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរ និងឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ("ឧក្រិដ្ឋកម្មថ្នាក់ជាតិ")។ មាស មុត បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនេះ តែមិនទទួលបានជោគជ័យទេ។ នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៥ ស.ច.ស.អ បានចេញដីកាបង្គាប់ឱ្យនាំខ្លួនលើកទីពីរ ដែលដីកានេះមិនត្រូវបានអនុវត្តដូចលើកមុនដែរ។

ភស្តុតាងចំនួន
~៧.០០០

ថ្ងៃសវនាការដោយ
ក.ស.ច.ស & អ.ប.ជ
ចំនួន ៤ ថ្ងៃ

អ្នកដាក់ពាក្យជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន
៦៤៦ នាក់

ដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលយកដោយចៅក្រមអន្តរជាតិនៃ អ.ប.ជ
ចំនួន ២៧ នាក់

នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ នៅក្នុងសវនាការមួយនៅខេត្តបាត់ដំបង ដែលមានវត្តមាន មាស មុត ស.ច.ស.អ Bohlander ដែលកាន់តំណែងបន្តពី ស.ច.ស.អ Harmon នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥ បានមោឃភាពការចោទប្រកាន់

ពីមុនមួយចំនួន និងបានចោទប្រកាន់ មាស មុត អំពីអំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម និងបទចោទបន្ថែមទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរ និងឧក្រិដ្ឋកម្មថ្នាក់ជាតិ។

នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ ស.ច.ស.អ បានជូនដំណឹងភាគីថា តាមវិធាន ៦៦*ស្ទួន* គាត់ដកអង្គហេតុមួយចំនួនចេញពីការស៊ើបអង្កេត ដែលពាក់ព័ន្ធខ្លាំងទៅនឹង ស៊ូ ម៉េត ហើយបានពិចារណាថា ការស៊ើបអង្កេតបានបិទបញ្ចប់។ ភាគីបានដាក់សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរជាច្រើន។ បន្ទាប់ពីបានធ្វើការស៊ើបអង្កេតតាមសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរមួយចំនួយរួចមក ស.ច.ស.អ បានចេញសេចក្តីជូនដំណឹងលើកទីពីរ និងលើកចុងក្រោយអំពីការបិទបញ្ចប់ការស៊ើបអង្កេតនៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧។

នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ស.ព.ជ បានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន ដោយបានស្នើឱ្យលើកលែងចោទប្រកាន់ ដោយសារមិនមានយុត្តាធិការបុគ្គល ចំណែក ស.ព.អ បានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន ដោយស្នើសុំឱ្យចោទប្រកាន់ មាស មុត ចំពោះអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរ។

**ដីកាដំណោះស្រាយ៖** នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ស.ច.ស ជាថ្មីម្តងទៀត បានចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា។ ស.ច.ស.ជ បានចេញដីកាសម្រេចលើកលែងចោទប្រកាន់ ដោយរកឃើញថា អ.វ.ត.ក មិនមានយុត្តាធិការបុគ្គលលើ មាស មុត ដែលគាត់បានសន្និដ្ឋានថា "មិនមានអំណាចច្រើន"។ ស.ច.ស.អ បានចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយបញ្ជូន មាស មុត ទៅជំនុំជម្រះចំពោះអំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (អំពើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើឱ្យទៅជាទាសករ ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត និងការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយ និងជាតិសាសន៍) ការបំពារបំពានយ៉ាងធ្ងន់ធ្ងរ និងឧក្រិដ្ឋកម្មថ្នាក់ជាតិ។ ដោយដាក់ មាស មុត "ស្ថិតនៅក្នុងយុត្តាធិការបុគ្គលយ៉ាងរឹងមាំ" ស.ច.ស.អ បានគូសបញ្ជាក់លើការចោទប្រកាន់ពីបទប្រល័យពូជសាសន៍ និងបានបញ្ជាក់ថា មាស មុត មានឋានៈកៀកទៅនឹងថ្នាក់ដឹកនាំជាន់ខ្ពស់ ដែលចរិតលក្ខណៈនិងផលប៉ះពាល់ពីអំពើរបស់គាត់មានអានុភាពលើសអំពើរបស់ អោ អាន, អ៊ឹម ចែម និង ឌុច។

កំណត់ហេតុស្តាប់ចម្លើយ
ចំនួន
៩១៦

ភាគីដាក់ឯកសារចំនួន
៤៣២ ឯកសារ

សេចក្តីសម្រេចចំនួន
៥៦២

សេចក្តីសម្រេចដោយសំឡេងភាគច្រើនលើសលុបចំនួន ៥៣ ក្នុងចំណោមការសម្រេចចំនួន ៦៨ របស់ អ.ប.ជ

ស.ច.ស.អ បានរកឃើញថា មាស មុត គឺជាកូនប្រសាប្រុសរបស់ តាម៉ុក ដែលជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍របស់ ប.ក.ក និងបានកាន់តួនាទីជាច្រើនខាងផ្នែកយោធា និងស៊ីវិល ដូចជា៖ ១) **មេបញ្ជាការកងពល ១៦៤** (អតីតកងពលលេខ ៣) ដែលទទួលខុសត្រូវជាអាទិ៍ លើដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យ ២) **លេខាតំបន់ស្វយ័តកំពង់សោម** រួមបញ្ចូលទាំងកំពង់ផែកំពង់សោម ៣) **សមាជិកបម្រុងនៃគណៈកម្មាធិការសេនាធិការរបស់កងទ័ពបដិវត្តកម្ពុជា** និងជាអនុរបស់ សុន សេន និង ៤) ចាប់ពីចុងឆ្នាំ១៩៧៨ ជា**សមាជិកបម្រុងនៃ**

**គណៈកម្មាធិការមជ្ឈិមនៃ ប.ក.ក៖** ចាប់ពីខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩ អនុលោមតាមផែនការដែលចូលរួមដោយ ស៊ូ ម៉េត, តាម៉ុក, សុន សេន និងបុគ្គលិកជាន់ខ្ពស់ផ្សេងទៀតនៃកងទ័ពបដិវត្តកម្ពុជា មាស មុត បានអនុវត្តគោលនយោបាយឧក្រិដ្ឋរបស់ ប.ក.ក នៅក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់គាត់។ នៅកំពង់សោម គាត់បានបង្កើត គ្រប់គ្រង និងត្រួតពិនិត្យការដ្ឋាន និងមន្ទីរសន្តិសុខ និងបានគាំទ្រ និងអនុវត្តគោលនយោបាយស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរួមដំណេកដោយបង្ខំ។ គាត់បានរៀបចំផែនការ និងបានអនុវត្តការបោសសម្អាតកងទ័ពបដិវត្តន៍កម្ពុជា និងបានចូលរួមផ្ទាល់ក្នុងការចាប់ខ្លួន និងការបញ្ជូនខ្លួនសមាជិកកងពល ១៦៤ និង ១១៧ ទៅកាន់មន្ទីរសន្តិសុខ ស-២១។ គាត់ក៏បានចេញបញ្ជាឱ្យកំណត់អត្តសញ្ញាណ ចាប់ខ្លួន និងសម្លាប់ក្រុមគោលដៅដូចជា ជនជាតិវៀតណាម និង ថៃ ដោយមានចេតនាលុបបំបាត់ជនជាតិវៀតណាម ដែលគាត់ចាត់ទុកថាជាសត្រូវស្នូរពូជរបស់ខ្មែរ។ ស.ច.ស.អ ក៏បានសង្កត់ធ្ងន់ផងដែរលើការបោះចោលសាកសពដ៏គួរឱ្យតក់ស្លុត ធ្វើឡើងតាមបញ្ជារបស់ មាស មុត ដែលទង្វើនេះលើសពីកម្រិតខ្ពស់ "ធម្មតា" នៃភាពឃោរឃៅនៃរបបកម្ពុជាប្រជាធិបតេយ្យ។

ដីកាបញ្ជូនរឿងទៅជំនុំជម្រះបានរកឃើញថា មាស មុត ទទួលខុសត្រូវ*ជាអាទិ៍*ចំពោះ ១) ការសម្លាប់ជនជាតិថៃ យ៉ាងហោចណាស់ចំនួន ១.២០០ នាក់ និង **ជនជាតិវៀតណាម**ចំនួន ៣.២៧៦ នាក់ ដែលបានចាប់ខ្លួននៅក្នុងដែនទឹក និងតាមបណ្តាកោះដែលអះអាងដោយកម្ពុជាប្រជាធិបតេយ្យ ២) ការធ្វើឱ្យទៅជាទាសករក្នុងលក្ខខណ្ឌអមនុស្សធម៌នូវកម្មាភិបាលកងពល ១៦៤ ដែលត្រូវបានរំសាយ និងជនស៊ីវិលចំនួនជាង ១៥.០០០ នាក់ នៅតាមការដ្ឋាននៅ **ស្ទឹងហាវ** និងនៅក្នុង **តំបន់រាម** (រួមបញ្ចូលទាំង **បិតត្រាង** និង **ការដ្ឋានព្រលានយន្តហោះកងកេង**) ក្នុងតំបន់កំពង់សោម ៣) ការដាក់ក្នុងមន្ទីរឃុំឃាំងក្នុងលក្ខខណ្ឌអមនុស្សធម៌ និងការសម្លាប់នៅ **វត្តឥន្ទញាណ** និង **មន្ទីរសន្តិសុខទឹកសាប** ៤) ការសម្លាប់ជនជាតិថៃ វៀតណាម និងជនស៊ីវិល នៅ **ទីតាំងសម្លាប់មនុស្សចម្ការផុនន** ៥) ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈនៅក្នុងតំបន់កំពង់សោមទាំងមូល ៦) ការធ្វើទារុណកម្ម និងការសម្លាប់ជនជាតិថៃ និងជនជាតិវៀតណាម ដែលបានបញ្ជូនមក **មន្ទីរសន្តិសុខ ស-២១** និង ៧) ការសម្លាប់មនុស្សចំនួន ២.១៥២ នាក់ ក្នុងពេល**បោសសម្អាតកងទ័ពបដិវត្តកម្ពុជា** - នៅ **មន្ទីរសន្តិសុខ ស-២១** និង *នៅកន្លែងផ្ទាល់* - នៃកម្មាភិបាលយោធាមកពី **កងពល ១៦៤, ១១៧, ៥០២** និង ៣១០។

ក្នុងចំណោមពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ៦៤៦ ក្នុងសំណុំរឿង ០០៣ ស.ច.ស.អ ទទួលយកចំនួន ២២ ហើយ ស.ច.ស.ជ បដិសេធចោលទាំងអស់។

**បណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ៖** បន្ទាប់មក មានបណ្តឹងឧទ្ធរណ៍ខ្វែងគ្នាជាច្រើនប្រឆាំងដីកាដំណោះស្រាយទាំងពីរ។ នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៩ ស.ព.ជ បានប្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយជំទាស់ម្តងទៀតទៅនឹងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក លើ មាស មុត និងបានអះអាងថា យុត្តិធម៌ត្រូវបាននាំមកជូនជនរងគ្រោះរួចហើយនៅក្នុងសំណុំរឿង ០០១ និង ០០២។ នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩ ស.ព.អ និង មាស មុត បានដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួន។ ស.ព.អ បានស្នើសុំឱ្យបដិសេធចោលដីកាសម្រេចលើកលែងចោទប្រកាន់ ដោយសារមានកំហុសអង្គហេតុ និងអង្គច្បាប់ ដែលគាត់បានអះអាងថាបានធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តឆន្ទានុសិទ្ធិរបស់ ស.ច.ស.ជ លើ

យុត្តាធិការបុគ្គល និងថា រឿងក្តីត្រូវបន្តទៅជំនុំជម្រះ ដោយផ្អែកលើមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ បណ្តឹងឧទ្ធរណ៍របស់ មាស មុត មិនបានជំទាស់ទៅនឹងអង្គសេចក្តីនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះទេ ផ្ទុយទៅវិញគាំ ឱ្យលើកលែងចោទប្រកាន់សំណុំរឿង ០០៣ លើកលែងតែ តាមរយៈសំឡេងភាគច្រើនលើសលុប អ.ប.ជ តម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងបដិសេធដីកាសម្រេចលើកលែងចោទប្រកាន់។


E3/915

ថ្ងៃ ៣១.១២.៧៨

មុត

ទទួលថ្ងៃ ៣១.១២.៧៨ ម៉ោង ១៤.៣០នាទី

*ទូរលេខ ផ្ញើពី មាស មុត ទៅកាន់មន្ទីរ ៨៧០ អំពីការឈ្លានពានរបស់ខ្មាំងលើទឹកដីកម្ពុជា*
*© គេហទំព័រ អ.វ.ត.ក*

សវនាការលើបណ្តឹងឧទ្ធរណ៍ត្រូវបានធ្វើឡើងនៅថ្ងៃទី២៧ ដល់ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩។ នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១ អ.ប.ជ បានចេញសេចក្តីពិចារណារបស់ខ្លួន ដោយសម្រេចជាឯកច្ឆ័ន្ទ ដែលមានសំអាងហេតុដូចគ្នាក្នុងសំណុំរឿង ០០៤/២ ដែរ ថា ការចេញដីកាដំណោះស្រាយផ្ទុយគ្នាគឺខុសច្បាប់។ បន្ទាប់មកចៅក្រមទាំងប្រាំរូបនៃ អ.ប.ជ បានបញ្ជាក់សុពលភាពរបស់ដីកាដំណោះស្រាយ។ ចៅក្រមជាតិបានថ្លែងថា ទាំងដីកាសម្រេចលើកលែងចោទប្រកាន់ និងដីកាបញ្ជូនរឿងទៅជំនុំជម្រះ "មានសុពលភាព" ប៉ុន្តែសន្និដ្ឋានថា សំណុំរឿង ០០៣ គួរត្រូវតម្កល់ក្នុងបណ្ណសារដ្ឋាន អ.វ.ត.ក។ ចៅក្រមអន្តរជាតិបានរកឃើញថា ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គច្បាប់ និងអង្គហេតុយ៉ាងធ្ងន់ធ្ងរ និងត្រូវចាត់ទុកជាមោឃៈ និងគ្មានសុពលភាព ផ្អែកលើមូលដ្ឋានអង្គសេចក្តី និងនីតិវិធី (សូមមើលបន្ថែមទៀតខាងក្រោម៖ *ទិដ្ឋភាពពិសេសតែមួយគត់*)។ ពួកគាត់បានបដិសេធបណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ និងបានតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

នៅពេលពិនិត្យមើលការវាយតម្លៃលើយុត្តាធិការបុគ្គល ចៅក្រមអន្តរជាតិបានសន្និដ្ឋានថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះជាក់ស្តែងបានជាតំណាងតិចតួចដល់ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មរបស់ មាស មុត និងតួនាទីនិងការទទួលខុសត្រូវរបស់គាត់។ ចំពោះភាពធ្ងន់ធ្ងរ ចៅក្រមអន្តរជាតិបានសន្និដ្ឋានថា តាមរយៈការប្រើប្រាស់វិធីសាស្ត្រសមស្របសម្រាប់ការគណនាចំនួនជនរងគ្រោះ ទំនងជាបានធ្វើឱ្យចំនួននោះខ្ពស់ជាងនេះខ្លាំង។ ចំពោះតួនាទីរបស់ មាស មុត វិញ ចៅក្រមអន្តរជាតិគួសបញ្ជាក់មុខតំណែងរបស់គាត់នៅក្នុង **គណៈកម្មាធិការមជ្ឈិម**ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ *ទាំងមូល* មិនមែនតែក្នុងឆ្នាំ១៩៧៨ នោះទេ ដែលចាប់ផ្តើមពីជំនួយការក្នុង ឆ្នាំ១៩៧៥រហូតដល់ជាសមាជិកបម្រុងក្នុងឆ្នាំ១៩៧៨។

ពួកគាត់ក៏បានរកឃើញថា មាស មុត គឺជាមេដឹកនាំជាន់ខ្ពស់របស់កងទ័ពបដិវត្តន៍កម្ពុជាផងដែរ៖ ក្នុងឋានៈជា **មេបញ្ជាការកងពល ១៦៤ មេបញ្ជាការទ័ពជើងទឹក** និង**សមាជិក** *ពេញសិទ្ធិ* **នៃគណៈកម្មាធិការសេនាធិការ** ក្នុងរយៈពេលនៃរបបទាំងមូល ដែលរាយការណ៍ផ្ទាល់ទៅកាន់មជ្ឈិមបក្ស និងបានដឹកនាំការបោសសម្អាតជាច្រើនដោយផ្ទាល់ ហើយក្នុងឆ្នាំ១៩៧៨ មាស មុត ត្រូវបានតែងតាំងជា**អនុសេនាធិការ** របស់ សុន សេន ដោយបានផ្លាស់មកទីក្រុងភ្នំពេញ និងបានអនុវត្តការគ្រប់គ្រងលើសាខាទាំបីរបស់កម្លាំងកងទ័ពកម្ពុជាប្រជាធិបតេយ្យ។

ក្នុងបរិបទនៃការសម្រេចលើសុពលភាពនៃដីកាដំណោះស្រាយពីរក្នុងសំណុំរឿង ០០៣ ចៅក្រមអន្តរជាតិ បានពិចារណា និងបានជំទាស់ទាំងទៅនឹងសេចក្តីសន្និដ្ឋានរបស់ អ.ជ.ត.ក ក្នុងសំណុំរឿង ០០៤/២ ដែលថា អ.ជ.ស.ជ តាមផ្នែករដ្ឋបាលមិនទទួលបានសំណុំរឿង ០០៤/២ និងទាំងទៅនឹងការបញ្ចប់រឿងក្តីនោះ។ ផ្ទុយទៅនឹងការសន្និដ្ឋានរបស់ អ.ជ.ត.ក តាមទស្សនៈរបស់ចៅក្រមអន្តរជាតិ ១) អ.ជ.ស.ជ ទទួលបានរឿងក្តីតាមរយៈសេចក្តីពិចារណារបស់ អ.ប.ជ។ អ.ជ.ត.ក មានវិការៈផ្នែកច្បាប់តាមរយៈការប្រៀបប្រដូចទម្រង់ការផ្នែករដ្ឋបាលនៃការបញ្ជូនសំណុំរឿង ទៅនឹងរបាំងយុត្តាធិការមួយ ដែលរារាំងសកម្មភាពរបស់ អ.ជ.ស.ជ។ អ.ជ.ស.ជ គួរតែបានបង្គាប់ឱ្យមានការបញ្ជូននេះ ២) ការសម្រេចជាឯកច្ឆ័ន្ទរបស់ អ.ប.ជ ដែលថា *ការចេញ*ដីកាដំណោះស្រាយពីររបស់ ស.ច.ស គឺខុសច្បាប់ មិនបានធ្វើឱ្យដីកាដំណោះស្រាយទាំងពីរនោះទៅជាមោឃៈ និងគ្មានសុពលភាពនោះទេ។ សេចក្តីសន្និដ្ឋានរបស់ អ.ជ.ត.ក ដែលគ្មានសំអាងហេតុនេះមិនត្រឹមត្រូវនោះទេ ផ្អែកលើទិដ្ឋភាពច្បាប់ ហើយចៅក្រម អ.ប.ជ ទាំងប្រាំរូបបានផ្តល់យោបល់យ៉ាងត្រឹមត្រូវលើសុពលភាពដាច់ដោយឡែកពីគ្នានៃដីកាដំណោះស្រាយ ដោយពួកគាត់ម្នាក់ៗក្នុងចំណោមពួកគាត់រកឃើញថាយ៉ាងហោចណាស់ដីកាមួយមានសុពលភាព ៣) អ.ជ.ត.ក មិនមានសិទ្ធិអំណាចបញ្ចប់រឿងក្តីនៅក្នុងដំណាក់កាលមុនការជំនុំជម្រះ ដោយមិនមានដីកាដំណោះស្រាយមានសុពលភាពបានឡើយ និងដោយមិនបានឃើញសំណុំរឿងនោះឡើយ ៥) ការបញ្ចប់រឿងក្តីតាមអំពើចិត្ត មិនបានផ្តល់ឱ្យភាគី ឬជនរងគ្រោះនូវភាពច្បាស់លាស់ ឬភាពស្ថាពរនោះទេ។

នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ចៅក្រម អ.ប.ជ បានចេញសេចក្តីពិចារណារបស់ពួកគេ លើបណ្តឹងឧទ្ធរណ៍របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ដែលពួកគេបានបញ្ជាក់ថា ពួកគេទាំងប្រាំរូបបានសន្និដ្ឋានថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព។ ចៅក្រមជាតិបានរកឃើញថា ដោយយោងទៅលើការសម្រេចរបស់ពួកគាត់ដែលថា ដីកាដំណោះស្រាយទាំងពីរមានសុពលភាព និងថាសំណុំរឿង ០០៣ គួរតម្កល់ទុកក្នុងបណ្ណសារដ្ឋាន អ.វ.ត.ក ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី *ទាំងអស់*គួរត្រូវបានបដិសេធចោល។ ចៅក្រមអន្តរជាតិបានសម្រេចថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីប្រាំនាក់បន្ថែមទៀត គួរត្រូវបានទទួលយក។

**បណ្តឹងវិវាទបន្តបន្ទាប់៖** បន្ទាប់ពីសេចក្តីពិចារណារបស់ អ.ប.ជ សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំ ឱ្យ ស.ច.ស បញ្ជូនសំណុំរឿង ០០៣ ទៅ អ.ជ.ស.ជ ដោយសារតែ អ.ប.ជ បានតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះជាឯកច្ឆ័ន្ទ ឬជាជម្រើសម្យ៉ាងទៀត អនុលោមតាមគោលជំហរស្វ័យប្រវត្តិ ពីព្រោះយ៉ាងហោចណាស់ មិនមានសំឡេងភាគច្រើនលើសលុបរបស់ អ.ប.ជ បដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ ស.ច.ស បានចេញសេចក្តីសម្រេចរបស់ខ្លួន បដិសេធអំណះអំណាងដែលថា ចៅក្រម អ.ប.ជ

ទាំងប្រាំរូបបានរកឃើញថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព និងបានបដិសេធមិនអនុវត្តគោលជំហរស្វ័យប្រវត្តិ។ ដោយមិនមានសេចក្តីណែនាំច្បាស់លាស់ពី អ.ប.ជ ទេនោះ ស.ច.ស មិនបញ្ជូនរឿងក្តីឡើយ ដោយសន្យាថានឹងបញ្ចប់រឿងក្តីនេះ ប្រសិនបើមិនមានស្ថាប័នតុលាការណាមានឆន្ទៈបញ្ជូនវាទៅជំនុំជម្រះ ឬបញ្ចប់វាទេនោះ។



អ្នកទស្សនារង់ចាំសវនាការ អ.ប.ជ ក្នុងសំណុំរឿង ០០៣ © គេហទំព័រ អ.វ.ត.ក

នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១ មាស មុត បានស្នើសុំ អ.ប.ជ ឱ្យបញ្ចប់បោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារដ្ឋាន។ នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ ស.ព.អ បានស្នើសុំ អ.ប.ជ ឱ្យបិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធី ដោយបញ្ជូនរឿងក្តីទៅ អ.ជ.ស.ជ។ នៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២១ អ.ប.ជ បានចេញសេចក្តីសម្រេចរួម ដោយបាន





ប្រកាសថាសំណើទាំងពីរមិនអាចទទួលយកបាន។ អង្គជំនុំជម្រះបានសម្រេចជាឯកច្ឆ័ន្ទថា ខ្លួនបានបំពេញភារកិច្ចរបស់ខ្លួនស្របតាមក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក និងថា ស.ច.ស ទទួលខុសត្រូវចំពោះដំណើរការរឿងក្តីនេះស្របតាមវិធាន ៧៧(១៣) និង (១៤)នៃវិធានផ្ទៃក្នុង។

នៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០២១ មាស មុត បានស្នើសុំឱ្យ អ.ជ.ត.ក បញ្ចប់សំណុំរឿង ០០៣។ នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០២១ ស.ព.អ បានប្តឹងសាទុក្ខអំពីការខកខានរបស់ អ.ប.ជ ក្នុងការបញ្ជូនរឿងក្តីទៅជំនុំជម្រះ ដូចដែលបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក។ នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១ អ.ជ.ត.ក បានបញ្ចប់សំណុំរឿង ០០៣ ដែលជាសេចក្តីសម្រេចស្ថាពរ មិនអាចប្តឹងទាស់បាន។ លើកលែងតែយោបល់ជំទាស់មួយរបស់ចៅក្រម Clark អង្គជំនុំជម្រះសម្រេចថា សេចក្តីសម្រេចរួមរបស់ អ.ប.ជ មិនបានរកឃើញជាឯកច្ឆ័ន្ទថាដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាពនោះទេ បើទោះបីជាចៅក្រម អ.ប.ជ ម្នាក់ៗបានធ្វើការសន្និដ្ឋានជាឯកលក្ខណៈដូច្នោះក្តី។ បន្ទាប់ពីសំអាងហេតុរបស់ខ្លួននៅក្នុងសំណុំរឿង ០០៤/២ អ.ជ.ត.ក បានសន្និដ្ឋានថាអវត្តមានដីកាបញ្ជូនរឿងទៅជំនុំជម្រះស្ថាពរ និងដែលអាចអនុវត្តបាន និងការបញ្ជូនសំណុំរឿងទៅកាន់ អ.ជ.ស.ជ ផ្តល់យុត្តិកម្មដល់ការបញ្ចប់រឿងក្តីមុនពេលមានការសម្រេចណាមួយអាចធ្វើទៅបាន ទាក់ទងនឹងពិរុទ្ធភាពរបស់ មាស មុត។ ជាលទ្ធផល នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១ ស.ច.ស បានបញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារដ្ឋាន។

## ទិដ្ឋភាពពិសេសមានតែមួយ

**ការដកខ្លួនរបស់ ស.ច.ស.ជ ចេញពីកិច្ចស៊ើបសួរ៖** ស.ច.ស.ជ និង ស.ច.ស.អ Blunk បានចេញសេចក្តីជូនដំណឹងរបស់ខ្លួនអំពីការបិទបញ្ចប់ការស៊ើបអង្កេត នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ និង ខុសពីរឿងក្តីផ្សេងៗទៀត ស.ច.ស.ជ មិនបានចូលរួមជាមួយ ស.ច.ស.អ ក្នុងបិទការស៊ើបអង្កេតពេញលេញនៅឆ្នាំ២០១៧ នោះទេ។ ដីកាសម្រេចលើកលែងចោទប្រកាន់របស់គាត់បានផ្អែកលើតែភ័ស្តុតាងដែលប្រមូលបានមុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ប៉ុណ្ណោះ ហើយមិនបានពិចារណាលើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់ ស.ព.អ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ ឡើយ។ ចៅក្រមអន្តរជាតិ នៃ អ.ប.ជ បានរកឃើញថា ស.ច.ស.ជ បានប្រព្រឹត្តកំហុសអង្គច្បាប់ដ៏ធ្ងន់ធ្ងរ ក្នុង ១) ការរក្សាជំហរថាការស៊ើបអង្កេតពេញលេញនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ទោះបីជាមិនបានចេញដីកាដំណោះស្រាយនៅពេលនោះ និងទោះបីជា ស.ច.ស.អ បម្រុង បានបើកការស៊ើបអង្កេតឡើងវិញនៅខែធ្នូ ឆ្នាំ២០១១ និង ២) ដីកាសម្រេចលើកលែងចោទប្រកាន់របស់គាត់បានមើលរំលងការចោទប្រកាន់ផ្អែកអង្គហេតុជាច្រើន ដែលបានប្តឹងទៅគាត់ ក៏ដូចជា ភ័ស្តុតាងទាំងអស់ដែលប្រមូលបានក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ នៅក្នុងសំណុំរឿង នៅក្រោមការថែរក្សារបស់គាត់ ដែលរួមមានឯកសារ និងកំណត់ហេតុស្តាប់ចម្លើយសាក្សីជាក់លាក់នៃសំណុំរឿង០០៣ ជាច្រើនរយឯកសារ។ ចៅក្រមអន្តរជាតិបានសន្និដ្ឋានថា ដីកាសម្រេចលើកលែងចោទប្រកាន់ "មិនពេញលេញ" នេះ គ្មានសុពលភាពទេ តាមវិធាន ៦៧ នៃវិធានផ្ទៃក្នុង។

**កងកម្លាំងប្រដាប់អាវុធ ក្នុងឋានៈជា "ជនស៊ីវិល"៖** ដូចបានពិភាក្សានៅក្នុងផ្នែកយុត្តិសាស្ត្រ ស.ច.ស.អ Bohlander បានចេញសេចក្តីជូនដំណឹងមួយដែលសម្រេចថា តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចន្លោះឆ្នាំ១៩៧៥ និង ១៩៧៩ ការវាយប្រហារដោយរដ្ឋមួយ ឬអង្គការមួយ ប្រឆាំងនឹងកងកម្លាំងប្រដាប់អាវុធរបស់*ខ្លួនឯងផ្ទាល់* បង្កើតបានជាការវាយប្រហារប្រឆាំងនឹង "ជនស៊ីវិល" សម្រាប់គោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ លើកលែងតែកងកម្លាំងដែលត្រូវបានគេវាយប្រហារនោះ មានសម្ព័ន្ធភាពជាមួយនឹង ឬបានផ្តល់ការគាំទ្រពាក់ព័ន្ធផ្នែកយោធា ទៅឲ្យភាគីបដិបក្ខទៅនឹងជម្លោះប្រដាប់អាវុធ។

# សំណុំរឿង ០០៤

## យឹម ទិត្យ



**កិច្ចស៊ើបសួរតាមផ្លូវតុលាការ៖** នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ ស.ច.ស.អ បម្រុងបានជូនដំណឹងដល់ យឹម ទិត្យ ថាគាត់គឺជាជនសង្ស័យម្នាក់នៅក្នុងការស៊ើបអង្កេតនៃសំណុំរឿង ០០៤។ នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥ ស.ច.ស.អ បានចោទប្រកាន់គាត់ដោយផ្ទាល់អំពីបទប្រល័យពូជសាសន៍លើប្រជាជនខ្មែរក្រោម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរ និងការរំលោភក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ("ឧក្រិដ្ឋកម្មថ្នាក់ជាតិ")។ បន្ទាប់ពីការបង្កើតសំណុំរឿង ០០៤/១ (អ៊ុម ចែម ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៦) និង ០០៤/២ (អោ អាន ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦) សំណុំរឿង ០០៤ បានផ្តោតតែទៅលើរឿងក្តីប្រឆាំងនឹង យឹម ទិត្យ។

នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ គាត់ត្រូវបានចោទប្រកាន់អំពីទម្រង់បន្ថែមទៀតនៃការទទួលខុសត្រូវ លើសពីអ្វីដែលមានរៀបរាប់នៅក្នុងដីកាចោទប្រកាន់ដំបូងទាក់ទងនឹងឧក្រិដ្ឋកម្មដូចគ្នានេះ។

នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧ ស.ច.ស.អ បានជូនដំណឹងភាគីថា តាមវិធាន ៦៦ស្ទួន គាត់បានដកអង្គហេតុទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្ម និងព្រឹត្តិការណ៍ ចំនួន ១៥ ចេញពីការស៊ើបអង្កេត។ នៅថ្ងៃជាមួយគ្នានេះដែរ ស.ច.ស បានជូនដំណឹងទៅភាគីថា ពួកគាត់ពិចារណាថាការស៊ើបអង្កេតត្រូវបានបិទបញ្ចប់ហើយ។ ភាគីបានដាក់សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរជាច្រើន។ បន្ទាប់ពីបានបំពេញកិច្ចស៊ើបសួរលើសំណើសុំបានមួយចំនួនរួចមក នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៧ ស.ច.ស បានចេញសេចក្តីជូនដំណឹងលើកទីពីរ និងចុងក្រោយរបស់ខ្លួន ដែលបានបិទបញ្ចប់ការស៊ើបអង្កេត។

នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ ស.ព.ជ បានដាក់ដីកាសន្និដ្ឋានស្ថាពរ ដែលបានស្នើសុំឱ្យបដិសេធចោលរាល់ការចោទប្រកាន់ទាំងអស់ប្រឆាំងនឹង យឹម ទិត្យ ដោយសារមិនមានយុត្តាធិការបុគ្គល។ នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០៨ ស.ព.អ បានដាក់ដីកាសន្និដ្ឋានស្ថាពរ ដែលបានស្នើសុំឱ្យបញ្ជូនខ្លួន យឹម ទិត្យ ទៅជំនុំជម្រះចំពោះអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

**ដីកាដំណោះស្រាយ៖** នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ស.ច.ស ជាថ្មីម្តងទៀតបានចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា និងដីកាបន្ថែមមួយទៀតបង្គាប់ឱ្យបញ្ចប់សំណុំរឿង ០០៤ ដែលនៅសេសសល់ ក្នុងកម្រិតដែលថា

ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៦
បើកការស៊ើបអង្កេតបឋម

ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩
បើកការស៊ើបអង្កេតតាមផ្លូវតុលាការ

ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩
ចេញដីកាដំណោះស្រាយផ្ទុយគ្នា

ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១
អ.ប.ជ ចេញសេចក្តីពិចារណា

ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១
អ.ជ.ត.ក បដិសេធរឿងក្តី

ការចោទប្រកាន់ណាមួយរបស់ ស.ព.អ មិនត្រូវបានដោះស្រាយនៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០៤/១, ០០៤/២ ឬ ០០៤។ ស.ច.ស.ជ បានចេញដីកាសម្រេចលើកលែងចោទប្រកាន់ ដែលបានសន្និដ្ឋានថា អ.វ.ត.ក មិនមានយុត្តាធិការបុគ្គលលើ យឹម ទិត្យ ដែល "គ្មានតួនាទីសំខាន់ក្នុងបក្ស"។ ស.ច.ស.អ បានចោទប្រកាន់ យឹម ទិត្យ ចំពោះបទប្រល័យពូជសាសន៍លើប្រជាជនខ្មែរក្រោម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (អំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការនិរទេស អំពើអមនុស្សធម៌ផ្សេងៗទៀត និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងជាតិសាសន៍) ការបំពារបំពានយ៉ាងធ្ងន់ធ្ងរ និងឧក្រិដ្ឋកម្មថ្នាក់ជាតិ ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្ម និងព្រឹត្តិការណ៍ដែលកើតមាននៅក្នុងភូមិភាគពីររបស់របបកម្ពុជាប្រជាធិបតេយ្យ៖ ភូមិភាគពាយ័ព្យ និងភូមិភាគនិរតី។ ក្នុងការបង្កើតយុត្តាធិការបុគ្គល គាត់បានគូសបញ្ជាក់លើ "ការឡើងតំណែងយ៉ាងឆាប់រហ័ស" របស់ យឹម ទិត្យ ដែលបានជួយជ្រោមជ្រែងដោយចំណងគ្រួសាររបស់គាត់ជាមួយនឹង តាម៉ុក ដែលជាលេខាភូមិភាគនិរតី និងជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ក៏ដូចជា ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មរបស់គាត់នៅតាមទីតាំងឧក្រិដ្ឋកម្មជាង ២០ ទីតាំង។ តាមទស្សនៈរបស់ ស.ច.ស.អ ដូចក្នុងសំណុំរឿង ០០៤/២ និង ០០៣ ដែរ ការរៀបចំផែនការ និងការចូលរួមរបស់ យឹម ទិត្យ ក្នុងអំពើប្រល័យពូជសាសន៍ មានលក្ខណៈគ្រប់គ្រាន់ដើម្បីសន្និដ្ឋានលើយុត្តាធិការបុគ្គល។

ស.ច.ស.អ បានរកឃើញថា យឹម ទិត្យ គឺជាប្អូនថ្លៃរបស់ តាម៉ុក ហើយការទទួលខុសត្រូវរបស់គាត់បានកើនឡើងជាបន្តបន្ទាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដំបូងឡើយនៅក្នុងភូមិភាគនិរតី បន្ទាប់មកនៅក្នុងភូមិភាគពាយ័ព្យ។ ត្រឹមខែតុលា ឆ្នាំ១៩៧៥ គាត់ត្រូវបានតែងតាំងនៅក្នុង **គណៈកម្មាធិការស្រុកគិរីវង់** (តំបន់ ១៣ ភូមិភាគនិរតី) ដំបូងឡើយជាអនុលេខា ហើយបន្ទាប់មកជាលេខា ទោះជាយ៉ាងណាគាត់តែងតែមានសិទ្ធិអំណាច *ជាក់ស្តែង*បន្ថែមទៀត នៅក្នុងភូមិភាគនិរតីទាំងមូល ជាពិសេសដោយសារតែទំនាក់ទំនងរបស់គាត់ជាមួយ តាម៉ុក។ ដូចគ្នានឹង អ៊ឹម ចែម និង អោ អាន ដែរ តាម៉ុក ក្រោយមកបានជ្រើសរើស យឹម ទិត្យ ឱ្យទទួលខុសត្រូវលើកិច្ចការក្រៅភូមិភាគនិរតី។ ចាប់ពីពាក់កណ្តាលឆ្នាំ ១៩៧៦ យឹម ទិត្យ បានទៅកាន់ភូមិភាគពាយ័ព្យកាន់តែទៀងទាត់ ដោយបានបើកវគ្គអប់រំជាមួយ តាម៉ុក ទៅមើលការដ្ឋាន និងមន្ទីរសន្តិសុខ ធ្វើជាប្រធានអង្គប្រជុំ និងបានជួបជាប្រចាំថ្ងៃជាមួយនឹងលេខាភូមិភាគពាយ័ព្យ រស់ ញឹម។ នៅខែមិថុនា ឆ្នាំ១៩៧៨ គាត់ត្រូវបានតែងតាំងជាផ្លូវការជា **លេខាតំបន់ ១, ៣ និង ៤** នៅក្នុងភូមិភាគពាយ័ព្យ ដែលបានក្លាយជា "មនុស្សដែលមានអំណាចជាងគេទីពីរបន្ទាប់ពី តាម៉ុក" ដោយបានជំនួស រស់ ញឹម ក្នុងឋានៈជាលេខាភូមិភាគពាយ័ព្យ។ ចន្លោះខែមិថុនា និងខែកញ្ញា ឆ្នាំ១៩៧៨ យឹម ទិត្យ ត្រូវបានតែងតាំងនៅក្នុង **គណៈកម្មាធិការភូមិភាគពាយ័ព្យ**។

ភស្តុតាងចំនួន
~១០.២០០

ថ្ងៃសវនាការដោយ
ក.ស.ច.ស & អ.ប.ជ
ចំនួន ១ ថ្ងៃ

អ្នកដាក់ពាក្យជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន
២.០១៤ នាក់

ដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលយកដោយចៅក្រមអន្តរជាតិនៃ អ.ប.ជ
ចំនួន ១.០៧៧ នាក់

ស.ច.ស.អ បានសន្និដ្ឋានថា យឹម ទិត្យ បានចូលរួមក្នុងផែនការឧក្រិដ្ឋជាមួយ តាម៉ុក និងកម្មាភិបាលភូមិភាគនិរតីផ្សេងទៀត ដើម្បី ១) អនុវត្តគោលនយោបាយ

ឧក្រិដ្ឋរបស់ ប.ក.ក នៅក្នុងភូមិភាគពាយ័ព្យ ២) ដើម្បីលុបបំបាត់ប្រជាជនខ្មែរក្រោម ដែល ប.ក.ក ចាត់ទុកថាជាវៀតណាម ឬមានទំនាក់ទំនងជិតស្និទ្ធទៅនឹងវៀតណាម និង ៣) ដើម្បីពន្លឿនប្រព័ន្ធធ្វើបាបនៅមន្ទីរសន្តិសុខវត្តព្រះធាតុ (តំបន់ ១៣ ភូមិភាគនិរតី)។ យឹម ទិត្យ រួមគ្នាជាមួយ តាម៉ុក បានដើរតួនាទីដ៏សំខាន់នៅក្នុងការអនុវត្តគោលនយោបាយរបស់ ប.ក.ក នៅក្នុងភូមិភាគពាយ័ព្យ។ គាត់បានរៀបចំការបោសសម្អាតភូមិភាគពាយ័ព្យ និងបានផ្តល់នូវបទបញ្ជាជាក់លាក់ឱ្យចាប់ខ្លួន ឃុំខ្លួន និងសម្លាប់កម្មាភិបាលភូមិភាគពាយ័ព្យដែលគេដាក់រហ័សនាមគាត់ថា "អាតាទិត្យ"។ គាត់បានត្រួតត្រាលើសហករណ៍ការដ្ឋាន និងមន្ទីរសន្តិសុខ និងបានចូលរួមក្នុងពិធីរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ នៅក្នុងសុន្ទរកថារបស់គាត់ យឹម ទិត្យ បានបរិហារយ៉ាងស៊ីចង្វាក់ទៅលើជនជាតិវៀតណាម និងអ្នកណាដែលមានទំនាក់ទំនងជាមួយវៀតណាម ដោយបានលើកទឹកចិត្តឱ្យអ្នកនៅក្រោមបង្គាប់របស់គាត់ កំណត់អត្តសញ្ញាណខ្មែរក្រោមដើម្បីអាចសម្លាប់ពួកគេបាន។ ក្នុងឋានៈជាសមាជិកគណៈកម្មាធិការស្រុកគិរីវង់ គាត់បានគ្រប់គ្រងផ្ទាល់លើមន្ទីរសន្តិសុខវត្តព្រះធាតុ។

ដីកាបញ្ជូនរឿងទៅជំនុំជម្រះបានសន្និដ្ឋានថា យឹម ទិត្យ ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរាប់សិបពាន់ ដែលបានប្រព្រឹត្តឡើងនៅ៖

- មន្ទីរសន្តិសុខចំនួន ១៤៖ *ក្នុងតំបន់ ១៣ (ភូមិភាគនិរតី)*៖ **មន្ទីរសន្តិសុខវត្តព្រះធាតុ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខវត្តអង្គសិរីមុនី**។ *ក្នុងតំបន់ ១ (ភូមិភាគពាយ័ព្យ)*៖ **មន្ទីរសន្តិសុខគាស់ក្រឡ មន្ទីរសន្តិសុខបាណន់ មន្ទីរសន្តិសុខខ្នងគួ មន្ទីរសន្តិសុខធិបតី មន្ទីរសន្តិសុខទួលម្ទេស**។ *ក្នុងតំបន់ ២ (ភូមិភាគពាយ័ព្យ)*៖ **មន្ទីរសន្តិសុខភូមិវាល មន្ទីរសន្តិសុខស្វាយជ្រំ**។ *ក្នុងតំបន់ ៣ (ភូមិភាគពាយ័ព្យ)*៖ **មន្ទីរសន្តិសុខវត្តគិរីរម្យ**។ *ក្នុងតំបន់ ៤ (ភូមិភាគពាយ័ព្យ)*៖ **មន្ទីរសន្តិសុខវត្តសម្តេច មន្ទីរសន្តិសុខវត្តពោធិ៍លង្ការ/កាច់រទេះ**។ *ក្នុងតំបន់ ៧ (ភូមិភាគពាយ័ព្យ)*៖ **គុកលេខ ០៨**។
- ទីតាំងសម្លាប់មនុស្សចំនួន ៦៖ ក្នុង *តំបន់ ១៣ (ភូមិភាគនិរតី)*៖ **ទីតាំងសម្លាប់មនុស្សភូមិព្រៃល ទីតាំងសម្លាប់មនុស្សវត្តអង្គុញ ទីតាំងសម្លាប់មនុស្សព្រៃភូមិស្លែង ទីតាំងសម្លាប់មនុស្សព្រៃសុខុន**។ ក្នុង *តំបន់ ២ (ភូមិភាគពាយ័ព្យ)*៖ **ទីតាំងសម្លាប់មនុស្សទួលសេះញ៉ូវ ទីតាំងសម្លាប់មនុស្សព្រៃក្របៅ**។ *ក្នុងតំបន់ ៧ (ភូមិភាគពាយ័ព្យ)*៖ **ទីតាំងសម្លាប់មនុស្សវាលបាក់ជញ្ជីង**។
- ការដ្ឋាន និងសហករណ៍ជាច្រើន៖ ក្នុងតំបន់១ (ភូមិភាគពាយ័ព្យ)៖ **ការដ្ឋានទំនប់កង្កួត ការដ្ឋានរោងចក្រស្ករសកំពង់គល់ សហករណ៍ធិបតី រួមបញ្ចូលទាំងការដ្ឋានទួលម្ទេស**។ ក្នុងតំបន់ ៤ (ភូមិភាគពាយ័ព្យ)៖ **ឃុំកំពង់ព្រាង ឃុំរាំងកេសី** និង
- **ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ**ក្នុងស្រុកសំឡូត *តំបន់ ១ (ភូមិភាគពាយ័ព្យ)*។

កំណត់ហេតុស្តាប់ចម្លើយ
ចំនួន
១.៦៧១

ភាគីដាក់ឯកសារចំនួន
៦៣៩ ឯកសារ

សេចក្តីសម្រេចចំនួន
៩៧៩ ឯកសារ

សេចក្តីសម្រេចដោយសំឡេងភាគច្រើនលើសលុបចំនួន ៤២ ក្នុងចំណោមការសម្រេចចំនួន ៥៧ របស់ អ.ប.ជ

**ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី៖** ស.ច.ស.អ បានទទួលយកអ្នក

ដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១០៦៣ ក្នុងចំណោមអ្នកដាក់ពាក្យចំនួន ២០១៤ ក្នុងសំណុំរឿង ០០៤ ខណៈដែល ស.ច.ស.ជ បានដិសេធពួកគេទាំងអស់។ នៅដំណាក់កាលបណ្តឹងឧទ្ធរណ៍ អ.ប.ជ បានចេញសេចក្តីពិចារណានៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១។ ចៅក្រមជាតិបានពិចារណាថាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ គួរត្រូវបដិសេធចោល ចំណែកឯចៅក្រមអន្តរជាតិបានសន្និដ្ឋានថា អ្នកដាក់ពាក្យចំនួន ១៤ នាក់បន្ថែមទៀត គួរត្រូវបានទទួលយក។



គ្រោងឆ្អឹងមនុស្សនៅសេសសល់នៅប្ញជនីយដ្ឋាននៃការចងចាំនៅមន្ទីរសន្តិសុខក្រាំងតាចាន់
© គេហទំព័រ អ.វ.ត.ក
ស្លាក៖ សូមរក្សាការស្ងៀមស្ងាត់ដើម្បីចូលរួមគោរពវិញ្ញាណក្ខន្ធដល់បងប្អូនដែលបានបាត់បង់ជីវិតដោយការធ្វើទារុណកម្មរបស់បនក្បត់ជាតិ ប៉ុល ពត, អៀង សារី, ខៀវ សំផន

**បណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ៖** មានបណ្តឹងឧទ្ធរណ៍ខ្វែងគ្នាចំនួនប្រាំប្រឆាំនឹងដីកាដំណោះស្រាយ។ នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ ស.ព.ជ បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយជំទាស់ជាចម្បងទៅនឹងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក លើ យឹម ទិត្យ។ នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ យឹម ទិត្យ បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយពីរ ដោយស្នើសុំ អ.ប.ជ ឱ្យបដិសេធដីកាដំណោះស្រាយទាំងពីរ ដោយសារមានកំហុសអង្គច្បាប់ ក្នុងការចេញដីកាទាំងពីរដំណាលគ្នា និងសុំឱ្យបញ្ជូនសំណុំរឿងត្រឡប់ទៅ ស.ច.ស វិញ ឬចេញដីកាដំណោះស្រាយតែមួយដោយ អ.ប.ជ ខ្លួនឯងផ្ទាល់។ ក្នុងថ្ងៃជាមួយគ្នានេះដែរ យឹម ទិត្យ បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយចោទប្រកាន់អំពី ១) ការរំលោភលើសិទ្ធិជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌របស់ខ្លួន ២) វិការៈផ្នែកនីតិវិធីនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និង ៣) កំហុសដែលប៉ះពាល់ដល់ការអនុវត្តឆន្ទានុសិទ្ធិរបស់ ស.ច.ស.អ លើយុត្តាធិការបុគ្គល។ នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៩ ភាគីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ ហើយនៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស.ព.អ បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់។ ស.ព.អ បានស្នើសុំថា ដីកាសម្រេចលើកលែងចោទប្រកាន់ត្រូវតែបដិសេធចោល ដោយសារមានកំហុសអង្គច្បាប់ និងអង្គហេតុ ដែលគាត់អះអាងថាបានប៉ះពាល់ដល់ការអនុវត្តឆន្ទានុសិទ្ធិរបស់ ស.ច.ស.ជ លើយុត្តាធិការបុគ្គល និងថា រឿងក្តីត្រូវបន្តដំណើរការទៅជំនុំជម្រះ ផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភាគីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ការរកឃើញរបស់ ស.ច.ស.ជ ខ្លួនឯងផ្ទាល់ល្មមគ្រប់គ្រាន់ក្នុងការបង្កើតយុត្តាធិការបុគ្គល និងបានស្នើសុំស្រដៀងគ្នានេះដែរថា រឿងក្តីនេះត្រូវបញ្ជូនទៅជំនុំជម្រះ។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១ អ.ប.ជ បានសម្រេចក្នុងការធ្វើសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ផ្អែកលើសារណាជាលាយលក្ខណ៍អក្សររបស់ភាគីតែប៉ុណ្ណោះ ហើយនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ បានចេញសេចក្តីពិចារណារបស់ខ្លួន។ ដូចក្នុងសំណុំរឿង ០០៤/២ និង ០០៣ ដែរ ចៅក្រមបានសន្និដ្ឋានជាឯកច្ឆ័ន្ទថា ការចេញដំណាលគ្នានៃដីកាដំណោះស្រាយពីរខ្វែងគ្នា គឺខុសច្បាប់។ បន្ទាប់មក ចៅក្រមបានពិចារណាលើសុពលភាពនៃដីកាដំណោះស្រាយនីមួយៗ ប៉ុន្តែខកខានមិនអាចរកសំឡេងភាគច្រើនលើសលុបបានដើម្បីបដិសេធ ឬតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាសម្រេចលើកលែងចោទប្រកាន់។

ចៅក្រមជាតិបានសន្និដ្ឋានថា ការទម្លាក់ការចោទប្រកាន់សំណុំរឿង ០០៤ ប្រឆាំងនឹង យឹម ទិត្យ "គឺត្រឹមត្រូវ" ដោយបានបិទបញ្ចប់រឿងក្តីនេះ និងបញ្ជូនវាទៅតម្កល់ក្នុងបណ្ណសារដ្ឋាន អ.វ.ត.ក។ តាមទស្សនៈរបស់ពួកគាត់ យុត្តាធិការបុគ្គលរបស់ អ.វ.ត.ក កំណត់ត្រឹមតែចុងចោទចំនួនប្រាំនាក់នៅក្នុងសំណុំរឿង ០០១ និង ០០២ និងថា ស.ព.អ បានផ្តួចផ្តើមឲ្យមានការស៊ើបអង្កេតបឋមក្នុងសំណុំរឿង ០០៤ ជាឯកតោភាគី និងដោយសម្ងាត់ ដែលនាំឲ្យសំណុំរឿងទាំងមូលខុសច្បាប់។ ស.ព.អ បានកត់សម្គាល់ថា ការរកឃើញចុងក្រោយនេះផ្ទុយទៅនឹងភស្តុតាងនីតិវិធីដែលមាន ហើយវិការៈណាមួយត្រូវបានជួសជុលដោយដំណើរការទៅមុខនៃកិច្ចដំណើរការនីតិវិធីអស់រយៈពេល ១៣ ឆ្នាំកន្លងមក។

ចៅក្រមអន្តរជាតិបានបដិសេធអំណះអំណាងរបស់ យឹម ទិត្យ ដែលថាដីកាដំណោះស្រាយទាំងពីរទៅជាមោឃៈ តាមរយៈការសន្និដ្ឋានរបស់ អ.ប.ជ ដែលថាការចេញដីកាដំណោះស្រាយពីរគឺខុសច្បាប់ ហើយសម្រាប់សំអាងហេតុដូចគ្នានឹងសំណុំរឿង ០០៤/២ ដែរ ចៅក្រមអន្តរជាតិបានសន្និដ្ឋានថា ដីកាសម្រេចលើកលែងចោទប្រកាន់ *ហួសដែនសមត្ថកិច្ច*និងត្រូវមោឃភាពចោល ហើយដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាពផ្នែកនីតិវិធី។ ដោយបានច្រានចោលបណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ និងមូលដ្ឋានទាំងអស់នៃបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ចៅក្រមអន្តរជាតិក៏បានសន្និដ្ឋានថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាពផ្នែកអង្គសេចក្តី។ ដោយសារតែដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនត្រូវបានបដិសេធដោយសំឡេងភាគច្រើនលើសលុប ចៅក្រមអន្តរជាតិសម្រេចថា សំណុំរឿង ០០៤ គួរត្រូវបញ្ជូនទៅ អ.ជ.ស.ដ អនុលោមតាមវិធាន ៧៧(១៣)(ខ)។ ពួកគាត់ក៏បញ្ជាក់ឡើងវិញអំពីកាតព្វកិច្ចរបស់អាជ្ញាធរកម្ពុជាក្រោមច្បាប់អន្តរជាតិ ក្នុងការចោទប្រកាន់ជនទាំងឡាយណាដែលត្រូវបានចោទអំពីអំពើប្រល័យពូជសាសន៍ ដូចជា មាស មុត និង យឹម ទិត្យ ក្នុងករណីដែល អ.វ.ត.ក ខកខានមិនបានអនុវត្តយុត្តាធិការ។

**បណ្តឹងវិវាទបន្តបន្ទាប់៖** ដោយហេតុថាសេចក្តីពិចារណារបស់ អ.ប.ជ ឆ្លុះបញ្ចាំងពីបញ្ហានានាដែលបានចេញនៅក្នុងសំណុំរឿង ០០៤/២ (និងមួយផ្នែកធំ សំណុំរឿង ០០៣) ការជាប់គាំងផ្នែកនីតិវិធីគឺមិនអាចចៀសរួចនោះទេ។ នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ យឹម ទិត្យ បានដាក់សំណើមួយសុំឲ្យ ស.ច.ស បញ្ចប់បោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៤ ទៅក្នុងបណ្ណសារដ្ឋានជាបន្ទាន់។ នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ ស.ព.អ បានប្តឹងរឿងក្តីនេះផ្ទាល់ទៅកាន់ អ.ជ.ត.ក ដោយបានប្តឹងសាទុក្ខអំពីការខកខានរបស់ អ.ប.ជ ក្នុងការបញ្ជូនសំណុំរឿង ០០៤ ទៅ អ.ជ.ស.ដ ដើម្បីធ្វើការជំនុំជម្រះ។

នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ អ.ជ.ត.ក បានបដិសេធបណ្តឹងសាទុក្ខរបស់ ស.ព.អ ដោយសំអាងលើមូលហេតុស្រដៀងគ្នានឹងសំណុំរឿង ០០៣។ លើកលែងតែមតិ

ជំទាស់របស់ចៅក្រម Clark អ.ជ.ត.ក បានសន្និដ្ឋានថា អវត្តមានដីកាបញ្ជូនរឿងទៅជំនុំជម្រះស្ពាពរ និងដែលអាចអនុវត្តបាន បន្ទាប់ពីសេចក្ដីសម្រេចរបស់ អ.ប.ជ ដែលថា ការចេញដីកាដំណោះស្រាយពីរគឺខុសច្បាប់នោះ វាផ្ដល់យុត្តិកម្មដល់ការបញ្ចប់រឿងក្ដី មុនពេលមានការកំណត់ណាមួយអាចធ្វើទៅបានអំពីពិរុទ្ធភាពរបស់ យឹម ទិត្យ។ សេចក្ដីសម្រេចរបស់ អ.ជ.ត.ក គឺចុងក្រោយ និងមិនអាចប្ដឹងទាស់បានទេ។ នៅថ្ងៃបន្ទាប់ ស.ច.ស បានបោះត្រា និងបញ្ចូលរឿងក្ដីនេះក្នុងបណ្ណសារដ្ឋាន។

## ទិដ្ឋភាពពិសេសមានតែមួយ

**អំពើហិង្សាផ្លូវភេទនៅក្រៅបរិបទអាពាហ៍ពិពាហ៍ដោយបង្ខំ:** ដូចបានពិភាក្សានៅក្នុងផ្នែកយុត្តិសាស្ត្រ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ ស.ព.អ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម បានប្ដឹងទៅ ស.ច.ស អំពីអង្គហេតុនានាទាក់ទងនឹងអំពើហិង្សាផ្លូវភេទ នៅគុកលេខ ០៨ (តំបន់ ៧ ភូមិភាគពាយ័ព្យ) និងក្នុងស្រុកបាកាន (តំបន់ ២ ភូមិភាគពាយ័ព្យ) ដែលតាមការចោទប្រកាន់បានប្រព្រឹត្តឡើងប្រឆាំងនឹងប្រជាជនជម្លៀសមកពីភូមិភាគបូព៌ា និង ស្ត្រីខ្មែរក្រោម។ ក្នុងអំឡុងពេលកិច្ចស៊ើបសួរ ទាំង ស.ច.ស.អ និង ស.ច.ស.ជ បានធ្វើការសន្និដ្ឋានថា ស្ត្រីទាំងនោះត្រូវបានគេរំលោភសេពសន្ថវៈមុនពេលសម្លាប់ ប៉ុន្តែចៅក្រមទាំងពីរមិនបានសន្និដ្ឋានថា យឹម ទិត្យ ទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មទាំងនេះទេ។

# ប្រភព និងលក្ខណៈនៃភស្តុតាង

ក.ស.ព, ស.ច.ស, អ.ជ.ស.ជ និង អ.ជ.ត.ក បានប្រមូល និងផ្អែកលើប្រភេទជាច្រើននៃភស្តុតាងឯកសារ ដែលបានបង្កើតឡើងនៅមុនពេល ក្នុងអំឡុងពេល និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាចម្លើយ និងសក្ខីកម្មរាប់ពាន់។

សំណាងល្អ **ភស្តុតាងឯកសារ**មួយចំនួនធំពីប្រភពផ្សេងៗ ត្រូវបានផ្តល់ជូនដល់ អ.វ.ត.ក។ នៅឆ្នាំ ១៩៧៩ និងដើមទសវត្សរ៍ឆ្នាំ ១៩៨០ ភស្តុតាងដ៏ច្រើនដែលបង្កើតឡើងដោយ ប.ក.ក ខ្លួនឯង ត្រូវបានគេរកឃើញពីទីតាំងផ្សេងៗក្នុងប្រទេសកម្ពុជា រួមទាំងមន្ទីរសន្តិសុខ ស-២១ និងផ្ទះរបស់កម្មាភិបាលជាន់ខ្ពស់ ប.ក.ក នៅភ្នំពេញ។ វាត្រូវបានថែរក្សាដោយស្ថាប័នឯកជន និងអង្គភាពរដ្ឋាភិបាលជាច្រើន រួមទាំងមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរទួលស្លែង (នៅអតីតទីតាំង ស-២១) ក្រសួងមហាផ្ទៃរបស់រដ្ឋាភិបាលកម្ពុជា និងបណ្ណាសារដ្ឋានជាតិកម្ពុជា។ ការរួមចំណែកមិនអាចកាត់ថ្លៃបានរបស់ DC-Cam មានសារៈសំខាន់ខ្លាំងចំពោះការងាររបស់ អ.វ.ត.ក.។ DC-Cam បានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ភស្តុតាងដល់តុលាការ ដោយធ្វើឱ្យមានឯកសារយ៉ាងច្រើនដែលទទួលបានតាមរយៈការស្រាវជ្រាវយ៉ាងល្អិតល្អន់ រួមទាំងឯកសារ ប.ក.ក. និងសម្ភារៈសហសម័យបរទេស ដូចជា របាយការណ៍ប្រព័ន្ធផ្សព្វផ្សាយ ឯកសារអង្គការសហប្រជាជាតិ និងទូរលេខបរទេស រួមជាមួយនឹងបទសម្ភាសន៍ជនរងគ្រោះ និងកម្មាភិបាល ប.ក.ក. ជាច្រើននាក់។ តុលាការក៏ទទួលបានភស្តុតាងសហសម័យមួយចំនួនពីអ្នកស្រាវជ្រាវជាន់ខ្ពស់ រួមមាន Christopher Goscha, Sydney Schanberg និង Walter Heynowski។ ទោះជាមានការស្នើសុំជាច្រើនលើកពីចៅក្រម អ.វ.ត.ក ក៏ដោយ ក៏ប្រទេសថៃ និងវៀតណាម មិនបានផ្តល់ឱ្យតុលាការនូវឯកសារបណ្ណសាររបស់ពួកគេ ដែលទាក់ទងនឹងកម្ពុជាប្រជា ធិបតេយ្យ នោះទេ។



*បញ្ជីឈ្មោះអ្នកទោស ស-២១ មានឈ្មោះអ្នកទោសដែលបានកំណត់ប្រភេទថាជាប្រជាជនខ្មែរកម្ពុជាក្រោម © គេហទំព័រ អ.វ.ត.ក*

ដូចដែល អ.ជ.ស.ជ បានកត់សម្គាល់នៅក្នុងសំណុំរឿង ០០២/០២ ឯកសារសហសម័យ ជាពិសេសឯកសារ ប.ក.ក គឺជា "ប្រភពភស្តុតាងដ៏សំខាន់បំផុតមួយចំនួន" ដោយសារតែការកន្លងផុតទៅនៃពេលវេលា ចាប់តាំងពីសម័យកម្ពុជាប្រជាធិបតេយ្យ។ ភស្តុតាង ប.ក.ក ដ៏គួរជឿជាក់បំផុត រួមមាន៖ (i) កំណត់ហេតុកិច្ចប្រជុំនៃគណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មាធិការមជ្ឈិម និងសេនាធិការកងទ័ពបដិវត្តន៍កម្ពុជា (ii) សុន្ទរកថា និងសេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ

(iii) សេចក្តីណែនាំរបស់ ប.ក.ក (iv) ការប្រាស្រ័យទាក់ទងជាលាយលក្ខណ៍អក្សរ រវាងនិងនៅក្នុងចំណោមអាជ្ញាធរ ប.ក.ក ផ្សេងៗទៀត (v) បណ្ណសារពាណិជ្ជកម្ម (vi) កំណត់ត្រា ស-២១ និង មន្ទីរសន្តិសុខក្រាំងតាចាន់ រួមទាំង បញ្ជីអ្នកទោស "ចម្លើយសារភាព" បញ្ជីសម្លាប់ និងជីវប្រវត្តិជនរងគ្រោះ និង (vii) ការបោះពុម្ពផ្សាយរបស់ ប.ក.ក ដូចជា ទស្សនាវដ្តីឃោសនា ការផ្សាយតាមវិទ្យុ និងភាពយន្តឃោសនា និងរូបថត។

ភស្តុតាងនេះ គឺមានសារៈសំខាន់សម្រាប់ការបង្ហាញពីគោលនយោបាយឧក្រិដ្ឋរបស់ ប.ក.ក រចនាសម្ព័ន្ធឋានានុក្រមរបស់វា និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនត្រូវចោទ/ជនជាប់ចោទ។ ដូចនេះ វាមានសារៈសំខាន់ណាស់សម្រាប់វាល់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់ ក.ស.ព និងបានផ្តល់មូលដ្ឋានភស្តុតាងយ៉ាងសំខាន់សម្រាប់ការចោទប្រកាន់ និង/ឬ ផ្តន្ទាទោសមេដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យ គឺ នួន ជា, អៀង សារី, ខៀវ សំផន និង អៀង ធីរិទ្ធ និងកម្មាភិបាលជាន់ខ្ពស់ពីររូប គឺ ឌុច និង មាស មុត។ ឧទាហរណ៍ ក្នុងសំណុំរឿង ០០២/០២ ក្នុងចំណោមឯកសារចំនួន ១០.៨០៤ ដែលត្រូវបានទទួលយក មានប្រមាណ ៣៧០០ ជាសម្ភារសហសម័យរបស់ ប.ក.ក។

ចៅក្រម អ.វ.ត.ក បានអនុញ្ញាតឱ្យប្រើប្រាស់ "ចម្លើយសារភាព" របស់ ស-២១ ដែលទទួលបានក្រោមការធ្វើទារុណកម្មលើមូលដ្ឋានមានកំណត់ នេះបើយោងតាមការបកស្រាយរបស់ពួកគេនៃមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្ម (CAT) ។ "ចម្លើយសារភាព" ទាំងនេះ ត្រូវបានពិចារណាសម្រាប់តែអង្គហេតុដែលចម្លើយសារភាពត្រូវបានបង្កើតឡើងប៉ុណ្ណោះ មិនមែនសម្រាប់ការពិតនៃខ្លឹមសាររបស់វាទេ លើកលែងតែវាទាក់ទងនឹងព័ត៌មានកំណត់អត្តសញ្ញាណជាមូលដ្ឋាន ដូចជាអត្តសញ្ញាណអ្នកទោស និងកាលបរិច្ឆេទនៃការចាប់ខ្លួន។ ចំណាររបស់អ្នកធ្វើទារុណកម្ម ឬកម្មាភិបាល ប.ក.ក ត្រូវបានប្រើប្រាស់ជាភស្តុតាងដោយសារតែឯកសារទាំងនេះ មិនមែនជាផ្នែកនៃចម្លើយរបស់អ្នកទោស។ សៀវភៅកត់ត្រា និងសៀវភៅកំណត់ហេតុអ្នកទោសពីមន្ទីរសន្តិសុខនានាក៏អាចពឹងផ្អែកផងដែរ ដរាបណាឯកសារទាំងនេះមិនត្រូវបានយកមកប្រើដើម្បីបង្ហាញការពិតនៃចម្លើយ ដែលធ្វើឡើងដោយអ្នកដែលទទួលរងការធ្វើទារុណកម្ម។

**ភស្តុតាងសក្ខីកម្ម** រួមទាំងពីអ្នកជំនាញ និងជនរងគ្រោះ សាក្សី និងអ្នកចូលរួមក្នុងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ រួមទាំង ដើមបណ្តឹងរដ្ឋប្បវេណី ជនសង្ស័យ ជនជាប់ចោទ និងទណ្ឌិត ក៏មានសារៈសំខាន់ផងដែរនៅក្នុងការស៊ើបអង្កេត និងការជំនុំជម្រះទាំងអស់របស់ អ.វ.ត.ក។ ដោយហេតុថា ជនរងគ្រោះ និងសាក្សីសំខាន់ៗមួយចំនួននៃឧក្រិដ្ឋកម្ម ក៏ដូចជាបញ្ហាពាក់ព័ន្ធនឹងពិរុទ្ធភាពរបស់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់ចម្លើយទៅកាន់ ស.ច.ស និងផ្តល់សក្ខីកម្ម



*ព្រះសង្ឃ ឯម មឿង ផ្តល់សក្ខីកម្មក្នុងនាមជាសាក្សី នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥*
*© គេហទំព័រ អ.វ.ត.ក*

នៅក្នុងកិច្ចដំណើរការនីតិវិធីរបស់តុលាការ។ ដូចគ្នានឹងជនជាប់ចោទដែរ ពួកគេមិនបានផ្តល់សក្ខីកម្មនៅក្រោមសម្បថទេ ដែលជាកត្តាមួយត្រូវបានពិចារណានៅពេលវាយតម្លៃលើភាពជឿជាក់បាននៃសក្ខីកម្មរបស់ពួកគេ។

ទោះជាយ៉ាងណាក៏ដោយ ការទទួលបាន និងការវាយតម្លៃភ័ស្តុតាងនេះ បានបង្កបញ្ហាប្រឈមជាច្រើន ឧទាហរណ៍ អំណាចអនុវត្តទន់ខ្សោយរបស់ អ.វ.ត.ក ធៀបនឹងសាក្សីមិនសហការ បានបង្ហាញឱ្យឃើញច្បាស់ នៅពេលដែលមន្ត្រីជាន់ខ្ពស់កម្ពុជា រួមទាំង អតីតព្រះមហាក្សត្រ នរោត្តម សីហនុ ផង បានបដិសេធមិនឆ្លើយតប ឬអនុវត្តតាមការកោះហៅរបស់តុលាការ ដើម្បីផ្តល់ភ័ស្តុតាង។ លើសពីនេះ នៅគ្រប់រឿងក្តីទាំងអស់ អតីតកម្មាភិបាល ប.ក.ក. និងចារី តែងតែស្ទាក់ស្ទើរក្នុងការផ្តល់ចម្លើយ ឬផ្តល់សក្ខីកម្ម និង/ឬព្យាយាមកាត់បន្ថយការចូលរួមរបស់ពួកគេនៅក្នុងឧក្រិដ្ឋកម្ម ទោះបីជាមានការធានាពីការមិនចោទប្រកាន់ក៏ដោយ។ នួន ជា, ខៀវ សំផន និង អៀង សារី បានបដិសេធការចោទប្រកាន់ ហើយភាគច្រើនបានបដិសេធមិនផ្តល់សក្ខីកម្មនៅក្នុងសវនាការ។ យ៉ាងណាក៏ដោយ ខៀវ សំផន បានផ្តល់ភ័ស្តុតាងមួយចំនួនអំពី ប.ក.ក និងគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិម ក្នុងអំឡុងពេលស៊ើបអង្កេតសំណុំរឿង ០០២។ នៅដើមដំបូងនៃការជំនុំជម្រះសំណុំរឿង ០០២/០១ នួន ជា បានពិភាក្សាអំពីកិច្ចប្រជុំមុនខែមេសា ឆ្នាំ១៩៧៥ ដែលបានសម្រេចលើការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ ការទទួលស្គាល់ទាំងនោះ និងសេចក្តីថ្លែងការណ៍ផ្សេងទៀតពីជនជាប់ចោទនៅក្នុងសៀវភៅ ការសម្ភាសន៍ និងខ្សែភាពយន្ត រវាងឆ្នាំ ១៩៧៩ និងការជំនុំជម្រះរបស់ អ.វ.ត.ក ត្រូវបានប្រើជាភ័ស្តុតាងប្រឆាំងនឹងពួកគេ។

ឌុច មានភាពលេចធ្លោជាករណីលើកលែងចំពោះការស្ទាក់ស្ទើរក្នុងការផ្តល់ភ័ស្តុតាងនេះ ដោយគាត់បានផ្តល់ភ័ស្តុតាងយ៉ាងទូលំទូលាយដល់ ស.ច.ស និង អ.ជ.ស.ជ ក្នុងការជំនុំជម្រះផ្ទាល់របស់គាត់ និងក្នុងការជំនុំជម្រះពីរផ្សេងទៀត។ ការទទួលស្គាល់របស់គាត់មានសារសំខាន់ខ្លាំងក្នុងចំណោមភ័ស្តុតាងដែលប្រើក្នុងការផ្តន្ទាទោសគាត់នៅក្នុងការជំនុំជម្រះក្តីរបស់គាត់។ នៅក្នុងការជំនុំជម្រះសំណុំរឿង ០០២ ចំនួនពីរ ក៏ដូចជាអំឡុងពេលស៊ើបអង្កេតសំណុំរឿង ០០៣ និង ០០៤ ភ័ស្តុតាងរបស់គាត់ត្រូវបានពឹងផ្អែកយ៉ាងខ្លាំង ដើម្បីបញ្ជាក់ការពិតលើឯកសារ ស-២១ រួមទាំងចំណារបស់ នួន ជា និង សុន សេន លើចម្លើយសារភាព ស-២១ និងដើម្បីបង្ហាញពីលក្ខខណ្ឌនៃការឃុំខ្លួន ការធ្វើទារុណកម្ម និងការប្រហារជីវិត ក៏ដូចជារចនាសម្ព័ន្ធអំណាចរបស់ ប.ក.ក សម្រាប់មន្ទីរ ស-២១។




*លោកសាស្ត្រាចារ្យ David Chandler ផ្តល់សក្ខីកម្មក្នុងនាមជាអ្នកជំនាញ នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១២ © គេហទំព័រ អ.វ.ត.ក*

# ផ្នែក III÷ សមិទ្ធផល

# គណនេយ្យភាព

ឯកសារមូលដ្ឋានគោលរបស់ អ.វ.ត.ក បញ្ជាក់ច្បាស់អំពីអាណត្តិរបស់តុលាការ៖ ក្នុងគោលបំណងវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់មនុស្សធម៌អន្តរជាតិនិងទម្លាប់អន្តរជាតិ និងអនុសញ្ញាអន្តរជាតិដែលទទួលស្គាល់ដោយប្រទេសកម្ពុជា ដែលបានប្រព្រឹត្តឡើងក្នុងអំឡុងចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ (ច្បាប់ អ.វ.ត.ក មាត្រា ១ កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១)។

ទោះបីជាមានបញ្ហាប្រឈមដែលបានបង្ហាញ រួមទាំងការចរចាជាច្រើនឆ្នាំលើលក្ខខណ្ឌនៃការបង្កើត និងការលំបាកយ៉ាងខ្លាំងក្នុងការសម្រេចបានវិធានផ្ទៃក្នុងដែលឯកភាពគ្នាក៏ដោយ អ.វ.ត.ក បានផ្តល់យុត្តិធម៌លើសពីអ្វីដែលបានរំពឹងទុក។ ឌុច ត្រូវបានកាត់ទោសពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរ ហើយចុងក្រោយត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិត។ នួន ជា បាននៅរស់ឃើញការបញ្ចប់ការជំនុំជម្រះ និងបណ្តឹងសាទុក្ខលើកទីមួយរបស់គាត់ និងសាលក្រមរបស់ អ.ជ.ស.ដ ប្រឆាំងនឹងគាត់ក្នុងការជំនុំជម្រះលើកទីពីរ ដែលជាលទ្ធផលនាំឱ្យមានការផ្តន្ទាទោសពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរ និងការផ្តន្ទាទោសមួយជីវិតចំនួនពីរដង។ ការជំនុំជម្រះ និងបណ្តឹងសាទុក្ខចំនួនពីររបស់ ខៀវ សំផន ត្រូវបានបញ្ចប់ ដូចគ្នានឹង នួន ជា ដែរ គាត់ក៏ត្រូវបានកាត់ទោសពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរផងដែរ។ អ.ជ.ត .ក បានកាត់ទោសដាក់ពន្ធនាគារអស់មួយជីវិតជាលើកទីពីរក្នុងសាលដីកាសំណុំរឿង ០០២/០២ របស់ខ្លួនដែលដំណើរការស្របគ្នាជាមួយនឹងទោសមួយជីវិតដែលខៀវ សំផន បានទទួលក្នុងសំណុំរឿង ០០២/០១។ គាត់នឹងចំណាយពេលសេសសល់នៃជីវិតរបស់គាត់ក្នុងពន្ធនាគារ។

ការផ្តន្ទាទោសទាំងនេះបង្កើតការទទួលខុសត្រូវតាមផ្លូវតុលាការចំពោះឧក្រិដ្ឋកម្ម ដែលបុរសទាំងនេះបានចូលរួមដោយចេតនា និងដោយឆន្ទៈ បន្ថែមលើគោលនយោបាយឧក្រិដ្ឋរបស់ខ្មែរក្រហម ដែលរួមមាន៖ i) ការគ្រប់គ្រងប្រជាជនកម្ពុជាតាមរយៈការបង្ខំឱ្យផ្លាស់ទីលំនៅទៅកាន់សហករណ៍ និងការដ្ឋាន និងធ្វើជាទាសករនៅក្នុងសហករណ៍ និងការដ្ឋាន ដែលជាទីមនុស្សជាច្រើនបានស្លាប់ ដោយសារតែលក្ខខណ្ឌដ៏អាក្រក់ដែលបានដាក់លើពួកគេ រួមមានពលកម្មដោយបង្ខំ និងកង្វះអាហារ និងការថែទាំវេជ្ជសាស្ត្រគ្រប់គ្រាន់។ ii) ការកំណត់អត្តសញ្ញាណ និងចាប់អ្នកដែលគេយល់ថាជាខ្មាំងរបស់ខ្មែរក្រហម រួមទាំងអតីតមន្ត្រីសាធារណៈរដ្ឋខ្មែរ ចាម វៀតណាម ហើយបានផ្តន្ទាទោសពួកគេដោយការធ្វើទារុណកម្ម និងការស្លាប់នៅក្នុងមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស និង iii) ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការបង្ខំឱ្យរួមដំណេកក្នុងអាពាហ៍ពិពាហ៍ទាំងនោះ។ ការជំនុំជម្រះទាំងនេះបាននាំមកនូវការពិតយ៉ាងមុតមាំអំពី ការស្លាប់ និងការបំផ្លិចបំផ្លាញដែលមនុស្សទាំងនេះ រួមជាមួយនឹងមនុស្សជាច្រើនទៀត បានធ្វើបាបដល់ជនរួមជាតិកម្ពុជារបស់ខ្លួន ឈ្លើយសឹក និងជនស៊ីវិលជាជនជាតិវៀតណាម ជនជាតិថៃ និងជនបរទេសដទៃទៀត ដោយមិនលើកលែង ទាំងក្មេង ឬចាស់ បុរស ស្ត្រី ឬកុមារឡើយ។

ការសម្រេចរបស់តុលាការទាំងនេះ គឺជាសមិទ្ធផលដ៏សំខាន់មួយរបស់តុលាការ ដោយបំពេញតាមតម្រូវការជាមូលដ្ឋានរបស់មនុស្ស៖ ដាក់ជនដែលមានការទទួលខុសត្រូវខ្ពស់បំផុតមួយចំនួន ឲ្យទទួលខុសត្រូវចំពោះការបង្កព្យសនកម្មដ៏ធ្ងន់ធ្ងរបំផុត ដែលជាតម្រូវការដែលត្រូវតែឆ្លើយតបដើម្បីឲ្យជនរងគ្រោះ ក្រុមចារី និង សង្គម ចេញឆ្ងាយពីឧក្រិដ្ឋកម្មដ៏អាក្រក់ទាំងនេះ។ ដំណើរស្វែងរកគណនេយ្យភាពនេះត្រូវបានលើកពីបុគ្គលទៅជាក្រុម ពីក្រុមទៅជារដ្ឋ ហើយឥឡូវនេះ ទៅកាន់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការព្រហ្មទណ្ឌអន្តរជាតូបនីយកម្ម ដោយកិច្ចព្រមព្រៀងរវាងរដ្ឋ រវាងរដ្ឋ និងអង្គការសហប្រជាជាតិ ឬដោយអង្គការសហប្រជាជាតិតែម្នាក់ឯង។

មានទិដ្ឋភាពមួយទៀតនៃតម្រូវការជាមូលដ្ឋានរបស់មនុស្សនេះ ដែលត្រូវបានឆ្លុះបញ្ចាំងផងដែរនៅក្នុងឯកសារមូលដ្ឋានគោលរបស់ អ.វ.ត.ក និងត្រូវបានអនុវត្តដោយតុលាការ - ថាការកំណត់គណនេយ្យភាពត្រូវធ្វើឡើងដោយត្រឹមត្រូវយុត្តិធម៌ និងតាមនីតិវិធីត្រឹមត្រូវនៃច្បាប់ (កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១២(២) ច្បាប់ អ.វ.ត.ក មាត្រា ៣៣ ថ្មី)។ នៅទីបំផុត ការផ្សះផ្សាពិតប្រាកដសន្តិភាពប្រកបដោយនិរន្តរភាពពិតប្រាកដ អាចកើតមានបានលុះត្រាតែអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មអន្តរជាតិ ត្រូវបានដាក់ឲ្យទទួលខុសត្រូវចំពោះការប្រព្រឹត្តិរបស់ខ្លួន តាមរយៈដំណើរការដោយយុត្តិធម៌ មិនលំអៀង និងឯករាជ្យដែលគោរពសិទ្ធិជនសង្ស័យ និងជនជាប់ចោទ ព្រមទាំងសិទ្ធិរបស់ជនរងគ្រោះផងដែរ។ ការធានានូវដំណើរការតុលាការប្រភេទនេះ - ដែលបង្ហាញឲ្យឃើញពីភាពខ្វះខាតនៅក្នុងដំណើរការរបស់តុលាការប្រជាជនបដិវត្តន៍ឆ្នាំ១៩៧៩ ប្រឆាំងនឹង ប៉ុល ពត និង អៀង សារី - មានសារសំខាន់សម្រាប់លទ្ធផលតុលាការ ដែលត្រូវទទួលយកថាអាចជឿជាក់បានដោយជនរងគ្រោះ និងអ្នករស់រានមានជីវិតអ្នកដែលត្រូវបានចោទប្រកាន់ថាបានបង្កព្យសនកម្ម ឬបានគាំទ្រដល់អ្នកដែលបានបង្កព្យសនកម្មទាំងនោះ និងសង្គមទាំងមូល។ ទោះបីជាពួកគេមិនយល់ស្របនឹងលទ្ធផលនេះក៏ដោយ បើលទ្ធផលនេះបានមកដល់ដោយត្រឹមត្រូវ នោះយុត្តិធម៌នឹងត្រូវបានគេមើលឃើញថាត្រូវបានផ្តល់ឲ្យ។

ការកំណត់អំពីគណនេយ្យភាពតាមរយៈដំណើរការតុលាការត្រូវបានបំពេញចំពោះរឿងក្តីពាក់ព័ន្ធនឹង ឌុច, នួន ជា និង ខៀវ សំផន។ ការអះអាងរបស់អ្នករិះគន់ដែលថា ការចំណាយរបស់ អ.វ.ត.ក លើសពីតម្លៃរបស់ខ្លួនក្នុងការសម្រេចបានការផ្តន្ទាទោសមនុស្សទាំងបីនាក់នេះ មិនបានបន្ថយឥទ្ធិពលនៃយុត្តិធម៌ដែលសម្រេចបានក្នុងសំណុំរឿង ០០១, ០០២/០១ និង ០០២/០២ឡើយ។ កម្លាំងនៃការរិះគន់នេះត្រូវបានថយចុះបន្ថែមទៀត នៅពេលដែលយើងពិចារណាលើចំនួនឧក្រិដ្ឋកម្មដែលត្រូវបានវិនិច្ឆ័យនៅក្នុងរឿងក្តីទាំងនេះ៖ ការជម្លៀសប្រជាជនដោយបង្ខំជាងពីរលានពីទីក្រុងភ្នំពេញក្នុងខែមេសា ឆ្នាំ១៩៧៥ និងឧក្រិដ្ឋកម្មរាប់រយរាប់ពាន់ទៀតនៅតាមទីតាំង និងព្រឹត្តិការណ៍ផ្សេងទៀតដែលបានពិចារណា។ លើសពីនេះទៅទៀត នៅពេលដែលយើងពិចារណាលើការចំណាយពិតប្រាកដនៃការកាត់ក្តីនីមួយៗនៃឧក្រិដ្ឋកម្មទាំងនោះនៅក្នុងតុលាការក្នុងស្រុក ជាពិសេសប្រសិនបើយើងពិចារណាក្នុងការរៀបចំក្នុងស្រុកវិញនោះ អ.វ.ត.ក មានប្រភេទនៃការចំណាយដូចគ្នានេះដែរ រួមទាំងប្រាក់ខែរបស់បុគ្គលិក អាគារ ឬការរៀបចំកែលម្អតុលាការ និងការិយាល័យពាក់ព័ន្ធ ដោយបំពាក់ឲ្យពួកវានូវគ្រឿងបរិក្ខា និងផ្តល់ការគាំទ្រផ្នែកភស្តុភារ រួមទាំងការធ្វើដំណើរទៅកាន់ប្រទេសផ្សេងទៀតសម្រាប់ការស៊ើបអង្កេត។

ហើយសមិទ្ធផលក្នុងការកំណត់គណនេយ្យភាពរបស់ ឌុច, នួន ជា និង ខៀវ សំផន ក្នុងកិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ និងមិនលំអៀង ដោយមាន

ការចូលរួមពីគ្រប់ភាគីទាំងអស់ ក៏មិនបានកាត់បន្ថយដោយសារការពិតដែលថា អ.វ.ត.ក មិនបាននាំខ្លួន អ៊ឹម ចែម, អោ អាន, មាស មុត និង យឹម ទិត្យ មកកាត់ទោសនោះដែរ។ ទោះជាយ៉ាងនេះក្តី ថាតើការសម្រេចសេចក្តីនៃរឿងក្តីផ្សេងទៀតទាំងអស់នេះឆ្លុះបញ្ចាំងពីដំណើរការត្រឹមត្រូវ និងយុត្តិធម៌ ឬយ៉ាងណា គឺមានភាពចម្រូងចម្រាស។

អោ អាន, មាស មុត និង យឹម ទិត្យ បានប្រឈមមុខនឹងការចោទប្រកាន់។ ទោះយ៉ាងណាក៏ដោយ រឿងក្តីរបស់ពួកគេត្រូវបានបញ្ចប់ដោយហេតុផលវិវាទយ៉ាងខ្លាំង ដោយមិនមានការឯកភាពគ្នារវាងចៅក្រម។ នៅក្នុងមតិជំទាស់របស់គាត់ទៅនឹងសេចក្តីសម្រេចរបស់ អ.ជ.ត.ក បដិសេធសំណុំរឿង ០០៤ ចៅក្រម Clark បានដកស្រង់យ៉ាងត្រឹមត្រូវ នូវសេចក្តីសង្កេតថា "មានតែការកុំតបតតែម្យ៉ាងគត់របស់មនុស្សល្អ ទើបអាចយកឈ្នះលើអំពើអាក្រក់បាន"។ ស.ព.ជ និង ស.ច.ស.ជ មួយចំនួននិងចៅក្រមអន្តរជាតិបានព្យាយាមបំពេញអាណត្តិរបស់តុលាការ និងធានាឱ្យមានការជំនុំជម្រះជនជាប់ចោទទាំងបីរូបនេះផ្អែកលើមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជុំនុំជម្រះទាំងនេះ។ ទោះជាយ៉ាងណាករណីទាំងបីនេះបានលើកឡើងពីបញ្ហាដែលបានពិភាក្សាយ៉ាងលម្អិតនៅក្នុងផ្នែក *បញ្ហាប្រឈមបែបរចនាសម្ព័ន្ធ* រួមទាំងក្នុងចំណោមបញ្ហាផ្សេងទៀត ផលប៉ះពាល់នៃដីកាដំណោះស្រាយផ្ទុយគ្នា និងកាតព្វកិច្ចរបស់ចៅក្រមក្នុងការអនុវត្តនីតិវិធីស្វ័យប្រវត្តិ ដែលតម្រូវឱ្យសំណុំរឿងបន្តដំណើរការទៅមុខ ពេលដែលមិនមានសំឡេងភាគច្រើនលើសលុបរារាំងដំណើរការរបស់វាទេនោះ។ រឿងក្តីរបស់ អ៊ឹម ចែម ត្រូវបានច្រានចោល ដោយផ្អែកលើការរកឃើញជាឯកច្ឆ័ន្ទរបស់ ស.ច.ស ដែលថា អ.វ.ត.ក ខ្វះយុត្តាធិការបុគ្គលលើរូបគាត់។ ទោះជាយ៉ាងណាក៏ដោយ អ.ប.ជ បានខ្វែងយោបល់គ្នាលើបញ្ហាអង្គសេចក្តី នៃការលើកលែងចោទបក្រាន់



*ឌុច, ខៀវ សំផន និង នួន ជា នៅថ្ងៃប្រកាសសាលក្រមរបស់ពួកគេ ក្នុងសំណុំរឿង ០០១ និង សំណុំរឿង ០០២/០១ © គេហទំព័រ អ.វ.ត.ក*

នេះ។ ចៅក្រមជាតិគាំទ្រការលើកលែងទោសប្រកាន់ ចំណែកឯចៅក្រមអន្តរជាតិបានរកឃើញកំហុសផ្នែកច្បាប់ និងអង្គហេតុយ៉ាងធ្ងន់ធ្ងរនៅក្នុងការវាយតម្លៃរបស់ ស.ច.ស អំពីតួនាទីក្នុងរបបកម្ពុជាប្រជាធិបតេយ្យរបស់ អៀង ធីរិទ្ធ និងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មរបស់គាត់ ដោយសន្និដ្ឋានថា តុលាការពិតជាមានយុត្តាធិការក្នុងរឿងក្តីនេះ។ ទោះបីជាមានមតិផ្នែកច្បាប់ខុសគ្នាខ្លាំងក៏ដោយ ការលើកលែងទោសប្រកាន់មានសុពលភាព ដោយសារ អ.ប.ជ មិនអាចទទួលបានសំឡេងភាគច្រើនលើសលុបដើម្បីបដិសេធវា។

ទិដ្ឋភាពមួយទៀតនៃគណនេយ្យភាព និងការផ្សះផ្សាពិតប្រាកដ គឺការផ្តល់សំណងដល់ជនរងគ្រោះ ដែលជាទម្រង់សំខាន់មួយនៃការទទួលស្គាល់ពីព្យសនកម្មដែលបានធ្វើចំពោះពួកគេ។ អ.វ.ត.ក ផ្តល់សំណងសមូហភាព និងសីលធម៌ - ផ្ទុយពីសំណងរូបិយវត្ថុ។ បន្ថែមពីលើការបង្កើតប្រវត្តិសាស្ត្រដែលកំណត់ដោយតុលាការនៃឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយសមាជិកនៃរបបខ្មែរក្រហម តុលាការបានអនុម័តគម្រោងសំណងជាច្រើនរួមមាន៖ i) ទិវាជាតិនៃការចងចាំ ii) បូជនីយដ្ឋាននៃការចងចាំដើម្បីគោរពដល់ជនរងគ្រោះនៃការជម្លៀសដោយបង្ខំ iii) ការសាងសង់មជ្ឈមណ្ឌលសិក្សាសន្តិភាព iv) គម្រោងអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម v) កម្មវិធីលើកកម្ពស់ការយល់ដឹងអំពីការប្រព្រឹត្តលើជនជាតិភាគតិចវៀតណាម និងចាម នៅក្នុងប្រទេសកម្ពុជាក្នុងរបបកម្ពុជាប្រជាប្រជាធិបតេយ្យ និង vi) គម្រោងលើកកម្ពស់ការព្យាបាល និងការផ្សះផ្សាអ្នករស់រានមានជីវិត និងការកែលម្អសុខភាព និងសុខុមាលភាពផ្លូវចិត្តរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន និងមនុស្សចាស់ដែលងាយរងគ្រោះផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា។ គម្រោងទាំងនេះអាចត្រូវបានគេរំពឹងថានឹងមានផលប៉ះពាល់យូរអង្វែងដល់ជនរងគ្រោះនៃរបបខ្មែរក្រហម និង គ្រួសាររបស់ពួកគេ។

# យុត្តិសាស្ត្រ

កំណត់ត្រាផ្នែកយុត្តិសាស្ត្ររបស់ អ.វ.ត.ក ថ្វីបើមានភាពចម្រូងចម្រាស ត្រូវតែចាត់ទុកជាជោគជ័យមួយជារួម។ អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចត្រួសត្រាយផ្លូវ ពាក់ព័ន្ធនឹងការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល និងឧក្រិដ្ឋកម្មនានា ដោយមានការថ្លឹងថ្លែងយ៉ាងប្រុងប្រយ័ត្នចំពោះសិទ្ធិរបស់ជនរងគ្រោះ និងសិទ្ធិការការពារក្តី ព្រមទាំងបានធ្វើការរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍន៍ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។ ទោះបីជាការពិនិត្យឡើងវិញគ្រប់ជ្រុងជ្រោយមិនអាចធ្វើបានក្នុងបរិបទកូនសៀវភៅនេះ តែវាក្យខណ្ឌនេះនឹងពិភាក្សា ព្រមទាំងវិភាគទៅលើសេចក្តីសម្រេចដ៏គួរឱ្យកត់សម្គាល់ទាំងនោះ។

## ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល

- សហឧក្រិដ្ឋកម្មរួម (JCE)

អង្គជំនុំជម្រះទាំងបីរបស់ អ.វ.ត.ក - គឺ អ.ប.ជ, អ.ជ.ស.ដ និង អ.ជ.ត.ក - បានសន្និដ្ឋានថា វាជាច្បាប់ដែលបានដោះស្រាយហើយ ដែលថា **សហឧក្រិដ្ឋកម្មរួមទម្រង់** I (JCE I) (ជាទម្រង់ "មូលដ្ឋាន" ដែលអ្នកចូលរួមប្រព្រឹត្តទាំងអស់ ធ្វើសកម្មភាពអនុលោមតាមគោលបំណង ឬផែនការឧក្រិដ្ឋកម្មរួម និងមានចំណែកនៅក្នុងចេតនា នៃឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក) ហើយ **សហឧក្រិដ្ឋកម្មរួមទម្រង់** II (JCE II) (ជាទម្រង់ "ប្រព័ន្ធ" ដែលមានចរិតលក្ខណៈកំណត់តាមអត្ថិភាពនៃប្រព័ន្ធនៃការធ្វើបាបដែលគេបានរៀបចំឡើង ដូចជា គុក ឬ ជំរំប្រមូលផ្តុំ ជាដើម) ត្រូវបានទទួលស្គាល់ថាជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល នៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ព្រមទាំងជាទម្រង់នៃ "ការប្រព្រឹត្ត" ក្រោមមាត្រា ២៩ថ្មី នៃច្បាប់ អ.វ.ត.ក។

យ៉ាងណាមិញ ដោយមានការដកចេញពីយុត្តិសាស្ត្ររបស់តុលាការ *ចំពោះកិច្ច* ផ្សេងទៀត អង្គជំនុំជម្រះ អ.វ.ត.ក បានយល់ស្របថា **សហឧក្រិដ្ឋកម្មរួមទម្រង់** III (JCE III) (ជាទម្រង់ "ពង្រីក" ដែលភ្ជាប់ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែល *មិន* មាននៅក្នុងផែនការរួម ដែលគេអាចព្យាករណ៍បានថាជាឧក្រិដ្ឋកម្មដែលអាចបានប្រព្រឹត្តឡើង ហើយជនជាប់ចោទបានទទួលយក ហានិភ័យនោះដោយស្ម័គ្រចិត្ត (ជាប្រភេទចេតនាមួយដែលយើងស្គាល់នៅក្នុងយុត្តិសាស្ត្រនៃច្បាប់ស៊ីវិលថា *ចេតនាប្រយោល*) គឺ *មិនមែន* ជាទម្រង់នៃការទទួលខុសត្រូវដែលបានទទួលស្គាល់ក្រោមច្បាប់ទម្លាប់អន្តរជាតិ ច្បាប់កម្ពុជា ឬគោលការណ៍ទូទៅណាមួយនៃច្បាប់ក្នុងស្រុក នៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ទេ។ ក្រោយពីមានការវិភាគយ៉ាងទូលំទូលាយមក ចៅក្រម អ.វ.ត.ក យល់ស្របថា លិខិតុបករណ៍ច្បាប់ និងយុត្តិសាស្ត្រមុនឆ្នាំ១៩៧៥ មិនបានផ្តល់ភស្តុតាងគ្រប់គ្រាន់ពីការអនុវត្តកន្លងមក ថាវាមានភាពស៊ីចង្វាក់គ្នាក្នុងការកំណត់អំពី JCE III នេះក៏ទេដែរ។ ចៅក្រមបានសន្និដ្ឋានជាចុងក្រោយថា ធម្មនុញ្ញនូរ៉ឹមប៊ឺក និងច្បាប់គ្រប់គ្រងក្រុមប្រឹក្សា លេខ១០ មិនគាំទ្រជាក់លាក់ចំពោះអត្ថិភាពនៃ JCE III នេះទេ ហើយយុត្តិសាស្ត្រ ដែលយើងបានពិនិត្យរួច ក៏មិនគាំទ្រដែរ។ និយាយឱ្យចំ ចៅក្រមបានសន្និដ្ឋានក្នុងរឿងក្តី Essen Lynching និង Borkum Island ដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានលើកយោងក្នុងរឿងក្តី *Tadić* សម្រាប់គោលបំណងដូចគ្នានេះ ក៏មិនបានផ្តល់សំអាងហេតុគ្រប់គ្រាន់

ដើម្បីកំណត់ពីទម្រង់នៃការទទួលខុសត្រូវដែលគេបានពឹងផ្អែកនោះដែរ។ អង្គជំនុំជម្រះបានសន្និដ្ឋានថា ច្បាប់ក្នុងស្រុកទូទៅ ដែលមិនមានធាតុផ្សំអន្តរជាតិ មិនអាចយកជាមូលដ្ឋានក្នុងការបង្កើតវិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិណាមួយបានឡើយ និងបានសន្និដ្ឋានថា ការអនុវត្ត JCE III នៅ អ.វ.ត.ក អាចជាការរំលោភលើគោលការណ៍នីត្យានុកូលភាព ដែលតម្រូវឱ្យមានការទទួលស្គាល់អំពើនោះថា ជាបទព្រហ្មទណ្ឌ*នៅពេលប្រព្រឹត្ត*។

ខណៈដែលចំណុចនេះឆ្លុះបញ្ចាំងពីសារធាតុនៃសេចក្តីសម្រេចរបស់ អ.ជ.ត.ក អ្វីដែលជាការចាប់អារម្មណ៍គឺថា ចៅក្រម អ.ជ.ត.ក មិនដូច អ.ប.ជ, អ.ជ.ស.ជ និង ស.ច.ស ទេ គឺពួកគាត់ពេញចិត្តមិនពឹងផ្អែកទៅលើប្រភេទ JCE ឬ ពាក្យពេចន៍ដែលបានប្រើប្រាស់ដោយតុលាការ ICTY ឡើយ ដោយសារមិនមានប្រើនៅក្នុងយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី២។ ផ្ទុយទៅវិញ ពួកគាត់បានផ្តោតទៅលើតែកាលៈទេសៈទាំងឡាយដែលច្បាប់បានចែងអំពីការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលជនជាប់ចោទបានប្រព្រឹត្តដោយមានការព្រមព្រៀងជាមួយជនផ្សេងទៀត ផ្អែកលើគោលបំណងរួម និងការរួមចំណែកដល់ការអនុវត្តអំពើនោះ សូម្បីតែនៅពេលដែលការរួមចំណែកនោះមិនមានតម្លៃស្មើនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មដូចបានចោទប្រកាន់ក៏ដោយ។

ដោយផ្អែកលើចំណុចនេះ អ.ជ.ត.ក បានអនុម័តក្នុងសាលដីកាសំណុំរឿង ០០២/០១ របស់ខ្លួន នូវនិយមន័យដ៏ទូលំទូលាយពិសេសមួយនូវអ្វីដែលមាននៅក្នុងគោលបំណងរួម រួមជាមួយនឹងបទដ្ឋានចេតនានៃ JCE ដែលមានចំនួនតិចជាងចេតនាផ្ទាល់។ ចៅក្រមបានសន្និដ្ឋានថា កាលណាគោលបំណងរួម មានគោលដៅចុងក្រោយមិនមែនឧក្រិដ្ឋ ជាឧក្រិដ្ឋកម្មដែលគ្មានចេតនា ចំណង់ ឬភាពជាក់លាក់ ដោយផ្ទាល់ រួមទាំងឧក្រិដ្ឋកម្មដែលគ្រាន់តែ "បានគិតទុកជាមុន" "បានព្យាករណ៍" ឬ "គ្មានការអើពើ" អាចស្ថិតនៅក្នុងគោលបំណងនោះ បើនិយាយដល់ការសម្រេចគោលដៅចុងក្រោយ។ អ.ជ.ត.ក បានឆ្លុះបញ្ចាំងឱ្យឃើញថា នេះជាចំណុចដូចគ្នានឹង *ចេតនាប្រយោល*។ ចំណែកធាតុអត្តនោម័ត ចៅក្រមបានរកឃើញថា ជនជាប់ចោទត្រូវតែមានចំណែកនៅក្នុងចេតនាក្នុងការប្រព្រឹត្តិគោលបំណងរួម និងមានចេតនាចំពោះបទឧក្រិដ្ឋដែលបានចោទប្រកាន់។ ខណៈ *ចេតនាប្រយោល* ក្នុងកម្រិតទាបមួយ គឺជាការគ្រប់គ្រាន់សម្រាប់ឧក្រិដ្ឋកម្មនោះក្តី ដូចជាអំពើមនុស្សឃាតជាដើម វាក៏គ្រប់គ្រាន់សម្រាប់ការទទួលខុសត្រូវ JCE ផងដែរ។ ជាការពិតណាស់ ទាក់ទងនឹងឧក្រិដ្ឋកម្មដែលមានចេតនាជាក់លាក់ លក្ខខណ្ឌតម្រូវអំពីចេតនាជាក់លាក់ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម នៅតែជាលក្ខខណ្ឌតម្រូវដដែល។



នៅក្នុងសាលក្រមសំណុំរឿង ០០២/០២ បន្តបន្ទាប់មកទៀត អ.ជ.ស.ជ បានដកចេញពីទម្រង់និយមន័យដ៏ទូលំទូលាយរបស់ អ.ជ.ត.ក ទាក់ទងនឹង JCE ហើយបានសង្កត់ធ្ងន់ជាថ្មីម្តងទៀតអំពីភាពខុសគ្នារវាង JCE I និង JCE III។ ដោយបានអនុម័តតាមអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY និង ICTR អ.ជ.ស.ជ បានសម្រេចថា *ចេតនាប្រយោល* នៃ JCE III មិនអាចផ្ទេរទៅ JCE I បានឡើយ ហើយការទទួលខុសត្រូវរបស់ JCE I កើតឡើងបានតែក្នុងចេតនាដោយផ្ទាល់ប៉ុណ្ណោះ។ អាស្រ័យហេតុនេះ អ.ជ.ស.ជ បានបដិសេធពិរុទ្ធភាពរបស់ នួន ជា និង ខៀវ សំផន លើអំពើមនុស្សឃាតដែលបានប្រព្រឹត្តក្នុង*ចេតនាប្រយោល* នៅតាមការដ្ឋាន និងមន្ទីរសន្តិសុខនានា ដោយផ្អែកលើការចូលរួមប្រព្រឹត្តក្នុង JCE របស់ពួកគេ។ ផ្ទុយមកវិញ អ.ជ.ស.ជ បានសន្និដ្ឋានថា ពួកគេមានការទទួលខុសត្រូវចំពោះ ការជួយ និងជំរុញ ដល់ឧក្រិដ្ឋកម្មទាំងនោះវិញ។

យ៉ាងណាមិញ នៅក្នុងសាលដីកាសំណុំរឿង ០០២/០២ របស់ខ្លួន អ.ជ.ត.ក បានបញ្ជាក់ជាថ្មីម្តងទៀតអំពីគោលជំហររបស់ខ្លួនក្នុងសំណុំរឿង០០២/០១ និងបានកំណត់ថា អ.ជ.ស.ដ មានកំហុសក្នុងការវិភាគរបស់ពួកគេ។ តាមទស្សនៈរបស់ខ្លួន អ.ជ.ស.ដ បានធ្វើមិនដឹងមិនឮចំពោះស្ថានភាពដែលថា ភវនីយភាពនៃការប្រព្រឹត្តិបទឧក្រិដ្ឋណាមួយ គឺត្រូវបានព្រមព្រៀង ឬទទួលយកដោយសមាជិកនៃ JCE ទាំងអស់ ដើម្បីពន្លឿនគោលបំណងរួម ដូច្នេះវាស្ថិតនៅក្នុងវិសាលភាពរបស់វា មិនមែននៅក្រៅនោះទេ។ លើសពីនេះ គេយល់ថា "ជាការពុំត្រឹមត្រូវក្នុងការតម្រូវឱ្យមានកម្រិតធាតុផ្សំអត្តនោម័ត សម្រាប់ទម្រង់នៃការចូលរួមខ្ពស់ជាងសម្រាប់ឧក្រិដ្ឋកម្មមូលដ្ឋាន"។ ហេតុដូច្នេះ អ.ជ.ត.ក ក៏បានកំណត់ឡើងវិញអំពីការទទួលខុសត្រូវរបស់ ខៀវ សំផន ពីការជួយ និងជំរុញនៅក្នុងអំពើមនុស្សឃាតដោយ *ចេតនាប្រយោល* ទៅជាការប្រព្រឹត្តិតាមរយៈ JCE វិញ។

## ឧក្រិដ្ឋកម្ម

- ### បុគ្គលិកយោធាជា "ប្រជាជនស៊ីវិល"

បន្ទាប់ពីមានការអំពាវនាវឱ្យដាក់សារណាក្នុងសំណុំរឿង០០៣ និង ០០៤ មក ស.ច.ស.អ Bohlander បានបកស្រាយថា ការវាយប្រហារសំដៅលើ "ប្រជាជនស៊ីវិលណាម្នាក់" ក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺរួមបញ្ចូលទាំងការវាយប្រហារដោយរដ្ឋ ឬអង្គការ ប្រឆាំងនឹងកម្លាំងប្រដាប់អាវុធរបស់*ខ្លួនឯង* លើកលែងតែកម្លាំងដែលទទួលរងការវាយប្រហារនោះ ជាសម្ព័ន្ធមិត្ត ឬជាអ្នកផ្តល់ការគាំទ្រពាក់ព័ន្ធនឹងយោធា ដល់ភាគីប្រឆាំងនឹងជម្លោះប្រដាប់អាវុធណាមួយ។ ការបកស្រាយនេះ - ដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការបោសសម្អាតផ្ទៃក្នុងយោធារបស់ខ្មែរក្រហម - ផ្ទុយពីនិយមន័យនៃពាក្យ "ជនស៊ីវិល" ដែលបានអនុម័តកន្លងមកនៅក្នុងសាលក្រមសំណុំរឿង០០១ និង០០២/០១ និងក្នុងសាលដីកាសំណុំរឿង០០២/០១ ដែលពឹងផ្អែកលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលមិនរាប់បញ្ចូលសមាជិកអង្គការប្រដាប់អាវុធទេ ទោះបីពួកគេលែងចូលរួមប្រយុទ្ធ (*ទាហានបាត់បង់សមត្ថភាពប្រយុទ្ធ*) ក៏ដោយ។

សំអាងហេតុរបស់ ស.ច.ស.អ បានសង្កត់ធ្ងន់ពីសារសំខាន់នៃ *បរិបទ*។ គាត់បានសន្និដ្ឋានថា ការដកចេញបុគ្គលិកយោធាពីកិច្ចការពារ ដោយគ្រាន់តែដោយសារតែឋានៈការងាររបស់ពួកគេ - គឺការងារដែលបានប្រគល់ដោយរដ្ឋ ឬអង្គការដែលនៅចុងបញ្ចប់រដ្ឋ ឬអង្គការនោះឯងជាអ្នកប្រព្រឹត្តបទរំលោភផ្សេងៗ - នឹង i) អនុវត្តជាយន្តការនិងមិនមានតក្កភាព នូវនិយមន័យច្បាប់មួយដែលអាចអនុវត្តបានតែក្នុងស្ថានភាពជាក់លាក់មួយ និងសាខានៃច្បាប់ណាមួយប៉ុណ្ណោះ (ច្បាប់មនុស្សធម៌អន្តរជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម តាមកត្តាពង្រីករបស់វា) ចំពោះច្បាប់មួយផ្សេងទៀត (ច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមកត្តាពង្រីករបស់វា) ii) ធ្វើឱ្យខកបំណងនៃច្បាប់ដែលហាមឃាត់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ iii) នាំឱ្យមានលទ្ធផលមិនសមទំនង និង iv) ផ្ទុយនឹងច្បាប់និងយុត្តិសាស្ត្រមុនឆ្នាំ១៩៧៥ ដែលពាក់ព័ន្ធទាំងអស់។

ដោយកត់សម្គាល់ថា ឋានៈរបស់បុគ្គលម្នាក់ៗក្នុងស្ថានភាព ឬទំនាក់ទំនងផ្លូវច្បាប់ណាមួយ មិនមែនជាកត្តាចាំបាច់ដូចគ្នានឹងស្ថានភាពផ្សេងទៀត និងថានិយមន័យនៃច្បាប់មនុស្សធម៌អន្តរជាតិ អំពី "ការវាយប្រហារ" មិនអនុវត្តចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នោះ ស.ច.ស.អ បានសន្និដ្ឋានថា និយមន័យច្បាប់មនុស្សធម៌អន្តរជាតិសម្រាប់ "ជនស៊ីវិល" មិនគួរផ្លាស់ប្តូរជាស្វ័យប្រវត្តិទេ។ គាត់យល់ឃើញថាអភិក្រមនេះ មានការពាក់ព័ន្ធជាពិសេសពេលដែល

ច្បាប់មនុស្សធម៌អន្តរជាតិមិនអាចអនុវត្តបានទាំងស្រុង ដូចក្នុងពេលសន្តិភាព ឬសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានប្រព្រឹត្តឡើងតែក្នុងពេលដែលកំពុងមានជម្លោះ ប៉ុន្តែមិនជាប់ពាក់ព័ន្ធនឹងបរិបទនៃជម្លោះនោះ។

ផ្អែកលើកិច្ចការរបស់គណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមនៃ អ.ស.ប, ស.ច.ស.អ បានសន្និដ្ឋានថា គោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺ "ការពារប្រឆាំងការរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តឡើងក្នុងទ្រង់ទ្រាយធំ ប្រឆាំងនឹងបុគ្គលនានា រួមទាំងជាតិសាសន៍នៃរដ្ឋខ្លួនឯងផង ដោយសារច្បាប់និងទម្លាប់សង្គ្រាមជាធរមាន មិនការពារពួកគេ"។ ការដកបុគ្គលិកយោធារបស់រដ្ឋ ឬអង្គការផ្ទាល់ខ្លួន ចេញពីកិច្ចការពារ គឺផ្ទុយទៅនឹងគោលបំណងនេះ។ ដូច ស.ព.អ បានកត់សម្គាល់ថា ការដកកម្លាំងប្រដាប់អាវុធចេញពីវិសាលភាពនៃកិច្ចការពាររបស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នឹងអនុញ្ញាតឱ្យរដ្ឋាភិបាល ឬអង្គការនោះ ប្រព្រឹត្តអំពើយង់ឃ្នងដ៏មហាវិនាសកម្មដោយមាននិទណ្ឌភាព ដោយគ្រាន់តែតាមរយៈការដាក់អ្នកទាំងនោះជាយោធារបស់ខ្លួន។

ស.ច.ស.អ ក៏បានរកឃើញផងដែរថា យុត្តិសាស្ត្រមុនឆ្នាំ១៩៧៥ ដ៏ទូលំទូលាយ មិនបានបកស្រាយលើការយល់ដឹងនៃឃ្លា "ប្រជាជនស៊ីវិល" ទេ ដោយគ្រាន់តែបានយោងសំដៅទៅរកច្បាប់មនុស្សធម៌អន្តរជាតិ ប៉ុណ្ណោះ និងថា និយមន័យនៃច្បាប់មនុស្សធម៌អន្តរជាតិ ចំពោះពាក្យថា "ជនស៊ីវិល" គឺត្រូវបានគេប្រើជាលើកដំបូងសម្រាប់ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងយុត្តិសាស្ត្រតុលាការ ICTY ក្នុងទសវត្សរ៍ឆ្នាំ១៩៩០ គឺ *ក្រោយ* យុត្តាធិការពេលវេលារបស់ អ.វ.ត.ក។

ជាអកុសល អ.ជ.ស.ដ បានទាត់ចោលគោលជំហររបស់ ស.ច.ស.អ នៅក្នុងសាលក្រមសំណុំរឿង ០០២/០២។ នៅក្នុងការច្រានចោលនេះ អ.ជ.ស.ដ បានកំណត់ខុសចំពោះសេចក្តីសម្រេចរបស់ ស.ច.ស.អ និងមើលរំលងការគាំទ្រជាច្រើនដែលមានចំពោះនិយមន័យរបស់ ស.ច.ស.អ។

- អំពើហិង្សាផ្លូវភេទ និងយេនឌ័រ

ទោះបីជា អ.វ.ត.ក មានកំណត់ត្រាច្របូកច្របល់ក្នុងការចោទប្រកាន់ចំពោះអំពើហិង្សាផ្លូវភេទ និងយេនឌ័រ ការវាយតម្លៃជារួមបានកំណត់ឱ្យឃើញនូវការចោទប្រកាន់ដូច្នេះ ថាជាសមិទ្ធផលមួយក្នុងចំណោមសមិទ្ធផលធំៗរបស់ អ.វ.ត.ក។

### អំពើហិង្សាផ្លូវភេទក្រៅបរិបទអាពាហ៍ពិពាហ៍ដោយបង្ខំ

ដោយមានករណីលើកលែងមួយ អំពើហិង្សាផ្លូវភេទក្រៅបរិបទអាពាហ៍ពិពាហ៍ដោយបង្ខំ មិនត្រូវបានចោទប្រកាន់ដោយជោគជ័យឡើយនៅ អ.វ.ត.ក។

នៅក្នុងសំណុំរឿង០០១ ស.ច.ស បានចោទប្រកាន់ ឌុច ចំពោះអំពើរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយ ដោយរកឃើញថា "យ៉ាងហោចណាស់មានការបញ្ចូលអង្គជាតដោយបង្ខំមួយត្រូវបានប្រព្រឹត្តឡើងនៅ ស-២១ នៅពេលអ្នកសួរចម្លើយម្នាក់បានយកឈើមួយរុកចូលក្នុងយោនីរបស់អ្នកទោសស្រីម្នាក់"។ អ.ជ.ស.ដ បានរកឃើញថា ឧប្បត្តិហេតុនេះបានបំពេញនូវនិយមន័យច្បាប់ ទាំងចំពោះអំពើរំលោភសេពសន្ថវៈ និងទាំងអំពើទារុណកម្ម ប៉ុន្តែជាចុងក្រោយ អ.ជ.ស.ដ បានកំណត់យកតែអំពើទារុណកម្មប៉ុណ្ណោះ ដោយពិចារណាលើអំពើនោះថា "ជាផ្នែកធ្ងន់ធ្ងរជាក់ស្តែងមួយនៃការធ្វើទារុណកម្មដ៏អួសបន្ទាយ និងដ៏ឃោរឃៅទៅលើជនរងគ្រោះ មុនពេលសម្លាប់រូបគាត់"។

នៅក្នុងសាលដីកាសំណុំរឿង០០១ របស់ខ្លួន អ.ជ.ត.ក បានអនុម័តសេចក្តីសម្រេចដំបូងមួយរបស់ អ.ប.ជ ថា អំពើរំលោភសេពសន្ថវៈគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដាច់ដោយឡែកមួយ ដែលមិនមានការបញ្ជាក់ច្បាស់លាស់នៅត្រឹមឆ្នាំ១៩៧៥ ដូច្នេះហើយ អ.វ.ត.ក មិនមានយុត្តាធិការរឿងក្តីលើឧក្រិដ្ឋកម្មនេះទេ។ ចៅក្រមបានរកឃើញថា ទោះបីជាអំពើរំលោភសេពសន្ថវៈ ត្រូវបានហាមឃាត់ជាឧក្រិដ្ឋកម្មសង្គ្រាមជាយូរមកហើយក៏ដោយ - ដូចជា ក្រម Lieber ឆ្នាំ១៨៦៣ អនុសញ្ញាទីក្រុងឡាអេ ឆ្នាំ១៨៩៩ និង ១៩០៧ អនុសញ្ញាទីក្រុងហ្សឺណែវ IV ពិធីសារបន្ថែម I និង ពិធីសារបន្ថែម II ជាដើម ក្នុងចំណោមក្រមមុនឆ្នាំ១៩៧៩ របស់ខ្លួន - ក៏លិខិតុបករណ៍ច្បាប់អន្តរជាតិមិនបានហាមឃាត់ជាទូទៅថា អំពើរំលោភសេពសន្ថវៈមិនមែន *ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ* នោះទេ។ ខណៈច្បាប់គ្រប់គ្រងក្រុមប្រឹក្សា លេខ១០ ពិតជាបានបញ្ចូលអំពើរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដាច់ដោយឡែកមួយក្តី ក៏ចៅក្រមមិនបានរកឃើញភ័ស្តុតាងផ្តន្ទាទោសអនុលោមតាមច្បាប់នេះទេ និងទោះជារដ្ឋអាជ្ញាតុលាការ IMT បានអានភ័ស្តុតាងអំពីអំពើរំលោភសេពសន្ថវៈដើម្បីបញ្ចូលទៅក្នុងកំណត់ហេតុនៅនូរ៉ឹមប៊ឺកក៏ដោយ ក៏នៅក្នុងសាលក្រមរបស់តុលាការ IMT មិនមាននិយាយអំពីរឿងនេះដែរ។ ជាលទ្ធផល អំពើរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺមិនមានបញ្ចូលក្នុងគោលការណ៍នូរ៉ឹមប៊ឺក ឆ្នាំ១៩៥០ ទេ។ អ.ជ.ត.ក មិនយល់ឃើញថាយុត្តិសាស្ត្រពីតុលាការ ICTY, ICTR និង SCSL ថាមាភាពគួរឱ្យជឿជាក់បាននោះទេ ដោយពិចារណាលើយុត្តាធិការពេលវេលានាពេលក្រោយមករបស់ខ្លួន ក៏ទេដែរ ផ្ទុយមកវិញដោយគ្រាន់តែសន្និដ្ឋានថា វាបានបង្ហាញឱ្យឃើញថា អំពើរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅតែជាទស្សនៈមួយដែលកំពុងតែកើតមានក្នុងទសវត្សរ៍ឆ្នាំ១៩៩០។ ទាំង អ.ប.ជ និងទាំង អ.ជ.ត.ក សុទ្ធតែមិនមានឆន្ទៈដូចគ្នាក្នុងការទាញយកគោលការណ៍ច្បាប់ទូទៅមួយ ចេញពីឧក្រិដ្ឋភាពដ៏ចំបងមួយនៃអំពើរំលោភសេពសន្ថវៈ រួមទាំងពីក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ ផង ដោយសារច្បាប់ក្នុងស្រុកមិនមានធាតុផ្សំ*ស្រប* អំពី ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

អ.ជ.ត.ក *បាន* តម្កល់ការកំណត់របស់ អ.ជ.ស.ដ ថា អំពើរំលោភសេពសន្ថវៈដូចបានកើតឡើងនៅ ស-២១ ជាដើម អាចបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើទារុណកម្ម។ អង្គជំនុំជម្រះនេះបានសម្រេចថា អំពើទារុណកម្ម ដូចបានកំណត់និយមន័យនៅក្នុងសេចក្តីប្រកាសស្តីពីអំពើទារុណកម្មរបស់មហាសន្និបាត អ.ស.ប ឆ្នាំ១៩៧៥ (មិនមែនអនុសញ្ញាស្តីពីអំពើទារុណកម្មឆ្នាំ១៩៨៤ ទេ) គឺមានអត្ថិភាពជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ហើយនិយមន័យរបស់វា គឺគ្របដណ្តប់លើអំពើរំលោភសេពសន្ថវៈ។ ក្នុងការធ្វើសេចក្តីសម្រេចនេះ អ.ជ.ត.ក បានបញ្ជាក់អះអាងថា “អំពើហិង្សាផ្លូវភេទ ចាំបាច់ត្រូវតែបង្កឱ្យមានការឈឺចាប់ ឬទុក្ខវេទនា មិនថាផ្លូវកាយ ឬផ្លូវចិត្ត”។

នៅក្នុងសំណុំរឿង០០២ ស.ច.ស បានប្តឹងអំពីអំពើហិង្សាផ្លូវភេទក្រៅបរិបទអាពាហ៍ពិពាហ៍ដោយបង្ខំជាថ្មីម្តងទៀត។ នៅក្នុងដីកាដំណោះស្រាយរបស់ខ្លួន ទោះបីមានការរកឃើញថា អំពើរំលោភសេពសន្ថវៈ បានកើតឡើងនៅមន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខភូមិភាគឧត្តរ មន្ទីរសន្តិសុខព្រៃដំរីស្រុត មន្ទីរសន្តិសុខស-២១ (ពង្រីកលើសពីអំពើរំលោភសេពសន្ថវៈដែលបានផ្តន្ទាទោស ឌុច) និងមន្ទីរសន្តិសុខសង់ ព្រមទាំងសហករណ៍ត្រាំកក់ ក៏ដោយ ក៏ ស.ច.ស បានសន្និដ្ឋានថា អំពើហិង្សាផ្លូវភេទនេះ មិនអាចភ្ជាប់ទៅជនជាប់ចោទ

តាមទម្រង់នៃការទទួលខុសត្រូវជាធរមានបានឡើយ ដូច្នេះពួកគេមិនត្រូវបានចោទប្រកាន់ចំពោះបទឧក្រិដ្ឋទាំងនេះទេ។ ពួកគេបានរកឃើញថា "សម្ព័ន្ធភាពស្និទ្ធស្នាលក្រៅបរិបទអាពាហ៍ពិពាហ៍ ត្រូវបានចាត់ទុកជាការប្រឆាំងនឹងអភិក្រមសមូហភាពរបស់ ប.ក.ក" ហើយគោលនយោបាយផ្លូវការរបស់ ប.ក.ក គឺដើម្បីទប់ស្កាត់អំពើរំលោភសេពសន្ថវៈ និងផ្តន្ទាទោសចារី។ ទោះបីគោលនយោបាយនេះមិនបានជោគជ័យក្នុងការទប់ស្កាត់ការកើតឡើងនៃអំពើនេះក៏ដោយ ក៏អំពើរំលោភសេពសន្ថវៈមិនត្រូវបានមេដឹកនាំ ប.ក.ក ប្រើប្រាស់ដើម្បីអនុវត្តគោលបំណងរួមឡើយ។ ទោះបី អ.ប.ជ ធ្លាប់បានសម្រេចថា JCE III មិនមានសម្រាប់ ស.ច.ស ក្នុងការដោះស្រាយចំពោះឧក្រិដ្ឋកម្មដែលអាចព្យាករណ៍បានក៏ដោយ ក៏ការវិភាគរបស់ ស.ច.ស បានមើលរំលងទម្រង់នៃការទទួលខុសត្រូវផ្សេងទៀតដែលអាចមាន ក្នុងករណីអវត្តមានចេតនាផ្ទាល់ ដូចជាការជួយនិងជំរុញ និងការទទួលខុសត្រូវលើការបញ្ជា ជាដើម។ មិនមានភាគីណាមួយបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធនេះទៅកាន់ អ.ប.ជ ទេ។

យ៉ាងណាមិញ សហមេធាវីនាំមុខដើមតំណាងបណ្តឹងរដ្ឋប្បវេណី បានព្យាយាមនាំយកអំពើរំលោភសេពសន្ថវៈទាំងនេះ ត្រឡប់មកវិញនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០២ នៅដំណាក់កាលសវនាការ។ អ.ជ.ស.ដ បានបដិសេធយ៉ាងត្រឹមត្រូវលើការព្យាយាមទាំងនេះចំនួនពីរលើក ទី១ គឺនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៥ និងលើកទី២ នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ដោយសារខ្លួនគ្មានអំណាចផ្លូវច្បាប់ក្នុងការបង្ហាញឡើងវិញនូវបទចោទប្រកាន់អង្គហេតុ ដែលត្រូវបានបដិសេធដោយ ស.ច.ស នៅចុងបញ្ចប់នៃកិច្ចស៊ើបសួរ។ សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី បានដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចលើកទី២នេះភ្លាមៗមុនបញ្ចប់សវនាការក្នុងសំណុំរឿង០០២/០២។ អ.ជ.ត.ក បានសម្រេចថាមិនអាចទទួលយកបានដោយសារមិនត្រូវនឹងពេលវេលា ហើយក៏មិនពិចារណាលើអង្គសេចក្តីរបស់វាដែរ។

នៅក្នុងសំណុំរឿង០០៤ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់ ស.ព.អ បានប្តឹងទៅ ស.ច.ស ចំពោះអង្គហេតុទាក់ទងនឹងអំពើហិង្សាផ្លូវភេទនៅគុកលេខ៨ (តំបន់៧ ភូមិភាគពាយ័ព្យ) និងនៅស្រុកបាកាន (តំបន់២ ភូមិភាគពាយ័ព្យ) ដែលបានចោទប្រកាន់ថាបានប្រព្រឹត្តជាចំបងប្រឆាំងនឹងអ្នកជម្លៀសមកពីភូមិភាគបូព៌ានិងស្ត្រីខ្មែរក្រោម ដែលពួកគេត្រូវបានរំលោភសេពសន្ថវៈមុននឹងសម្លាប់។ ក្នុងអំឡុងនៃកិច្ចស៊ើបសួរ ស.ច.ស.អ បានរកឃើញភស្តុតាងច្បាស់លាស់ និងស៊ីចង្វាក់គ្នាថា អំពើរំលោភសេពសន្ថវៈជាអំពើអមនុស្សធម៌ផ្សេងៗទៀត ត្រូវបានប្រព្រឹត្តប្រឆាំងនឹងស្ត្រី នៅក្នុងស្រុកបាកាន ប៉ុន្តែថា មិនមានភស្តុតាងគ្រប់គ្រាន់អំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ យឹម ទិត្យ។ ទោះបីជាមិនមានការបញ្ជាក់ច្បាស់លាស់ក៏ដោយ ក៏ប្រហែលជាចំណុចនេះហើយដែលយើងអាចសន្មតថា ជាមូលហេតុដែល ស.ច.ស.អ មិនចោទប្រកាន់ យឹម ទិត្យ ចំពោះឧក្រិដ្ឋកម្មទាំងនេះក្នុងអំឡុងនៃកិច្ចស៊ើបសួរ។ ដូចក្នុងសំណុំរឿង០០២ ដែរ សេចក្តីសម្រេចនោះហាក់ដូចជាមើលរំលងទម្រង់នៃការទទួលខុសត្រូវជាធរមាន។

នៅចុងបញ្ចប់នៃកិច្ចស៊ើបសួរនៃសំណុំរឿង ០០៤ ស.ច.ស.ជ ក្នុងដីកាសម្រេចលើកលែងចោទប្រកាន់របស់ខ្លួន បានរកឃើញថា ស្ត្រីជម្លៀសមកពីភូមិភាគបូព៌ា និងស្ត្រីខ្មែរក្រោម ជាទូទៅត្រូវបានគេរំលោភសេពសន្ថវៈមុនសម្លាប់ និងថា ចារីមិនត្រូវបានផ្តន្ទាទោសឡើយ។ យ៉ាងណាក៏ដោយ គាត់ខកខានមិនបានភ្ជាប់ឧក្រិដ្ឋកម្មទាំងនេះទៅ យឹម ទិត្យ ទេ។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ ស.ច.ស.អ

មិនមានចែងអំពីការរកឃើញនូវអំពើហិង្សាផ្លូវភេទនេះទេ ទោះបីតាមកាតព្វកិច្ចផ្លូវច្បាប់តម្រូវឱ្យគាត់ធ្វើការសម្រេចទាក់ទងនឹងការចោទប្រកាន់*ទាំងអស់*ដែលបានប្ដឹងទៅគាត់ ក៏ដោយ។ ចំណុចនេះគឺជាការសន្និដ្ឋានមិនពេញចិត្តមួយ អំពីកិច្ចស៊ើបសួរក្នុងឧក្រិដ្ឋកម្មផ្លូវភេទធ្ងន់ធ្ងរជាក់ស្ដែង ដែលជាការដកហូតសិទ្ធិរបស់សហព្រះរាជអាជ្ញា និងសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបាននូវសេចក្ដីសម្រេចមួយដែលមានសំអាងហេតុ ចំពោះការចោទប្រកាន់ទាំងនេះ។

## អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរួមដំណេកក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ

បទបញ្ញានៃការរៀបអាពាហ៍ពិពាហ៍ គឺជារឿងចាំបាច់នៃគោលនយោបាយ ប.ក.ក ដែលបម្រើឱ្យពហុបំណង៖ ការត្រួតត្រាលើអន្តរកម្មខាងមនោសញ្ចេតនា ឬផ្លូវភេទក្រៅអាពាហ៍ពិពាហ៍ (ដែលត្រូវបានចាត់ទុកថា ជាគ្រោះថ្នាក់ដ៏ធំមួយចំពោះបដិវត្តន៍ និងការរារាំងដល់ការលះបង់ចំពោះ*អង្គការ*) និងជាពិសេសនៅពេលដែលរបបនេះកាន់តែចម្រើនវ័យ គឺដើម្បីបង្កើនចំនួនប្រជាជនរបស់កម្ពុជាប្រជាធិបតេយ្យ។ មេដឹកនាំ ប.ក.ក ខិតខំជំរុញដើម្បីសម្រេចបាននូវគោលបំណងទីពីរនេះ ដោយការចាប់ផ្គូផ្គងគូស្រករ តាមរយៈជីវប្រវត្តិរបស់ពួកគេ និងដោយការបង្ខំពួកគេឱ្យរៀបការ និងរួមដំណេកជាមួយគ្នា។ បក្សជាអ្នកកំណត់ថា អ្នកណាត្រូវរៀបការជាមួយអ្នកណា និងនៅពេលណា ជាទូទៅជាមួយបុគ្គលដែលមានការអនុគ្រោះ ដូចជា ទាហានពិការ កម្មាភិបាល និងយុទ្ធជន ជាដើម ដោយអង្គការជាអ្នកផ្ដល់ឱ្យពួកគេនូវជម្រើសក្នុងការជ្រើសរើសគូស្រកររបស់ខ្លួន។ តាមទម្លាប់ មានគូស្រករចាប់ពី ៧០ ទៅ ៨០ គូ ឬរហូតដល់ ១០០ គូ ត្រូវបានគេរៀបការនៅក្នុងពិធីរៀបការទ្រង់ទ្រាយធំ ដោយប្រឆាំងនឹងប្រពៃណី និងវប្បធម៌ ហើយជាញឹកញាប់ ពួកគេទើបតែបានជួបគ្នាជាលើកដំបូងនៅក្នុងពិធីទាំងនេះនិងគ្មានការចូលរួមពីក្រុមគ្រួសាររបស់ពួកគេឡើយ។ នៅពេលឡើងប្ដេជ្ញា គូស្រករថ្មីថ្មោង បានសន្យាស្មោះត្រង់ចំពោះ*អង្គការ* និងបង្កើតកូនជូន*អង្គការ*។ បន្ទាប់មក គេក៏យកពួកគេទៅដាក់នៅកន្លែងស្នាក់នៅមួយ ដើម្បីឱ្យពួកគេរស់នៅនិងរួមសង្វាសជាមួយគ្នា ជាទូទៅតែងមានឈ្លបលួចតាមដានពួកគេ។

គូស្រករថ្មីថ្មោងត្រូវបានគេគំរាមកំហែងដោយផ្ទាល់ ឬដោយប្រយោល ថានឹងយកទៅអប់រំ វាយដំ ឬសម្លាប់ចោល ប្រសិនបើពួកគេមិនព្រមរៀបការ ឬរួមសង្វាសជាមួយគ្នា ហើយការលែងលះគ្នាត្រូវបានហាមឃាត់។ ជាលទ្ធផលទាំងបុរស និងទាំងស្ត្រីដែលជាជនរងគ្រោះនៃអាពាហ៍ពិពាហ៍ និងការរួមភេទដោយបង្ខំទាំងនេះ បានទទួលរងនូវទុក្ខវេទនាពីជំងឺបាក់ស្មារតីក្នុងរយៈពេលវែងទាំងផ្លូវកាយ និងផ្លូវចិត្ត។

- *អាពាហ៍ពិពាហ៍ដោយបង្ខំ*

អាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានផ្ដន្ទាទោសដោយជោគជ័យជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើអមនុស្សធម៌ផ្សេងៗទៀត ក្នុងសំណុំរឿង០០២/០២ និងបានបញ្ចូលក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅក្នុងសំណុំរឿង០០៣, ០០៤ និង ០០៤/២។ ស.ច.ស និងអង្គជំនុំជម្រះផ្សេងទៀត បានទាត់ចោលដូចៗគ្នានូវការតវ៉ាផ្សេងៗ ទាក់ទងនឹងនីត្យានុកូលភាពនៃការចោទប្រកាន់។ ចំពោះការពិតដែលថា ឧក្រិដ្ឋកម្មទាំងនេះត្រូវបានដាក់បញ្ចូលក្នុងវិសាលភាពនៃរឿងក្ដីរបស់ អ.វ.ត.ក តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា តែនៅពេលក្រោយមកនោះ មិនអាចបិទបាំងសមិទ្ធផលដែលសម្រេចបានដ៏សំខាន់នេះឡើយ។

ការកាត់ទោសមេដឹកនាំខ្មែរក្រហមក្នុងសំណុំរឿង០០២/០២ បានធ្វើឡើងផ្អែកលើការកាត់ទោសពីមុនរបស់ តុលាការ SCSL អំពីអាពាហ៍ពិពាហ៍ដោយបង្ខំ ដោយបានបញ្ជាក់នូវភាពខុសគ្នារវាងអាពាហ៍អាពិពាហ៍តាមប្រពៃណី ធ្វើឡើងដោយការជឿទុកចិត្តគ្នាទៅវិញទៅមក និងការព្រមព្រៀងគ្នាតាមប្រតិភូកម្មរវាងឪពុកម្ដាយ និងកូន ហើយនិងអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលគ្មានការព្រមព្រៀងគ្នាពិតប្រាកដ ដោយសារបរិយាកាសហិង្សា និងបង្ខិតបង្ខំរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។ ពួកគាត់ក៏ទទួលបានសមិទ្ធផលនាំផ្លូវដ៏អស្ចារ្យសម្រាប់យុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិតាមមធ្យោបាយជាច្រើន។គួរឱ្យកត់សម្គាល់ជាង នេះគឺការលើកឡើងជាលើកដំបូងថា អាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាគោលនយោបាយរបស់រដ្ឋ និងការទទួលស្គាល់ថា ទាំងស្ត្រី *ទាំងបុរស* គឺជាជនរងគ្រោះ។ ខណៈអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរួមសង្វាសក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាផ្នែក និងជាកញ្ចប់នៃគោលនយោបាយ ប.ក.ក តែមួយដូចគ្នា ចៅក្រមបានចោទប្រកាន់ និងជាចុងក្រោយ បានកាត់ទោសចំពោះអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើរំលោភសេពសន្ថវៈជាអំពើអមនុស្សធម៌ផ្សេងៗទៀត ដាច់ដោយឡែកពីគ្នា ដោយបានទទួលស្គាល់នូវព្យសនកម្មខុសៗគ្នាពីអំពើនីមួយៗ។ ផ្អែកលើការរំលោភសិទ្ធិជាមូលដ្ឋាននៃការព្រមព្រៀងដោយស្ម័គ្រចិត្ត និងជំងឺបាក់ស្មារតីជាក់លាក់ដែលបណ្ដាលមកពីអាពាហ៍ពិពាហ៍មិនមែនស្ម័គ្រចិត្តដែលមានចំពោះជនរងគ្រោះ ចៅក្រម អ.វ.ត.ក បានពង្រឹងសាររបស់តុលាការ SCSL ថា អាពាហ៍ពិពាហ៍ដោយបង្ខំមិនមែនគ្រាន់តែជាឧក្រិដ្ឋកម្មផ្លូវភេទលេចធ្លោនោះទេ។



គម្រោងសំណាងផ្កាស្លាក្រោមអង្គការ © Bophana

- *ការរួមភេទដោយបង្ខំ (ការរួមដំណេកក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ)*

នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង០០២ ស.ច.ស បានអនុវត្តនិយមន័យដ៏ទូលំទូលាយចំពោះពាក្យថា អំពើរំលោភសេពសន្ថវៈ ដែលបានអនុម័តដោយ អ.ជ.ស.ដ នៃតុលាការ ICTR នៅក្នុងរឿងក្ដី Akayesu ដោយបានសន្និដ្ឋានថា"ដោយការដាក់ឱ្យអនុវត្តនូវការរួមដំណេកក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ ចារីបានប្រព្រឹត្តនូវការឈ្លានពានផ្នែករាងកាយក្នុងលក្ខណៈផ្លូវភេទ ប្រឆាំងនឹងជនរងគ្រោះ ក្នុងកាលៈទេសៈបង្ខិតបង្ខំ ក្នុងពេលអវត្តមាននូវការព្រមព្រៀងរបស់ជនរងគ្រោះ" និងបានចោទប្រកាន់ និងឱ្យបញ្ជូនខ្លួនជនជាប់ចោទទាំងបួននាក់ទៅជំនុំជម្រះពីបទ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើរំលោភសេពសន្ថវៈទាំងស្ត្រី និងទាំងបុរស។ ជាការបន្ថែម ពួកគាត់បានបញ្ជាក់អះអាងថា អង្គហេតុ

អាចត្រូវបានកំណត់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើអមនុស្សធម៌ផ្សេងៗទៀត ក្នុងទម្រង់ជាអំពើហិង្សាផ្លូវភេទ។

ក្នុងចម្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី និង អៀង ធីរិទ្ធ ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ អ.ប.ជ បានសន្និដ្ឋានថា អំពើរំលោភសេពសន្ថវៈ មិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានបញ្ចូល នៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ទេ។ ដូចបានពិភាក្សាខាងលើ អ.ជ.ត.ក បានបញ្ជាក់ពីការសន្និដ្ឋាននេះមួយឆ្នាំក្រោយមក នៅក្នុងសាលដីកានៃសំណុំរឿង០០១។ យ៉ាងណាមិញ អ.ប.ជ បានតម្កល់សេចក្ដីសម្រេចរបស់ ស.ច.ស ថា អង្គហេតុដូចគ្នាអាចត្រូវបានកំណត់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង០០៣ និង ០០៤/២ ក៏បានអនុវត្តតាមនេះដែរ ដោយបានចោទប្រកាន់ និងឱ្យបញ្ជូនខ្លួន មាស មុត និង អោ អាន ទៅជំនុំជម្រះចំពោះ អំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈអំពើរំលោភសេពសន្ថវៈទាំងស្ត្រី និងទាំងបុរស។

ដូចបានកត់សម្គាល់ខាងលើ ក្នុងសាលក្រមសំណុំរឿង០០២/០២ អ.ជ.ស.ដ បានរកឃើញថា នួន ជា និង ខៀវ សំផន មានពិរុទ្ធចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃ អំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈអំពើដូចបានកំណត់ដាច់ដោយឡែកជា អាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើរំលោភសេពសន្ថវៈ។ ទោះជាយ៉ាងណា ចៅក្រមបានរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលបានប្រព្រឹត្តតាមរយៈអំពើដូចបានកំណត់ជាអំពើរំលោភសេពសន្ថវៈនេះ អនុវត្តបានតែចំពោះស្ត្រី ប៉ុណ្ណោះ។ អ.ជ.ស.ដ បានសម្រេចថា បុរសដែលត្រូវបានបង្ខំឱ្យរួមសង្វាសក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ មិនមែនជាជនរងគ្រោះនៃអំពើរំលោភសេពសន្ថវៈទេ និងបើតាមអង្គជំនុំជម្រះនេះ គឺដោយសារនិយមន័យនៃពាក្យ អំពើរំលោភសេពសន្ថវៈដែលមានអត្ថិភាពនៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ គឺតម្រូវឱ្យបញ្ចូលអង្គជាត ដូច្នេះមិនអនុវត្តចំពោះបុរសទេ។ បន្ទាប់មក អ.ជ.ស.ដ ក៏បានពិចារណាថាតើ ពួកគេជាកម្មវត្ថុនៃអំពើហិង្សាផ្លូវភេទដែលមានតម្លៃស្មើនឹង អំពើអមនុស្សធម៌ផ្សេងៗទៀត ដែរឬអត់។ អ.ជ.ស.ដ បានរកឃើញថា មិនមានតម្លៃស្មើទេ៖ ទោះបីចៅក្រមបានទទួលស្គាល់ថា បុរសជាកម្មវត្ថុនៃអំពើហិង្សាផ្លូវភេទផ្ទុយនឹងសេចក្តីថ្លៃថ្នូររបស់មនុស្សក៏ដោយ ក៏ពួកគាត់លើកឡើងថា គ្មានភស្តុតាងច្បាស់លាស់ក្នុងការកំណត់លើភាពធ្ងន់ធ្ងរនៃទុក្ខវេទនាផ្លូវកាយ និងផ្លូវចិត្តរបស់បុរសដែរ។

សហព្រះរាជអាជ្ញា បានប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសំណុំរឿង០០២/០២ លើចំណុចតែមួយនេះ ដោយបានស្នើឱ្យ អ.ជ.ត.ក ទទួលស្គាល់នូវព្យសនកម្មដែលបានបង្កចំពោះជនរងគ្រោះទាំងបុរស ទាំងស្ត្រី ដែលត្រូវបានខ្មែរក្រហមបង្ខំឱ្យចូលរួមពាក់ព័ន្ធនៅក្នុងការរួមភេទមិនមែនស្ម័គ្រចិត្ត។ សហព្រះរាជអាជ្ញាបានតវ៉ាថាគ្មានការសន្មតតាមផ្លូវច្បាប់ណាមួយថា បុរសទទួលរងការខូចខាតឬភាពមិនថ្លៃថ្នូរ តិចជាងស្ត្រី ពីការរួមភេទដោយបង្ខំឡើយ និងថា ដោយសារការធ្វើឱ្យមានកំហុសធ្ងន់ធ្ងរផ្នែកច្បាប់ និងអង្គហេតុ អ.ជ.ស.ដ ហាក់ដូចជាបានទទួលឥទ្ធិពលពីទស្សនៈសន្មត់ជាមុនមិនត្រឹមត្រូវ ដែលបានបង្កើតនូវផ្នត់គំនិតមួយថា បុរស គឺជា - និងអាច*ត្រឹមតែជា* - ចារីប៉ុណ្ណោះ មិនអាចជាជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្មផ្លូវភេទ បានឡើយ។ ទស្សនៈសន្មតនេះ រួមមានទាំងជំនឿដែលថា បុរសមានទស្សនៈមើលឃើញឱកាសនៃការរួមភេទជាមួយស្ត្រីទាំងអស់ គឺជារឿងវិជ្ជមាន និងមិនទទួលរងនូវការខូចខាតផ្លូវអារម្មណ៍ណាមួយពីការរួមភេទនៃភេទផ្ទុយគ្នានេះទេ បើទោះជាមិនមែនព្រមព្រៀងក្តី។ ទស្សនៈសន្មតជាមុននេះ មិនត្រឹមតែគ្មានសុពលភាពទាំងផ្នែកច្បាប់ និងទាំងអង្គហេតុប៉ុណ្ណោះទេ គឺ

វាថែមទាំងមិនមានភស្តុតាងគាំទ្រដោយផ្ទាល់ពីកំណត់ហេតុផងដែរ រួមទាំងជនរងគ្រោះភេទដែលត្រូវបានចាត់ទុកជាបុរសដែលត្រូវបានគេបង្ខំឱ្យរៀបការនិងចូលរួមពាក់ព័ន្ធនឹងការរួមភេទជាមួយស្ត្រីប្រឆាំងនឹងឆន្ទៈរបស់ខ្លួន។

នៅក្នុងសាលដីកាសំណុំរឿង០០២/០២ របស់ខ្លួន អ.ជ.ត.ក បានទទួលយកបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា និងបានទទួលស្គាល់ថា បុរសជាជនរងគ្រោះនៃការរួមភេទដោយបង្ខំ ដែលនេះជាការលើកតម្លៃមួយឱ្យស្មើនឹងជនរងគ្រោះជាស្ត្រី។ អង្គជំនុំជម្រះបានរកឃើញថា អ.ជ.ស.ដ មានកំហុសដោយមើលរំលងលើភស្តុតាងដែលមានតម្លៃពាក់ព័ន្ធយ៉ាងខ្លាំងទាក់ទងនឹងបទពិសោធន៍របស់ជនរងគ្រោះជាបុរស ដោយសារពួកគាត់ខកខានមិនបានអនុវត្តឱ្យបានត្រឹមត្រូវនូវគោលច្បាប់ សម្រាប់អំពើអមនុស្សធម៌ផ្សេងៗទៀត និងដោយសារការផ្តោតទៅលើតែធាតុផ្សំនៃអំពើរំលោភសេពសន្ថវៈ ជាជាងចរិកលក្ខណៈនៃទង្វើដែលបានចោទប្រកាន់ គឺអំពើនៃការរួមភេទដោយបង្ខំ រវាងជនរងគ្រោះជាបុរស *និង* ស្ត្រី ដែលពួកគេត្រូវបានគេបង្ខំឱ្យរៀបការជាមួយគ្នា។ អ.ជ.ត.ក បានសន្និដ្ឋានថា អំពើបែបនេះបានរំលោភសិទ្ធិជាមូលដ្ឋាននៃបូរណភាពរាងកាយ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស និងមានទម្ងន់ស្មើទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានបញ្ចូល។ អ.ជ.ត.ក បានរកឃើញភស្តុតាងបញ្ជាក់ថា ជនរងគ្រោះជាបុរសបានទទួលរងនូវការឈឺចាប់ធ្ងន់ធ្ងរ ព្រមទាំងការមាក់ងាយ និងការបន្ទាបបន្ថោកធ្ងន់ធ្ងរជាក់ស្តែង ប្រហាក់ប្រហែលនឹងជនរងគ្រោះជាស្ត្រីដែរ។ ជាការបន្ថែម អ.ជ.ត.ក បានរកឃើញថា បុរសបានទទួលរងនូវការបាត់បង់សេចក្តីថ្លៃថ្នូរជាពិសេសដោយឡែក ដោយសារបានបង្ខំប្រពន្ធរបស់ខ្លួនឱ្យក្លាយជាជនរងគ្រោះតាមរយៈការបញ្ចូលអង្គជាតដែលគ្មានការព្រមព្រៀង។

- *ការមានគភ៌ដោយបង្ខំ និងការធ្វើឱ្យមានគភ៌ដោយបង្ខំ*

ដូចបានពិភាក្សាខាងលើ គោលបំណងជាចម្បងមួយនៃអាពាហ៍ពិពាហ៍តាមការចាត់តាំង និងកើតឡើងដដែលៗនៃការរួមភេទដោយបង្ខំគឺដើម្បីបង្កើនចំនួនប្រជាជនរបស់កម្ពុជាប្រជាធិបតេយ្យ - ដើម្បីផលិតកូនដែលអាចបម្រើបដិវត្តន៍ និងដើម្បីបង្កើនផលិតភាពជាអតិបរមា។ នៅក្នុងសំណុំរឿង០០២ ស.ច.ស បានបដិសេធលើសំណើរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដែលស្នើឱ្យស៊ើបអង្កេតលើទង្វើនេះជាការមានគភ៌ដោយបង្ខំ តែមិនមានជនជាប់ចោទណាម្នាក់ក្នុងសំណុំរឿង០០២ បានជាប់ចោទពីបទមានគភ៌ដោយបង្ខំឡើយ។



*ពិព័រណ៍ចល័តស្តីពី ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងរបបខ្មែរក្រហម @ Youtube*

នៅក្នុងសំណុំរឿង០០៤ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានស្នើជាថ្មីម្តងទៀតឱ្យ ស.ច.ស ស៊ើបអង្កេតលើការមានគភ៌ដោយបង្ខំ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

នៃ អំពើអមនុស្សធម៌ផ្សេងៗទៀត (តាមនិយមន័យចែងក្នុងច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម ដែលមានលក្ខខណ្ឌតម្រូវថា "ចារីបានបង្ខាំងស្ត្រីម្នាក់ ឬច្រើននាក់ ដោយបានធ្វើឱ្យពួកគេមានគភ៌ទាំងបង្ខំ ក្នុងចេតនាធ្វើឱ្យប៉ះពាល់ទៅលើ សមាសភាពនៃចំនួនប្រជាជននៃជាតិពន្ធុណាមួយ ឬការអនុវត្តការរំលោភធ្ងន់ធ្ងរផ្សេងទៀតលើច្បាប់អន្តរជាតិ")។ ស.ព.អ បានគាំទ្រលើសំណើនេះ ប៉ុន្តែបានទាញអំណះអំណាងថា និយមន័យតាមច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម មិនអាចអនុវត្តបានឡើយនៅ អ.វ.ត.ក ដោយដាក់ការសន្និដ្ឋានថា ទង្វើនោះគួរត្រូវបានស៊ើបអង្កេតជា *ការធ្វើឱ្យមានគភ៌ដោយបង្ខំ* វិញ មានន័យថា ការបង្ខំ ឬការបង្ខិតបង្ខំស្ត្រី និងក្មេងស្រីឱ្យក្លាយជាជនមានគភ៌ ដែលប្រឆាំងនឹងឆន្ទៈរបស់ពួកគេ។ ស.ព.អ បានទាញអំណះអំណាងថា ទង្វើនេះបានឡើងដល់កម្រិតធ្ងន់ធ្ងរដល់កំពូល ដែលជាការរំលោភលើតម្លៃនៃសិទ្ធិមិនអាចដកហូតបាន មានដូចជា សេចក្តីថ្លៃថ្នូររបស់មនុស្ស ស្វ័យភាព សមភាព និងជម្រើសក្នុងការបន្តពូជ ដែលមានវិបាកផ្នែកសង្គម សេដ្ឋកិច្ច ជីវភាព និងសុខភាពយ៉ាងធ្ងន់ធ្ងរ ព្រមទាំងបណ្តាលឱ្យមានគ្រោះថ្នាក់ផ្លូវចិត្តយ៉ាងខ្លាំង។

ស.ច.ស.អ Bohlander បានបដិសេធលើសំណើរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងបានទាត់ចោលសេចក្តីសន្និដ្ឋានរបស់ ស.ព.អ ដោយការសម្រេចថា i) គ្មានភ័ស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ការមានគភ៌ដោយបង្ខំ ឬការធ្វើឱ្យមានគភ៌ដោយបង្ខំក្តី គឺជា អំពើអមនុស្សធម៌ផ្សេងៗទៀតមួយ ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ii) កង្វះភ័ស្តុតាងអំពីទង្វើនោះ និង iii) ថា សំណើនឹងធ្វើឱ្យមានការពន្យារពេលមិនអាចទទួលយកបានដល់កិច្ចស៊ើបសួរ និងជាបន្ទុកមិនត្រឹមត្រូវចំពោះមេធាវីការពារក្តី។

ស.ច.ស.អ បានសម្រេចយ៉ាងត្រឹមត្រូវថា អំពើអមនុស្សធម៌ផ្សេងៗទៀត គឺជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មួយនៅក្នុងច្បាប់ទម្លាប់អន្តរជាតិ គិតត្រឹមឆ្នាំ១៩៧៥ ដែលបញ្ញត្តិជាបទព្រហ្មទណ្ឌនូវអំពើដែលមាន*ចរិកលក្ខណៈ* និងទម្ងន់ ស្រដៀងគ្នានឹង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានបញ្ចូល និងថាមិនចាំបាច់មានអំពើជាមូលដ្ឋានទេ មានន័យថា មានគភ៌ដោយបង្ខំ។ល។ ដើម្បីអាចចោទប្រកាន់ពីបទព្រហ្មទណ្ឌនៅក្នុងច្បាប់ជាតិ និងអន្តរជាតិ គាត់យល់ស្របថា និយមន័យតាមច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម មិនអាចអនុវត្តបាន។ ប៉ុន្តែ នៅក្នុងការផ្តល់សំអាងហេតុរបស់គាត់ គឺត្រូវតែមាន "និយមន័យដែលអាចទទួលយកបានយ៉ាងទូលំទូលាយ និងបទដ្ឋាន[សិទ្ធិមនុស្ស]ដែលអាចទទួលយកជាទម្លាប់ ពាក់ព័ន្ធនឹងការមានគភ៌ដោយបង្ខំ នៅឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩"។ តាមការពិនិត្យលើក្រម Lieber ឆ្នាំ១៨៦៣ អនុសញ្ញាទីក្រុងហ្សឺណែវ IV និង ពិធីសារបន្ថែម ឆ្នាំ១៩៧៧ ស.ច.ស.អ បានពិចារណាថា ក្នុងឆ្នាំ១៩៧៥ ស្ត្រីភាគច្រើនបានទទួលនូវការការពារយ៉ាងច្បាស់លាស់ពីអំពើរំលោភសេពសន្ថវៈ ពេស្យាចារដោយបង្ខំ និងទម្រង់នៃការបៀតបៀនមិនសមរម្យផ្សេងទៀត។ គាត់បានរកឃើញថាគ្មាននិយមន័យដែលបានដោះស្រាយចប់សព្វគ្រប់ អំពីការមានគភ៌ដោយបង្ខំទេទាំងនៅក្នុងច្បាប់កម្ពុជាឬច្បាប់អន្តរជាតិត្រឹមឆ្នាំ១៩៧៥ និងក៏គ្មាន "បទដ្ឋានសិទ្ធិមនុស្សច្បាស់លាស់"ដែលពាក់ព័ន្ធដែរ ហើយ *ការធ្វើឱ្យមានគភ៌ដោយបង្ខំ* ក៏គាត់បានរកឃើញថា គ្មានដូចគ្នា។

តាមការយល់ឃើញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ គឺ ស.ច.ស.អ មានការភាន់ច្រឡំក្នុងការអនុវត្តលក្ខខណ្ឌតម្រូវផ្នែកច្បាប់ សម្រាប់កំណត់ អំពើអមនុស្សធម៌ផ្សេងៗទៀត ដែលបានតម្កល់ដោយ អ.ជ.ត.ក នៅក្នុងសំណុំរឿង០០២/០១ និង ០០២/០២។ *ភាពធ្ងន់ធ្ងរ* គឺជាគន្លឹះនៃ អំពើអមនុស្សធម៌ផ្សេងៗទៀត ជា

ប្រភេទសេសសល់មួយដែលត្រូវបានបង្កើតឡើងសម្រាប់បំពេញចន្លោះប្រហោងដោយសារចារីណ្ណាសវៃអាចនឹងទទួលបាននិទណ្ឌភាព។ *មិនមាន* លក្ខខណ្ឌតម្រូវឱ្យមានទង្វើជាមូលដ្ឋានជាក់លាក់ដែលហាមឃាត់ច្បាស់ៗក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិទេ ដែលនេះជាការផ្ទុយពីការរកឃើញរបស់ ស.ច.ស.អ និងក៏មិនចាំបាច់ត្រូវតែអនុលោមតាមនិយមន័យច្បាប់ដែរ។

ជាចុងក្រោយ សូមត្រឡប់ទៅមើលការអះអាងរបស់ ស.ច.ស.អ ទាក់ទងនឹងកង្វះភ័ស្តុតាងវិញម្តង។ សូមកត់សម្គាល់ថា ប្រសិនបើអ្នកស៊ើបអង្កេតសួរសំណួរផ្សេងៗពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនេះ ម្ល៉េះភ័ស្តុតាងពាក់ព័ន្ធនឹងលេចចេញមកជាមិនខាន។ ជាការគួរឱ្យសោកស្តាយដែលការមានគភ៌ដោយបង្ខំមិនត្រូវបានស៊ើបអង្កេតឱ្យបានពិតប្រាកដនៅ អ.វ.ត.ក។

# ការកសាងសមត្ថភាព

ការកសាងសមត្ថភាព ដែលគេស្គាល់ផងដែរថា ការអភិវឌ្ឍន៍សមត្ថភាព បានកើតឡើងទាំងនៅក្នុង និងខាងក្រៅ អ.វ.ត.ក និងបានរួមចំណែកដល់កិច្ចការរបស់តុលាការ និងកេរដំណែលនៅក្នុងប្រទេសកម្ពុជា និងហួសពីប្រទេសកម្ពុជា។ តាមរយៈអភិក្រមពហុមុខព្រួញ អ.វ.ត.ក បានអនុវត្តរចនាសម្ព័ន្ធ និងបានផ្តល់ឧបករណ៍យុត្តិសាស្ត្រនិងការអប់រំ ដើម្បីពង្រឹងតួនាទីដ៏សំខាន់ដែលមិនអាចខ្វះបាននៃវិធានដែលពឹងផ្អែកលើប្រព័ន្ធច្បាប់ជាធំ និងសង្គមដែលដើរតួនាទីក្នុងការផ្តល់យុត្តិធម៌យ៉ាងត្រឹមត្រូវ និងមិនលម្អៀង។

កំណត់ត្រាច្បាប់ និងនីតិវិធីតុលាការ គឺជាកេរដំណែលស្នូលចំនួនពីរនៃការកសាងសមត្ថភាពរបស់ខ្លួន។ កំណត់ត្រាទាំងនេះរម្លឹកពីការប្រព្រឹត្តិទៅនៃប្រព័ន្ធតុលាការដែលក្រសោបយកសិទ្ធិក្នុងការទទួលបានការជំនុំជម្រះ ដោយត្រឹមត្រូវយុត្តិធម៌សម្រាប់ភាគីទាំងអស់ រួមទាំងភាគីដើមបណ្តឹងរដ្ឋប្បវេណី ជាពិសេស គឺជនត្រូវចោទនិងជនជាប់ចោទ សេចក្តីសម្រេចនានាដែលបានធ្វើឡើងដោយឯករាជ្យ និងមិនលម្អៀងដោយចៅក្រមកម្ពុជានិងអន្តរជាតិ ដែលពឹងផ្អែកលើអង្គច្បាប់និងអង្គហេតុ និងការចេញដីកា សេចក្តីសម្រេច និងសាលក្រមជាលាយលក្ខណ៍អក្សរដែលមានសំអាងហេតុជាភាសាខ្មែរ។ ក្រោយការបិទបញ្ចប់ អ.វ.ត.ក កិច្ចការរបស់តុលាការ គឺនៅតែត្រូវបានថែរក្សា អាចចូលពិនិត្យមើលបាន និងអាចរកបានដើម្បីជាដំណឹង និងកែសម្រួលទៅលើយន្តការតុលាការនៅក្នុងប្រទេសកម្ពុជា និងដើម្បីអប់រំសាធារណជនកម្ពុជាអំពីសិទ្ធិ និងកាតព្វកិច្ចជាមូលដ្ឋាននៅក្នុងកិច្ចដំណើរការនីតិវិធីច្បាប់។

កេរដំណែលនៃការអភិវឌ្ឍន៍សមត្ថភាពស្នូលផ្សេងទៀតរបស់ អ.វ.ត.ក គឺកំណើននៃចំណេះដឹងអំពីច្បាប់សារធាតុ និងច្បាប់នីតិវិធីអន្តរជាតិ និងការគ្រប់គ្រងសំណុំរឿង ព្រមទាំងជំនាញបច្ចេកទេសកាន់តែប្រសើរ ដែលចៅក្រម មេធាវី និងមន្ត្រីគ្រប់គ្រងរដ្ឋបាលជាតិជាច្រើនបានទទួលនៅពេលពួកគេបានបម្រើការងារនៅតុលាការនេះ។ ពួកគេនឹងពង្រីកដែនសមត្ថភាពវិជ្ជាជីវៈរបស់ពួកគេតាមរយៈកិច្ចការរដ្ឋបាល និងតុលាការដែលកំពុងអនុវត្ត និងតាមរយៈវគ្គអប់រំនិងសិក្ខាសាលាអភិវឌ្ឍន៍វិជ្ជាជីវៈខ្លីៗដែលមានចំពោះពួកគាត់។



*ផ្នែកគាំពារជនរងគ្រោះរៀបចំសិក្ខាសាលាស្តីអំពីការយល់ដឹងអំពីស្ត្រីនៅក្នុងសម័យយុត្តិធម៌អន្តរកាល © គេហទំព័រ អ.វ.ត.ក*

ជាឧទាហរណ៍ខ្លះៗ នាបណ្តាឆ្នាំដំបូងរបស់តុលាការ បុគ្គលិកកម្ពុជាបានធ្វើដំណើរទៅតុលាការ ICTY និង ICC ដើម្បីធ្វើបទសម្ភាសន៍ជាមួយមេធាវី

អ្នកស៊ើបអង្កេត និងអ្នកវិភាគអំពីដំណើរការស៊ើបអង្កេត និងការគ្រប់គ្រងសំណុំរឿងដោយប្រសិទ្ធភាព។ ចំណែកនៅ អ.វ.ត.ក ឯណេះវិញ ទាំងបុគ្គលិកជាតិនិងអន្តរជាតិសុទ្ធតែទទួលបានការដុសខាត់ជំនាញ តាមរយៈការធ្វើការងារដោយផ្ទាល់លើសំណុំរឿងរបស់ អ.វ.ត.ក និងតាមរយៈសិក្ខាសាលាច្បាប់ផងដែរ (ដែលផ្ដោតលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងច្បាប់មនុស្សធម៌អន្តរជាតិ) វគ្គសិក្សាភាសាខ្មែរនិងអង់គ្លេស វគ្គសិក្សាបច្ចេកវិទ្យា និងសិក្ខាសាលាលើជំនាញស៊ើបអង្កេត។ តុលាការបានបើកវគ្គបណ្ដុះបណ្ដាលស្ដីពីអំណាចនៃយ៉េនឌ័រ និងយុត្តិធម៌អន្តរកាល និងបានសហការណ៍ជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការធ្វើបទបង្ហាញអំពីវគ្គអប់រំខ្លីៗដើម្បីជួយដល់មេធាវីកម្ពុជា ក្នុងការធ្វើតំណាងឲ្យកូនក្ដីរបស់ខ្លួនឲ្យមានប្រសិទ្ធភាពនៅ អ.វ.ត.ក។

បុគ្គលិកជាតិយកចំណេះដឹង និងជំនាញទាំងនេះទៅជាមួយពួកគេដើម្បីប្រើប្រាស់ជាប្រយោជន៍ និងបញ្ជ្រៀប នៅក្នុងប្រព័ន្ធរដ្ឋបាល និងប្រព័ន្ធច្បាប់របស់កម្ពុជា។

សមិទ្ធផលនៃការអភិវឌ្ឍន៍សមត្ថភាពដ៏សំខាន់មួយទៀតរបស់ អ.វ.ត.ក គឺការប្រើប្រាស់កម្មសិក្សាការី/កម្មសិក្សាការិនីកម្ពុជា និងអន្តរជាតិ។ ពេញមួយជីវិតនៃដំណើរការរបស់តុលាការ គ្រប់ស្ថាប័នទាំងអស់របស់តុលាការបានពឹងផ្អែកយ៉ាងខ្លាំងទៅលើពួកគេ ក្នុងការបំពេញអាណត្តិរបស់ស្ថាប័ននីមួយៗរៀងៗខ្លួន ដែលបានធ្វើឲ្យនិស្សិតច្បាប់ និងអ្នកអាជីពវ័យក្មេងទាំងនេះ ជាផ្នែកដ៏សំខាន់បំផុតមួយនៅក្នុងក្រុមរបស់ពួកគេ។ កម្មសិក្សាការី/កម្មសិក្សាការិនីបានបំពេញកិច្ចការជាច្រើនដូចគ្នានឹងមេធាវី អ្នកវិភាគ និងមន្ត្រីអាជីពទទួលបន្ទុកកិច្ចការសាធារណៈរបស់ អ.វ.ត.ក ដែរ។ បទពិសោធន៍ទទួលបានតាមការអនុវត្តផ្ទាល់នេះ បានជួយអភិវឌ្ឍន៍លើជំនាញរបស់ពួកគេ និងបានរួមចំណែកយ៉ាងសំខាន់ដល់ដំណើរការតុលាការនៅ អ.វ.ត.ក ហើយកម្មសិក្សាការី/កម្មសិក្សាការិនីជាតិ គឺជាផ្នែកនៃមូលដ្ឋានចំណេះដឹង និងជំនាញ ដែលពួកគេនាំយកទៅប្រើប្រាស់នៅក្នុងការងាររបស់ពួកគេក្នុងប្រព័ន្ធរបស់កម្ពុជា។



*សិស្សានុសិស្សប្រមាណ៧០០ នាក់មកពីខេត្តត្បូងឃ្មុំ និងខេត្តព្រៃវែង បំពេញទស្សនកិច្ចនៅ អ.វ.ត.ក នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៨ © គេហទំព័រ អ.វ.ត.ក*

សម្រាប់សាធារណជនកម្ពុជាវិញ កម្មវិធីអប់រំនិងផ្សព្វផ្សាយនៅ អ.វ.ត.ក និងនៅទូទាំងប្រទេសកម្ពុជា បានផ្ដល់ចំណេះដឹងដល់អ្នកចូលរួមអំពីការងាររបស់តុលាការ និងបានជួយសម្រួលដល់កិច្ចសន្ទនាអំពីប្រវត្តិខ្មែរក្រហម និងអំពីអត្ថន័យនៃការផ្ដល់យុត្តិធម៌ដោយត្រឹមត្រូវ និងមិនលម្អៀង។ ជាឧទាហរណ៍ អ.វ.ត.ក បានរៀបចំឲ្យមានទស្សនកិច្ចសិក្សា និងបាឋកថា ជូនដល់អ្នកចូលរួមជាសិស្ស/និស្សិត និងគ្រូបង្រៀនកម្ពុជារាប់ពាន់នាក់ដែលមកពីសាលានានាដូចជាសាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យបាត់ដំបង និងវិទ្យាល័យឯកភ្នំជាដើម។ ដូចគ្នានេះដែរ អ.វ.ត.ក ក៏បានធ្វើការជាមួយម្ចាស់ជំនួយមូលនិធិ

ពីខាងក្រៅ ជាចំបង គឺអង្គការមិនមែនរដ្ឋាបាល ដើម្បីធានាថា ប្រជាជនកម្ពុជាអាចចូលរួមវគ្គអប់រំរបស់តុលាការ ដែលធ្វើឱ្យពួកគេស៊ាំនឹងប្រព័ន្ធតុលាការដែលពឹងផ្អែកលើការជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌ និងវិធាននៃច្បាប់។ នៅទូទាំងប្រទេសកម្ពុជា សម្ភារអប់រំត្រូវបានបែងចែក ហើយការធ្វើបទបង្ហាញពីការងាររបស់តុលាការក៏បានធ្វើឡើង។



គរុសិស្ស ៣០០ នាក់ មកពីវិទ្យាស្ថានជាតិអប់រំធ្វើទស្សនកិច្ចនៅ អ.វ.ត.ក
© គេហទំព័រ អ.វ.ត.ក

ការកសាងសមត្ថភាពនៅ អ.វ.ត.ក ពិតជាបានជួបបញ្ហាប្រឈមខ្លះៗដែលបានកំហិតដល់វិសាលភាពរបស់តុលាការ។ ជាឧទាហរណ៍ ការកំហិតផ្នែកមូលនិធិនាំឱ្យមិនមានការកសាងសមត្ថភាពសម្រាប់អ្នកអាជីពពីខាងក្រៅ ដូចតុលាការអន្តរជាតិ និងតុលាការកូនកាត់ទាំងអស់ផ្សេងទៀតដែរ មានន័យថាបុគ្គលិក អ.វ.ត.ក លះបង់ពេលវេលារបស់ខ្លួនលើតែសកម្មភាពទាំងឡាយណាដែលអាណត្តិតុលាការ និងរដ្ឋបាលអនុញ្ញាតឱ្យខ្លួនប៉ុណ្ណោះ។ ការិយាល័យរដ្ឋបាលក៏បានធ្វើការផ្លាស់ប្តូរផងដែរក្នុងបណ្តាឆ្នាំថ្មីៗនេះនូវអាទិភាពមូលនិធិផ្ទៃក្នុងរបស់ខ្លួនចេញពីសកម្មភាពផ្សព្វផ្សាយ និងការកសាងសមត្ថភាពអ្នកអាជីព ហើយបានធ្វើការកាត់បន្ថយយ៉ាងច្រើននូវបុគ្គលិកផ្នែកកិច្ចការសាធារណៈរបស់ខ្លួន។ លើសពីនេះទៀត បុគ្គលិកច្បាប់កម្ពុជាជាច្រើននៅ អ.វ.ត.ក ក៏តម្រូវឱ្យបំពេញអាណត្តិការងារពេញម៉ោងតាមតួនាទីក្នុងរដ្ឋាភិបាលកម្ពុជារបស់ពួកគេ ជាហេតុធ្វើឱ្យមានការកាត់បន្ថយការចូលរួម និងការបង្ហាញខ្លួនរបស់ពួកគេចំពោះកិច្ចការរបស់ អ.វ.ត.ក ដែលជាលទ្ធផលបានកំហិតលើចំណេះដឹង និងជំនាញរបស់ពួកគេដើម្បីនាំយកទៅជាមួយខ្លួនដែលបានទទួលពីបទពិសោធន៍ទាំងនោះ។

ទោះជាយ៉ាងណា ការកំហិតទាំងនេះមិនបានប៉ះពាល់ដល់ជោគជ័យរួមនៃកេរដំណែលកសាងសមត្ថភាពរបស់ អ.វ.ត.ក ឡើយ ដែលយើងបានទទួលស្គាល់យ៉ាងត្រឹមត្រូវថា វាគឺជាសមិទ្ធផលដ៏សំខាន់មួយ។

# ផ្នែក IV÷ បញ្ហាប្រឈម

# បញ្ហាប្រឈមផ្នែករចនាសម្ព័ន្ធ

## ក. សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត

ក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក ដែលបានបង្កើតសហចៅក្រមស៊ើបអង្កេត និង សហព្រះរាជអាជ្ញាឯករាជ្យ និងស្មើភាពគ្នាពីរ គឺភាគីអន្តរជាតិមួយ និង ភាគីកម្ពុជាមួយ បានបង្ហាញអំពីបញ្ហាប្រឈមដែលកើតមានជុំវិញផលវិបាកនៃការខ្វែងគំនិតគ្នាដែលមិនអាចផ្សះផ្សាបានរវាងពួកគេ។ ជាអកុសល អ.វ.ត.ក មិនបានដោះស្រាយបញ្ហាប្រឈមទាំងនេះបានដោយជោគជ័យនោះឡើយ ដូចដែលបានពិភាក្សាខាងក្រោម។

### • សហព្រះរាជអាជ្ញាដែលមានសិទ្ធិអំណាចស្មើគ្នា និងឯករាជ្យ

គេអាចដឹងជាមុនបានថា ការខ្វែងគំនិតគ្នាជាមូលដ្ឋានអាចកើតឡើងរវាងសហព្រះរាជអាជ្ញា ដែលមានសិទ្ធិអំណាចស្មើគ្នា និងឯករាជ្យ ដូចជាលទ្ធផលដែលថា សហព្រះរាជអាជ្ញាម្នាក់ អាចសម្រេចចិត្តបំពេញកិច្ចតែម្នាក់ឯង ឧទាហរណ៍ ចាប់ផ្តើមការស៊ើបអង្កេតតាមផ្លូវតុលាការក្រោមវិធាន ៥៣។ ជាការពិត មាត្រា ៦ និង មាត្រា៧ នៃ កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ២០ នៃច្បាប់ អ.វ.ត.ក និង វិធាន ៧១ នៃវិធានផ្ទៃក្នុង ព្យាករណ៍អំពីយថាហេតុទាំងនេះ។ មាត្រាទាំងនេះបានដាក់យន្តការដោះស្រាយការខ្វែងគំនិតគ្នាដែលអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាបញ្ជូនការខ្វែងគំនិតរបស់ពួកគេទៅអង្គបុរេជំនុំជម្រះ ប៉ុន្តែមិនមែនជា*លក្ខខណ្ឌតម្រូវ*នោះទេ។ ក្នុងករណីដែលការខ្វែងគំនិតគ្នាមិនត្រូវបានបញ្ជូន ឬនៅពេលដែលអង្គបុរេជំនុំជម្រះបរាជ័យមិនអាចរកសំឡេងភាគច្រើនលើសលុបដើម្បីដោះស្រាយការខ្វែងគំនិតគ្នា នោះក្របខ័ណ្ឌច្បាប់ចែងអំពី "គោលជំហរស្វ័យប្រវត្តិ"៖ ក្នុងករណីបែបនេះ ការចោទប្រកាន់ "ត្រូវបន្ត"។ លើសពីនេះទៅទៀត វិធាន ១(២) បញ្ជាក់យ៉ាងច្បាស់ថា ការយោងនៅក្នុងវិធានផ្ទៃក្នុងនេះចំពោះពាក្យសហព្រះរាជអាជ្ញា គឺរួមបញ្ចូលទាំង ការធ្វើការសម្រេចចិត្តដោយសហព្រះរាជអាជ្ញាណាម្នាក់ក្នុងចំណោមអ្នកទាំងពីរ និងក្នុងឱកាសជាច្រើន អង្គបុរេជំនុំជម្រះបានផ្តល់ការបញ្ជាក់ជាឯកច្ឆន្ទតាមផ្លូវតុលាការថាសហព្រះរាជអាជ្ញា(និងសហចៅក្រមស៊ើបអង្កេត) អាចបំពេញកិច្ចតែម្នាក់ឯងដើម្បីឱ្យកិច្ចដំណើរការនីតិវិធីដំណើរការទៅមុខ។

ប៉ុន្តែ ទោះបីជាយ៉ាងនេះក្តី ភាពមិនច្បាស់លាស់ដែលអាចជៀសវាងបាន នៅក្នុងឯកសារមូលដ្ឋានរបស់ អ.វ.ត.ក បានអនុញ្ញាតឱ្យអ្នកដែលមានបំណងរារាំងកិច្ចដំណើរការនីតិវិធី ស្វែងរកបទប្បញ្ញត្តិដែលគាំទ្រដល់លក្ខខណ្ឌតម្រូវមួយដែលថា សហព្រះរាជអាជ្ញា ត្រូវតែអនុវត្តការងារទាំងអស់រួមគ្នា។ ឧទាហរណ៍ មាត្រា ១៦ នៃច្បាប់ អ.វ.ត.ក ចែងថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវតែជាការទទួលខុសត្រូវរបស់ព្រះរាជអាជ្ញាទាំងពីរ ដែលត្រូវធ្វើការរួមគ្នាដើម្បីរៀបចំដីកាទាំងនេះ។ វិធានផ្ទៃក្នុងមួយចំនួន ក៏ហាក់ដូចជាតម្រូវស្រដៀងគ្នាឱ្យបំពេញកិច្ចរួមគ្នា ប្រសិនបើត្រូវបានអនុវត្តក្រៅបរិបទ និងដោយមិនមានការយោងទៅ លើវិធាន ១(២)។ ឧទាហរណ៍ វិធាន ៤៩(១) និង ៥០(២) កំណត់ថា ការចោទប្រកាន់ និងការស៊ើបអង្កេតបឋម អាចត្រូវបានផ្តួចផ្តើមឡើង និងអនុវត្តតាមការស្នើសុំរបស់សហព្រះរាជអាជ្ញាប៉ុណ្ណោះ។ នៅក្រោមវិធាន ៥៣ សហព្រះរាជអាជ្ញា គឺជាអ្នកដែលបើកការស៊ើបអង្កេតតាមផ្លូវតុលាការ។

ដំបូងឡើយ គ្មានការខ្វែងគំនិតគ្នារវាងសហព្រះរាជអាជ្ញា ដែលប៉ះពាល់ដោយផ្ទាល់ដល់ការរីកចម្រើននៃកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ទេ ហើយចៅក្រមអង្គបុរេជំនុំជម្រះ បានអនុវត្តយ៉ាងត្រឹមត្រូវនូវគោលជំហរស្វ័យប្រវត្តិក្នុងឆ្នាំ២០០៩ ក្នុងការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក្នុងរឿងក្តី ០០៣ និង ០០៤ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅកាន់សហចៅក្រមស៊ើបអង្កេតដើម្បីធ្វើការស៊ើបអង្កេត។ ទោះជាយ៉ាងណាក៏ដោយ ទោះបីជាមានសកម្មភាពជាឯកច្ឆន្ទរបស់អង្គបុរេជំនុំជម្រះពីមុនក៏ដោយ នៅចុងបញ្ចប់នៃការស៊ើបអង្កេតរឿងក្តី ០០៤ ចៅក្រមជាតិទាំងបីរូបរបស់អង្គបុរេជំនុំជម្រះ បានប្រើភាពមិនច្បាស់លាស់ទាំងនេះដើម្បីសម្រេចថា សំណុំរឿងទាំងមូលគឺខុសច្បាប់ ដោយសារចោទប្រកាន់ថា សហព្រះរាជអាជ្ញាអន្តរជាតិបានបំពេញកិច្ចជាឯកតោភាគីក្នុងការស៊ើបអង្កេតបឋម កាលពី១៣ ទៅ ១៥ ឆ្នាំមុន។ ការសន្និដ្ឋានបែបនេះ គឺផ្ទុយគ្នាទាំងស្រុងទៅនឹងយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះខ្លួនឯងផ្ទាល់ ហើយក៏ផ្ទុយទៅនឹងភ័ស្តុតាងនីតិវិធីដែលមាន។ ទោះជាត្រឹមត្រូវក៏ដោយ ក៏ចៅក្រមបានធ្វើមិនដឹងមិនឮផងដែរថាកំហុស ត្រូវបានដោះស្រាយតាមរយៈការរីកចម្រើននៃកិច្ចដំណើរការនីតិវិធីរួចទៅហើយដែរ។ ការពឹងផ្អែកលើភាពមិនច្បាស់លាស់សើរៗទាំងនេះ ធ្វើឱ្យប៉ះពាល់មិនចាំបាច់លើការបិទបញ្ចប់កិច្ចដំណើរការនីតិវិធីដែលអាចជៀសវាងបាន ប្រសិនបើឯកសារមូលដ្ឋានគោល និងវិធានផ្ទៃក្នុង ចែងក្នុងពាក្យពេចន៍ច្បាស់លាស់អំពីសិទ្ធិអំណាចរបស់សហព្រះរាជអាជ្ញាម្នាក់ក្នុងការបំពេញកិច្ចជាឯកតោភាគី ដែលត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការលើបញ្ហាច្បាប់សំខាន់ៗ។

- **សហចៅក្រមស៊ើបអង្កេតដែលមានសិទ្ធិអំណាចស្មើគ្នា និងឯករាជ្យ**

ការពិចារណាតាមប្រព័ន្ធតុលាការអំពីផលវិបាកនៃការមានសហចៅក្រមស៊ើបអង្កេតដែលមានសិទ្ធិអំណាចស្មើគ្នា និងឯករាជ្យចំនួនពីរនាក់ និងយន្តការដោះស្រាយការខ្វែងគំនិតគ្នាដែលអនុញ្ញាតស្រដៀងគ្នានេះ ដែលមានចែងក្នុងមាត្រា ៥ និងមាត្រា ៧ នៃកិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ២៣ នៃច្បាប់ អ.វ.ត.ក និង វិធាន ៧២ នៃវិធានផ្ទៃក្នុង បានបង្ហាញពីបញ្ហាប្រឈមដែលចុងក្រោយនាំឱ្យមហន្តរាយដល់ការចោទប្រកាន់ក្នុងរឿងក្តី ០០៣, ០០៤/២ និង ០០៤។

ការវិភាគលើប្រព័ន្ធស៊ើបអង្កេតជាតិ និងអន្តរជាតិ បង្ហាញពីភាពខុសប្លែកពីគេតែមួយគត់នៃរចនាសម្ព័ន្ធនេះ ដែលមិនមាននៅក្នុងប្រទេសណាមួយឡើយដែលប្រើច្បាប់ស៊ីវិល ដែលនៅបន្តប្រើចៅក្រមស៊ើបអង្កេត។ ដូចនៅក្នុងប្រព័ន្ធកម្ពុជាធម្មតាដែរ ចៅក្រមស៊ើបអង្កេតជាធម្មតាធ្វើការតែម្នាក់ឯង។ ក្នុងករណីដែលបទប្បញ្ញត្តិចែងអំពីចៅក្រមច្រើននាក់ដែលមានសិទ្ធិអំណាចស្មើគ្នា និងឯករាជ្យការស៊ើបអង្កេតលើរឿងក្តីស្មុគស្មាញ វាតែងតែមានយន្តការចាំបាច់មួយដើម្បីដោះស្រាយការខ្វែងគំនិតគ្នា និងជៀសវាងការជាប់គាំងផ្នែកនីតិវិធី ជាធម្មតាដោយការបោះឆ្នោតភាគច្រើន ឬសំឡេងឆ្នោតរបស់ចៅក្រមប្រធាន។ នៅកម្រិតអន្តរជាតិ តុលាការឧក្រិដ្ឋកម្មពិសេសនៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល (សាលាក្តីកូនកាត់មួយទៀតផ្អែកលើប្រព័ន្ធច្បាប់ស៊ីវិល) ប្រើប្រព័ន្ធសហចៅក្រមស៊ើបអង្កេតដែលមានសិទ្ធិអំណាចស្មើគ្នា និងឯករាជ្យចំនួនពីរនាក់។ ប៉ុន្តែតុលាការនោះអនុវត្តយន្តការខ្វែងគំនិតគ្នា *ជាភាគពួកកិច្ច* ដែលមានចែងយ៉ាងច្បាស់លាស់ក្នុងករណីដែលពួកគេមិនអាចឯកភាពគ្នាបាន ដែលផ្ទុយស្រឡះពីប្រព័ន្ធ *អនុញ្ញាត របស់ អ.វ.ត.ក*។ សាលាក្តីនោះ ប្រើអង្គជំនុំជម្រះអយ្យការពិសេស (Chambre d'Accusation Spéciale) ដែលមានចៅក្រមបីរូប (ចៅក្រមអន្តរជាតិពីររូប និង ចៅក្រមជាតិមួយរូប) ដែលសម្រេចលើវិវាទដោយសំឡេងភាគច្រើនក្នុងរយៈពេលប្រាំថ្ងៃ។

ដូចគ្នាសម្រាប់សហព្រះរាជអាជ្ញាដែរ ក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក ផ្តល់នូវយន្តការស្វ័យប្រវត្តិ ដែលមានបំណងជៀសវាងការជាប់គាំងនៅក្នុងដំណើរការតុលាការ ដែលកើតចេញពីការខ្វែងគំនិតគ្នារវាង ស.ច.ស។ ក្របខ័ណ្ឌច្បាប់នេះចែងថា ការស៊ើបអង្កេត - ដែលត្រូវបានបកស្រាយតាមផ្លូវតុលាការមានន័យថា "រឿងក្តី" បន្ទាប់ពីការចេញដីកាដំណោះស្រាយ - "ត្រូវបន្ត" ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេត មិនបញ្ជូនបញ្ហាខ្វែងយោបល់គ្នាទៅអង្គបុរេជំនុំជម្រះ ឬក្នុងករណីដែលបន្ទាប់ពីការបញ្ជូន មិនមានសំឡេងភាគច្រើនលើសលុបរបស់អង្គបុរេជំនុំជម្រះ ដើម្បីបដិសេធសកម្មភាពដំណើរការស៊ើបអង្កេតបន្ត។ អ្វីដែលអនុញ្ញាតឱ្យការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣, ០០៤/១, ០០៤/២ និង ០០៤ ឱ្យឈានដល់ការបិទបញ្ចប់ ដោយមានជនសង្ស័យបីនាក់ក្នុងចំណោមបួននាក់ដែលត្រូវបានចោទប្រកាន់ដោយសហចៅក្រមអន្តរជាតិ គឺជាសមត្ថភាពនេះដែលផ្ទុះបញ្ចាំងនៅក្នុងវិធាន ១(២) និងបានបញ្ជាក់ជាច្រើនលើកច្រើនសារដោយអង្គបុរេជំនុំជម្រះ ក្នុងការអនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេតម្នាក់បំពេញកិច្ចតែម្នាក់ឯង ដើម្បីដំណើរការការស៊ើបអង្កេត។ នៅពេលដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានចេញ ហើយមិនមានសំឡេងភាគច្រើនលើសលុបរបស់ចៅអង្គបុរេជំនុំជម្រះ នោះវិធាន ៧៧(១៣)(ខ) អនុវត្តគោលជំហរស្វ័យប្រវត្តិដោយកំណត់ថា អង្គជំនុំជម្រះសាលាដំបូង *ត្រូវ* ទទួលយករឿងក្តី ពោលគឺរឿងក្តី *ត្រូវ* បន្តទៅជំនុំជម្រះ។

ប្រព័ន្ធនេះបានបែកបាក់ជាចម្បងដោយសារតែចៅក្រមអង្គបុរេជំនុំជម្រះបរាជ័យក្នុងការទទួលយកថា ផលវិបាកដែលអាចកើតមាននៃការមានសហចៅក្រមស៊ើបអង្កេតឯករាជ្យស្មើភាពគ្នាពីរនាក់និងយន្តការខ្វែងយោបល់គ្នាដែល *អនុញ្ញាត* គឺថា សហចៅក្រមស៊ើបអង្កេតទាំងពីររូបនេះ អាចចេញដីកាដំណោះស្រាយផ្ទុយគ្នា ដោយផ្អែកលើការសន្និដ្ឋានអង្គច្បាប់ និងអង្គហេតុ ដែលមិនអាចផ្សះផ្សាបាន។ នៅក្នុងសំណុំរឿង ០០៤/២ សំណុំរឿង ០០៣ និងបន្ទាប់មក សំណុំរឿង ០០៤ សហចៅក្រមស៊ើបអង្កេត ជឿតាមការយល់របស់ខ្លួនឯងចំពោះក្របខ័ណ្ឌរបស់ អ.វ.ត.ក ហើយជ្រើសរើសមិនបញ្ជូនការខ្វែងគំនិតរបស់ពួកគេទៅអង្គបុរេជំនុំជម្រះទេ។ ដើម្បីជាផលប្រយោជន៍នៃតម្លាភាព និងការអនុវត្តឯករាជ្យភាពរបស់ពួកគេ ផ្ទុយទៅវិញ ពួកគេបានចេញដីកាដំណោះស្រាយផ្ទុយគ្នាពីរនៅក្នុងរឿងក្តីនីមួយៗ។ ប៉ុន្តែ នៅក្នុងបរិបទនៃបណ្តឹងឧទ្ធរណ៍របស់ភាគី ប្រឆាំងនឹងដីកាដំណោះស្រាយទាំងនោះ ចៅក្រមអង្គបុរេជំនុំជម្រះបានសម្រេចថា ការចេញដីកាដំណោះស្រាយផ្ទុយគ្នាពីរ គឺខុសច្បាប់ ដូច្នេះហើយពួកគេក៏មិនឱ្យតម្លៃ មិនទទួលយក និងមិនអនុវត្តតថភាពនៃក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក។

ភាពបរាជ័យនេះបានកើនឡើង ដំបូងនៅកម្រិតអង្គបុរេជំនុំជម្រះ ហើយបន្ទាប់មកនៅអង្គជំនុំជម្រះតុលាការកំពូល។ ទោះបីជាចៅក្រមអង្គបុរេជំនុំជម្រះមិនបានបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅក្នុងរឿងក្តីទាំងនោះដោយសំឡេងភាគច្រើនលើសលុបក៏ដោយ ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ បានបដិសេធមិនអនុវត្តយន្តការស្វ័យប្រវត្តិ និងមិនបញ្ជូនរឿងក្តីទៅជំនុំជម្រះទេ។ ការណ៍នេះបានបង្កើតឱ្យមានភាពមិនប្រាកដប្រជាផ្នែកតុលាការដែលមិនអាចទទួលយកបាន ដែលជាការរំលោភលើគោលបំណងច្បាស់លាស់នៃឯកសារមូលដ្ឋានគោល និងអត្ថន័យច្បាស់លាស់នៃវិធាន ៧៧(១៣)(ខ) ដែលចែងថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវប្តឹងទៅអង្គជំនុំជម្រះសាលាដំបូងក្នុងករណីដែលពួកវាមិនត្រូវបានបដិសេធដោយសំឡេងភាគច្រើនលើសលុបរបស់អង្គបុរេជំនុំជម្រះ។ បន្ទាប់មកការខ្វះសិទ្ធិអំណាច និងការទទួលខុសត្រូវច្បាស់លាស់របស់អង្គជំនុំជម្រះតុលាការកំពូលក្នុងការចេញដីកាដែលមានលក្ខណៈចាប់បង្ខំ ដើម្បីកែតម្រូវ

បរាជ័យបែបនេះ និងដើម្បីឲ្យខ្លួនឯងគោរពតាមគោលជំហរស្វ័យប្រវត្តិនេះ ឬកង្វះឆន្ទៈរបស់ខ្លួនក្នុងការធ្វើដូច្នេះ បានធ្វើឲ្យអង្គជំនុំជម្រះតុលាការកំពូល រំលត់សំណុំរឿងទាំងបី។

បញ្ហាប្រឈមទាំងនេះ ដែលទាក់ទងនឹងសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត អាចត្រូវបានដោះស្រាយដោយការប្រើពាក្យពេចន៍ច្បាស់លាស់ជាងនេះ និងស៊ីចង្វាក់គ្នានៅក្នុងឯកសារមូលដ្ឋានគោល ហើយវិធានផ្ទៃក្នុងមានការបញ្ជាក់ច្បាស់ៗអំពី៖

i. សិទ្ធិអំណាចរបស់សហព្រះរាជអាជ្ញា ឬសហចៅក្រមស៊ើបអង្កេតនីមួយៗ ក្នុងការបំពេញកិច្ចតែម្នាក់ឯង។
ii. យន្តការដោះស្រាយការខ្វែងគំនិតគ្នាជាកាតព្វកិច្ច ដើម្បីដោះស្រាយការខ្វែងគំនិតគ្នាដែលមិនអាចផ្សះផ្សាបាន។
iii. លក្ខណៈចាប់បង្ខំនៃយន្តការស្វ័យប្រវត្តិរបស់ អ.វ.ត.ក នៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី រួមទាំងភារកិច្ចតុលាការ និងរដ្ឋបាល ក្នុងការចាត់វិធានការចាំបាច់ទាំងអស់ដើម្បីអនុវត្តគោលជំហរនោះដូចជាការបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូងសម្រាប់ការជំនុំជម្រះ និង
iv. សិទ្ធិអំណាច និងកាតព្វកិច្ចរបស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងការកែកំហុសរបស់អង្គជំនុំជម្រះជាន់ទាប និងការបង្គាប់ឲ្យមានវិធានការកែតម្រូវ ដែលមានលក្ខណៈចាប់បង្ខំលើចៅក្រមទាំងអស់ រួមទាំងការបង្គាប់ឲ្យសំណុំរឿងបន្តទៅជំនុំជម្រះ ដោយអនុលោមតាមគោលជំហរស្វ័យប្រវត្តិ។

ជាការបន្ថែម បញ្ហាប្រឈមទាំងនេះបង្ហាញពីតម្រូវការសម្រាប់សាលាក្តី "កូនកាត់" ដែលមាន "លក្ខណៈជាអន្តរជាតិ" នៅពេលអនាគត ត្រូវមានចៅក្រមអន្តរជាតិភាគច្រើននៅក្នុងអង្គជំនុំជម្រះ ដែលពេលនោះ គួរតែប្រើការបោះឆ្នោតដោយសំឡេងភាគច្រើនធម្មតា។ គំរូដែលបានកែប្រែនេះនឹងមិនអនុញ្ញាតឲ្យអង្គការសហប្រជាជាតិ ឬរដ្ឋ មានសិទ្ធិអំណាចបដិសេធចៅក្រមដែលជ្រើសរើសដោយភាគីម្ខាងទៀតនោះទេ។ បទពិសោធន៍របស់ អ.វ.ត.ក បានបង្ហាញថា គំរូតាមសំឡេងភាគច្រើនលើសលុប មិនគ្រប់គ្រាន់ក្នុងការការពារកិច្ចដំណើរការតុលាការពីសម្ពាធខាងក្រៅដោយផ្ទាល់ និងដោយប្រយោលឡើយ។

## ៤. ការិយាល័យរដ្ឋបាល

មុខងាររបស់ការិយាល័យរដ្ឋបាល ត្រូវបានសម្គាល់ដោយភាពជោគជ័យ និងការបរាជ័យក្នុងការបំពេញអាណត្តិរបស់ខ្លួន។ បញ្ហាប្រឈមទាក់ទងនឹងដំណើរការនិងការគាំទ្ររបស់ការិយាល័យរដ្ឋបាល ដែលបានកើតមានជាចម្បងជុំវិញបញ្ហា៖ i) កង្វះវិសាលភាពយ៉ាងច្បាស់អំពីសិទ្ធិអំណាចរបស់ការិយាល័យរដ្ឋបាល និងការអនុវត្តរបស់ការិយាល័យរដ្ឋបាលចំពោះសិទ្ធិអំណាចទាំងនោះ ii) បញ្ហារចនាសម្ព័ន្ធទាក់ទងនឹងផ្នែកគាំពារការការពារក្តី និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានដាក់នៅក្រោមការិយាល័យរដ្ឋបាល និង iii) កង្វះនិយមន័យច្បាស់លាស់នៃមុខងារស្វយ័តរបស់បុគ្គលិកផ្នែកច្បាប់នៃផ្នែកគាំពារការការពារក្តី និង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងវិសាលភាពនៃការគាំទ្រដែលត្រូវការរបស់ការិយាល័យរដ្ឋបាលសម្រាប់មុខងារទាំងនោះ។ កង្វះនូវដំណោះស្រាយប្រកបដោយប្រសិទ្ធភាពសម្រាប់ការមិនឯកភាពនឹងសកម្មភាពរបស់ការិយាល័យរដ្ឋបាល បានបន្ថែមលើបញ្ហាប្រឈមទាំងនេះ។

ភាសាមិនច្បាស់លាស់ និងមិនស៊ីចង្វាក់គ្នានៅក្នុងឯកសារមូលដ្ឋានគោល និងវិធានផ្ទៃក្នុង បានប្រាប់ជាមុនពីបញ្ហាប្រឈម ទាក់ទងនឹងវិសាលភាពនៃសិទ្ធិអំណាចរបស់ការិយាល័យរដ្ឋបាល និងឯករាជ្យភាព *ជាក់ស្តែង* របស់ស្ថាប័ន និងផ្នែកផ្សេងទៀតរបស់ អ.វ.ត.ក។ មាត្រា ៨ នៃកិច្ចព្រមព្រៀង អ.វ.ត.ក និង វិធាន ៩ នៃវិធានផ្ទៃក្នុង កំណត់ភារកិច្ចឱ្យការិយាល័យរដ្ឋបាលជាអ្នកផ្តល់ "សេវាកម្ម" និង "ការគាំទ្រ" ដល់ អង្គជំនុំជម្រះ សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា។ ផ្ទុយទៅវិញ មាត្រា ៣០ នៃច្បាប់ អ.វ.ត.ក កំណត់អាណត្តិអំពី*ការគ្រប់គ្រង*របស់ការិយាល័យរដ្ឋបាលលើបុគ្គលិកនៃផ្នែកទាំងនោះទៅវិញ។ កង្វះភាពច្បាស់លាស់នេះបានបង្ហាញឱ្យឃើញក្នុងផ្នែកជាក់លាក់ ហើយភាពមិនច្បាស់លាស់ទាំងនេះមួយចំនួនត្រូវបានពិភាក្សានៅខាងក្រោម។

- **ផ្នែក ថវិកា និង ធនធាន**

មាត្រា ៣១ *ថ្មី*នៃច្បាប់ អ.វ.ត.ក ដែលផ្តល់ឱ្យការិយាល័យរដ្ឋបាល តាមរយៈអនុប្រធាន នូវសិទ្ធិអំណាចក្នុងការគ្រប់គ្រងធនធាន ដែលបានផ្តល់តាមរយៈមូលនិធិទំនុកចិត្តរបស់ អ.ស.ប បាននាំឱ្យមានដំណើរការថវិការបស់ UNAKRT ផ្តាច់មុខ ផ្ទុយពីដំណើរការថវិការបស់ UNAKRT ប្រកបដោយបរិយាបន្ន ដែលធ្វើឱ្យប៉ះពាល់ដល់ឯករាជ្យភាពរបស់សហព្រះរាជអាជ្ញា និងឯករាជ្យភាពរបស់ភាគីផ្សេងៗទៀត។ ដំណើរការនោះរារាំងភាគីនានាពីការតស៊ូមតិ និងការការពារនៅកម្រិតខ្ពស់ (ដូចជាគណៈកម្មាធិការថវិកានៃទីស្នាក់ការកណ្តាលរបស់ អ.ស.ប នៅទីក្រុងញូវយ៉ក) ការផ្តល់មូលនិធិដែលពួកគេកំណត់ថាចាំបាច់ដើម្បីសម្រេចបាននូវអាណត្តិរបស់ខ្លួន។ វាក៏រារាំងពួកគេពីការបង្ហាញជំហររបស់ខ្លួនលើបញ្ហាថវិកាទៅកាន់ទីស្នាក់ការកណ្តាលរបស់អង្គការសហប្រជាជាតិ ដែលអាចប៉ះពាល់ដល់ដំណើរការឯករាជ្យរបស់ពួកគេផងដែរ។

គំរូដំណើរការថវិកាប្រកបដោយបរិយាបន្ននឹងអនុញ្ញាតឱ្យមានការចូលរួមប្រកបដោយអត្ថន័យពីស្ថាប័ន និងផ្នែកនីមួយៗនៃ អ.វ.ត.ក ដោយមានសិទ្ធិអំណាចសំខាន់ស្វយ័ត ហើយធានាថា ការវាយតម្លៃលើតម្រូវការថវិការបស់ពួកគេត្រូវបានបង្ហាញទៅខាងក្រៅ ទាំងដោយប្រធានស្ថាប័ន ឬប្រធានផ្នែកទាំងនេះដោយផ្ទាល់ ឬតាមរយៈការិយាល័យរដ្ឋបាល។ ជាការពិតណាស់ ការិយាល័យរដ្ឋបាលអាច និងគួរតែបង្ហាញទស្សនៈរបស់ខ្លួនទៅកាន់ប្រធានតុលាការ និងប្រធានផ្នែកនានា ទាក់ទងនឹងលទ្ធភាពអាចរកបានថវិកាតាមតម្រូវការដែលពួកគេបានកំណត់។ ប៉ុន្តែ ការដាក់ស្នើចុងក្រោយនៃតម្រូវការទាំងនោះដូចដែលបានវាយតម្លៃដោយប្រធាននៃផ្នែកគាំពារការការពារក្តី (ដោយមានការចូលរួមចំណែកពីមេធាវីការពារក្តីក្នុងនាមជាអ្នកតំណាងភាគីនៃកិច្ចដំណើរការនីតិវិធី) និង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនគួរត្រូវបានធ្វើឱ្យលែងមានប្រសិទ្ធភាពដោយផ្នែករដ្ឋបាលនោះទេ។

កង្វះឯករាជ្យភាពដូចគ្នាបានកើតមានទាក់ទងនឹងតម្រូវការធនធានផ្សេងទៀត។ សហព្រះរាជអាជ្ញា ឬភាគីផ្សេងៗទៀតត្រូវតែពឹងផ្អែកលើការិយាល័យរដ្ឋបាល ហើយអាចស្នើសុំធនធាន ប៉ុន្តែមិនមានដំណោះស្រាយទេ ប្រសិនបើសំណើត្រូវបានបដិសេធ ករណីបែបនេះបានកើតមានញឹកញាប់ណាស់ ហើយចំណុចនេះគឺទាក់ទងនឹងធនធានជាមូលដ្ឋាន ដូចជា ឧបករណ៍សម្រាប់ដំណើរមុខងារចាំបាច់របស់ផ្នែកនានា ដើម្បីអនុវត្តអាណត្តិរបស់ពួកគេ និងការគាំទ្របរិសកម្មសម្រាប់សកម្មភាពបន្ទាន់ភ្លាមៗ ដូចជាការស៊ើបអង្កេតក្នុងករណីមានការស្លាប់ក្នុងពេលឃុំខ្លួនបណ្តោះអាសន្នជាដើម។

ការបកស្រាយជាក់ស្តែងរបស់ការិយាល័យរដ្ឋបាលអំពីអាណត្តិរបស់ខ្លួនក្នុង *ការគ្រប់គ្រង* មូលនិធិដែល អ.វ.ត.ក ទទួលបាន ទុកដូចជា *កម្មសិទ្ធិ* ផ្ទាល់ខ្លួន

លើមូលនិធិទាំងនោះ ដែលខ្លួនអាចបែងចែករវាងស្ថាប័ន និងផ្នែកនានាតាមការសម្រេចជាឯកតោភាគីរបស់ខ្លួននោះ បាននាំឲ្យមានតម្រូវការចាំបាច់ក្នុងការត្រួតពិនិត្យលើស្ថាប័ននេះ។ ការយល់ច្រឡំនេះ បានកើតឡើងយ៉ាងច្បាស់នៅក្នុងបរិបទនៃការផ្តល់មូលនិធិដល់សកម្មភាពមុខងារសេសសល់ នៅក្នុងអំឡុងពេលនៃការផ្លាស់ប្តូរទៅកាន់តុលាការមុខងារសេសសល់។ ពិតជាត្រឹមត្រូវ ការិយាល័យរដ្ឋបាលបានទទួលស្គាល់ថា សកម្មភាពបែបនេះមួយចំនួនអាចចាប់ផ្តើមបានយ៉ាងត្រឹមត្រូវក្នុងអំឡុងពេលអន្តរកាលនេះ។ ទោះជាយ៉ាងណាការិយាល័យរដ្ឋបាលបានធ្វើតាមទស្សនៈរបស់ខ្លួនដែលថា ខ្លួនជាម្ចាស់មូលនិធិរបស់តុលាការដើម្បីកំណត់កាតព្វកិច្ចមូលនិធិរបស់តុលាការទាំងនេះចំពោះសកម្មភាពដែលខ្លួនកំណត់ប្រភេទថាជា “គម្រោងរបស់ អ.វ.ត.ក” ប៉ុន្តែ តាមពិតជាគម្រោងដែលការិយាល័យរដ្ឋាបាលកំណត់អត្តសញ្ញាណជាឯកតោភាគី ហើយការអនុវត្តគម្រោងទាំងនោះ ខ្លួនជាអ្នកត្រួតពិនិត្យ។ ស្របពេលជាមួយគ្នានេះការិយាល័យរដ្ឋបាលបានបដិសេធការចូលប្រើប្រាស់មូលនិធិ អ.វ.ត.ក ទាំងនេះយ៉ាងហោចណាស់ក៏សម្រាប់សកម្មភាពមុខងារសេសសល់មួយដែលត្រូវបានកំណត់អត្តសញ្ញាណ និងត្រួតពិនិត្យដោយការិយាល័យសហព្រះរាជអាជ្ញា។ នេះបើទោះបីជា ក.ស.ព ជាស្ថាប័នឯករាជ្យមួយរបស់ អ.វ.ត.ក ដូចគ្នានឹងការិយាល័យរដ្ឋបាលក្តី ដូច្នេះហើយនាំឲ្យសកម្មភាពរបស់ ក.ស.ព ជាគម្រោងរបស់ អ.វ.ត.ក ដែរ ក្នុងន័យដូចគ្នានឹងគម្រោងរបស់ការិយាល័យរដ្ឋបាល ដែលជាគម្រោងរបស់ អ.វ.ត.ក ផងដែរ។

- **ផ្នែក កិច្ចការសាធារណៈ**

វិធាន ៩(៤) នៃវិធានផ្ទៃក្នុង ចាត់តាំងការិយាល័យរដ្ឋបាលឲ្យធ្វើជាបណ្តាញផ្លូវការរបស់ អ.វ.ត.ក សម្រាប់ការប្រាស្រ័យទំនាក់ទំនងទាំងខាងក្នុង និងខាងក្រៅ លើកលែងតែវាប៉ះពាល់ដល់សិទ្ធិអំណាចរបស់ចៅក្រម ឬ សហព្រះរាជអាជ្ញា ក្នុងការផ្តល់ព័ត៌មានទាក់ទងនឹងមុខងាររបស់ពួកគេ។ ការផ្តល់សិទ្ធិអំណាចនេះដល់ការិយាល័យរដ្ឋបាល ដោយមិនកំណត់វិសាលភាពនៃគុណវុឌ្ឍិធ្វើឲ្យប៉ះពាល់ដល់ឯករាជ្យភាពរបស់ចៅក្រម និង សហព្រះរាជអាជ្ញា។ វាក៏មើលរំលងការលើកឡើងណាមួយរបស់ផ្នែកគាំពារការការពារក្តី ឬ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។ ទាំងអស់នេះនាំឲ្យមានចម្ងល់ពីសិទ្ធិអំណាចរបស់ចៅក្រម ឬភាគីក្នុងការចេញការប្រាស្រ័យទំនាក់ទំនងជាសាធារណៈទាន់ពេលវេលារួមគ្នា ឬដាច់ដោយឡែកពីគ្នា ដោយផ្តល់នូវទស្សនៈពិសេសរបស់ពួកគេ ហើយធ្វើឲ្យការអនុវត្តសិទ្ធិអំណាចនោះពឹងផ្អែកលើការយល់ព្រមពីការិយាល័យរដ្ឋបាល។ ស្ថាប័នឯករាជ្យរបស់តុលាការ និងភាគីផ្សេងទៀត គួរតែមានសិទ្ធិអំណាចពេញលេញក្នុងការទំនាក់ទំនងជាមួយសាធារណជន និងពិតណាស់ ត្រូវតែស្ថិតក្នុងដែនកំណត់សីលធម៌ជានិច្ច។

- **ផ្នែកគាំពារការការពារក្តី និង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ខណៈពេលដែលការិយាល័យសហព្រះរាជអាជ្ញា គឺជាការិយាល័យឯករាជ្យក្របខ័ណ្ឌរចនាសម្ព័ន្ធរបស់ អ.វ.ត.ក ហាក់ដូចជាដាក់ភាគីផ្សេងទៀតនៅក្នុងកិច្ចដំណើរការនីតិវិធី តាមរយៈផ្នែកគាំពារការការពារក្តី និង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី នៅក្រោមការិយាល័យរដ្ឋបាល ឬយ៉ាងហោចណាស់ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ការិយាល័យនេះក្នុងផ្នែកមួយចំនួន។ ផ្នែកគាំពារការការពារក្តីគាំទ្រមុខងារការពារក្តី ហើយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី តំណាងឲ្យផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងពេលជំនុំជម្រះ និងលើសពីនេះ ជាមួយនឹងឯករាជ្យភាព

ដែលកំណត់អាណត្តិចាំបាច់។ ទោះជាយ៉ាងណាក៏ដោយ ការដាក់ផ្នែកគាំពារការការពារក្តី និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងការិយាល័យរដ្ឋបាល បានបង្កើតបញ្ហាប្រឈមយ៉ាងខ្លាំងចំពោះដំណើរការសំខាន់ៗរបស់ផ្នែកទាំងនោះ បើចំពោះករណីផ្នែកគាំពារការការពារក្តីគឺមុខងារឯករាជ្យនៃការការពារក្តី ហើយនឹងបង្កឱ្យមានសំណួរអំពីការដាក់ភាគីក្នុងរចនាសម្ព័ន្ធត្រឹមត្រូវរបស់ អ.វ.ត.ក។

ទោះយ៉ាងណាក៏ដោយ បញ្ហាប្រឈមដែលផ្នែកទាំងនេះមានគឺលើសពីបញ្ហារចនាសម្ព័ន្ធទៅទៀត។ វិធានផ្ទៃក្នុងបញ្ជាក់យ៉ាងច្បាស់ថា ផ្នែកគាំពារការការពារក្តី និង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានស្វ័យភាពទាក់ទងនឹង បញ្ហា *សំខាន់ៗ* ទាំងអស់ដែលទាក់ទងនឹងការការពារក្តី (វិធាន ១១) និងបញ្ហារបស់ដើមបណ្តឹងរដ្ឋប្បវេណី (វិធាន ១២) - ដោយមិនបញ្ជាក់ពីវិសាលភាពនៃស្វ័យភាព ឬបញ្ហាសំខាន់ៗទាំងនោះទេ។ ផ្ទុយទៅវិញ ការិយាល័យរដ្ឋបាលមានកាតព្វកិច្ចផ្តល់ការគាំទ្រ *ផ្នែករដ្ឋបាល* ចាំបាច់ដល់ផ្នែកទាំងនេះ និងដល់មេធាវីការតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ តែជាថ្មីម្តងទៀត គឺគ្មាននិយមន័យច្បាស់លាស់។

ការខកខានក្នុងការបញ្ជាក់ឱ្យបានច្បាស់លាស់នៅក្នុងវិធានផ្ទៃក្នុងអំពីលក្ខណៈ និងវិសាលភាពនៃស្វ័យភាពរបស់ផ្នែកទាំងអស់នេះ ថាអ្វីខ្លះដែលជា "បញ្ហាសំខាន់" និងអ្វីខ្លះដែលជា "ការគាំទ្រផ្នែករដ្ឋបាល" ដែលត្រូវបានរំពឹងទុកពីការិយាល័យរដ្ឋបាលនោះ បានបន្សល់ទុកឱ្យការិយាល័យរដ្ឋបាលដែលទទេស្អាតមួយនេះ ជាញឹកញាប់បំពេញបង្គ្រប់ដោយការពឹងផ្អែកលើការបកស្រាយផ្ទាល់ខ្លួននៃពាក្យពេចន៍ទាំងនេះ ដើម្បីបដិសេធការគាំទ្រដែលបានស្នើសុំ រួមទាំងរយៈពេលនៃកិច្ចសន្យាបុគ្គលិក និងការគាំទ្រផ្នែកភស្តុភារ។ ប្រសិនបើការិយាល័យរដ្ឋបាលធ្វើការកំណត់ច្បាស់លាស់នូវវិសាលភាពនៃការសម្រេចចិត្តដោយស្វ័យភាពរបស់ផ្នែកនានា ទាក់ទងនឹងបញ្ហាសំខាន់ៗនោះ ការិយាល័យរដ្ឋបាលបានធ្វើហួសពីសិទ្ធិអំណាចរបស់ខ្លួន ហើយដូចដែលបានពិភាក្សាខាងក្រោម ប្រហែលជាធ្វើឱ្យមានកំហុសញឹកញាប់ដោយមិនមានការត្រួតពិនិត្យឡើងវិញ។ កង្វះអន្ទះរបស់អង្គជំនុំជម្រះក្នុងការទម្ពះរបាំងស្វ័យភាពតាមការសន្មត់របស់ការិយាល័យរដ្ឋបាលនៅក្នុងបញ្ហារដ្ឋបាល ធ្វើឱ្យបញ្ហានោះកាន់តែធ្ងន់ធ្ងរឡើង សូម្បីតែបញ្ហានោះជាបញ្ហាសំខាន់ ពោលគឺសិទ្ធិអំណាចស្វយ័ត *របស់ភាគី* ក៏ដោយ។ វាជាការសមស្របសម្រាប់ភាគី ក្នុងការសម្រេចនូវអ្វីដែលស្ថិតនៅក្នុងវិសាលភាពនៃអាណត្តិរបស់ខ្លួន ជាមួយចៅក្រម ឬយន្តការត្រួតពិនិត្យសមស្របផ្សេងទៀត ដែលជាមជ្ឈត្តករចុងក្រោយ គឺមិនមែនការិយាល័យរដ្ឋបាលទេ។

អតីតប្រធានផ្នែកគាំពារការការពារក្តី បានរាយការណ៍អំពីការលំបាកក្នុងការទទួលបានការអនុមតិធនធានហិរញ្ញវត្ថុសម្រាប់ផ្នែករបស់គាត់ ប៉ុន្តែសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហាក់បីដូចជាបានទទួលរងផលប៉ះពាល់ជាអវិជ្ជមានជាពិសេស ដោយសារបញ្ហាប្រឈមទាំងនេះ។ ការិយាល័យរដ្ឋបាលដែលមានកំណើននិយ័តភាព បានពឹងផ្អែកសេចក្តីសម្រេចគាំទ្ររបស់ខ្លួនលើការបកស្រាយរបស់ខ្លួនលើវិសាលភាពនៃមុខងារស្វយ័តរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទោះបីជាការបកស្រាយនេះមិនសមស្របនឹងវិធានផ្ទៃក្នុងក៏ដោយ។ ឧទាហរណ៍ ការិយាល័យរដ្ឋបាលបានកំណត់ថា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនតំណាងឱ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីទេ ប៉ុន្តែមានមុខងារជាអ្នកសម្របសម្រួលប៉ុណ្ណោះ ដែលនេះជាការផ្ទុយទៅនឹងវិធានផ្ទៃក្នុងដែលដាក់កាតព្វកិច្ច *ធ្វើតំណាង* ផលប្រយោជន៍របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅពេលសវនាការ និងពេលផ្សេងៗទៀត (វិធាន

២៣ ស្ទួនពីរ(៥))។ ដោយផ្អែកលើការបកស្រាយរបស់ខ្លួន ការិយាល័យរដ្ឋបាលនៅតែបដិសេធក្នុងការផ្តល់មូលនិធិគាំទ្រចំពោះសកម្មភាពតំណាងជាដដែល ដូចជាកិច្ចប្រជុំជាមួយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនិងដើមបណ្តឹងរដ្ឋប្បវេណី ជាដើម។ កិច្ចប្រជុំដូច្នេះ គឺមានសារសំខាន់ខ្លាំងនៅទូទាំងដំណើរការទាំងមូល ដើម្បីផ្តល់ព័ត៌មានដល់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីពួកគាត់បានជ្រួតជ្រាប សម្រេចចិត្ត និងបញ្ជាក់ពីផលប្រយោជន៍របស់ពួកគាត់នៅគ្រប់ដំណាក់កាលទាំងអស់។ ការិយាល័យរដ្ឋបាលក៏បានបង្ខាំងធនធានផ្សេងៗផងដែរដោយសារតែការបកស្រាយរបស់ខ្លួនអំពីអាណត្តិតាមផ្លូវតុលាការរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលការិយាល័យរដ្ឋបាលសម្រេចច្រានចោលគ្រប់កិច្ចការទាំងអស់ដែលមិនបានស្នើឡើងដោយអង្គជំនុំជម្រះ។ ការណ៍នេះមិនត្រឹមតែជារឿងចម្លែកក្នុងការអនុវត្តសម្រាប់ភាគីទាំងអស់នៅគ្រប់តុលាការព្រហ្មទណ្ឌអន្តរជាតិប៉ុណ្ណោះទេ ប៉ុន្តែក៏ឈានដល់ "បញ្ហាសារធាតុ" យ៉ាងច្បាស់ក្រឡែត និងរារាំងដល់កិច្ចការវិវាទកម្មរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលប៉ះពាល់ដោយផ្ទាល់ទៅលើផលប្រយោជន៍កូនក្តីរបស់ពួកគេ។ ផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរនៃសិទ្ធិអំណាចហួសប្រមាណនេះទីបំផុតនាំឱ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិដកខ្លួនដោយស្នាក់ស្នើចេញពីការតំណាងរបស់ខ្លួនក្នុងខែមិថុនា ឆ្នាំ២០២២ ដោយសារតែគាត់មិនមានលទ្ធភាពអនុវត្តភារកិច្ចតាមអាណត្តិរបស់គាត់ ក្នុងលក្ខណៈមួយដែលបម្រើយ៉ាងល្អបំផុតឱ្យដើមបណ្តឹងរដ្ឋប្បវេណីរាប់ពាន់នាក់ក្នុងសំណុំរឿង ០០២។

លទ្ធភាពរបស់អង្គភាពគាំពារការការពារក្តីដើម្បីបំពេញតម្រូវការតាមសំណូមពរផ្នែកគាំទ្ររបស់មេធាវីការពារក្តី ជាការពិតណាស់ គឺពឹងផ្អែកលើថវិកាដែលបានដាក់ស្នើដោយការិយាល័យរដ្ឋបាល។ ក៏ប៉ុន្តែ មិនដូចសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទេ មេធាវីការពារក្តីគឺពឹងទៅលើគម្រោងជំនួយផ្នែកច្បាប់ដែលមានបទប្បញ្ញត្តិចែងយ៉ាងលម្អិតគួរសមអំពីសិទ្ធិនៃការទទួលបានធនធានរបស់ពួកគេ និងពីរបៀបដែលផ្នែកគាំពារការការពារក្តីធ្វើសេចក្តីសម្រេចចិត្ត។ មេធាវីការពារក្តីក៏ត្រូវបានជួលដោយផ្អែកលើកិច្ចសន្យាសេវាកម្មច្បាប់ ដែលពួកគេត្រូវការពឹងផ្អែកទៅលើចៅក្រមរដ្ឋបាលក្នុងការដោះស្រាយជម្លោះជាមួយផ្នែកគាំពារការការពារក្តីទាក់ទងសំណើសុំធនធាន ស្របតាមគម្រោងជំនួយផ្នែកច្បាប់។ផ្ទុយទៅវិញសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងបុគ្គលិកច្បាប់ដែលពាក់ព័ន្ធ ពុំមានក្របខ័ណ្ឌឯកសារដែលចែងបញ្ញត្តិអំពីការបែងចែកធនធានរបស់ខ្លួនទេ និងត្រូវទុកចោលដោយគ្មានដំណោះស្រាយប្រសិនបើចៅក្រមមិនអន្តរាគមន៍ទៅការិយាល័យរដ្ឋបាលឱ្យផ្តល់ការគាំទ្រតាមសំណើសុំទេនោះ។ កង្វះនូវដំណើរការមានប្រសិទ្ធភាពរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហាក់ដូចជាបានអនុញ្ញាតឱ្យការិយាល័យរដ្ឋបាលកំណត់ ដាក់កំហិត និងគ្រប់គ្រងទៅលើមុខងារដោយអាណត្តិរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងបុគ្គលិកច្បាប់ដែលពាក់ព័ន្ធយ៉ាងមានប្រសិទ្ធភាព។

តាមរចនាសម្ព័ន្ធនៅ អ.វ.ត.ក បញ្ហាប្រឈមទាំងនេះអាចត្រូវបានជម្នះតាមរយៈ៖

i. ការបង្កើតផ្នែកសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងផ្នែកគាំពារការការពារក្តី ជាផ្នែកឯករាជ្យរបស់ អ.វ.ត.ក ឬតាមជម្រើសផ្សេងសម្រាប់ផ្នែកគាំពារការការពារក្តី បង្កើតទៅជាផ្នែកអ្នកការពារអាថិចារី (អង្គភាពអ្នកការពារក្តីចំបង)។
ii. ការចែងច្បាស់លាស់អំពីវិសាលភាពនៃសិទ្ធិអំណាចរដ្ឋបាលរបស់ការិ-

យាល័យរដ្ឋបាល ទាក់ទងនឹងការគាំទ្រចំពោះមុខងារការការពារក្តី និងមុខងារសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងថិរវេលានៃកិច្ចសន្យា និងការគាំទ្រផ្នែកភ័ស្តុភារ និងការធានាឱ្យប្រាកដថា សិទ្ធិអំណាចនេះមិនពង្រីកដល់ការបកស្រាយទៅលើភារកិច្ចដោយអាណត្តិរបស់ភាគីទាំងនេះ។

iii. ការបង្កើតគម្រោងជំនួយផ្នែកច្បាប់តម្លាភាព សម្រាប់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ធ្វើដូច្នេះវានឹងកាត់បន្ថយនូវវិសាលភាពនៃសេចក្តីសម្រេចផ្នែកថវិកាតាមទំនើងចិត្តរបស់ការិយាល័យរដ្ឋបាល។

iv. ការធានាឱ្យមាននូវសេវាកម្មផ្សេងៗរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈកិច្ចសន្យាសេវាកម្មច្បាប់ ដែលរួមមាន យន្តការដោះស្រាយជម្លោះ ធ្វើដូច្នេះវានឹងផ្តល់នូវយន្តការសម្រាប់គ្រប់គ្រងតាមផ្លូវតុលាការ និងក្រៅប្រព័ន្ធតុលាការយ៉ាងមានប្រសិទ្ធសម្រាប់ដោះស្រាយលើសេចក្តីសម្រេចគាំទ្រដែលមានជម្លោះរបស់ការិយាល័យរដ្ឋបាល និង

v. ការធានាឱ្យប្រាកដថា សេចក្តីសម្រេចគាំទ្រលើសំណើសុំណាមួយត្រូវបានធ្វើឡើងដោយប្រធាន ឬអនុប្រធានការិយាល័យរដ្ឋបាល និងមិនត្រូវបានធ្វើប្រតិភូកម្មអំណាចទៅឱ្យសមាជិកបុគ្គលិកជាន់ទាបណាម្នាក់ឡើយ។

ការពង្រឹងលើប្រព័ន្ធទូទាត់ ឬការបង់ប្រាក់ផ្សេងៗសម្រាប់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក៏ជារឿងមួយដ៏សំខាន់ផងដែរ ដើម្បីឱ្យការធ្វើតំណាងឱ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីមានប្រសិទ្ធភាព។ នៅ អ.វ.ត.ក មានមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន ទោះជាមិនច្រើនបំផុតក៏ដោយ មិនទទួលបានប្រាក់កម្រៃជាច្រើនឆ្នាំមកហើយ ហើយពួកគេក៏មិនបានទទួលបុរេប្រទាន ឬសំណងណាមួយសម្រាប់ការចំណាយផ្សេងៗដែលពាក់ព័ន្ធនឹងសកម្មភាពដែលមានសារសំខាន់ដល់ការធ្វើតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីក៏ទេដែរ ដូចជាលើការទូទាត់ចំពោះសកម្មភាពចូលរួមប្រជុំជាមួយកូនក្តីរបស់ពួកគេ ជាដើម។ ការណ៍នេះបានធ្វើឱ្យពួកគេមិនអាចអនុវត្តកាតព្វកិច្ចរបស់ពួកគេឱ្យមានប្រសិទ្ធភាព រួមទាំងការសម្របសម្រួលជាមួយ និងគាំទ្រចំពោះសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

- **សេចក្តីសន្និដ្ឋាន**

បញ្ហាជារួមដែលពាក់ព័ន្ធលើគ្រប់បញ្ហាប្រឈមទាំងអស់ដូចបានពិភាក្សា គឺថា អ.វ.ត.ក ពុំមានយន្តការដែលមានប្រសិទ្ធភាពសម្រាប់ដោះស្រាយជម្លោះជាមួយការិយាល័យរដ្ឋបាល និងលើពាក្យបណ្តឹងប្រឆាំងនឹងការិយាល័យរដ្ឋបាលទេ ដែលគួរឱ្យហួសចិត្ត ក្នុងនាមជាផ្នែកមួយនៃអង្គភាពមួយដែលត្រូវបានបង្កើតឡើងដើម្បីពង្រឹងការអនុវត្តគណនេយ្យភាព តែបែរជាធ្វើឱ្យស្ថាប័នមួយនេះ គ្មានគណនេយ្យភាពយ៉ាងមានប្រសិទ្ធភាពចំពោះសកម្មភាពដែលរងការជំទាស់របស់ខ្លួនទៅវិញ។ មិនដូចតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀតទេ ទីនេះគឺគ្មានប្រធានសម្រាប់បំពេញមុខងារនេះឡើយ។ តាមជម្រើសផ្សេង គណៈកម្មាធិការឯករាជ្យផ្ទៃក្នុងមួយអាចនឹងដោះស្រាយបញ្ហាដូច្នេះបាន ប៉ុន្តែបច្ចុប្បន្នមិនមានស្ថាប័នបែបនេះបំពេញមុខងារនោះយ៉ាងមានប្រសិទ្ធភាពទេ ហើយក៏គ្មានអាជ្ញាធរដែលយើងស្គាល់ណាមួយនៅក្រៅ អ.វ.ត.ក អាចឱ្យយើងបញ្ជូនជម្លោះ ឬពាក្យបណ្តឹងអំពីសកម្មភាព ឬកង្វះសកម្មភាពដែលបានធ្វើឡើងដោយការិយាល័យរដ្ឋបាល ដើម្បីដោះស្រាយនោះដែរ។ ទោះបីការិយាល័យរដ្ឋបាលជា

អង្គភាព*គាំទ្រ* របស់ អ.វ.ត.ក ក៏អំពើអកម្មនេះបានបង្កើតនូវស្ថាប័នរដ្ឋបាលមួយដែលអាចកាន់កាប់អំណាចមិនសមាមាត្រទៅលើមុខងាររបស់ អ.វ.ត.ក។

វិធាន១៩ នៃវិធានផ្ទៃក្នុង ពិតជាផ្តល់នូវយន្តការណាមួយសម្រាប់ប្រើប្រាស់លើការគ្រប់គ្រងដូច្នេះឱ្យមានប្រសិទ្ធភាព ដោយបង្កើតគណៈកម្មាធិការរដ្ឋបាលតុលាការ ជាវេទិកាមួយសម្រាប់ ស.ព.អ និងចៅក្រម ក្នុងការផ្តល់ប្រឹក្សា និងការណែនាំដល់ការិយាល័យរដ្ឋបាល "អំពីសកម្មភាពទាំងអស់ដែលទាក់ទងនឹងការគាំទ្រផ្នែករដ្ឋបាល និងតុលាការ ជូនចំពោះ ក.ស.ព, ក.ស.ច.ស និងអង្គជំនុំជម្រះ រួមទាំង ការរៀបចំ និងការអនុវត្តថវិកា"។

យ៉ាងណាមិញ គណៈកម្មាធិការរដ្ឋបាលតុលាការ ហាក់ដូចជាមិនបានអនុវត្តអាណត្តិរបស់ខ្លួនឱ្យបានពេញលេញ ឬបានជួបប្រជុំជាទៀងទាត់ឡើយ។ ចំណែកវិធានផ្ទៃក្នុង ក៏មានកង្វះខាតក្នុងការដោះស្រាយលើបញ្ហាគ្រប់គ្រងឱ្យបានពេញលេញចំពោះមុខងាររបស់ការិយាល័យរដ្ឋបាលផងដែរ តាមរយៈ ១) ការមិនផ្តល់ជូនគណៈកម្មាធិការរដ្ឋបាលតុលាការ នូវមុខងារគ្រប់គ្រងជម្លោះជាផ្លូវការ ២) ការមិនបញ្ចូលប្រធានផ្នែកគាំពារការការពារក្តី និង/ឬ សហមេធាវីការពារក្តី ឬសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ជាសមាជិករបស់គណៈកម្មាធិការ ៣) ការមិនបញ្ចូលនៅក្នុងពាក្យពេចន៍នៃវិធានផ្ទៃក្នុងដើម្បីផ្តល់ប្រឹក្សា និងការណែនាំទៅកាន់ការិយាល័យរដ្ឋបាលទាក់ទងនឹងគ្រប់សកម្មភាពទាំងអស់ពាក់ព័ន្ធនឹងការគាំទ្រផ្នែករដ្ឋបាលសម្រាប់ផ្នែកគាំពារការការពារក្តី និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅតាមអត្ថន័យនៃវិធានផ្ទៃក្នុង និង ៤) ការជួបប្រជុំតែនៅពេលណាមានការកោះហៅរបស់ប្រធានប៉ុណ្ណោះ គឺមិនមែនតាមសំណើរបស់សមាជិកនៃគណៈកម្មាធិការណាម្នាក់ឡើយ។

# ថវិកា

អ.វ.ត.ក ត្រូវបានបង្កើតឡើងដោយផ្អែកលើគម្រោងថវិកាស្ម័គ្រចិត្ត ដោយអង្គការសហប្រជាជាតិប្ដេជ្ញាផ្ដល់ហិរញ្ញប្បទានដល់ផ្នែកអន្តរជាតិ និងផ្ដល់ការគាំទ្រផ្សេងទៀត ចំណែករដ្ឋាភិបាលកម្ពុជា សន្យាផ្ដល់មូលនិធិទៅផ្នែកជាតិ និងផ្ដល់សេវាចាំបាច់ផ្សេងទៀត រួមទាំងអាគារ និងទីតាំង អ.វ.ត.ក.។

អ.វ.ត.ក បានធានាផ្នែកថវិកាជាបុរេប្រទាន ក្នុងរយៈពេលបីឆ្នាំដំបូងរបស់ខ្លួន និងបានពឹងផ្អែកយ៉ាងជោគជ័យលើយន្តការថវិកាស្ម័គ្រចិត្តអស់រយៈពេលជាច្រើនឆ្នាំសម្រាប់ប្រតិបត្តិការ។ ចាប់តាំងពីចាប់ផ្ដើមដោយមានការគាំទ្រពីអង្គការសហប្រជាជាតិ អ.វ.ត.ក បានបោះជំហានដើម្បីពង្រីកមូលដ្ឋានម្ចាស់ជំនួយ និងអនុវត្តប្រសិទ្ធភាពផ្ទៃក្នុង។ ការបង្កើតភាពជាដៃគូជាមួយស្ថាប័នផ្សេងៗ ដូចជា UN Women, Justice Rapid Response និងអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា បានផ្ដល់នូវថវិកា និងសេវាគាំទ្រផ្សេងៗ ដើម្បីពន្លឿនការងាររបស់តុលាការ ទាក់ទងនឹងជនរងគ្រោះនិងដើមបណ្ដឹងរដ្ឋប្បវេណី។ កិច្ចព្រមព្រៀង អ.វ.ត.ក បានណែនាំអំពីវិធានការចំណាយសន្សំសំចៃក្នុងការបង្កើតតុលាការដោយផ្អែកលើអភិក្រមបញ្ចូលតាមដំណាក់កាល ដូចជាការបញ្ចូលចៅក្រមតាមតម្រូវការ។ បន្ទាប់មកទៀត ក្នុងរយៈពេលទាំងមូលនៃជីវិត អ.វ.ត.ក វិធានផ្ទៃក្នុងត្រូវបានធ្វើវិសោធនកម្មដើម្បីឱ្យស្របទៅនឹងនីតិវិធីស៊ើបសួរ និងសវនាការ។ ឧទាហរណ៍ ក្នុង ឆ្នាំ២០១០ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានបង្កើតដើម្បីបញ្ចូលតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ទៅក្នុងដំណាក់កាលជំនុំជម្រះ និងដំណាក់កាលក្រោយៗមកទៀត ដូចជា ឆ្នាំ២០១៥ វិធាន ៦៦ស្ទួន និងវិធាន ៨៩ ស្ទួនបី ត្រូវបានបន្ថែមដើម្បីអនុញ្ញាតឱ្យ ស.ច.ស និង អ.ជ.ស.ដ កាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ និងសវនាការ ដោយមានការធានាថា វានៅតែរក្សាបាននូវតំណាងវិសាលភាពនៃសេចក្ដីសន្និដ្ឋានចោទប្រកាន់ដើម និងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

ក៏ប៉ុន្តែ មានកង្វះថវិកាធ្ងន់ធ្ងរបានកើតឡើងចំពោះផ្នែកអន្តរជាតិ ដែលចាប់ផ្ដើមនៅឆ្នាំ២០១២ ហើយនៅក្នុងឆ្នាំ២០១៣ មានកង្វះថវិកាធ្ងន់ធ្ងរបានកើតឡើងចំពោះបុគ្គលិកជាតិ ដែលនាំឱ្យមានការដើរចេញ។ ក្រោយមក ទោះបីជាមានការបរិច្ចាគមួយចំនួនពីរដ្ឋាភិបាលកម្ពុជា និងការគាំទ្រជាបន្តចំពោះផ្នែកទាំងពីរពីម្ចាស់ជំនួយអន្តរជាតិដែលមានការតាំងចិត្ត និងចិត្តសប្បុរសធម៌ ដូចជា ក្រុមម្ចាស់ជំនួយធំៗ (ដែលបានបរិច្ចាគអស់រយៈជាច្រើនឆ្នាំ រួមមានប្រទេស ជប៉ុន អូស្ត្រាលី បារាំង អាល្លឺម៉ង់ សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស ស៊ុយអែត និងសហគមន៍អឺរ៉ុប) ក៏ដោយ ក៏បញ្ហាកង្វះថវិកានៅតែមាន។ សន្និសីទសន្យាមួយនៅទីក្រុងញូយ៉ក នៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៣ បានពង្រីកមូលដ្ឋានម្ចាស់ជំនួយបន្តិចបន្តួចដែរ ប៉ុន្តែនៅតែមិនអាចឱ្យតុលាការធានាបាននូវថវិកាក្នុងចំនួនមួយគ្រប់គ្រាន់តាមការព្យាករណ៍ ដើម្បីបំពេញតម្រូវការផ្នែកថវិកាសមរម្យរបស់ខ្លួនឡើយ។ ហេតុដូច្នេះ ចាប់តាំងពី ឆ្នាំ២០១៤ មក អ.វ.ត.ក ចាំបាច់ត្រូវស្នើសុំជំនួយហិរញ្ញវត្ថុពីអង្គការសហប្រជាជាតិ។ អង្គការសហប្រជាជាតិក៏បានផ្ដល់កម្ចីពិសេសដល់រដ្ឋាភិបាលកម្ពុជាដោយគ្មានលក្ខខណ្ឌផងដែរ ក្រៅអំពីសុំឱ្យរដ្ឋាភិបាលកម្ពុជាសងកម្ចីវិញនៅពេលណាមួយអាចធ្វើទៅបាន។

គម្រោងថវិកាស្ម័គ្រចិត្ត មានទាំងចំណុចវិជ្ជមាន និងចំណុចអវិជ្ជមាន។ វាជាយន្តការទាក់ទាញថវិកាពីម្ចាស់ជំនួយ ដែលអនុញ្ញាតឱ្យពួកគេបរិច្ចាកថវិកាដោយ

ពុំតម្រូវឱ្យពួកគេជាប់កាតព្វកិច្ចផ្តល់ថវិការយៈពេលវែង។ ជាការពិត អ.វ.ត.ក ទំនងជាមិនអាចបង្កើតបានឡើយ ប្រសិនបើគម្រោងថវិកាស្ម័គ្រចិត្តនេះមិនត្រូវបានអនុមតិទេនោះ ហើយបើគ្មាន អ.វ.ត.ក ទេ នោះវាជាការជាក់ស្តែងណាស់ថា គ្មានចារីណាម្នាក់នឹងត្រូវដាក់ឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដ៏យង់ឃ្នងរបស់ពួកគេឡើយ ហើយក៏គ្មានវិធានការយុត្តិធម៌ត្រូវបានផ្តល់ជូនដល់ជនរងគ្រោះដោយផ្ទាល់ និងជនរងគ្រោះដោយប្រយោល ក៏ទេដែរ។

នៅក្នុងន័យនេះ ចំណុចអវិជ្ជមាននៃគម្រោងបរិច្ចាគស្ម័គ្រចិត្ត រួមមាន ការខ្វះខាតចៀសមិនរួច ដែលបានកើតឡើងចំពោះតុលាការទាំងអស់ ដែលទទួលការឧបត្ថមថវិកាតាមការស្ម័គ្រចិត្ត មិនមែនតែ អ.វ.ត.ក នោះទេ។ គម្រោងនេះបានបញ្ជាក់ឱ្យឃើញថា មិនមែនជាគំរូផ្តល់ថវិកាមាននិរន្តភាពទេ និងជាគំរូមួយដែលធ្វើឱ្យសាលាក្តីនានាងាយរងគ្រោះទៅនឹងការផ្លាស់ប្តូរនៅក្នុងកាលៈទេសនយោបាយ និងសេដ្ឋកិច្ច ទាំងនៅក្នុងស្រុកនិងសកលលោក ដែលប៉ះពាល់លើការប្តេជ្ញាចិត្តរបស់ម្ចាស់ជំនួយ។ តុលាការ SCSL តុលាការ STL ព្រមទាំងតុលាការនេះ សុទ្ធតែបានពឹងផ្អែកលើជំនួយហិរញ្ញវត្ថុពីអង្គការសហប្រជាជាតិ ដែលចុងបញ្ចប់បានដាក់កាតព្វកិច្ចលើរដ្ឋទាំងឡាយឱ្យផ្តល់ថវិកាដល់ពួកគេ។

ជាងនេះទៀតនោះបញ្ហាកង្វះហិរញ្ញវត្ថុបានបង្កើតឱ្យមានភាពមិនប្រាកប្រជានៅ អ.វ.ត.ក ដែលអាចប៉ះពាល់ជាសក្តានុពល ទៅលើលទ្ធភាពអនុវត្តអាណត្តិតុលាការរបស់ខ្លួន ថ្វីត្បិតការនេះជាចុងក្រោយត្រូវបានបញ្ចៀសក៏ដោយ។ ជាការពិត ទោះបី អតីត ស.ព.អ មិនច្បាស់ពីមូលហេតុដែល ស.ច.ស ក្នុងឆ្នាំ២០១៧ បានរង់ចាំរហូតដល់កិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣, ០០៤ និង ០០៤/២ ស្ទើរតែបញ្ចប់ ហើយវិបត្តិថវិកាដ៏អាក្រក់របស់ អ.វ.ត.ក បានកន្លងផុតទៅក្តី ក៏ការពិតដែល ស.ច.ស បានដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរអំពីផលប៉ះពាល់ លើស្ថានភាពថវិការបស់ អ.វ.ត.ក ទៅលើកិច្ចស៊ើបសួរទាំងនោះ ប្រហែលដោយសារមានសញ្ញាបង្ហាញអំពីភាពមិនច្បាស់លាស់ នៃគម្រោងថវិកាស្ម័គ្រចិត្តដែលជាប់មកជាមួយ។ នៅតុលាការ STL ឈុតឆាកដ៏អាក្រក់មួយបានកើតឡើងក្នុងឆ្នាំ២០២១ ដែលបានរាំងមិនអាចឱ្យដំណើរការបានលើការជំនុំជម្រះថ្មីមួយដែលហៀបនឹងចាប់ផ្តើមទៅហើយនោះ និងបានបញ្ចប់យ៉ាងមានប្រសិទ្ធភាពនូវមុខងាររបស់តុលាការស្ទើរតែទាំងអស់។

ទោះបីកិច្ចការតុលាការនៅ អ.វ.ត.ក នៅតែបន្តក៏ដោយ ភាពមិនប្រាកដប្រជាទាំងនេះ បានបន្ទាបតម្លៃខាងសីលធម៌។ វាបានបូកបន្ថែមទៅលើភាពតានតឹងដែលបុគ្គលិកបានជួប ដូចជាភាពមិនច្បាស់លាស់នៃរយៈពេលការងាររបស់ពួកគេ ប៉ុន្តែការទទួលខុសត្រូវជាអាជីពរបស់ពួកគេនៅតែមានការប្តេជ្ញាចិត្តដើម្បីផលិតឱ្យបាននូវការងារដែលមានគុណភាពខ្ពស់ ដោយពុំគិតអំពីចំនួនមុខតំណែងដែលបានផ្តល់នៅមានកម្រិត និងម៉ោងការងារដែលតម្រូវច្រើនប៉ុនណានោះទេ។ ពិតណាស់ នៅបណ្តាឆ្នាំក្រោយៗមកទៀតរបស់ អ.វ.ត.ក កិច្ចសន្យាការងាររបស់បុគ្គលិកត្រូវបានបន្តភាគច្រើនរៀងរាល់បីខែម្តង។ ចំនួនបុគ្គលិកផ្លាស់ប្តូរខ្ពស់ដែលជាហេតុធ្វើឱ្យមានការបាត់បង់ចំណេះដឹងខាងស្ថាប័ន គឺជាលទ្ធផលដែលមិនអាចចៀសរួច ដែលបង្កើតបាននូវភាពគ្មានប្រសិទ្ធភាពនៅក្នុងដំណើរការតុលាការ។ ជាការបន្ថែម ការធានាបាននូវនិរន្តរភាពនៃការបរិច្ចាគស្ម័គ្រចិត្ត គឺជាគ្រឹះស្ថានដែលស៊ីពេលមួយដែលយើងអាចយល់បាន ដោយសារវាធ្វើឱ្យអ្នកចូលរួមងាកចេញពីការផ្តោតការយកចិត្តទុកដាក់ទៅលើការងារស្នូលរបស់តុលាការ។ ជាចុងក្រោយ តុលាការដែលស្នើសុំជំនួយហិរញ្ញវត្ថុពីម្ចាស់ជំនួយ គឺជាចក្ខុមួយដែលអនុញ្ញាតឱ្យអ្នកចូលចិត្តបន្ទាបតម្លៃ ជំទាស់ថា វា

មិនបានជួយអ្វីនៅក្នុងយុត្តិធម៌មិនលម្អៀងនោះទេ ប៉ុន្តែវាជួយដេញថ្លៃរកម្ចាស់ជំនួយទៅវិញ។

យន្តការថវិកាស្ម័គ្រចិត្តជួយនាំមកនូវយុត្តិធម៌ ព្រមទាំងគណនេយ្យភាពចំពោះឧក្រិដ្ឋកម្មឃោរឃៅដែលប៉ះពាល់ជនរងគ្រោះដោយផ្ទាល់ និងដោយប្រយោល ព្រមទាំងសហគមន៍សកលលោកទាំងមូល។ ម្ចាស់ជំនួយដែលមានសប្បុរសធម៌បានបរិច្ចាកថវិកាយ៉ាងច្រើន ដើម្បីឱ្យប្រតិបត្តិការតុលាការអាចដំណើរការទៅបាន។ ពិតមែនហើយ ដើម្បីទទួលបានជោគជ័យ គម្រោងនេះចាំបាច់ត្រូវកែសម្រួលដើម្បីបញ្ចូលម្ចាស់ជំនួយ ដែលបានប្តេជ្ញាចិត្តជាផ្លូវការក្នុងការផ្តល់ថវិកាដោយស្ម័គ្រចិត្តដរាបណាអាណត្តិតុលាការមានតម្រូវការ។ ទោះជាមានការកែសម្រួលដូច្នេះក្តី គំរូដែលល្អនិងមាននិរន្តរភាព គឺគំរូថវិកាដែលបានវាយតម្លៃដោយ អង្គការសហប្រជាជាតិ ដូចបានទទួលស្គាល់ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ (UNSG) កាលពីដើមឆ្នាំ២០០៣ និងបានធ្វើទិន្នេសម្តងម្កាលនាពេលក្រោយមក។ នេះជាយន្តការថវិកាស្ម័គ្រចិត្តដែលមានការប្រែប្រួលចៀសមិនរួច ដែលអាចទទួលយកការបរិច្ចាគដោយស្ម័គ្រចិត្តពីបណ្តារដ្ឋនានា ប៉ុន្តែបើតាមកិច្ចព្រមព្រៀងបង្កើតតុលាការវាជាកាតព្វកិច្ចរបស់អង្គការសហប្រជាជាតិ ក្នុងការផ្តល់ថវិកាបង្គ្រប់លើថវិកាដែលខ្វះ។ ចំណុចនេះនឹងបង្កើតបាននូវស្ថិរភាពផ្នែកហិរញ្ញវត្ថុដែលកំពុងតែត្រូវការបំផុតសម្រាប់ការងារតុលាការ ដោយបានដកចេញនូវរបាំងនៃដំណើរស្វែងរកជំនួយប្រចាំឆ្នាំ ឬកន្លះឆ្នាំដែលតែងតែស៊ីពេលយូរ។ ជាការពិតណាស់ ការអនុញ្ញាតឱ្យមានការបរិច្ចាគដោយស្ម័គ្រចិត្តធ្វើឱ្យតុលាការអាចបំពេញកិច្ចការរបស់ខ្លួនយ៉ាងប្រសិទ្ធភាព។




**ជំនួយរបស់ក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗ គិតជាដុល្លា (២០០៦-២០២២)**

| | |
|---|---|
| អង្គការសហប្រជាជាតិ (កម្ចី/ជំនួយ/ប្រាក់ឧបត្ថម្ភធន) | ៩៦.៦៤៦.៤១៧ |
| ជប៉ុន | ៨៨.២៦៧.៧៤៦ |
| កម្ពុជា | ៤៥.៥១៦.០៦៨ |
| អូស្ត្រាលី | ៣៥.៥៣៥.០៩៣ |
| សហរដ្ឋអាមេរិក | ៣២.៣៣០.៧៩៣ |
| សហភាពអឺរ៉ុប | ៣១.៦៧២.៩៩៤ |
| អាល្លឺម៉ង់ | ១៧.៩៩៥.៣៥៣ |
| ស៊ុយអែដ | ១៤.៩៩០.៧៩៧ |
| ផ្សេងៗ (ប្រទេស/ម្ចាស់ជំនួយឯកត្តលក្ខណៈ) | ៦០.៨២១.៨០៥ |

# ការកន្លងផុតទៅនៃពេលវេលា

យុត្តាធិការពេលវេលានៃ អ.វ.ត.ក បានរួមបញ្ចូលឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ប្រព្រឹត្តក្នុងចន្លោះពី ២៧ ទៅ ៣១ ឆ្នាំ មុនពេលការស៊ើបអង្កេតបានចាប់ផ្តើមនៅពាក់កណ្តាលឆ្នាំ២០០៦។ ដូច្នេះ ការកន្លងផុតទៅនៃពេលវេលាបានបង្កបញ្ហាប្រឈមជាច្រើនសម្រាប់ការងាររបស់តុលាការ៖ ឥទ្ធិពលដែលអាចកើតមានរបស់វាលើការចងចាំ និងសុខភាព និងភាពចុះខ្សោយរបស់ជនសង្ស័យ ជនជាប់ចោទ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ជាមួយនឹងការពន្យារពេលជាបន្តបន្ទាប់ក្នុងកិច្ចដំណើរការនីតិវិធី ធនធានកាន់តែច្រើនដែលត្រូវការសម្រាប់ការស៊ើបអង្កេត និងការជំនុំជម្រះ និងការបាត់បង់ជនសង្ស័យ និងជនជាប់ចោទជាច្រើននាក់ មុនការបញ្ចប់កិច្ចដំណើរការនីតិវិធី។

ទោះបីជារយៈពេលខ្លីជាងការជំនុំជម្រះក្នុងរឿងក្តី ណាស៊្សី នៃប្រទេសអាល្លឺម៉ង់ដែលកំពុងបន្តក៏ដោយ ក៏បញ្ហាប្រឈមជាក់ស្តែងបំផុតគឺផលប៉ះពាល់សក្តានុពលនៃការកន្លងផុតទៅនៃពេលវេលា លើការចងចាំរបស់អ្នកចូលរួមក្នុងកិច្ចដំណើរការនីតិវិធី។ នេះគឺជាកត្តាមួយក្នុងចំណោមកត្តាជាច្រើន ដែលតុលាការត្រូវពិចារណានៅពេលវាយតម្លៃភាពអាចជឿជាក់បាននៃភស្តុតាង អាស្រ័យលើសមត្ថភាពបុគ្គល ដែលជាកត្តាអាចបណ្តាលឱ្យបាត់បង់ការចងចាំ ឬការចងចាំមិនច្បាស់លាស់ ទាក់ទងនឹងព័ត៌មានលម្អិតនៃហេតុការណ៍ និងលំដាប់នៃហេតុការណ៍ និងបទពិសោធន៍។ តុលាការបានជម្នះលើបញ្ហាប្រឈមនេះ ដោយពិចារណាលើភាពស៊ីចង្វាក់ផ្ទៃក្នុងនៃភស្តុតាងរបស់បុគ្គលម្នាក់ៗ នៅក្នុងបរិបទនៃសក្ខីកម្ម និងចម្លើយផ្សេងទៀតរបស់អ្នកពាក់ព័ន្ធ កំណត់ត្រា ប.ក.ក ផ្ទៃក្នុង និងឯកសារសហសម័យផ្សេងទៀត ដូចជារបាយការណ៍សារព័ត៌មាន ដែលទាំងអស់នេះជាការរំលឹកព្រឹត្តិការណ៍នៃសម័យកាលកម្ពុជាប្រជាធិបតេយ្យ។

ទោះជាយ៉ាងណា បញ្ហាប្រឈមដ៏សំខាន់បំផុតដែលកើតឡើងដោយការកន្លងផុតទៅនៃពេលវេលានោះ គឺឥទ្ធិពលរបស់វាទៅលើកិច្ចដំណើរការនីតិវិធី ដោយសារតែសុខភាពមិនល្អ និងភាពចុះខ្សោយរបស់ជនសង្ស័យ ជនជាប់ចោទ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី និងសមត្ថភាពផ្លូវកាយ និងផ្លូវចិត្តរបស់ពួកគេក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធី។ បញ្ហាសុខភាពបានធ្វើឱ្យ អ.វ.ត.ក បាត់បង់ភស្តុតាងដែលពាក់ព័ន្ធពីសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានស្លាប់មុនពេលពួកគេអាចបង្ហាញភស្តុតាងរបស់ខ្លួន ឬមានភាពចុះខ្សោយពេកក្នុងការធ្វើដូច្នេះ។ អាយុ និងភាពចុះខ្សោយរបស់ជនសង្ស័យ និងជនជាប់ចោទមានន័យថា អ.វ.ត.ក មិនអាចឈានដល់ការវិនិច្ឆ័យចុងក្រោយក្នុងគ្រប់រឿងក្តីទាំងអស់បានទេ។ ដូចបានពិភាក្សាពីមុន អៀង ធីរិទ្ធ (កើតឆ្នាំ ១៩៣២) ត្រូវបានរកឃើញថាមិនមានសម្បទាគ្រប់គ្រាន់ក្នុងការជំនុំជម្រះ មុនការជំនុំជម្រះរបស់គាត់ចាប់ផ្តើម ហើយ អៀង សារី (កើតឆ្នាំ ១៩២៥) បានស្លាប់ក្នុងឆ្នាំ ២០១៣ ក្នុងពេលជំនុំជម្រះ។ ចំណែក ស៊ូ ម៉េត បានស្លាប់ក្នុងពេលស៊ើបអង្កេតរបស់តុលាការ។ ជាងនេះទៀត តាម៉ុក និង កែ ពក ដែលជាកម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហម ដែលអាចត្រូវបានគេចាត់ទុកថា ស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវបំផុតនោះ ក៏បានស្លាប់ភ្លាមៗមុនពេល អ.វ.ត.ក ចាប់ផ្តើមប្រតិបត្តិការ។ ទោះយ៉ាងណា យុត្តិធម៌លើសពីអ្វីដែលបានរំពឹងទុកត្រូវបានប្រគល់ជូននៅ អ.វ.ត.ក ដោយមានរឿងក្តីបានដំណើរការប្រឆាំងនឹងជនជាប់ចោទជាច្រើននាក់។ ឌុច (កើតឆ្នាំ ១៩៤២) បាននៅរស់ឃើញការបិទបញ្ចប់ការជំនុំជម្រះ និងបណ្តឹង

សាទុក្ខរបស់ខ្លួន។ នួន ជា (កើតឆ្នាំ ១៩២៦) បាននៅរស់ឃើញការបិទបញ្ចប់ការជំនុំជម្រះ និងបណ្តឹងសាទុក្ខលើកទីមួយរបស់ខ្លួន និងសាលក្រមរបស់ អ.ជ.ស.ដ ប្រឆាំងនឹងគាត់ក្នុងការជំនុំជម្រះលើកទីពីរ។ ខៀវ សំផន (កើតឆ្នាំ ១៩៣១) បានរស់ឃើញការជំនុំជម្រះ និងបណ្តឹងសាទុក្ខទាំងពីររបស់គាត់ត្រូវបានបញ្ចប់។ លើសពីនេះ អោ អាន (កើតឆ្នាំ ១៩៣៣) យឹម ទិត្យ (កើតឆ្នាំ ១៩៣៦) និង មាស មុត (កើត ១៩៣៨) នៅរស់មានជីវិតដើម្បីប្រឈមនឹងការចោទប្រកាន់ និងបានឃើញរឿងក្តីរបស់ពួកគេត្រូវបានច្រានចោល ហើយរឿងក្តីប្រឆាំងនឹង អ៊ឹម ចែម (កើតឆ្នាំ ១៩៤៦) ត្រូវបានច្រានចោលក្នុងពេលដែលគាត់នៅមានជីវិត។

ការពន្យារពេលសំខាន់ៗបានកើតឡើងដោយតម្រូវការរបស់តុលាការ ក្នុងការសម្រេចលើសម្បទាផ្លូវកាយ និងផ្លូវចិត្តរបស់ជនជាប់ចោទក្នុងការចូលរួមការជំនុំជម្រះ ដោយមានការវាយតម្លៃជាបន្តបន្ទាប់ដោយអ្នកជំនាញផ្នែកវេជ្ជសាស្ត្រ។ ក្តីបារម្ភទាំងនេះច្រើនតែនាំឱ្យមានការបន្ថយវគ្គសវនាការប្រចាំសប្តាហ៍ ឬសវនាការខ្លីជាងមុន ហើយជួនកាលរហូតដល់មានការផ្អាកសវនាការ ទាំងអស់នេះជាអ្វីដែលបូកបន្ថែមលើពេលវេលាដែលត្រូវការសម្រាប់រឿងក្តីទាំងនេះ។ ជាការពិតណាស់ ជនជាប់ចោទ អៀង សារី, នួន ជា និង ខៀវ សំផន ជារឿយៗមិនអាចចូលរួមកិច្ចដំណើរការក្នុងតុលាការបានទេ ដោយសារភាពអស់កម្លាំង ឈឺ ឬការសម្រាកព្យាបាលនៅមន្ទីរពេទ្យ។ នៅពេលដែលជនជាប់ចោទទាំងនេះមិនបានលះបង់សិទ្ធិ ក្នុងការមានវត្តមាន ឬចៅក្រមយល់ថា ចាំបាច់ត្រូវមានវត្តមានរបស់ពួកគេ ដូច្នេះអវត្តមានរបស់ពួកគេបានបញ្ឈប់កិច្ចដំណើរការនីតិវិធី។ កង្វល់ទាក់ទងនឹងសុខភាព និងអាយុរបស់ អៀង សារី, នួន ជា, ខៀវ សំផន គឺជាកត្តាចម្បងដែលនាំទៅដល់ការបំបែកការចោទប្រកាន់លើពួកគាត់ ដែលបណ្តាលឱ្យមានការជំនុំជម្រះចំនួនពីរ និងច្រើនឆ្នាំបន្ថែមទៀត ទៅលើការបិទបញ្ចប់កិច្ចដំណើរការនីតិវិធី។

បញ្ហាទាំងនេះក៏បានបន្ថែមទៅលើធនធាន ដែលត្រូវការសម្រាប់កិច្ចដំណើរការនីតិវិធីរបស់តុលាការផងដែរ។ ឧទាហរណ៍ បុគ្គលិកពេទ្យដើម្បីព្យាបាលភាពចុះខ្សោយរបស់ជនជាប់ចោទ និងវាយតម្លៃកាយសម្បទា និងផ្លូវចិត្តរបស់ពួកគេ ដើម្បីចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ព្រមទាំងសម្ភារបរិក្ខារនានា ដើម្បីអនុញ្ញាតឱ្យជនជាប់ចោទចូលរួមពីក្រៅតុលាការក្នុងករណីចាំបាច់។

អ.វ.ត.ក បានដោះស្រាយបញ្ហាប្រឈមទាំងនេះ ដោយបង្កើតនូវមូលដ្ឋានភស្តុតាងពហុប្រភព ទូលំទូលាយ ផ្អែកលើមូលដ្ឋានដែលចៅក្រមអាចពឹងផ្អែកបាន ក្នុងការឈានទៅដល់ការសម្រេចលើកិច្ចស៊ើបអង្កេត និងការជំនុំជម្រះរបស់ពួកគេ។ តុលាការបានបង្ហាញនូវភាពបត់បែនដ៏ល្អ ក្នុងការបំពេញតម្រូវការទាក់ទងនឹងសុខភាពរបស់ជនសង្ស័យ ជនជាប់ចោទ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ផ្តល់ជំនាញវេជ្ជសាស្ត្រតាមតម្រូវការ បំពាក់ឧបករណ៍ក្នុងបន្ទប់ឃុំខ្លួន ដើម្បីអនុញ្ញាតឱ្យជនជាប់ចោទចូលរួមពីចម្ងាយក្នុងកិច្ចដំណើរការនីតិវិធី និងការវិភាគយ៉ាងហ្មត់ចត់ពីបញ្ហាសម្បទាផ្លូវចិត្ត ដើម្បីធានាថាជនជាប់ចោទទទួលបានការប្រព្រឹត្តិត្រឹមត្រូវយុត្តិធម៌។

# ធនធានខាងក្រៅ

## អ្នកចូលរួមចំណែកក្នុងប្រទេសកម្ពុជា

1. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍កម្ពុជា៖ https://www.adhoccambodia.org/
2. មជ្ឈមណ្ឌលឯកសារកម្ពុជា៖ https://dccam.org/
3. អង្គការចិត្តសង្គមអន្តរវប្បធម៌៖ https://tpocambodia.org/
4. សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង៖ https://tuolsleng.gov.kh/

## សៀវភៅ និងអត្ថបទ

### ក. ឯកសារដែលសិក្សាយ៉ាងទូលំទូលាយអំពី អ.វ.ត.ក


5. Alexander Hinton. *The Justice Facade: Trials of Transition in Cambodia*. Oxford, UK: Oxford University Press, 2018.
6. Cheryl S. White. *Bridging Divides in Transitional Justice: The Extraordinary Chambers in the Courts of Cambodia*. Cambridge, UK: Intersentia Ltd., 2017.
7. Craig Etcheson. *Extraordinary Justice: Law, Politics, and the Khmer Rouge Tribunals*. New York, USA: Columbia University Press, 2019.
8. John D. Ciorciari and Anne Heindel. *Hybrid Justice: The Extraordinary Chambers in the Courts of Cambodia*. Ann Arbor, USA: University of Michigan Press, 2014.
9. Nina H.B. Jørgensen. *The Elgar Companion to the Extraordinary Chambers in the Courts of Cambodia*. Cheltenham, UK: Edward Elgar Publishing, 2018.
10. Rebecca Gidley. *Illiberal Transitional Justice and the Extraordinary Chambers in the Courts of Cambodia*. Cham, Switzerland: Palgrave Macmillan, 2019.

11. Simon M. Meisenberg and Ignaz Stegmiller. *The Extraordinary Chambers in the Courts of Cambodia: Assessing their Contribution to International Criminal Law*. The Hague, The Netherlands: T.M.C. Asser Press, 2016.

## ខ. ទិដ្ឋភាពពិសេសនៃ អ.វ.ត.ក

### *(i) អ.វ.ត.ក ជាសាលាក្តីអន្តរជាតូបនីយកម្ម៖ មូលដ្ឋានគ្រឹះ ក្របខ័ណ្ឌ និងការវិវឌ្ឍ*

12. David Scheffer. *The Extraordinary Chambers in the Courts of Cambodia*. In the Book "International Criminal Law: International Enforcement", Volume 3, 3rd ed., edited by M. Cherif Bassiouni. Leiden, The Netherlands: Koninklijke Brill NV, 2008.

13. Ernestine E. Meijer. *The Extraordinary Chambers in the Courts of Cambodia for Prosecuting Crimes Committed by the Khmer Rouge: Jurisdiction, Organization, and Procedure of an Internationalized National Tribunal*. In the Book "Internationalized Criminal Courts: Sierra Leone, East Timor, Kosovo, and Cambodia", edited by Cesare P.R. Romano, André Nollkaemper and Jann K. Kleffner. Oxford, UK: Oxford University Press, 2004.

14. Hanna Bertelman. *International Standards and National Ownership? Judicial Independence in Hybrid Courts: The Extraordinary Chambers in the Courts of Cambodia*, Nordic Journal of International Law 79, 3 (2010): 341-382.

15. John D. Ciorciari. *Compromising on Hybrid Justice*. In the Book "Sovereignty Sharing in Fragile States", by John D. Ciorciari. Stanford, USA: Stanford University Press, 2021.

16. John D. Ciorciari and Anne Heindel. *Experiments in International Criminal Justice: Lessons from the Khmer Rouge Tribunal*, Michigan Journal of International Law 35, 2 (2014): 369-442.

17. Tomas Hamilton and Michael Ramsden. *The Politicisation of Hybrid Courts: Observations from the Extraordinary Chambers in the Courts of Cambodia*, International Criminal Law Review 14, 1 (2014): 115-147.

### *(ii) យុត្តាធិការលើរូបបុគ្គល*

18. Randle C. DeFalco. *Cases 003 and 004 at the Khmer Rouge Tribunal: The Definition of "Most Responsible" Individuals According*

*to International Criminal Law*, Genocide Studies and Prevention: An International Journal 8, 2 (2014): 45-65.

19. Sara Ochs. *In Need of Prosecution: The Role of Personal Jurisdiction in the Khmer Rouge Tribunal*, Stanford Journal of International Law 55, 2 (2019): 117-154.
20. Stuart Ford. *Senior Leaders and Those Most Responsible at the Extraordinary Chambers in the Courts of Cambodia*, FIU Law Review 15, 1 (2021): 31-36.

## គ. អ.វ.ត.ក ក្នុងការអភិវឌ្ឍនីតិព្រហ្មទណ្ឌអន្តរជាតិ

### *(i) នីតិព្រហ្មទណ្ឌអន្តរជាតិសំខាន់ៗ*

#### *ក. ឧក្រិដ្ឋកម្ម*

21. Cameron Christensen. *Forced Marriage at the Cambodian Crossroads: ECCC can Develop a New Crime Against Humanity*, Brigham Young University Law Review 2015, 6 (2015): 1825-1845.
22. Elinor Fry and Elies van Sliedregt. *Targeted Groups, Rape and Dolus Eventualis: Assessing the ECCC's Contributions to Substantive International Criminal Law*, Journal of International Criminal Justice 18, 3 (2020): 701-721.
23. Emma Palmer and Sarah Williams. *A shift in attitude? Institutional change and sexual and gender-based crimes at the Extraordinary Chambers in the Courts of Cambodia*, International Feminist Journal of Politics 19, 1 (2017): 22-38.
24. Kai Ambos. *The ECCC's Contribution to Substantive ICL: The Notion of "Civilian Population" in the Context of Crimes Against Humanity*, Journal of International Criminal Justice 18, 3 (2020): 689-700.
25. Rachel Killean, Eithne Dowds and Amanda Kramer. *Soldiers as Victims at the ECCC: Exploring the Concept of 'Civilian' in Crimes Against Humanity*, Leiden Journal of International Law 30, 3 (2017): 685-705.
26. Rosemary Grey. *Seen and unseen: sexual and gender-based crimes in the Khmer Rouge Tribunals Case 002/02 judgment*, Australian Journal of Human Rights 25, 3 (2019): 466-487.

27. Sergey Vasiliev. *ECCC Appeals: Appraising the Supreme Court Chamber's Interventions*, Journal of International Criminal Justice 18, 3 (2020): 723-745.

### *ខ. ទម្រង់នៃការទទួលខុសត្រូវ*

28. Cóman Kenny. *Jurisprudence Continues to Evolve: The ECCC's Revision of Common Purpose Liability*, Journal of International Criminal Justice 16, 3 (2018): 623-644.

29. Katrina Gustafson. *ECCC Tackles JCE: An Appraisal of Recent Decisions*, Journal of International Criminal Justice 8, 5 (2010): 1323-1332.

30. Randle C. DeFalco and Jared L. Watkins. *Joint Criminal Enterprise and the Jurisdiction of the Extraordinary Chambers in the Courts of Cambodia*, Rutgers Law Review 63, 1 (2010): 193-273.

31. Rehan Abeyratne. *Superior Responsibility and the Principle of Legality at the ECCC*, The George Washington International Law Review 44, 1 (2012): 39-78.

32. Robert Charles Clarke. *Return to Borkum Island: Extended Joint Criminal Enterprise Responsibility in the Wake of World War II*, Journal of International Criminal Justice 9, 4 (2011): 839-861.

### *(ii) នីតិវិធី និងភស្តុតាង*

33. Göran Sluiter and Marc Tiernan. *The Right to an Effective Defence During ECCC Investigations*, Journal of International Criminal Justice 18, 3 (2020): 641-664.

34. Sarah Williams. *The Severance of Case 002 at the ECCC: A Radical Trial Management Technique or a Step Too Far?*, Journal of International Criminal Justice 13, 4 (2015): 815-843.

35. Vincent de Wilde d'Estmael. *The use of the archives of the Tuol Sleng Genocide Museum and the Documentation Center of Cambodia by the Extraordinary Chambers in the Courts of Cambodia*. In the Book "Archives and Human Rights", edited by Boel, Jens, Perrine Canavaggio and Antonio González Quintana. London, UK: Routledge, 2021.

36. Yvonne McDermott. *The ECCC's Approach to Evidence and Proof*, Journal of International Criminal Justice 18, 3 (2020): 747-764.

## ឃ. ការចូលរួមរបស់ជនរងគ្រោះនៅ អ.វ.ត.ក

### *(i) ភាពជាជនរងគ្រោះក្នុងបរិបទនៃអំពើឃោរឃៅទ្រង់ទ្រាយធំ*

37. Johanna Herman. *Uncooked Rice: Justice and Victimhood at the Extraordinary Chambers in the Courts of Cambodia and Beyond*. In the Book "The Politics of Victimhood in Post-conflict Societies", edited by Druliolle, Vincent and Roddy Brett. Cham, Switzerland: Palgrave Macmillan, 2018.

38. Julie Bernath. *'Complex Political Victims' in the Aftermath of Mass Atrocity: Reflections on the Khmer Rouge Tribunal in Cambodia*, International Journal of Transitional Justice 10, 1 (2016): 46-66.

### *(ii) ការចូលរួមរបស់ជនរងគ្រោះក្នុងកិច្ចដំណើរការនីតិវិធី អ.វ.ត.ក*

39. Christoph Sperfeldt and Jeudy Oeung. *The Evolution of Cambodian Civil Society's Involvement with Victim Participation at the Khmer Rouge Trials*. In the Book "Civil Society and Transitional Justice in Asia and the Pacific", edited by Kent, Lia, Joanne Wallis and Claire Cronin. Acton, Australia: ANU Press, 2019.

40. Helen Jarvis. *"Justice for the deceased": victims' participation in the Extraordinary Chambers in the Courts of Cambodia*, Genocide Studies and Prevention: An International Journal 8, 2 (2014): 19-27.

41. Megan Hirst and Kinga Tibori-Szabó (eds.). *Victim Participation in International Criminal Justice: Practitioners' Guide*. The Hague, The Netherlands: T.M.C. Asser Press, 2017.

42. Phuong N. Pham, Patrick Vinck, Mychelle Balthazard, Judith Strasser and Chariya Om. *Victim Participation and the Trial of Duch at the Extraordinary Chambers in the Courts of Cambodia*, Journal of Human Rights Practice 3, 3 (2011): 264-287.

43. Rachel Killean and Luke Moffett. *Victim Legal Representation before the ICC and ECCC*, Journal of International Criminal Justice 15, 4 (2017): 713-740.

44. Silke Studzinsky. *Participation Rights of Victims as Civil Parties and the Challenges of Their Implementation Before the Extraor dinary Chambers in the Courts of Cambodia*. In the Book "Victims of International Crimes: An Interdisciplinary Discourse", edited by Bonacker, Thorsten and Christoph Safferling. The Hague, The Netherlands: T.M.C. Asser Press, 2013.

45. Toni Holness and Jaya Ramji-Nogales. *Participation as Reparations: The ECCC and Healing in Cambodia*, Cambodia's Hidden Scars: Trauma Psychology in the Wake of the Khmer Rouge (Documentation Center of Cambodia), (2011).

### *(iii) សំណង*

46. Christoph Sperfeldt. *Collective Reparations at the Extraordinary Chambers in the Courts of Cambodia*, International Criminal Law Review 12, 3 (2012): 457-490.

47. Juan-Pablo Perez-Leon-Acevedo. *Reparation Modalities at the Extraordinary Chambers in the Courts of Cambodia (ECCC)*, The Law & Practice of International Courts and Tribunals 19, 3 (2020): 451-469.

48. Rachel Killean and Luke Moffett. *What's in a Name?: 'Reparations' at the Extraordinary Chambers in the Courts of Cambodia*, Melbourne Journal of International Law 21, 1 (2020): 115-143.

49. Toni Shapiro-Phim. *Embodying the Pain and Cruelty of Others*, International Journal of Transitional Justice, 14, (2020): 209-219.

## ង. កេរដំណែលរបស់ អ.វ.ត.ក

### *(i) យុត្តិធម៌ និងគណនេយ្យភាព*

50. Alexander Laban Hinton. *Man or Monster?: The Trial of a Khmer Rouge Torturer*, Durham, USA: Duke University Press, 2016.

51. Christoph Sperfeldt. *From the Margins of Internationalized Criminal Justice: Lessons Learned at the Extraordinary Chambers in the Courts of Cambodia*, Journal of International Criminal Justice 11, 5 (2013): 1111-1137.

52. Diane Orentlicher. *'Worth the Effort'? Assessing the Khmer Rouge Tribunal*, Journal of International Criminal Justice 18, 3 (2020): 615-640.

53. Paolo Lobba and Niccol Pons. *Rethinking the Legacy of the ECCC: Selectivity, Accountability, Ownership*, Journal of International Criminal Justice 18, 3 (2020): 599-614.

54. Rachel Hughes, Maria Elander, Christoph Sperfeldt, Helen Jarvis, William Smith, Lyma Nguyen and Wendy Lobwein. *Achievements and Legacies of the Khmer Rouge Trials: Reflections from Inside the Tribunal*, Australian Feminist Law Journal 44, 2 (2018): 303-324.

*(ii) ការផ្សព្វផ្សាយរបស់ អ.វ.ត.ក និងផលជះលើការបង្រួបបង្រួម និងការកសាងប្រទេសនៅកម្ពុជា*

55. Abe Toshihiro. *Perceptions of the Khmer Rouge Tribunal among Cambodians: Implications of the Proceedings of Public Forums Held by a Local NGO*, South East Asia Research 21, 1 (2013): 5-26.

56. Caitlin McCaffrie. *An Educational Legacy: Exploring the Links between Education and Resilience at the ECCC*, Leiden Journal of International Law 33, 4 (2020): 975-991.

57. Christoph Sperfeldt. *Cambodian Civil Society and the Khmer Rouge Tribunal*, International Journal of Transitional Justice 6, 1 (2012): 149-160.

58. Peter Manning. *Governing Memory: Justice, Reconciliation and Outreach at the Extraordinary Chambers in the Courts of Cambodia*, Memory Studies 5, 2 (2012): 165-181.

59. Rosemary Grey and Rachel Killean. *Communicating Justice: Cambodian Press Coverage of the ECCC's Final Judgment*, International Criminal Law Review 23 (2023): 487-521.

## ការសិក្សាអំពីផលប៉ះពាល់

60. Caitlin McCaffrie, Somaly Kum, Daniel Mattes and Lina Tay. *So We Can Know What Happened: The Educational Potential of the Extraordinary Chambers in the Courts of Cambodia*. Stanford, USA: WSD HANDA Center for Human Rights and International Justice at Stanford University, 2018

61. Judith Strasser, Thida Kim, Silke Studzinsky and Sopheap Taing. *A Study about Victims' Participation at the Extraordinary Cham*

*bers in the Courts of Cambodia and Gender-Based Violence under the Khmer Rouge Regime*. Phnom Penh, Cambodia: Trans cultural Psychosocial Organization Cambodia, 2015.

62. Julian Poluda. *Promoting Gender Equality and Improving Access to Justice for Female Survivors and Victims of Gender-Based Violence under the Khmer Rouge Regime*. Phnom Penh, Cambodia: United Nations Trust Fund to End Violence against Women, Victims Support Section of the Extraordinary Chambers in the Courts of Cambodia, Cambodian Defenders Project, Transcultural Psychosocial Organization Cambodia, 2015.
63. Julian Poluda, Sineth Siv and Sotheary Yim. *Promoting Gender Equality and Improving Access to Justice for Female Survivors and Victims of Gender-Based Violence under the Khmer Rouge Regime: Final Evaluation of the ECCC Non-Judicial Gender Project (Phase 2)*. Phnom Penh, Cambodia: United Nations Trust Fund to End Violence against Women, Victims Support Section of the Extraordinary Chambers in the Courts of Cambodia, Transcultural Psychosocial Organization Cambodia, 2019.
64. Laura McGrew and Heather Ryan. *Performance and Perception: The Impact of the Extraordinary Chambers in the Court of Cambodia*. New York, USA: Open Society Foundations, 2016.
65. Phuong Pham, Patrick Vinck, Mychelle Balthazard, Sokhom Hean and Eric Stover. *So We Will Never Forget: A Population-Based Survey on Attitudes about Social Reconstruction and the Extraordinary Chambers in the Courts of Cambodia*. Berkeley, USA: University of California, Berkeley, 2009.
66. Phuong Pham, Patrick Vinck, Mychelle Balthazard and Sokhom Hean. *After the First Trial: A Population-Based Survey on Knowledge and Perceptions of Justice and the Extraordinary Chambers in the Courts of Cambodia*. Berkeley, USA: University of California, Berkeley, 2011.
67. Terith Chy. *A Thousand Voices: Questions on Additional Prosecution Posted by the Co-Prosecutors at the Extraordinary Chambers in the Courts of Cambodia*. Phnom Penh, Cambodia: Documentation Center of Cambodia, 2009.
68. Timothy Williams, Julie Bernath, Boravin Tann and Somaly Kum. *Justice and Reconciliation for the Victims of the Khmer Rouge? Victim Participation in Cambodia's Transitional Justice Process*. Marburg: Centre for Conflict Studies; Phnom Penh, Cambodia: Centre for the Study of Humanitarian Law, 2018.

## ការបោះពុម្ពផ្សាយសំខាន់ៗដោយសាក្សី អ.វ.ត.ក


69. Craig Etcheson. *The Rise and Demise of Democratic Kampuchea*. 1st ed., New York, USA: Routledge, 1984.

70. David P. Chandler. *Voices from S-21: Terror and History in Pol Pot's Secret Prison*. Berkeley, USA: University of California Press, 2000.

71. David P. Chandler. *A History of Cambodia*. 4th ed., Boulder, USA: Westview Press, 2008.

72. Elizabeth Becker. *When the War was Over: Cambodia and the Khmer Rouge revolution*. New York, USA: PublicAffairs, 1998.

73. Henri Locard and David P. Chandler. *Pol Pot's Little Red Book: The Sayings of Angkar*. Chiang Mai, Thailand: Silkworm Books, 2004.

74. Henri Locard. *Pourquoi les Khmers Rouges*. 2nd ed., Paris, France: Vendmiaire, 2016.

75. Peg LeVine. *A contextual study into the weddings and births under the Khmer Rouge: the ritual revolution*. Thesis, Monash University, 2007.

76. Philip Short. *Pol Pot: The History of a Nightmare*. London, UK: J. Murray, 2004.

77. Nakagawa Kasumi. *Gender-based Violence During the Khmer Rouge Regime: Stories of Survivors from the Democratic Kampuchea (1975-1979)*. 2nd ed., Phnom Penh, 2008.

78. Osman Ysa. *Oukoubah: Justice for the Cham Muslims under the Democratic Kampuchea Regime*. Phnom Penh, Cambodia: Documentation Center of Cambodia, 2002.

79. Vann Nath. *A Cambodian Prison Portrait: One Year in the Khmer Rouge's S-21*. Bangkok, Thailand: White Lotus, 1998.


## ការបោះពុម្ពផ្សាយសំខាន់ៗដោយ DC-CAM


80. Gunnar Bergström and Hedda Ekerwald. *Living Hell: Democratic Kampuchea, August 1978*. Phnom Penh, Cambodia: Documentation Center of Cambodia, 2008.

81. John D. Ciorciari and Anne Heindel. *On Trial: The Khmer Rouge Accountability Process*. Phnom Penh, Cambodia: Documentation Center of Cambodia, 2009.

82. Meng-Try Ea and Sorya Sim. *Victims and Perpetrators?: Testimony of Young Khmer Rouge Comrades*. Phnom Penh, Cambodia: Documentation Center of Cambodia, 2001.
83. Meng-Try Ea. *The Chain of Terror: The Khmer Rouge Southwest Zone Security System*. Phnom Penh, Cambodia: Documentation Center of Cambodia, 2005.
84. Stephen Heder and Brian D. Tittemore. *Seven Candidates for Prosecution: Accountability for the Crimes of the Khmer Rouge*. Phnom Penh, Cambodia: Documentation Center of Cambodia, 2004.
85. Suzannah Linton. *Reconciliation in Cambodia*. Phnom Penh, Cambodia: Documentation Center of Cambodia, 2004.
86. Terith Chy. *When the Criminal Laughs*. Phnom Penh, Cambodia: Documentation Center of Cambodia, 2014.

## ភាពយន្តឯកសារ

87. Annie Goldson and Robert Hamill (Writers), Annie Goldson and Peter Gilbert (Directors), BNO Productions and Pan Pacific Films (Producers), *Brother Number One*, 2012.
88. David Aronowitsch and Staffan Lindberg (Directors), *Facing Genocide: Khieu Samphan and Pol Pot*, 2010.
89. Lida Chan and Guillaume Suon (Directors), *Red Wedding*, 2011.
90. Rithy Panh (Writer and Director), *Bophana: A Cambodian Tragedy*, 1996.
91. Rithy Panh (Writer and Director), *S-21: The Khmer Rouge Killing Machine*, 2003.
92. Rithy Panh (Writer and Director), *Duch, le maître des forges de l'enfer*, 2011.
93. Thet Sambath and Robert Lemkin (Writers and Directors), *Enemies of the People: A Personal Journey into the Heart of the Killing Fields*, 2009.
94. Walter Heynowski and Gerhard Scheumann (Writers and Directors), *Kampuchea: Sterben und Auferstehen (Kampuchea: Death and Rebirth)*, 1980.
95. Walter Heynowski and Gerhard Scheumann (Writers and Directors), *Die Angkar*, 1981.

# ដៃគូសហការ

មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ត្រូវបានបង្កើតឡើងដោយលោក ឆាំង យុ ក្នុងឆ្នាំ១៩៩៥ ជាអង្គការក្រៅរដ្ឋាភិបាលមិនស្វែងរកប្រាក់ចំណេញ ដែលធ្វើការក្នុងគោលបំណងគាំទ្រដល់ការចងចាំ និងយុត្តិធម៌សម្រាប់ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍កម្ពុជា។ ឥឡូវនេះអង្គការនេះមានទីស្នាក់ការកណ្តាលនៅទីក្រុងភ្នំពេញ និងការិយាល័យ ឬទីតាំងពាក់ព័ន្ធចំនួន ១៩ នៅក្នុងប្រទេសកម្ពុជា។ https://www.dccam.org/

សមាគមព្រះរាជអាជ្ញាច្បាប់ព្រហ្មទណ្ឌអន្តរជាតិ (AICLP) គឺជាសមាគមវិជ្ជាជីវៈមិនស្វែងរកប្រាក់ចំណេញ ក្នុងគោលបំណងពង្រឹងតួនាទីរបស់ព្រះរាជអាជ្ញា និងអ្នកស៊ើបអង្កេតក្នុងការស្វែងរកយុត្តិធម៌សម្រាប់ឧក្រិដ្ឋកម្មអន្តរជាតិ។ AICLP តស៊ូមតិដើម្បីឯករាជ្យភាព និងការទទួលខុសត្រូវរបស់ព្រះរាជអាជ្ញា នៅក្នុងប្រព័ន្ធយុត្តិធម៌សកល ដោយធានាថាអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរត្រូវបានដាក់ឱ្យទទួលខុសត្រូវ ខណៈពេលដែលការពារបាននូវដំណើរការត្រឹមត្រូវតាមច្បាប់ និងនីតិរដ្ឋ។ https://www.iclprosecutors.org/



Brenda J. Hollis



Helen Worsnop



Chloé Veuve

សៀវភៅកេរដំណែលនេះត្រូវបានរៀបចំ កែសម្រួល និងបោះពុម្ពដោយសហព្រះរាជអាជ្ញាអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) ជំនួយការជាន់ខ្ពស់ព្រះរាជអាជ្ញា Helen Worsnop និង ទីប្រឹក្សាការងារ Chloé Veuve

ខែមិថុនា ឆ្នាំ២០២៥